# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## បឋមភាគ ៣

ភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥៤៧

# អដ្ឋសាលិនី

## បឋមភាគ

## ៣

ព. ស.

២៥៥៧

# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## (ឈ្មោះធម្មសង្គណី)

### បឋមភាគ ៣

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែសម្រួលរៀបរៀងដោយកល្យាណធម្មោ សុន្ទរ៍-សារមៀន

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥៥៧ គ. ស. ២០១៣

# សេចក្តីបញ្ជាក់

*គម្ពីរ* **អដ្ឋកថាព្រះអភិធម្ម** *ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ*

**១.បឋមភាគ** *ឈ្មោះ* **អដ្ឋសាលិនី** *អធិប្បាយគម្ពីរ* ***ធម្មសង្គណី***

**២.ទុតិយភាគ** *ឈ្មោះ* **សម្មោហវិនោទនី** *អធិប្បាយគម្ពីរ* ***វិភង្គ***

**៣.តតិយភាគ** *ឈ្មោះ* **បរមត្ថទីបនី** *អធិប្បាយគម្ពីរ* ***បញ្ចបករណ៍***

*តាំងពី* ***ធាតុកថា*** *រហូតដល់ចប់គម្ពីរ* ***បដ្ឋាន*** *ទាំងអស់ ។*

*បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា* ***អភិធម្មបិដក បឋមភាគ ៣*** *កើតឡើងដោយស្នាព្រះហស្តនៃ* ***ព្រះពុទ្ធឃោសាចារ្យ*** *ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញ គ្រាន់តែជាអ្នកផ្តើមប្រែសម្រួលរៀបរៀង ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ* ***សូមបញ្ជាក់*** *និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្តីនៃធម៌ដែលមាននៅ*

ក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គង ទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរងនូវព្រះអភិធម្ម បិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះ យើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏ អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើម ឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និង វិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បី សម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តា ជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែ សម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្ដី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំតាមរយៈគណៈកម្មការដែលមានអាសយដ្ឋានដូចនៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀងអក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

ភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣

**លោក សុន្ទរ៍ សាមៀន**

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ “ឮ”

## នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

-ព្រះមហា **រស់ សុភា** (ព្រះបាឡាត់នៃសម្ដេចអគ្គមហាសង្ឃរាជ)

-ព្រះមហាសុវណ្ណបជ្ជោតោ **កង ណាំ** (ចៅអធិការវត្តសំពៅមាស)

-ភិក្ខុវជិរប្បញ្ញោ **គូ សុភាព** (គណៈកម្មការបច្ចេកទេស នៃពុទ្ធិក-បណ្ឌិតសភា ក្នុងសាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជា) ។

-សមណនិស្សិតខន្តិជាតិកោ **វ៉ៃ ភិរក្ស**

-ភិក្ខុសាមណេរជាពហុស្សូតក្នុង **វត្តនិរោធារាម**

-លោក **សួនឱសថ** (ក្រុមទ្រទ្រង់ព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ)

-ឧបាសក **វ៉ៃ គឹមហាច** (គណកម្មការវត្តសុវណ្ណមាលីទន្លេបិទ)

-ឧបាសក **សំរ៉េង ចំណេ** -ឧបាសក **រឿង សិរីសុគន្ធ**

-អ្នកគ្រូ **ធី សុធី** -ឧបាសក **ឌូច សុខុម**

-លោកធម្មរក្ខិតោ **គង់ ស៊ីវន** ។

## អ្នកមានឧបការៈក្នុងការងារធម្មទាននេះ

-លោកបញ្ញាបទីបោ **ព្រឿង ប៊ុនធឿន**

-លោកខន្តិជាតិកោ **វ៉ៃ ភិរក្ស**

-ឧបាសិកា **លី ស៊ីវឌួ** ជាដើម

-ឧបាសិកា **ឌុន ស៊ូគី** ជាដើម

-ភិក្ខុសាមណេរ **វត្តគិរីរម្យចាស់** ជាដើម

-លោក **រេហង សុវណ្ណារ៉ា**

-ឧបាសក **ស្រុង ចាន់ណា** និងក្រុមគ្រួសារ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសទ្ធានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទ ទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យអត្ថបទនៃគម្ពីរនេះ ចេញជារូបរាងឡើង ។

បន្ទាប់ពីបឋមភាគ ៣ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវបឋមភាគ ៤ ជាបន្តទៀត ។

អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ ញាតិញោមទាំងក្នុង និងក្រៅប្រទេស មេត្តាជួយឧបត្ថម្ភ ដើម្បីបូជាធម៌ តាមកម្លាំងសទ្ធា ។

ម្យ៉ាងទៀត បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ ដើម្បីថតចម្លងជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៨៦ ៥២ ៣៤

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង និងក្រៅប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗ ស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

***ដោយអំណាចនៃមហាកុសលផលធម្មទាននេះ សូមឲ្យ ៖***

*-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ*

*-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា*

*-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ*

*-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕*

………………………………………………………………………………………………………………………………

**តារាងកែតម្រូវ** ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

**បឋមភាគ ៣** ឈ្មោះ ..........................

សម្រាប់បោះពុម្ពបន្ត អាសយដ្ឋាន ..................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# អដ្ឋសាលិនី អដ្ឋកថាព្រះអភិធម្មបិដក

# ឈ្មោះ ធម្មសង្គណី

# បឋមភាគ ៣

**មាតិកាធម៌** **ទំព័រ**

## អដ្ឋកថាចិត្តុប្បាទកណ្ឌ


អធិប្បាយអសុភជ្ឈាន ..... ..... ..... .... ..... ..... ..... ១

សម្តែងអំពីរូបាវចរកុសល ..... ..... ..... .... ..... ........ ១

សម្តែងអំពីសប្បាយ ១០ យ៉ាង ..... ..... ..... .... ..... ... ៦

សម្តែងអំពីអរូបាវចរកុសល ៤ ..... ..... ..... .... ..... ... ១០

វិនិច្ឆ័យពាក្យថាអាកាសានញ្ចាយតនៈ ..... ..... ..... .... ... ១៨

អធិប្បាយកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ..... ..... ...... ៣៧

អធិប្បាយលោកុត្តរកុសល ..... ..... ..... .... ..... ...... ៤៣

កថាសម្តែងអំពីសុញ្ញតាជាដើម ..... ..... ..... .... ..... ... ៦១

ពណ៌នាមហាន័យ ២០ ក្នុងបឋមមគ្គ ..... ..... ..... ..... .. ៩៣

អធិប្បាយមគ្គចិត្តដួងទី ២ ..... ..... ..... .... .... ..... .. ៩៥

សម្តែងអំពីមគ្គចិត្តមួយពាន់ដោយន័យជាដើម ..... ..... ..... ៩៨

# អដ្ឋសាលិនី

ការឧបមាដោយហិបរតនៈ ..... ..... ..... .... ..... .... ១០២

**កថាសម្តែងធម្មទេ្ទសវារៈក្នុងបទអកុសល**

អធិប្បាយអកុសលចិត្តដួងទី ១ ..... ..... ..... .... ..... .. ១១១

វិនិច្ឆ័យពាក្យថា ទិដ្ឋិគតសម្បយុត្ត ..... ..... ..... ..... .... ១១២

សម្តែងអំពីធម្មទេ្ទសមានផស្សៈជាដើម ..... ..... ..... ..... ១១៣

លក្ខណាទិចតុក្កៈនៃមិច្ឆាទិដ្ឋិ ..... ..... ..... .... ..... .... ១១៤

លក្ខណាទិចតុក្កៈនៃលោភៈ ..... ..... ..... .... .... ..... ១១៦

លក្ខណាទិចតុក្កៈនៃមោហៈ ..... ..... ..... .... ..... ... ១១៧

លក្ខណាទិចតុក្កៈនៃអភិជ្ឈា ..... ..... ..... .... ..... .... ១១៨

លក្ខណាទិចតុក្កៈនៃឧទ្ធច្ចៈ ..... ..... ..... .... .... ..... ១២១

អដ្ឋកថាសម្តែងនិទ្ទេសវារៈ ..... ..... ..... .... .... ..... ១២៤

អធិប្បាយអកុសលចិត្តដួងទី ២ ..... ..... ..... ..... ..... ១៣១

អធិប្បាយអកុសលចិត្តដួងទី ៣ ..... ..... ..... ..... ..... ១៣២

អធិប្បាយអកុសលចិត្តដួងទី ៤ ..... ..... ..... ..... ..... ១៣៣

អធិប្បយអកុសលចិត្តដួងទី ៥ ..... ..... ..... ..... ..... ១៣៤

អធិប្បាយអកុសលចិត្តដួងទី ៦, ៧, ៨ ..... ..... ..... ..... ១៣៥

អធិប្បាយអកុសលចិត្តដួងទី ៩ ..... ..... ..... .... ...... ១៣៥

លក្ខណាទិចតុក្កៈនៃទោមនស្ស ..... ..... ..... .... ..... ១៣៦

មាតិកាធម៌

លក្ខណាទិចតុក្កៈនៃទោសៈ ..... ..... ..... .... .... ..... ១៣៦

លក្ខណាទិចតុក្កៈនៃឥស្សា ..... ..... ..... .... .... ...... ១៣៨

លក្ខណាទិចតុក្កៈនៃមច្ឆរិយៈ ..... ..... ..... ..... ...... ១៣៨

លក្ខណាទិចតុក្កៈនៃកុក្កុច្ចៈ ..... ..... ..... .... .... ..... ១៣៩

អធិប្បាយអកុសលចិត្តដួងទី ១០ ..... ..... ..... .... ..... ១៤១

អធិប្បាយអកុសលចិត្តដួងទី ១១ ..... ..... ..... .... .... ១៤២

លក្ខណាទិចតុក្កៈនៃវិចិកិច្ឆា ..... ..... ..... .... ..... .... ១៤៣

អធិប្បាយអកុសលចិត្តដួងទី ១២ ..... ..... ..... .... ..... ១៤៦

អធិប្បាយអំពីអព្យាកតធម៌ ..... ..... ..... ..... ..... ១៤៩

អធិប្បាយអំពីមនោធាតុកុសលវិបាក ..... ..... ..... ..... ១៥៤

អធិប្បាយអំពីមនោវិញ្ញាណធាតុ ..... ..... ..... ..... .... ១៥៦

អធិប្បាយអំពីមហាវិបាកចិត្ត ៨ ដួង ..... ..... ..... ...... ១៥៨

អធិប្បាយអំពីទ្វារវិបាកមាតិកាកថា ..... ..... ..... ..... .... ១៦២

សម្តែងអំពីវិបាកចិត្ត ១៦ ដួង តាមន័យរបស់ព្រះចូឡនាគត្ថេរ ១៦៧

សម្តែងអំពីនិយាម ៥ យ៉ាង ..... ..... ..... ..... ១៧៤

ឧបមាវិបាកចិត្តប្រៀបដូចមនុស្សគាបអំពៅ ..... ..... ..... ១៨០

សម្តែងអំពីទុហេតុកបដិសន្ធិមានកម្មជាទុហេតុកៈ ..... ..... ១៨២

សម្តែងអំពីអហេតុកបដិសន្ធិ ..... ..... ..... ..... ...... ១៨៣

អដ្ឋសាលិនី

ចិត្តប្រៀបដូចនាយទ្វារជាដើម ..... ..... ..... ..... ..... ១៩១
ចិត្តប្រៀបដូចក្មេងអ្នកស្រុក ..... ..... ..... ..... ....... ១៩៣
នាមរូបប្រៀបដូចមនុស្សខ្វាក់ និង មនុស្សខ្វិន ..... ..... .... ១៩៥
សម្តែងអំពីការទទួលអារម្មណ៍ដែលមានឧបនិស្សយប្បច្ច័យ .... ១៩៧
ចក្ខុវិញ្ញាណអាស្រ័យបច្ច័យ ៤ ទើបកើតឡើងបាន .... ... ... ១៩៧
វិបាកចិត្ត ១២ ដួង ក្នុងវាទៈនៃព្រះមហាទត្តត្ថេរ .... ..... .... ២០៣
វិបាកចិត្ត ១០ ដួង ក្នុងវាទៈនៃព្រះមហាធម្មរក្ខិតត្ថេរ ..... ..... ២០៨
សម្តែងអំពីរូបាវចរវិបាកជាដើម ..... ..... ..... ..... .... ២១៥
សម្តែងអំពីលោកុត្តរវិបាក ..... ..... ..... ..... ..... .... ២១៦
សម្តែងអំពីអញ្ញាតាវិន្ទ្រិយ ក្នុងលោកុត្តរវិបាកដួងទី ៤ ...... ២២១
សម្តែងអំពីអកុសលវិបាក ..... ..... ..... ..... ..... .... ២២៣
សម្តែងអំពីកិរិយាអព្យាកតៈ ពោលដោយមនោធាតុ ដែលជា
កិរិយាចិត្ត ..... ..... ..... ..... ..... ..... ..... ..... .. ២២៥
សម្តែងអំពីមនោវិញ្ញាណធាតុ ជាកិរិយាចិត្ត សហគតៈដោយ
សោមនស្ស ..... ..... ..... ..... ..... ..... ..... ..... ២២៨
សម្តែងអំពីមនោវិញ្ញាណធាតុ ជាកិរិយាចិត្ត សហគតៈដោយ
ឧបេក្ខា ..... ..... ..... ..... ..... ..... ..... ..... .... ២៣០

សម្តែងអំពីមហាកិរិយាចិត្ត ៨ ដួង ..... ..... ..... ...... ២៣១
សម្តែងអំពីហសនចិត្ត ១៣ ដួង ..... ..... ..... ..... .... ២៣២
សម្តែងអំពីរូបាវចរកិរិយា និងអរូបាវចរកិរិយា ..... ..... ... ២៣២

## អដ្ឋកថារូបកណ្ឌ

សម្តែងអំពីឯកកឧទ្ទេស ..... ..... ..... ..... ..... .... ២៣៥
សម្តែងអំពីអព្យាកតៈ គឺរូប ..... ..... ..... ..... ..... ... ២៣៧
សម្តែងអំពីមហាភូតរូប ..... ..... ..... ..... ..... ..... ២៣៨
សម្តែងអំពីមហាភូត គឺអ្នកលេងកលល្បិចជាដើម ..... ..... ២៤២

## អដ្ឋកថាមាតិការូបកណ្ឌ

សម្តែងអំពីឯកមាតិកា ..... ..... ..... ..... ..... ..... ២៤៦
សម្តែងអំពីការសង្គ្រោះរូបមាន ២ ប្រភេទ .... .... ..... ... ២៤៧
សម្តែងអំពីតិករូប គឺរូបមាន ៣ ប្រភេទ .... ..... ..... ..... ២៤៨
សម្តែងអំពីរូបមាន ៤ ប្រភេទជាដើម ..... ..... ..... ..... ២៤៩
សម្តែងអំពីការសង្គ្រោះរូបមាន ៥ ប្រភេទ ..... ..... ..... ២៥២

# អក្សរសង្ខេប

## ដែលប្រើក្នុងអដ្ឋកថាព្រះអភិធម្ម បឋមភាគ ៣ នេះគឺ

| | |
|---|---|
| អភិ. | = ព្រះអភិធម្មបិដក |
| អំ. សត្តក. | = អង្គុត្តរនិកាយ សត្តកនិបាត |
| អំ. អដ្ឋក. | = អង្គុត្តរនិកាយ អដ្ឋកនិបាត |
| អំ. ទសក. | = អង្គុត្តរនិកាយ ទសកនិបាត |
| អំ. នវក. | = អង្គុត្តរនិកាយ នវកនិបាត |
| ខុ. | = ខុទ្ទកនិកាយ |
| ខុ. ឧ. | = ខុទ្ទកនិកាយ ឧបរិបណ្ណាសកៈ |
| ខុ. ធ. | = ខុទ្ទកនិកាយ ធម្មបទ |
| ខុ. បដិ. | = ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ខុ. សុ. | = ខុទ្ទកនិកាយ សុត្តនិបាត |
| ទី. បា. | = ទីឃនិកាយ បាដិកវគ្គ |
| ទី. ម. | = ទីឃនិកាយ មហាវគ្គ ឬទីឃនិកាយ មជ្ឈិមបណ្ណាសកៈ |
| ម. ឧ. | = មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ |
| ម. ម. | = មជ្ឈិមនិកាយ មហាវគ្គ |
| វិនយ. | = វិនយបិដក |
| វិសុទ្ធិ. | = វិសុទ្ធិមគ្គបករណ៍ |
| សំ. ម. | = សំយុត្តនិកាយ មហាវគ្គ ឬសំយុត្តនិកាយ មហាវារវគ្គ |
| សំ. ស. | = សំយុត្តនិកាយ សឡាយតនវគ្គ ។ |

# អដ្ឋសាលិនី

# អដ្ឋកថាព្រះអភិធម្មបិដក

# (ឈ្មោះធម្មសង្គណី)

## បឋមភាគ ៣

## ព. ស. ២៥៥៧

# អដ្ឋសាលិនី អដ្ឋកថាព្រះអភិធម្មបិដក
# ឈ្មោះ ធម្មសង្គណី
# បឋមភាគ ៣

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៚

## អដ្ឋកថា ចិត្តុប្បាទកណ្ឌ

### អធិប្បាយអសុភជ្ឈាន
### សម្តែងអំពីរូបាវចរកុសល

ឥឡូវនេះ ដើម្បីសម្តែងរូបាវចរកុសល ដែលជាប្រយោជន៍ជួយអនុគ្រោះដ៏សមគួរដល់សត្វអ្នកមានរាគចរិតជាដើម ដែលប្រព្រឹត្តទៅដោយអំណាចនៃឈានតែមួយក្នុងអារម្មណ៍ផ្សេងៗនោះ ទើបទ្រង់ផ្តើមពាក្យមានជាអាទិ៍ថា "កតមេ ធម្មា កុសលា" ដូច្នេះទៀត ។

បណ្តាបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧទ្ធុមាតកសញ្ញាសហគតំ** (សហគតដោយឧទ្ធុមាតកសញ្ញា) ជាដើមតទៅ ៖

សាកសព ឈ្មោះថា **ឧទ្ធុមាតៈ** ព្រោះប៉ោងឡើងដោយការហើមប៉ោងឡើងតាមលំដាប់ព្រោះអស់ជីវិត ដូចកូនបាល់ប៉ោងឡើងដោយខ្យល់ដូច្នោះ, សាកសពដែលឈ្មោះថា **ឧទ្ធុមាតៈ** នោះឯង ឈ្មោះថា ឧទ្ធុមាតកៈ; ម្យ៉ាង ឈ្មោះថា **ឧទ្ធុមាតកៈ** ព្រោះអត្ថថា ជាសាកសពប៉ោងឡើងគួរខ្ពើម ព្រោះជារបស់បដិកូល,

ពាក្យថា ឧទ្ធុមាតកៈនេះជាឈ្មោះរបស់សាកសពយ៉ាងនោះ ។ សាកសពដែលមានស្បែកបែកធ្លាយចេញ ដោយប្រការផ្សេងៗ (ដែលស្អុយរលួយ) លោកហៅថា **វិនីលៈ**, សាកសពដែលឈ្មោះថា **វិនីលៈ** នោះឯង ឈ្មោះថា **វិនីលកៈ**; ម្យ៉ាងទៀត ឈ្មោះថា **វិនីលកៈ** ព្រោះជារបស់គួរខ្ពើមមានពណ៌ខៀវជាំ ព្រោះជារបស់គួរបដិកូល, ពាក្យថា **វិនីលកៈ** នេះ ជាឈ្មោះរបស់សាកសពដែលមានពណ៌ក្រហមក្នុងកន្លែងមានសាច់ច្រើន មានពណ៌សក្នុងកន្លែងដែលកកដោយខ្ទុះ និងមានពណ៌ខៀវដោយច្រើនក្នុងទីមានពណ៌ខៀវ ដូចដណ្ដប់ដោយសំពត់ពណ៌ខៀវ ។ សាកសពដែលមានខ្ទុះហូរចេញទៅក្នុងទីដែលបែកធ្លាយហើយ ឈ្មោះថា **វិបុព្វៈ** (ខ្ទុះហូរចេញ), សាកសពដែលមានខ្ទុះហូរចេញនោះឯង ឈ្មោះថា **វិបុព្វកៈ**; ម្យ៉ាងទៀតដែលឈ្មោះថា **វិបុព្វកៈ** ព្រោះអត្ថថា គួរខ្ពើមមានខ្ទុះហូរចេញ ព្រោះជារបស់បដិកូល, ពាក្យថា **វិបុព្វកៈ** នេះជាឈ្មោះរបស់សាកសពដែលមានសភាពដូច្នោះ ។

សាកសពដែលដាច់ជា ២ កំណាត់ ហៅថា **វិច្ឆិទ្ទៈ**; សាសពដែលមានឈ្មោះថា វិច្ឆិទ្ទៈនោះឯង ឈ្មោះថា **វិច្ឆិទ្ទកៈ**; ម្យ៉ាងទៀត ឈ្មោះថា **វិច្ឆិទ្ទកៈ** ព្រោះអត្ថថា គួរខ្ពើមជាកំណាត់ដុំផ្សេងៗ ព្រោះជារបស់បដិកូល, ពាក្យថា **វិច្ឆិទ្ទកៈ** នេះ ជាឈ្មោះរបស់សាកសពដែលដាច់ពាក់កណ្ដាល ។

សាកសពទាំងឡាយដែលមានឆ្កែស្រុក និងឆ្កែចចកខាំស៊ីដោយអាការផ្សេងៗ ដែលខ្ចាត់ខ្ចាយរាត់រាយទៅ ឈ្មោះថា **វិក្ខាយិតៈ**; សាកសពដែលឈ្មោះថា វិក្ខាយិតៈនោះឯង ឈ្មោះថា **វិក្ខាយិតកៈ** ។ ម្យ៉ាងទៀត ឈ្មោះថា **វិក្ខាយិតកៈ** ព្រោះអត្ថថា ជារបស់គួរខ្ពើម ជារបស់ដែលសត្វខាំស៊ី ព្រោះជារបស់បដិកូល, ពាក្យ

ថា **វិក្ខាយិតកៈ** នេះជាឈ្មោះរបស់សាកសពដូច្នោះ ។

សាសពដែលខ្ចាត់ខ្ចាយរាត់រាយទៅ ឈ្មោះថា **វិក្ខិត្តៈ**, សាកសពដែលវិក្ខិត្តៈ នោះឯង ឈ្មោះថា **វិក្ខិត្តកៈ**; ម្យ៉ាងទៀត ដែលឈ្មោះថា **វិក្ខិត្តកៈ** ព្រោះអត្ថថា ជារបស់គួរខ្ពើម ជារបស់ខ្ចាត់ខ្ចាយរាត់រាយទៅ ព្រោះជារបស់បដិកូល ។ ពាក្យថា **វិក្ខិត្តកៈ** នេះ ជាឈ្មោះសាកសពដែលខ្ចាត់ខ្ចាយ រាត់រាយទៅអំពីទីនោះៗ យ៉ាងនេះ គឺ "ដៃទៅទិសមួយទៅ, ជើងទៅទិសមួយទៅ, ក្បាលទៅទិសមួយទៅ" ។

សាកសពដែលត្រូវគេកាប់បំផ្លាញឱ្យវិនាស ខ្ចាត់ខ្ចាយដោយន័យមុននោះឯង ឈ្មោះថា **ហតវិក្ខិត្តកៈ** ។ ពាក្យថា **ហតវិក្ខិត្តកៈ** នេះ ជាឈ្មោះរបស់សាកសពដែលត្រូវគេកាប់ចិញ្ច្រាំដោយសាស្ត្រាវុធក្នុងអវយវៈតូចធំ ដោយអាការដូចជាសញ្ញាលេខបូក (កាកបាទ) ខ្ចាត់ខ្ចាយទៅ ដោយន័យដូចបានពោលហើយនោះ ។

សាកសពដែលមានដំណក់លោហិត ហូរប្រឡាក់ពាសពេញទាំងខាងនោះទាំងខាងនេះ ឈ្មោះថា **លោហិតកៈ**; ពាក្យថា **លោហិតកៈ** នេះ ជាឈ្មោះរបស់សាកសពដែលប្រឡាក់ដោយលោហិតដែលហូរទៅ ។

ហ្វូងដង្កូវទាំងឡាយ លោកហៅថា **បុឡុវា**, សាកសពដែលត្រូវកកកុញដែលណែនទៅដោយហ្វូងដង្កូវរុកចោះ ឈ្មោះថា **បុឡុវកៈ**; ពាក្យថា **បុឡុវកៈ** នេះ ជាឈ្មោះរបស់សាកសពដែលពេញទៅដោយហ្វូងដង្កូវ ។

សាកសពដែលមានតែឆ្អឹងប៉ុណ្ណោះ ហៅថា **អដ្ឋិកៈ**; ម្យ៉ាងទៀត ឈ្មោះថា **អដ្ឋិកៈ** ព្រោះអត្ថថា ជាឆ្អឹងដែលគួរខ្ពើម ព្រោះជារបស់បដិកូល, ពាក្យថា **អដ្ឋិកៈ** នេះ ជាឈ្មោះរបស់សាកសពដែលមានរាងឆ្អឹងខ្លះ, មានដុំឆ្អឹងមួយដុំខ្លះ; សាកសព

ទាំងនេះ ជាឈ្មោះរបស់និមិត្តដែលកើតឡើង ព្រោះអាស្រ័យសាកសពដែលហើមប៉ោងជាដើមទាំងនេះខ្លះ, របស់ឈានដែលបានក្នុងនិមិត្តទាំងឡាយខ្លះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ឧទ្ធុមាតកសញ្ញាខាងដើមទាំងនោះតទៅ ៖

សញ្ញាដែលកើតឡើង ដោយអំណាចអប្បនាក្នុងសាកសពដែលហើមប៉ោងឡើងជានិមិត្ត ឈ្មោះថា **ឧទ្ធុមាតកសញ្ញា**, ចិត្តដែលសហគតដោយឧទ្ធុមាតកសញ្ញានោះ ព្រោះអត្ថថា ជាសម្បយោគ ឈ្មោះថា **ឧទ្ធុមាតកសញ្ញាសហគត**; សូម្បីតែនៅក្នុងចិត្តដែលសហគតដោយ **វិនីលកសញ្ញា** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ប៉ុន្តែក្នុងអធិការនៃអសុភនេះ វិធីចម្រើនយ៉ាងណាដែលគប្បីពោល, វិធីចម្រើននោះ ខ្ញុំ(ព្រះពុទ្ធឃោសាចារ្យ) ពោលទុកហើយក្នុង**វិសុទ្ធិមគ្គ** [១] ដោយប្រការទាំងពួង; ការពណ៌នាបាលីដែលនៅសល់ គប្បីជ្រាបដោយន័យដែលពោលទុកហើយនោះចុះ; ក្នុងអសុភនេះ តែមួយពួកៗមាន ២៥ ដោយអំណាចនៃបឋមជ្ឈានតែម្យ៉ាង ដូចក្នុងឧបេក្ខាព្រហ្មវិហារដែរ មានដោយអំណាចនៃចតុត្ថជ្ឈាន; ព្រោះភាវៈនៃអារម្មណ៍ដែលជាអសុភ មិនគប្បីពង្រីក ។ អារម្មណ៍និមិត្តដែលកើតឡើងក្នុងកន្លែងសាកសព ឧទ្ធុមាតកៈមានដ៏តូច គប្បីជ្រាបថាជា**បរិត្តារម្មណ៍**, ដែលកើតឡើងក្នុងឧទ្ធុមាតកៈដ៏ធំជាអប្បមាណារម្មណ៍; សូម្បីនៅក្នុងអសុភដែលសល់ក៏មានន័យដូចគ្នានេះដែរ ។ (បាលីបកិណ្ណកកថាពោលថា)៖

**ឥតិ អសុភានិ សុភគុណោ**

**ទសសតលោចនេន ថុតកិត្តិ**

---

[១] វិសុទ្ធិ. ១ (អសុភកម្មដ្ឋាននិទ្ទេស) ។

**យានិ អសេច ឧសភស្ស**
**ឯកេកជ្ឈានហេតូនិ ។**
**ឯវំ បាលិនយេនេវ តាវ សព្វា តានិ ជានិត្វា**
**តេស្វេវ អយំ ភិយ្យោ បកិណ្ណកកថាបិ ខិញ្ញេយ្យា ។**

ព្រះទសពលទ្រង់មានព្រះគុណដ៏ល្អ ទ្រង់មានព្រះកិត្តិសព្ទ គួរដល់ការសរសើរ ដោយការក្រឡេកឃើញទាំងពាន់ (ន័យ) បានត្រាស់អសុភទាំងឡាយដែលជាហេតុនៃឈានតែម្យ៉ាងៗទុកដោយប្រការដូច្នេះ ។

បណ្ឌិតកាលជ្រាបអសុភទាំងអស់នោះ ដោយន័យនៃព្រះបាលីយ៉ាងនេះមុនហើយ គប្បីជ្រាបកថាជាចំណែកផ្សេងៗនេះ ក្នុងអសុភទាំងនោះឱ្យក្រៃលែងឡើងទៅ [២] ។

ពិតមែនហើយ បុគ្គលរមែងប្រាសចាកការប្រព្រឹត្តិមិននឹងហ្ន (ការឡេះឡោះ) បាន ព្រោះក្នុងអសុភណាមួយ បណ្តាអសុភទាំងនោះ ដូចអ្នកមានរាគៈទៅប្រាសហើយ ព្រោះការដែលរាគៈត្រូវខ្លួនសង្កត់ទុក ក្នុងឈានដែលពន្លុះហើយ; កាលបើដូច្នោះ ប្រភេទនៃអសុភណា ប្រភេទនៃអសុភនោះ គប្បីជ្រាបថា ត្រាស់ទុកដោយការដល់នូវសេចក្តីប្រព្រឹត្តទៅដោយខ្លួនឯងនៃសាកសព និងដោយអំណាចនៃការទម្លាយរាគចរិត; ព្រោះសាកសពកាលដល់ភាវៈជារបស់បដិកូល (ហើយ) ក៏នឹងគប្បីដល់សភាពហើមប៉ោងឡើងនៃសាកសព, ឬដល់សភាពជាសាកសពយ៉ាងណាមួយមានពណ៌ខៀវជាំជាដើម; ដោយហេតុនេះ កុលបុត្រគប្បីកំណត់និមិត្តក្នុង

---

[២] វិសុទ្ធិ. ១ (អសុភកម្មដ្ឋាននិទ្ទេស) ។

អសុភយ៉ាងណានីមួយតាមដែលនឹងរកបានយ៉ាងនេះថា “សាកសពដែលហើមប៉ោងឡើងជារបស់បដិកូល, សាកសពដែលមានពណ៌ខៀវជាំ ជារបស់បដិកូល” ជាដើម គប្បីជ្រាបថាត្រាស់ប្រភេទនៃអសុភ ១០ យ៉ាង ដោយអំណាចនៃការដល់នូវភាពជារបស់ខ្លួនឯងនៃសាកសពដូច្នេះ ៕

## សម្តែងអំពីសប្បាយ ១០ យ៉ាង

ម្យ៉ាងទៀត ពោលដោយការប្លែកគ្នា (វិសេស) ក្នុងអសុភទាំង ១០ នោះ សាកសពដែលជាឧទ្ធុមាតកៈ (ហើមប៉ោងឡើង) ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងសរីរសណ្ឋាន ព្រោះប្រកាស (ប្រាកដ) ដល់ការវិបត្តិនៃសរីរសណ្ឋាន ។ សាកសពដែលមានពណ៌ខៀវជាំ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងសរីរវណ្ណ ព្រោះប្រកាសដល់ការវិបត្តិ ការត្រេកអរក្នុងពណ៌ ។ សាកសពដែលមានខ្ទុះហូរ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងក្លិននៃសរីរៈ ដែលតាក់តែងឡើងដោយផ្កាឈើ និងរបស់ក្រអូបជាដើម ព្រោះប្រកាសសភាពជាក្លិនស្អុយ ដែលជាប់ទាក់ទងដោយប្រភេទនៃសាកសព ។ សាកសពដែលដាច់ជាដុំ ជាកំណាត់ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងភាពជាឃនៈ (ដុំ) នៃសរីរៈ ព្រោះប្រកាសភាពប្រហោងនៃកាយខាងក្នុង ។ សាកសពដែលត្រូវសត្វខាំស៊ី ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងកន្លែងដែលមានសាច់ក្រពុំ ក្នុងចំណែកនៃរាងកាយមានដោះជាដើម ព្រោះប្រកាសការវិនាសទៅនៃការសម្បូរណ៍ដោយសាច់ក្រពុំ ។ សាកសពដែលមានអវយវៈខ្ចាត់ខ្ចាយទៅ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងភាពសង្ហារក្នុងដំណើរនៃ

អវយវៈតូចធំ ព្រោះប្រកាសនូវការខ្ចាត់ខ្ចាយទៅនៃអវយវៈតូចធំ ។ សាកសព ដែលត្រូវគេកាត់ដុំៗ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងការដល់ព្រមនៃគ្រោងរាងកាយ ព្រោះប្រកាសភាពពិការរបស់គ្រោងរាងកាយ ។ សាកសពដែលមានឈាមប្រឡាក់ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងភាពល្អស្អាតដែលកើតអំពីការប្រដាប់តាក់តែង ព្រោះប្រកាសភាពបដិកូល ដោយការប្រឡាក់ឈាម ។ សាកសពដែលមានហ្វូងដង្កូវរុកចោះ ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងរាងកាយថាជារបស់យើង ព្រោះប្រកាសដល់ភាពដែលរាងកាយជារបស់សាធារណ៍ដល់ត្រកូលហ្វូងដង្កូវមិនមែនតិច ។ សាកសពដែលសល់តែឆ្អឹង ជាសប្បាយដល់បុគ្គលអ្នកត្រេកអរក្នុងការសម្បូរណ៍នៃធ្មេញ ព្រោះប្រកាសដល់ភាពជារបស់បដិកូលនៃឆ្អឹងក្នុងសរីរៈ ។ គប្បីជ្រាបថា ប្រភេទនៃអសុភ ១០ យ៉ាង ព្រះមានព្រះភាគត្រាស់ទុកស្តម្បីដោយអំណាចនៃការទម្លាយរាគចរិត មានការប្រកាសដូច្នេះ ។

ក្នុងអសុភ ១០ យ៉ាងនេះ ចិត្តនឹងស្ងប់តាំងនៅបានដោយកម្លាំងរបស់វិតក្កៈប៉ុណ្ណោះ វៀរវិតក្កៈចេញហើយ ក៏មិនអាចតាំងនៅបាន ព្រោះការដែលអារម្មណ៍មានកម្លាំងខ្សោយដោយជារបស់បដិកូល ដូចជាទូកចតនៅក្នុងស្ទឹងដែលមានក្រសែទឹកហូរយ៉ាងត្របាញ់ រមែងឈប់បានដោយកម្លាំងថ្នោលប៉ុណ្ណោះ វៀរចាកឈើថ្នោលហើយ ក៏មិនអាចចតនៅបានដូច្នោះដែរ, ព្រោះហេតុដូច្នោះ ក្នុងអសុភកម្មដ្ឋាននេះ រមែងមានបានត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ, ទុតិយជ្ឈានជាដើម មិនមានឡើយ ។

ម្យ៉ាងទៀត ក្នុងអារម្មណ៍ជារបស់បដិកូលនេះ បីតិ និងសោមនស្ស ក៏រមែង

កើតឡើង ព្រោះការដែលព្រះយោគាវចរឃើញអានិសង្សយ៉ាងនេះថា **“យើងនឹងផុតចាកជរា និងមរណៈ ព្រោះបដិបទានេះពិត១”** , និងព្រោះលះសេចក្ដីក្ដៅក្រហាយនៃនីវរណៈបាន ដូចបុគ្គលក្រងផ្កាឈើ ព្រោះឃើញអានិសង្សថា “ឥឡូវនេះយើងនឹងបានថ្លៃឈ្នួលច្រើន” ទើបកើតបីតិសោមនស្សក្នុងគំនរលាមក និងដូចបុគ្គលមានរោគជាទុក្ខ ព្រោះព្យាធិកើតឡើង មានបីតិសោមនស្សក្នុងការប្រព្រឹត្តទៅនៃការដាក់ថ្នាំបញ្ចុះដូច្នោះ ។

សូម្បីអសុភទាំង ១០ យ៉ាងនេះ ដោយលក្ខណៈមានតែម្យ៉ាងប៉ុណ្ណោះ, ព្រោះថា សូម្បីអសុភ ១០ យ៉ាងនេះ មានសភាពជារបស់បដិកូល ដោយជារបស់មិនស្អាត មានក្លិនស្អុយ គួររង្កាសប៉ុណ្ណោះជាលក្ខណៈ; ដោយលក្ខណៈនេះ អសុភនេះទើបមិនប្រាកដក្នុងសរីរៈដែលស្លាប់ហើយតែម្យ៉ាងទេ, រមែងប្រាកដក្នុងរាងកាយដែលមានជីវិតដែរ ដូចព្រះមហាតិស្សត្ថេរលោកនៅក្នុងចេតិយបព៌ត (កោះសីហឡៈ) លោកឃើញឆ្អឹងធ្មេញ [៣] , និងដូចប្រាកដដល់សាមណេរឧបដ្ឋាកព្រះសង្ឃរក្ខិតត្ថេរដែលក្រឡេកមើលព្រះរាជាទ្រង់គង់ប្រថាប់លើ-កដំរីដូច្នោះ; ព្រោះថា រាងកាយដែលស្លាប់ហើយ ជាអសុភយ៉ាងណា, សូម្បីសរីរៈដែលកំពុងរស់នៅក៏ជាអសុភដូច្នោះដែរ; ប៉ុន្តែថា ក្នុងរាងកាយដែលរស់នៅនេះ លក្ខណៈនៃអសុភរមែងមិនប្រាកដ ព្រោះគ្រឿងប្រដាប់ (អលង្ការ) ចូលមកបិទបាំងទុកដូច្នោះឯង ៕

**អសុភកថាចប់**

---

[៣] វិសុទ្ធិ. ១/ (សីលនិទ្ទេស ឥន្ទ្រិយសំវរសីល) ។

***សួរថា*** រូបាវចរអប្បនានេះ មានបឋវីកសិណជាខាងដើម មានអដ្ឋិកសញ្ញា ជាបរិយោសាន ជាអារម្មណ៍ប៉ុណ្ណោះឬ ? ឬសូម្បីយ៉ាងដទៃ ក៏មានដែរ ។ ឆ្លើយថា សូម្បីយ៉ាងដទៃដែលជាអារម្មណ៍ក៏មានដែរ ។ ប៉ុន្តែក្នុងព្រះអភិធម្មនេះ មិនបាន ត្រាស់អានាបានជ្ឈាន និងកាយគតាសតិភាវនាទុកទេ; សូម្បីមិនបានត្រាស់ទុក ក៏ពិតមែនហើយ, ប៉ុន្តែថា លោកក៏បញ្ជាក់ដល់វាយោកសិណទុកដែរ ទើបត្រូវ បញ្ជាក់ដល់អានាបានជ្ឈានដោយពិត ។ ម្យ៉ាងទៀត កាលបញ្ជាក់ដល់វណ្ណកសិណ ទាំងឡាយ ក៏ត្រូវបញ្ជាក់ដល់កាយគតាសតិ ដែលកើតឡើងដោយចតុក្កឈាន និងបញ្ចកឈាន ក្នុងកោដ្ឋាសៈមានសក់ជាដើម, និងក្នុងអសុភ ១០ យ៉ាង ទ្រង់ កាន់យកហើយ កាយគតាសតិដែលប្រព្រឹត្តទៅដោយអំណាចនៃឈានដែលមនសិ ការបដិកូលក្នុងអាការ ៣២ និងដោយអំណាចនៃឈានដែលកើតឡើងអំពីវណ្ណៈ ក្នុងព្រៃខ្មោច (ប៉ាឆា) ៩ ប្រភេទ ក៏រមែងត្រូវទ្រង់កាន់យកហើយដូចគ្នា ។ អប្បនា ដែលជារូបាវចរទាំងអស់ រមែងត្រូវបានត្រាស់ទុកហើយក្នុងទីនេះ ដោយប្រការ ដូច្នេះ ៕

***រូបាវចរកថាចប់***

## អដ្ឋកថាចិត្តុប្បាទកណ្ឌ
## សម្តែងអំពីអរូបាវចរកុសល ៤

ឥឡូវនេះ ដើម្បីទ្រង់សម្តែងអរូបាវចរកុសល ទើបទ្រង់ផ្តើមពាក្យថា **"កតមេ ធម្មា កុសលា"** ដូច្នេះទៀត ។

បណ្តាបទទាំងនេះ បទថា **អរូបូបបត្តិយា** សេចក្តីថា អរូបភព ហៅថា អរូប, ការកើតឡើងក្នុងអរូប ហៅថា **អរូបូបបត្តិ**, ព្រះយោគាវចរចម្រើនមគ្គ បដិបទាដើម្បីចូលដល់អរូបភពនោះ ។

បទថា **មគ្គំ ភាវេតិ** សេចក្តីថា រមែងញុំាងឧបាយ គឺហេតុ គឺការណៈ ឱ្យកើតឡើង គឺឱ្យចម្រើនឡើង ។ បទថា **សព្វសោ** បានដល់ ដោយអាការទាំងពួង, ម្យ៉ាងវិញទៀត អធិប្បាយថា ទាំងអស់មិនមានសល់ ។ បទថា **រូបសញ្ញានំ** បានដល់ រូបាវចរជ្ឈាន ដែលត្រាស់ទុកដោយមានសញ្ញាជាប្រធាន និងជាអារម្មណ៍របស់ឈាននោះ ។ ពិតមែនហើយ សូម្បីរូបាវចរជ្ឈាន ក៏ត្រាស់ហៅថា "រូប" ដូចក្នុងប្រយោគមានពាក្យជាដើមថា "អ្នកមានរូប រមែងឃើញរូបទាំងឡាយ"[៤], សូម្បីអារម្មណ៍នៃរូបាវចរជ្ឈាននោះ ក៏ត្រាស់ថា "រូប" ដូចក្នុងប្រយោគមានអាទិ៍ជាដើមថា "រមែងឃើញរូបខាងក្រៅដែលមានពណ៌សម្បុរល្អ និងមិនល្អ"[៥]

---

[៤] អភិ., ទី. ម. ។

[៥] អភិ., ទី. ម. ។

ព្រោះហេតុដូច្នោះ ក្នុងទីនេះ ពាក្យថា **រូបសញ្ញានំ** នេះ ទើបជាឈ្មោះរបស់រូបាវចរជ្ឈាន តាមដែលពោលទុកដោយមានសញ្ញាជាប្រធានយ៉ាងនេះថា "សញ្ញាក្នុងរូប ឈ្មោះថា **រូបសញ្ញា** " ; រូបាវចរជ្ឈានដែលឈ្មោះថា **រូបសញ្ញា** ព្រោះអត្ថថា មានរូបជាគ្រឿងសម្គាល់, អធិប្បាយថា រូបជាឈ្មោះរបស់ឈាននោះ ។ ម្យ៉ាងទៀត ពាក្យថា **រូប** នេះ ក៏គប្បីជ្រាបថា ជាឈ្មោះរបស់អារម្មណ៍នៃឈាននោះ ដែលផ្សេងគ្នាដោយរូបមានបឋវីកសិណជាដើម ។

បទថា **សមតិក្កមា** (ព្រោះឈានកន្លង) បានដល់ ព្រោះបន្ថយ (វិរាគះ) និងរំលត់ ។ ពាក្យនេះមានអធិប្បាយទុកយ៉ាងណាខ្លះ ? លោកអធិប្បាយថា ព្រះយោគាវចរចូលអាកាសានញ្ចាយតនៈ ព្រោះបន្ថយ និងរំលត់ គឺហេតុដែលបន្ថយ និងហេតុដែលរំលត់នូវរូបសញ្ញាទាំងឡាយ គឺឈាន ១៥ ដោយកុសល, វិបាក និងកិរិយាទាំងនោះ និងរូបសញ្ញាទាំងឡាយ គឺអារម្មណ៍ ៨ យ៉ាង ដោយអំណាចនៃបឋវីកសិណជាដើមទាំងនោះដោយអាការទាំងពួង ឬថា ដោយមិនមានចំណែកសេសសល់ ។ ពិតមែនហើយ ព្រះយោគាវចរមិនអាចចូលអាកាសានញ្ចាយតនៈនោះ ដោយនៅមិនបានឈានកន្លងរូបសញ្ញាដោយប្រការទាំងពួងទេ; ក្នុងរូបសញ្ញាទាំងនោះ ព្រោះអ្នកនៅមិនបានស្រាយសេចក្តីត្រេកអរក្នុងអារម្មណ៍ ក៏ឈានកន្លងនូវសញ្ញាទៅមិនបាន, និងកាលឈានកន្លង នូវសញ្ញាទាំងឡាយបានហើយ អារម្មណ៍ក៏រមែងត្រូវឈានកន្លងទៅបានដូចគ្នា, ព្រោះហេតុដូច្នោះ ទើបមិនត្រាស់ដល់ការឈានកន្លងនូវអារម្មណ៍ ត្រាស់តែការឈានកន្លងនូវសញ្ញាទាំងឡាយប៉ុណ្ណោះ ទុកក្នុងវិភង្គយ៉ាងនេះថា ៖

"ពាក្យថា ព្រោះឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង មានអធិប្បាយថា រូបសញ្ញាតើដូចម្ដេច ? ការចាំ កិរិយាដែលចាំ សេចក្ដីចាំរបស់ព្រះយោគាវចរអ្នកចូលរូបាវចរសមាបត្តិ ឬរបស់អ្នកឧប្បត្តិក្នុងរូបភូមិ ឬរបស់ព្រះអរហន្តលោកនៅជាសុខក្នុងទិដ្ឋធម៌ (ពេលបច្ចុប្បន្ន), ទាំងនេះហៅថា **រូបសញ្ញា**; ភិក្ខុឈានកន្លងហើយ ឆ្លងហើយ ឆ្លងផុតហើយនូវរូបសញ្ញាទាំងនេះ, ដោយហេតុនោះទើបហៅថា "ព្រោះឈានកន្លងរូបសញ្ញា ដោយប្រការទាំងពួង" [៦] ។ ក៏ព្រោះសមាបត្តិទាំងនេះ គប្បីពោលដោយការឈានកន្លងអារម្មណ៍ មិនមែនពោលក្នុងអារម្មណ៍តែមួយប៉ុណ្ណោះដូចបឋមជ្ឈានជាដើមទេ, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ការពណ៌នាសេចក្ដីនេះ ទ្រង់ធ្វើទុកដោយអំណាចនៃការឈានកន្លងអារម្មណ៍ ។

ពាក្យថា **បដិឃសញ្ញានំ អត្ថង្គមា** (ព្រោះការរលត់ទៅនៃបដិឃសញ្ញា) សេចក្ដីថា សញ្ញាដែលកើតឡើងព្រោះការប៉ះខ្ទប់វត្ថុមានចក្ខុវត្ថុជាដើម និងអារម្មណ៍មានរូបារម្មណ៍ជាដើម ឈ្មោះថា **បដិឃសញ្ញា**, ពាក្យថា **បដិឃសញ្ញា** នេះជាឈ្មោះរបស់រូបសញ្ញាជាដើម ។ សមដូចដែលត្រាស់ទុកក្នុងវិភង្គថា "ពាក្យថា ព្រោះការរលត់ទៅនៃបដិឃសញ្ញា ដូចនេះ មានអធិប្បាយថា បដិឃសញ្ញា តើដូចម្ដេច ? រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា, ទាំងនេះហៅថា **បដិឃសញ្ញា**" [៧] ។ មានអធិប្បាយថា ព្រោះរំលត់ គឺព្រោះលះ គឺព្រោះការ

---

[៦] អភិ. ។

[៧] អភិ. ។

មិនកើតឡើង បានដល់ធ្វើមិនឱ្យប្រព្រឹត្តទៅដោយប្រការទាំងពួងនៃបដិឃសញ្ញាសូម្បីទាំង ១០ គឺ កុសលវិបាក ៥ អកុសលវិបាក ៥ នៃបដិសញ្ញាទាំងនោះ ។ បដិឃសញ្ញាទាំងនោះ រមែងមានដល់អ្នកចូលឈានមានបឋមជ្ឈានជាដើមដោយពិត, ព្រោះក្នុងសម័យនោះ ចិត្តរមែងមិនប្រព្រឹត្តទៅតាមផ្លូវបញ្ចទ្វារទេ ។ សូម្បីកាលបើដូច្នោះ គប្បីជ្រាបពាក្យដែលត្រាស់ដល់បដិឃសញ្ញាទាំងនោះក្នុងអភិធម្មនេះដោយអំណាចនៃការលើកតម្កើងសរសើរឈាននេះ ដើម្បីការញុំាងឈាននេះឱ្យកើតឡើង ដូចការពោលដល់សុខ និងទុក្ខដែលលះបានហើយក្នុងឈានដទៃទុកក្នុងឈានទី ៤ និងដូចពោលដល់សក្កាយទិដ្ឋិជាដើម ដែលលះបានហើយក្នុងមគ្គដទៃទុកក្នុងមគ្គទី ៣ ដូច្នោះដែរ ។

ម្យ៉ាងទៀត បដិឃសញ្ញាទាំងនេះ មិនមានដល់អ្នកចូលរូបាវចរជ្ឈាន ក៏ពិតមែនហើយ, ប៉ុន្តែ រមែងមិនមានព្រោះលះបានហើយ ក៏មិនបាន, ព្រោះថា ការចម្រើនរូបាវចរ មិនមែនប្រព្រឹត្តទៅព្រមដើម្បីការធ្វើឱ្យអស់ទៅនូវសេចក្តីត្រេកអរក្នុងរូបទេ ។ ម្យ៉ាងទៀត បដិឃសញ្ញាទាំងនេះ រមែងប្រព្រឹត្តទៅព្រម ព្រោះអាស្រ័យរូប, ប៉ុន្តែភាវនានេះ រមែងប្រព្រឹត្តទៅព្រមដើម្បីឱ្យអស់ទៅនូវសេចក្តីត្រេកអរក្នុងរូប; ព្រោះហេតុដូច្នោះ សមគួរនឹងពោលបានថា បដិឃសញ្ញាទាំងនោះព្រះយោគាវចរលះបានហើយក្នុងឈាននេះ ។ ម្យ៉ាងទៀត មិនមែនត្រឹមតែការពោលប៉ុណ្ណោះទេ សូម្បីការទ្រទ្រង់ទុកយ៉ាងនេះដោយចំណែកមួយនោះក៏សមគួរដែរ; ពិតមែនហើយ ព្រះមានព្រះភាគត្រាស់ថា សំឡេងជាបន្លា (សត្រូវ) របស់

អ្នកចូលបឋមជ្ឈាន ព្រោះនៅលះមិនទាន់បានក្នុងកាលមុន [៨] អំពីកាលនេះ; តែក្នុងទីនេះ ព្រះអង្គទ្រង់ត្រាស់ការដែលអរូបសមាបត្តិទាំងឡាយជាអនេញ្ជា និងសេចក្តីដែលអរូបសមាបត្តិទាំងឡាយជាសន្តិវិមោក្ខ ព្រោះលះ (បដិឃសញ្ញា) បានហើយដោយពិត; អាឡារតាបសកាលាមគោត្រ ចូលអរូបជ្ឈាន មិនបានឃើញនិងមិនបានឮសំឡេង [៩] រទេះប្រមាណ ៥០០ រទេះ ដែលឆ្លងទៅជិតទីអាស្រ័យ ។

បទថា **នានត្តសញ្ញានំ អមនសិការា** (ព្រោះមិនមានមនសិការនូវនានត្តសញ្ញា) សេចក្តីថា សញ្ញាទាំងឡាយដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេង, ឬសញ្ញាទាំងឡាយផ្សេងគ្នា; ក្នុងទីនេះ បំណងយកសញ្ញាទាំងនេះ ដែលត្រាស់ចែកទុកក្នុងវិភង្គយ៉ាងនេះថា "ក្នុងសញ្ញាទាំងនោះ នានត្តសញ្ញាតើដូចម្តេច ? សញ្ញាកិរិយាដែលចាំបាន ភាពជាអ្នកចាំបានរបស់អ្នកមិនចូលសមាបត្តិ ឬថាអ្នកដល់ព្រមដោយមនោធាតុ ឬថា អ្នកដល់ព្រមដោយមនោវិញ្ញាណធាតុ, ទាំងនេះហៅថានានត្តសញ្ញា" [១០] ចំណែកសញ្ញាដែលដល់ព្រមដោយមនោធាតុ និងមនោវិញ្ញាណធាតុរបស់អ្នកមិនចូលសមាបត្តិ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមានសេចក្តីផ្សេងគ្នា និងសភាវៈដែលផ្សេងគ្នាដោយរូប និងសំឡេងជាដើម ។

ម្យ៉ាងទៀត សូម្បី **សញ្ញា** ទាំង ៤៤ យ៉ាងនេះគឺ

**- កាមាវចរកុសលសញ្ញា ៨**

---

[៨] អំ. ទសក. ។

[៩] ទី. ម. ១៦។

[១០] អភិ. ។

- អកុសលសញ្ញា ១២
- កាមាវចរកុសលវិបាកសញ្ញា ១១
- អកុសលវិបាកសញ្ញា ២
- កាមាវចរកិរិយាសញ្ញា ១១

មានសេចក្ដីផ្សេងគ្នា មានសភាវៈផ្សេងគ្នា មិនដូចគ្នា, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **“នានត្តសញ្ញា”** , ព្រោះមិនមែនមនសិការ, ព្រោះមិនសញ្ជឹងគិត, ព្រោះមិននឹកគិត, ព្រោះមិននាំមក, ព្រោះមិនពិចារណានានត្តសញ្ញាទាំងនោះ ដោយប្រការទាំងពួង; លោកអធិប្បាយទុកថា ព្រោះមិនសញ្ជឹងគិត, មិនមនសិការ, មិនពិចារណាសញ្ញាទាំងនោះ; ក៏ព្រោះតែនៅក្នុងអាកាសានញ្ចាយតនៈនោះ រូបសញ្ញា, បដិឃសញ្ញាខាងដើម រមែងមិនមាន សូម្បីក្នុងភពដែលកើតឡើងដោយឈាននេះ, និងចាំបាច់ពោលទៅថ្វីដល់ក្នុងកាលដែលចូលឈាននេះក្នុងភពនោះ, ព្រោះហេតុដូច្នោះ ទើបត្រាស់ការមិនមានសញ្ញាទាំង ២ នោះដោយពាក្យថា ព្រោះការឈានកន្លង ព្រោះការរលត់ទៅនៃបដិឃៈទាំងនោះ ។ ប៉ុន្តែ ក្នុងនានត្តសញ្ញាទាំងឡាយ សញ្ញា ២៧ យ៉ាងនេះ គឺកាមាវចរកុសលសញ្ញា ៨, កិរិយាសញ្ញា ៩ (មហាកិរិយា ៨, មនោទ្វារាវជ្ជនៈ ១), អកុសលសញ្ញា ១០ (វៀរទោសៈ ២), មិនមានក្នុងភពដែលកើតហើយដោយឈាននេះ, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ពាក្យនេះត្រាស់ទុកថា **ព្រោះមិនមនសិការសញ្ញា** ទាំងនោះ; ព្រោះថា ក្នុងការកើតឡើង កាលព្រះយោគាវចរកំពុងចូលឈាននេះ ក៏ចូលឈានព្រោះមិនមនសិការសញ្ញាទាំងនោះឡើយ, ប៉ុន្តែកាលមនសិការសញ្ញាទាំងនោះ ក៏

រមែងមិនចូលដូចនេះ; កាលពោលដោយសង្ខេបក្នុងសញ្ញាទាំងនេះ ត្រាស់ការលះរូបាវចរធម៌ទាំងពួងដោយពាក្យថា “**រូបសញ្ញានំ សមតិក្កមា** = ព្រោះការឈានកន្លងរូបសញ្ញាទាំងឡាយ” , នឹងគប្បីជ្រាបថា ត្រាស់ការលះ និងការមិនមនសិការចិត្ត និងចេតសិកដែលជាកាមាវចរទាំងពួងដោយពាក្យនេះថា “**បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា** ព្រោះការរលត់ទៅនៃបដិឃសញ្ញា ព្រោះមិនមនសិការនូវនានត្តសញ្ញា” ; ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ពន្យល់អាកាសានញ្ចាយតនសមាបត្តិទុកដោយបទទាំង ៣ គឺដោយការឈានកន្លងរូបសញ្ញា ១៥ យ៉ាង, ដោយការរលត់ទៅនៃបដិឃសញ្ញា ១០ យ៉ាង, ដោយការមិនមនសិការនានត្តសញ្ញា ៤៤ យ៉ាង ។

ប្រសិនបើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ពន្យល់យ៉ាងនោះ ? ឆ្លើយថា ដើម្បីនឹងឱ្យកើតសេចក្ដីឧស្សាហ៍ និងដើម្បីប្រឡោមលួងលោមចិត្ត (ធ្វើឱ្យចិត្តរីករាយ) ដល់អ្នកស្ដាប់ទាំងឡាយ; ប្រសិនបើអាចារ្យពួកខ្លះដែលមិនមែនជាបណ្ឌិត នឹងគប្បីពោលថា “ព្រះសាស្ដារមែងត្រាស់ថា ពួកលោកចូរធ្វើអាកាសានញ្ចាយតនសមាបត្តិឱ្យកើត” ដូចនេះ ក៏អ្វីហ្ន៎ជាប្រយោជន៍, អ្វីហ្ន៎ជាអានិសង្សរបស់អាកាសានញ្ចាយតនសមាបត្តិដែលកើតឡើងនោះ”; ព្រោះហេតុដូច្នោះ ព្រះអង្គទើបទ្រង់ពន្យល់សមាបត្តិតាមហេតុទាំងនេះ ដោយព្រះតម្រិះថា “សូមជនទាំងនោះ កុំបានដើម្បីនឹងពោលយ៉ាងនេះឡើយ” ។ ពិតមែនហើយជនទាំងនោះបានស្ដាប់ព្រះតម្រាស់នោះហើយ ក៏នឹងគិតថា “បានឮថា សមាបត្តិនេះនឹងមានជាយ៉ាងនេះ នឹងស្ងប់យ៉ាងនេះ នឹងប្រណីតយ៉ាងនេះ ពួកយើងនឹងញ៉ាំង

សមាបត្តិនោះឱ្យកើត” , ពេលនោះពួកគេក៏នឹងនាំគ្នាធ្វើឧស្សាហ៍ដើម្បីឱ្យសមាបត្តិនោះកើតឡើង ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់លើកតម្កើងអាកាសានញ្ចាយតនសមាបត្តិនេះ ដល់ព្រះយោគាវចរទាំងនោះដើម្បីលួងលោមចិត្ត ដូចនាយឈ្មួញស្ករអំពៅឈ្មោះវិសកណ្ណកៈ; លោកហៅឈ្មោះវិសកណ្ណកពាណិជ្ជថា “អ្នកជួញស្ករអំពៅ” ; បានឮថា នាយឈ្មួញស្ករអំពៅនោះ ប្រើប្រាស់រទេះផ្ទុកស្ករអំពៅ និងស្ករត្នោតជាដើម ទៅបច្ចន្តគ្រាមហើយឃោសនាថា “ពួកលោកចូរមកទទួលស្ករអំពៅវិសកណ្ណកៈ, ពួកលោកចូរមកទទួលស្ករអំពៅវិសកណ្ណកៈ” ក៏គិតថា “វត្ថុនេះសាហាវណាស់ ឈ្មោះថា មានពិស បុគ្គលណាទំពារស៊ី បុគ្គលនោះត្រូវតែស្លាប់ សូម្បីបន្លាចាក់ហើយ ក៏ឱ្យស្លាប់បាន វត្ថុទាំងពីរនេះ កាចសាហាវណាស់ វានឹងមានប្រយោជន៍អ្វី” ដូចនេះ ទើបនាំគ្នាបិទទ្វារផ្ទះ, និងឱ្យពួកក្មេងៗគេចចេញទៅ ។ នាយឈ្មួញ ឃើញការធ្វើនោះហើយ ទើបគិតថា “អ្នកស្រុកទាំងនេះមិនឆ្លាតក្នុងវោហារ, ណ្ហើយចុះ យើងនឹងឱ្យគេទិញទៅដោយឧបាយ” ទើបឃោសនាថា “ពួកលោកចូរមកទទួលទឹកអំពៅដ៏ផ្អែមក្រៃលែង, ពួកលោកចូរមកទទួលទឹកត្នោតដ៏ឆ្ងាញ់អស្ចារ្យ, ពួកលោកនឹងបានស្ករអំពៅ និងស្ករត្នោតថ្លៃល្មមសមគួរ, និងយកមាសកៈប៉ូម (ក្លែងក្លាយ) និងកហាបណៈប៉ូមជាដើមមកទិញក៏បាន” ។ ពួកអ្នកស្រុកស្តាប់ពាក្យនោះហើយ ខ្លះក៏នាំគ្នារីករាយពេញចិត្តទៅឱ្យតម្លៃ សូម្បីដោយច្រើនហើយកាន់យក ។

ក្នុងពាក្យទាំងនោះ គប្បីប្រៀបធៀបឧបមាព្រះតម្រាស់ដែលព្រះមានព្រះ

ភាគត្រាស់ថា “ពួកអ្នកចូរញ៉ាំងអាកាសានញ្ចាយតនសមាបត្តិឱ្យកើត” ប្រៀបដូចការឃោសនារបស់នាយឈ្មួញថា “ពួកលោកចូរទទួលស្ករអំពៅវិសកណ្ណកៈ” ។ ព្រះមានព្រះភាគត្រាស់ថា “ពួកអ្នកគប្បីធ្វើអាកាសានញ្ចាយតនៈឱ្យកើត” ប្រៀបដូចពួកអ្នកស្រុកនាំគ្នាគិតថា “វត្ថុទាំង ២ នេះកាចសាហាវណាស់, អ្វីទៅហ្ន៎ជាប្រយោជន៍ក្នុងទីនេះ” ។ មនុស្សដែលស្តាប់ក៏នឹងគិតថា “អ្វីទៅហ្ន៎ជាអានិសង្សក្នុងទីនេះ, ពួកយើងរមែងមិនជ្រាបគុណរបស់វត្ថុនេះ” ពេលនោះ ព្រះមានព្រះភាគប្រកាសអានិសង្សមានការឈានកន្លងរូបសញ្ញាជាដើម ដូចកាលនាយឈ្មួញនោះឃោសនាពាក្យជាដើមថា “ពួកលោកចូរមកទទួលយកទឹកឃ្មុំផ្អែមទៅចុះ” ។ ពិតមែនហើយ ព្រះមានព្រះភាគត្រាស់សរសើរគុណអាកាសានញ្ចាយតនសមាបត្តិ ក៏ដើម្បីឱ្យកើតសេចក្តីឧស្សាហ៍ និងដើម្បីលួងលោមចិត្តដោយទ្រង់ព្រះតម្រិះថា “ជនទាំងនេះដែលព្រះអង្គឱ្យរីករាយពេញចិត្តហើយ ដោយអានិសង្សនេះ នឹងធ្វើឧស្សាហ៍ដ៏ធំហើយញ៉ាំងសមាបត្តិនេះឱ្យកើត” ដូចនេះ, អ្នកស្រុកទាំងឡាយនោះស្តាប់ពាក្យឃោសនានាយឈ្មួញ ហើយឱ្យតម្លៃសូម្បីដោយច្រើន ទើបកាន់យកស្ករអំពៅដូច្នោះ ៕

## វិនិច្ឆ័យពាក្យថាអាកាសានញ្ចាយតនៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អាកាសានញ្ចាយតនសញ្ញាសហគតំ** ដូចតទៅនេះ ៖

អាកាសដែលឈ្មោះថា **អនន្តៈ** ព្រោះអត្ថថា មិនមានទីបំផុត, អាកាសនោះមិនមានទីបំផុត ឈ្មោះថា **អាកាសានន្តៈ**, **អាកាសានន្តៈ**នោះឯង ឈ្មោះថា **អាកាសានញ្ចៈ**, អាកាសមិនមានទីបំផុតនោះ ឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា ជាទីតាំងមាំរបស់ឈានព្រមទាំងសម្បយុត្តធម៌នេះ ដូចទីតាំងនៅរបស់ទេពទាំងឡាយ ឈ្មោះថា **ទេវាយតនៈ**; ព្រោះហេតុដូច្នោះ ឈាននេះទើបឈ្មោះថា **អាកាសានញ្ចាយតនៈ** ដោយប្រការដូច្នេះ ។ អាកាសានញ្ចៈនោះផង អាយតនៈនោះផង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អាកាសានញ្ចាយតនៈ**, ពាក្យថា **អាកាសានញ្ចាយតនៈ** នេះ ជាឈ្មោះរបស់កសិណុគ្ឃាដិមាកាស (អាកាសដែលបើកកសិណ) ។ ឈានដែលសហគតជាមួយនឹងសញ្ញាដែលដល់អប្បនាក្នុងអាកាសានញ្ចាយតនៈនោះ ឈ្មោះថា **អាកាសានញ្ចាយតនសញ្ញាសហគត**; ក្នុងទីដទៃត្រាស់ថា "អាកាសជាអនន្តៈ (មិនមានទីបំផុត)" [១១] យ៉ាងណា, ក្នុងទីនេះ មិនបានទ្រង់កាន់យកអាកាសដែលមិនមានទីបំផុត ឬថា បន្តិចបន្តួចដូច្នោះទេ; ព្រោះហេតុអ្វី ព្រោះកាលទ្រង់កាន់យកអាកាសដែលមិនមានទីបំផុត ក៏មិនកាន់យកអាកាសបន្តិចបន្តួច, កាលកាន់យកអាកាសបន្តិចបន្តួច ក៏មិនកាន់យកអាកាសដែលមិនមានទីបំផុត; កាលបើដូច្នោះ អារម្មណ៍ ៤ ពួក ក៏មិនសម្បូរណ៍, ទេសនា ក៏មិនបាន ១៦ ដង, ប៉ុន្តែព្រះអធ្យាស្រ័យរបស់ព្រះសម្មាសម្ពុទ្ធ អាចដើម្បីទេសនាក្នុងទីនេះបាន ១៦ ដង; ព្រោះហេតុដូច្នោះ ទើបមិនត្រាស់ពាក្យថា "មិនមានទីបំផុត" ឬថា

---

[១១] អភិ., ទី., ម. ។

“បន្តិចបន្តួច” ប៉ុន្តែត្រាស់ថា **“អាកាសានញ្ចាយតនសញ្ញាសហគត** = សហគតដោយអាកាសានញ្ចាយតនសញ្ញា; ក៏កាលបើដូច្នោះ ពាក្យទាំង ២ ក៏រមែងជាពាក្យដែលទ្រង់កាន់យកដូចគ្នា, អារម្មណ៍ ៤ ពួក ក៏សម្បូរណ៍, ទេសនាក៏ដល់ ១៦ ដង; សេចក្តីនៃព្រះបាលីដែលសល់ គប្បីជ្រាបដោយន័យដែលពោលទុកអំពីខាងលើចុះ ។

ម្យ៉ាងទៀត ក្នុងអាកាសានញ្ចាយតនៈនេះ ឈ្មោះថា **ទុក្ខាបដិបទា** ព្រោះសេចក្តីលំបាកក្នុងការអស់ទៅនៃនិក្កន្តិក្នុងរូបាវចរចតុត្ថជ្ឈាន, ឈ្មោះថា **ជាទន្ធាភិញ្ញា** ព្រោះការយឺតយូរក្នុងការអប់រំអប្បនារបស់អ្នកមានសេចក្តីត្រេកអរក្នុងនិក្កន្តិដែលអស់ទៅហើយ ។ ម្យ៉ាងទៀត គប្បីជ្រាប**សុខាបដិបទា** និង**ខិប្បាភិញ្ញា** ដោយបរិយាយផ្ទុយគ្នា ។ ក៏ឈានដែលប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណបន្តិចបន្តួច គប្បីជ្រាបថា **ជាបរិត្តារម្មណ៍**, ឈានដែលប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណដ៏ធំទូលាយ គប្បីជ្រាបថា **ជាអប្បមាណារម្មណ៍** ។ សូម្បីនៅក្នុងឈាននេះ មានធម៌មួយពួកៗ ២៥ ដោយអំណាចនៃចតុត្ថជ្ឈាន ដូចក្នុងឧបេក្ខាព្រហ្មវិហារ; ក៏ក្នុងអាកាសានញ្ចាយតនៈនេះយ៉ាងណា, សូម្បីក្នុងវិញ្ញាណញ្ចាយតនៈជាដើមក្រៅអំពីនេះ ក៏មានធម៌មួយពួកៗ ២៥ ដូច្នោះដែរ; ប៉ុន្តែខ្ញុំនឹងពណ៌នាហេតុត្រឹមតែថាការផ្សេងគ្នាក្នុងវិញ្ញាណញ្ចាយតនៈជាដើមទាំងនោះប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អាកាសានញ្ចាយតនំ សមតិក្កមា** = ព្រោះឈានកន្លងអាកាសានញ្ចាយតនៈនេះតទៅ ក៏អាកាសានញ្ចៈ ឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា ជាទីតាំងមាំរបស់ឈាននោះ ដោយន័យដែលពោលទុកអំពីមុននោះឯង, ព្រោះហេតុនោះ សូម្បីឈាននេះ ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ។ សូម្បី

អារម្មណ៍របស់អាកាសានញ្ចាយតនៈនោះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយ; ព្រះយោគាវចរគប្បីឈានកន្លងធម៌ទាំង ២ គឺឈាននេះ និងអារម្មណ៍នេះ ដោយការមិនធ្វើឱ្យប្រព្រឹត្តទៅ និងមិនមនសិការ ហើយគប្បីចូលដល់វិញ្ញាណញ្ចាយតនៈនេះ, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ទ្រង់រួមវត្ថុទាំង ២ នេះហើយ ត្រាស់ពាក្យនេះថា "ព្រោះការឈានកន្លងអាកាសានញ្ចាយតនៈ" ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **វិញ្ញាណញ្ចាយតនសញ្ញាសហគតំ** នេះតទៅ ៖

ទីបំផុតនៃវិញ្ញាណនោះ មិនមានដោយអំណាចដែលធ្វើទុកក្នុងចិត្តថា "**អនន្តំ**" ព្រោះហេតុនោះ វិញ្ញាណនោះឯង ទើបឈ្មោះថា **អនន្តៈ**, **អនន្តៈ**នោះឯងឈ្មោះថា **អនញ្ចំ**, ព្រះភគវាមិនត្រាស់ថា វិញ្ញាណដែលមិនមានទីបំផុត ឈ្មោះថា "**វិញ្ញាណានញ្ចៈ**" ទេ, តែត្រាស់ថា "**វិញ្ញាណញ្ចៈ**" ; ព្រោះក្នុងពាក្យថា **វិញ្ញាណញ្ចៈ** នេះជារុឡ្ហីសព្ទ (សព្ទដែលគេនិយមនិយាយ) ; វិញ្ញាណញ្ចៈនោះឯងឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា តាំងមាំដោយសញ្ញានេះ ព្រោះហេតុនោះ ទើបឈ្មោះថា **វិញ្ញាណញ្ចាយតនៈ**; ឈានដែលសហគតដោយសញ្ញា ដែលប្រព្រឹត្តទៅក្នុងវិញ្ញាណញ្ចាយតនៈនោះ ព្រោះហេតុនោះ ឈាននោះទើបឈ្មោះថា **វិញ្ញាណញ្ចាយតនសញ្ញាសហគត**, ពាក្យថា វិញ្ញាណញ្ចាយតនសញ្ញាសហគតនេះ ជាឈ្មោះរបស់ឈានដែលមានវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាសជាអារម្មណ៍ ។ ក្នុងវិញ្ញាណញ្ចាយតនៈនេះ ជាទុក្ខាបដិបទា ព្រោះលំបាកក្នុងការអស់ទៅនៃនិកន្តិ

ក្នុងអាកាសានញ្ចាយតនសមាបត្តិ, ជាទន្ធាភិញ្ញា ព្រោះការយឺតយូរ ក្នុងការអប់រំ អប្បនារបស់អ្នកមាននិក្កន្តិឱ្យអស់ទៅ, ជាសុខាបដិបទា និងខិប្បាភិញ្ញាដោយការផ្ទុយគ្នា, គប្បីជ្រាបឈាននេះថាជាអារម្មណ៍ ព្រោះប្រារព្ធសមាបត្តិដែលមានការបើកកសិណាតិចតួចឱ្យជាអារម្មណ៍ហើយប្រព្រឹត្តទៅ, គប្បីជ្រាបថាជា អប្បមាណារម្មណ៍ដោយបរិយាយផ្ទុយគ្នា; ពាក្យដ៏សេសដូចនឹងពាក្យមុនដែរ ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងពាក្យថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** = ព្រោះឈានកន្លងវិញ្ញាណញ្ចាយតនៈ នេះតទៅ ៖

វិញ្ញាណញ្ចៈ ឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា ជាទីតាំងរបស់ឈាននោះ ដោយន័យដែលពោលទុកក្នុងកាលមុននោះឯង ព្រោះហេតុដូច្នោះ សូម្បីឈានក៏ឈ្មោះថា **វិញ្ញាណញ្ចាយតនៈ**, សូម្បីអារម្មណ៍របស់ឈាននោះ ដោយន័យដែលពោលហើយនោះឯង ក៏ហៅថា **វិញ្ញាណញ្ចាយតនៈ**; ព្រះយោគាវចរឈានកន្លងវត្ថុទាំងពីរ គឺឈាននេះ និងអារម្មណ៍នេះ មានប្រការដូច្នេះ ដោយការមិនឱ្យប្រព្រឹត្តទៅ និងដោយមិនមានមនសិការ ហើយទើបចូលដល់អាកិញ្ចញ្ញាយតនៈនេះឯង, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ទ្រង់រួបរួមវត្ថុទាំងពីរនោះ ចូលជាមួយគ្នាហើយត្រាស់ពាក្យនេះថា “ព្រោះឈានកន្លងវិញ្ញាណញ្ចាយតនៈ” ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អាកិញ្ចញ្ញាយតនសញ្ញាសហគតំ** នេះដូចតទៅ ៖

ក៏ឈាននេះ ឈ្មោះថា **អាកិញ្ចនៈ** ព្រោះអត្ថថា មិនមានអ្វីសូម្បីបន្តិច

បន្ទួច, មានអធិប្បាយថា ដោយហោចទៅសូម្បីត្រឹមតែភង្គខណៈ ក៏មិនគប្បីនៅសល់ គឺមិនបានមានឡើយ; ភាវៈនៃអ្វីតិចតួចមិនមាន ឈ្មោះថា **អាកិញ្ចញ្ញៈ**, ពាក្យថា **អាកិញ្ចញ្ញៈ** នេះជាឈ្មោះរបស់ឈានដែលប្រាសចាកអាកាសានញ្ចាយតនៈ និងវិញ្ញាណជាអារម្មណ៍ ។ អាកិញ្ចញ្ញៈនោះ ជាអាយតនៈដោយអត្ថថា ជាទីតាំងមាំដោយសញ្ញានេះ ព្រោះហេតុដូច្នោះ ឈាននេះ ទើបឈ្មោះថា **អាកិញ្ចញ្ញាយតនៈ**, ឈានដែលសហគតដោយសញ្ញាដែលប្រព្រឹត្តទៅក្នុងអាកិញ្ចញ្ញាយតនៈនោះ ឈ្មោះថា **អាកិញ្ចញ្ញាយតនសហគត**, ពាក្យថា អាកិញ្ចញ្ញាយតនៈនេះ ជាឈ្មោះរបស់ឈានដែលប្រាសចាកវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស ។ ក្នុងអាកិញ្ចញ្ញាយតនៈនេះ ជាទុក្ខាបដិបទា ព្រោះលំបាកក្នុងការអស់ទៅនៃនិកន្តិរបស់វិញ្ញាណញ្ចាយតនសមាបត្តិ, ជាទន្ធាភិញ្ញា ព្រោះសេចក្ដីយឺតយូរក្នុងការអប់រំអប្បនារបស់អ្នកប្រាថ្នាក្នុងការអស់ទៅ, ជាសុខាបដិបទា និងខិប្បាភិញ្ញាដោយបរិយាយផ្ទុយគ្នា គប្បីជ្រាបឈ្មោះថា **បរិត្តារម្មណ៍** ព្រោះមានអារម្មណ៍ប្រាសចាកវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណបន្តិចបន្តួច, ឈ្មោះថា **អប្បមាណារម្មណ៍** ដោយបរិយាយផ្ទុយគ្នា និងបរិត្តារម្មណ៍ ។ ពាក្យដែលសល់ដូចនឹងន័យមុនទាំងអស់ដែរ ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងពាក្យថា **អាកិញ្ចញ្ញាយតនំ សមតិក្កមា** នេះតទៅ ៖

**អាកិញ្ចញ្ញៈ** ដោយន័យមុននោះឯង ឈ្មោះថាជា **អាយតនៈ** ព្រោះអត្ថថា ជាទីតាំងមាំរបស់ឈាននោះ, ព្រោះហេតុដូច្នោះ សូម្បីឈានក៏ឈ្មោះថា **អាកិញ្ចញ្ញាយតនៈដែរ**, សូម្បីអារម្មណ៍ក៏ឈ្មោះថា **អាកិញ្ចញ្ញាយតនៈ** ដោយន័យដែល

បានពោលទុកហើយនោះឯង ពាក្យដ៏សេសដូចន័យមុនទាំងអស់ គប្បីជ្រាបការឈានកន្លងវត្ថុសូម្បីទាំងពីរ គឺឈាននោះផង អារម្មណ៍នោះផង ដោយការមិនធ្វើឱ្យប្រព្រឹត្តទៅ និងដោយការមិនមានមនសិការ ហើយគប្បីចូលដល់នេវសញ្ញានាសញ្ញានេះឯង, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ព្រះភគវាទ្រង់រួមវត្ថុទាំងពីរនេះ ហើយត្រាស់ថា "ព្រោះការឈានកន្លងអាកិញ្ចញ្ញាយតនៈ" ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **នេវសញ្ញានាសញ្ញាយតនសហគតំ** នេះតទៅ ៖

ក៏ឈាននោះ ត្រាស់ហៅថា "នេវសញ្ញានាសញ្ញាយតនៈ" ព្រោះសភាវៈនៃសញ្ញាណា, សញ្ញានោះរមែងមានដល់អ្នកបដិបត្តិយ៉ាងណា, ដើម្បីសម្តែងសញ្ញានោះមុន ទើបទ្រង់លើកបទថា "**នេវសញ្ញីនាសញ្ញី**" ឡើងក្នុង **វិភង្គ** ហើយត្រាស់ថា "ព្រះយោគាវចររមែងមនសិការអាកិញ្ចញ្ញាយតនៈនោះឯង ដោយសន្តតៈ (ភាពស្ងប់), រមែងចម្រើនសមាបត្តិដែលមានសង្ខារដ៏សេស, ព្រោះហេតុនោះ ទើបត្រាស់ហៅថា នេវសញ្ញីនាសញ្ញី" [១២] ។

បណ្តាបទនោះ បទថា **សន្តតោ មនសិករោតិ** = រមែងមនសិការដោយសេចក្តីស្ងប់, បានដល់រមែងមនសិការថា "សមាបត្តិនេះស្ងប់ហ្ន៎, ព្រោះសូម្បីធ្វើសេចក្តីមិនមានឱ្យជាអារម្មណ៍ហើយតាំងនៅបាន" ហើយមនសិការសមាបត្តិនោះថា "ជាសេចក្តីស្ងប់" ព្រោះអារម្មណ៍ស្ងប់ ។

---

[១២] អភិ. ។

*សួរថា* បើមនសិការដោយសេចក្ដីស្ងប់ហើយ, ការឈានកន្លងនឹងមានយ៉ាងណា ?

ឆ្លើយថា ព្រោះភាពជាអ្នកត្រូវការនឹងមិនទឹកដល់ ។ ពិតណាស់ ព្រះយោគាវចរនោះរមែងមនសិការឈាននោះដោយសេចក្ដីស្ងប់ ក៏ពិតមែនហើយ, ប៉ុន្តែថា ការពឹង ការប្រមូលមកនូវមនសិការនោះ រមែងមិនមានដល់ព្រះយោគីនោះថា "យើងនឹងទឹកដល់, យើងនឹងចូល, យើងនឹងអធិដ្ឋាន, យើងនឹងចេញ, យើងនឹងពិចារណាឈាននោះ" ។

*សួរថា* ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះនេវសញ្ញានាសញ្ញាយតនៈ ជាធម៌ស្ងប់ជាង ប្រណីតជាងអាកិញ្ចញ្ញាយតនៈ ។

ឧបមាថា ព្រះរាជាទ្រង់ឡើងលើ-កនែដំរីមួយដ៏ប្រសើរស្ដេចត្រាច់ទៅក្នុងផ្លូវព្រះនគរ ដោយអានុភាពនៃព្រះរាជាអ្នកជាធំ ទ្រង់ទតព្រះនេត្រចំពោះមនុស្សមានសិប្បៈ ដែលមានជាងឆ្លាក់ភ្លុកដំរីជាដើម ស្លៀកសំពត់មួយផ្ទាំង ជូតសំពត់មួយផ្ទាំង ត្រង់ក្បាលយ៉ាងមាំ មានខ្លួនប្រឡាក់ប្រឡូសដោយកម្ទេចភ្លុកជាដើម កំពុងធ្វើសិប្បៈ និងឆ្លាក់ភ្លុកជាដើមមិនមែនតិច ទ្រង់ក៏សព្វព្រះទ័យក្នុងការឆ្លាក់របស់ជាងទាំងនោះយ៉ាងនេះថា "គួរអស្ចារ្យហ្ន៎, អាចារ្យអ្នកឆ្លាតអាចធ្វើសូម្បីសិប្បៈទាំងឡាយមានឈ្មោះបែបនេះបាន" , តែមិនបានមានព្រះតម្រិះយ៉ាងនេះថា "ឱហ្ន៎ ខ្លួនយើងគប្បីលះ រាជសម្បត្តិហើយជាអ្នកសិប្បៈដូចនេះ" ; ខនោះព្រោះហេតុអ្វី ? ព្រោះរាជសម្បត្តិមានតម្លៃច្រើន; ព្រះអង្គក៏ទ្រង់ស្ដេចឆ្លងផុតអ្នកសិប្បៈទាំងឡាយ

ទៅយ៉ាងណា, ព្រះយោគាវចរក៏យ៉ាងនោះដែរ រមែងមនសិការសមាបត្តិនោះ ដោយភាពស្ងប់ក៏ពិតមែន, ប៉ុន្តែ លោកក៏មិនរំពឹង មិនប្រមូលមក មិនធ្វើមនសិការថា "យើងនឹងនឹកដល់សមាបត្តិនោះ នឹងចូលសមាបត្តិនោះ នឹងអធិដ្ឋាន-នឹងចេញ-នឹងពិចារណាសមាបត្តិនោះ" ; កាលបើមនសិការសមាបត្តិនោះ ដោយសន្តិភាពហើយ រមែងពន្លុះសញ្ញាដែលសល់ អប្បនាដ៏ល្អិតយ៉ាងក្រៃលែង ដោយន័យដែលពោលទុកក្នុងកាលមុននោះឯង, ឈ្មោះថា **នេវសញ្ញានាសញ្ញី** រមែងមានដោយសមាបត្តិណា, ត្រាស់ហៅសមាបត្តិនោះថា ព្រះយោគីរមែងចម្រើនសមាបត្តិ មានសង្ខារដ៏សេសជាអារម្មណ៍ដូច្នេះ ។

ពាក្យថា **សមាបត្តិមានសង្ខារដ៏សេសជាអារម្មណ៍** គឺអរូបសមាបត្តិទី ៤ មានសង្ខារដល់សេចក្ដីល្អិតជាទីបំផុត ។

ឥឡូវនេះ ដើម្បីទ្រង់សម្ដែងព្រះតម្រិះដែលត្រាស់ថា "នេវសញ្ញានាសញ្ញាយតនៈ" ដោយអំណាចនៃសញ្ញាដែលព្រះយោគាវចរពន្លុះយ៉ាងនេះ ដោយអត្ថទើបត្រាស់ថា "បទថា **នេវសញ្ញានាសញ្ញាយតនៈ** បានដល់ ធម៌ទាំងឡាយ គឺចិត្ត និងចេតសិករបស់បុគ្គលអ្នកចូលសមាបត្តិនេវសញ្ញានាសញ្ញាយតនៈ ឬអ្នកកើតឡើងក្នុងនេវសញ្ញានាសញ្ញាយតនភព ឬព្រះខីណាស្រពអ្នកនៅជាសុខក្នុងទិដ្ឋធម៌" ។ បណ្ដាលោកទាំង ៣ នោះ ក្នុងទីនេះទ្រង់បំណងយកធម៌ គឺចិត្ត និងចេតសិករបស់អ្នកចូលសមាបត្តិ ។

ចំណែកវចនត្ថៈ (អត្ថនៃពាក្យ) ក្នុងឈានគប្បីជ្រាបដូច្នេះ ៖

ឈានដែលឈ្មោះថា **នេវសញ្ញានាសញ្ញា** = មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន, ព្រោះអត្ថថា សញ្ញារបស់ឈានព្រមទាំងសម្បយុត្តធម៌ មែងមានក៏មិនមែន, មិនមានសញ្ញាក៏មិនមែន គឺ **មិនមានសញ្ញាគ្រោតគ្រាត**, មានតែសញ្ញាល្អិត ឈាននោះជាសភាវៈដែលមានសញ្ញាក៏មិនមែន, មិនមានសញ្ញាក៏មិនមែន ដោយជាអាយតនៈ ព្រោះរាប់បញ្ចូលដោយមនាយតនៈផង និងធម្មាយតនៈផង ព្រោះហេតុនោះ ឈាននោះទើបឈ្មោះថា **នេវសញ្ញានាសញ្ញាយតនៈ** ។

ម្យ៉ាងទៀត សញ្ញាក្នុងឈាននេះ ឈ្មោះថា **នេវសញ្ញា** (មិនមែនសញ្ញា) ព្រោះមិនអាចធ្វើកិច្ចរបស់សញ្ញាបានដោយចំពោះទេ និងឈ្មោះថា **នាសញ្ញា** (មិនមានសញ្ញា) ព្រោះជាធម៌នៅដោយល្អិតនៃសង្ខារដ៏សេស, ព្រោះហេតុដូច្នោះ ឈាននោះ ទើបឈ្មោះថា **នេវសញ្ញានាសញ្ញា** ។ ឈានដែលឈ្មោះថា នេវសញ្ញានាសញ្ញានោះផង ឈ្មោះថា **ជាអាយតនៈ** ព្រោះអត្ថថា ជាទីតាំងមាំនៃធម៌ដ៏សេសផង ព្រោះហេតុនោះ ទើបឈ្មោះថា **នេវសញ្ញានាសញ្ញាយតនៈ** ។ ក៏ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននេះ សញ្ញាដូចនេះតែម្យ៉ាងក៏មិនមែនដែរ, តាមពិតសូម្បីវេទនាក៏ឈ្មោះថា **នេវវេទនានាវេទនា** = មានវេទនាក៏មិនមែន មិនមានវេទនាក៏មិនមែន, សូម្បីចិត្តក៏ឈ្មោះថា **នេវចិត្តនាចិត្ត** = មានចិត្តក៏មិនមែន មិនមានចិត្តក៏មិនមែន, សូម្បីផស្សៈក៏ឈ្មោះថា **នេវផស្សនាផស្សៈ** = មានផស្សៈក៏មិនមែន មិនមានផស្សៈក៏មិនមែន ។ ក្នុងសម្បយុត្តធម៌ដ៏សេស ក៏មានន័យដូចគ្នា

នេះដែរ ។ តែទេសនានេះ គប្បីជ្រាបថា ទ្រង់ធ្វើសញ្ញាឱ្យជាប្រធាន ។ បណ្ឌិតគប្បីជ្រាបសេចក្ដីនេះ ដោយឧបមាទាំងឡាយតាំងពីរឿងប្រេងលាបបាត្រជាដើម ៖

បានឮថា **សាមណេរ** យកប្រេងលាបបាត្រហើយទុកដាក់ក្នុងវេលាឆាន់យាគូ (បបរ) ព្រះសង្ឃត្ថេរពោលនឹងសាមណេរថា "សាមណេរចូរនាំបាត្រមក" ; សាមណេរឆ្លើយនឹងលោកថា "បពិត្រលោកម្ចាស់ ក្នុងបាត្រមានប្រេង" , ពេលនោះព្រះថេរៈទើបពោលថា "សាមណេរចូរនាំប្រេងមក, យើងនឹងដាក់ឱ្យពេញដបប្រេង" , សាមណេរទើបឆ្លើយប្រាប់ថា "បពិត្រលោកម្ចាស់ ប្រេងមិនមាន" ។

ក្នុងការឧបមានោះ ប្រេងឈ្មោះថា មានមែន ព្រោះអត្ថថា ជារបស់មិនគួរជាមួយនឹងយាគូ (បបរ) ព្រោះជាវត្ថុមាននៅខាងក្នុង ប្រេងនោះឈ្មោះថា មិនមាន ព្រោះជារបស់មិនមានសម្រាប់ដាក់បំពេញក្នុងវត្ថុទាំងឡាយមានដបជាដើមយ៉ាងណា, សូម្បីសញ្ញានោះក៏យ៉ាងនោះដែរ ឈ្មោះថា **សញ្ញា** ក៏មិនមែន ព្រោះមិនអាចធ្វើកិច្ចរបស់សញ្ញាដោយចំពោះ និងឈ្មោះថា **មិនមានសញ្ញាក៏មិនមែន** ព្រោះជារបស់មាននៅដោយសេចក្ដីជារបស់ល្អិតនៃសង្ខារដ៏សេស ។

**សួរថា** ក៏ក្នុងឈាននេះ កិច្ចរបស់សញ្ញាជាយ៉ាងណា ?

ឆ្លើយថា កិច្ចរបស់សញ្ញា គឺចាំបាន ស្គាល់ច្បាស់នូវអារម្មណ៍ និងការចូលដល់សេចក្ដីជាអារម្មណ៍នៃវិបស្សនា ហើយកើតការនឿយណាយ ។

សេចក្ដីថា សញ្ញានោះមិនអាចធ្វើកិច្ច គឺការចាំស្គាល់ច្បាស់ដោយរួសរាន់ ដូចតេជោធាតុក្នុងទឹក (ពុះរហូត) រីង មិនអាចធ្វើកិច្ច គឺការដុតឱ្យឆេះសន្ធោសន្ធៅបាន ។ សញ្ញានេះ មិនអាចដើម្បីធ្វើសូម្បីចូលដល់សភាពជាអារម្មណ៍នៃវិបស្សនា

ហើយឱ្យកើតសេចក្តីនឿយណាយ ដូចសញ្ញាក្នុងសមាបត្តិដទៃដែលសេស (វៀរសញ្ញាក្នុងឈាននេះ) ព្រោះថា ភិក្ខុមិនបានអាស្រ័យខន្ធពួកដទៃធ្វើទុកហើយ ទើបឈ្មោះថា **មិនអាចដើម្បីពិចារណាខន្ធ** គឺនេវសញ្ញានាសញ្ញាយតនៈ ហើយពន្លុះនិព្វិទា ។ សូម្បីព្រះសារីបុត្តត្ថេរ លោកឃើញច្បាស់ដោយប្រក្រតី និងលោកដែលមានបញ្ញាច្រើនគប្បីអាចដូចនឹងព្រះសារីបុត្រដែរ, សូម្បីលោកនេះ ក៏គប្បីឃើញដោយអំណាចនៃការពិចារណាជាកលាបៈ (កង១) ប៉ុណ្ណោះ យ៉ាងនេះថា "ន័យថាធមិទាំងនេះ មិនមានហើយក៏មាន, លុះមានហើយ ក៏ប្រែប្រួល"[១៣] មិនមែនឃើញដោយអំណាចនៃវិបស្សនាធមិតាមលំដាប់បទទេ; សមាបត្តិនេះដល់សេចក្តីល្អិតយ៉ាងនេះ; បណ្ឌិតគប្បីជ្រាបសេចក្តីនេះ ដោយការឧបមាដូចទឹកក្នុងផ្លូវ ដូចឧបមាដោយប្រេងលាបបាត្រតទៅ ៖

បានឮថា សាមណេរដើរទៅខាងមុខព្រះថេរៈអ្នកដើរតាមផ្លូវ ឃើញទឹកបន្តិចហើយទូលព្រះថេរៈថា "បពិត្រលោកម្ចាស់ មានទឹក, សូមទានមេត្តាដោះស្បែកជើង" ; លំដាប់នោះ ព្រះថេរៈពោលថា "បើមានទឹក, អ្នកចូរនាំសំពត់ងូតទឹកមក, ខ្ញុំនឹងស្រង់ទឹក" , សាមណេរទូលថា "ទឹកមិនមានទេលោកម្ចាស់" ។

ក្នុងពាក្យឧបមានោះ គប្បីជ្រាបថា ឈ្មោះថា ទឹកមានដែរ ដោយអត្ថថាគ្រាន់តែសើមស្បែកជើង, ដែលឈ្មោះថា **មិនមាន** ដោយអត្ថថា មិនល្មមដែលនឹងងូត យ៉ាងណា, សមាបត្តិនោះ ក៏យ៉ាងនោះដែរ ឈ្មោះថា **នេវសញ្ញា** (មិនមាន

---

[១៣] ម. ឧ. ។

សញ្ញា) ព្រោះមិនអាចធ្វើកិច្ចរបស់សញ្ញា ដោយឆាប់រហ័សបាន, ឈ្មោះថា **មិនមានសញ្ញាក៏មិនមែន** ព្រោះសញ្ញាមានដែរ ដោយសេចក្តីជារបស់ល្អិតនៃសង្ខារដ៏សេស និងមិនមែនប្រៀបធៀបដោយឧបមាទាំងនេះប៉ុណ្ណោះ, គប្បីញ៉ាំងសេចក្តីនេះឱ្យជាក់ច្បាស់ ដោយឧបមាដែលសមគួរសូម្បីដទៃទៀត; ដោយន័យដែលពោលមក ឈានឈ្មោះថា **នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ** ព្រោះអត្ថថា សហគតដោយសញ្ញាដែលប្រព្រឹត្តទៅក្នុងនេវសញ្ញានាសញ្ញាយតនៈនេះ ឬសហគតដោយសញ្ញាដែលជានេវសញ្ញានាសញ្ញាយតនៈ ពាក្យនេះជាឈ្មោះរបស់ឈានដែលមានអារម្មណ៍ (ឈានកន្លង) អាកិញ្ចញ្ញាយតនសមាបត្តិ ។ ក្នុងឈាននេះឈ្មោះថា **ទុក្ខាបដិបទា** ព្រោះជាទុក្ខក្នុងការអស់ទៅនៃនិកន្តិក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ, ឈ្មោះថា **ទន្ធាភិញ្ញា** ព្រោះសេចក្តីយឺតយូរ ក្នុងការអប់រំអប្បនារបស់អ្នកមាននិកន្តិអស់ទៅ, ឈ្មោះថាជាសុខាបដិបទា និងខិប្បាភិញ្ញា ដោយបរិយាយផ្ទុយគ្នា ។ គប្បីជ្រាបសេចក្តីជាបរិត្តារម្មណ៍ ព្រោះប្រារព្ធសមាបត្តិ មានអារម្មណ៍ប្រាសចាកវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណឡើងបន្តិច ហើយប្រព្រឹត្តទៅ, គប្បីជ្រាបសេចក្តីជាអប្បមាណារម្មណ៍ដោយបរិយាយផ្ទុយគ្នា; ពាក្យដ៏សេសដូចនឹងន័យមុននោះដែរ ។

ព្រះពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ជានាថៈ (ទីពឹង) មានព្រះរូបមិនមាននរណាប្រដូចបាន ត្រាស់អរូបជ្ឈាន ៤ យ៉ាងណាទុក ព្រះយោគីគ្រាជ្រាបអរូបជ្ឈាន ៤ នោះហើយ គប្បីដឹងសូម្បីកថាបកិណ្ណកៈ ក្នុងអរូបជ្ឈាននោះតទៅ ។ ព្រោះអរូបសមាបត្តិ ៖

សូម្បីទាំង ៤ នេះ រមែងមានព្រោះការឈានកន្លងអារម្មណ៍ អ្នកប្រាជ្ញលោកមានបញ្ញា មិនប្រាថ្នានឹងលះចេញនូវការអធិប្បាយអង្គនៃសមាបត្តិពួកនោះ ។

មែនពិត បណ្ដាសមាបត្តិទាំងនោះ គប្បីជ្រាបអរូបសមាបត្តិទាំង ៤ ដែលកើតឡើងដោយការឈានកន្លងអារម្មណ៍ ដោយប្រការទាំងពួង គឺអរូបសមាបត្តិទី ១ ព្រោះកន្លងឈានដែលមានរូបនិមិត្ត, អរូបសមាបត្តិទី ២ ព្រោះឈានកន្លងអាកាស, អរូបសមាបត្តិទី ៣ ព្រោះឈានកន្លងវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស និងអរូបសមាបត្តិទី ៤ ព្រោះឈានកន្លងដោយប្រាសចាកវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស ។

តែបណ្ឌិតទាំងឡាយ មិនប្រាថ្នាការឈានកន្លងអង្គក្នុងសមាបត្តិទាំងនោះ ដែលមិនមានដូចរូបាវចរសមាបត្តិទេ; ព្រោះថា ក្នុងរូបាវចរសមាបត្តិទាំងអស់នោះ រមែងមានអង្គរបស់ឈាន ២ ប៉ុណ្ណោះ គឺឧបេក្ខា និងឯកគ្គតាចិត្ត ។ សូម្បីកាលបើដូច្នោះ ៖

សុបណីតតរា ហោន្តិ បច្ឆិមា បច្ឆិមា ឥធ
ឧបមា តត្ថ វិញ្ញេយ្យា បាសាទតលសាដិកា ។

សមាបត្តិដែលកើតក្រោយៗ ក្នុងទីនេះ ក៏ជាសភាពប្រណីតល្អជាងសមាបត្តិមុនៗ គប្បីជ្រាបឧបមាក្នុងសមាបត្តិទាំងនោះ ដូចផ្ទៃប្រាសាទ និងសំពត់សាដកតទៅ ៖

ឧបមាថា ប្រាសាទ ៤ ជាន់ខាងក្រោមបំផុត មានកាមគុណ ៥ ដ៏ប្រណីត

ដោយអំណាចនៃការរាំច្រៀង ប្រគំតន្ត្រី ក្លិនក្រអូបផ្កាឈើដែលគួរពេញចិត្ត គ្រឿងផឹក ភោជនមានរសដ៏ល្អ មានទីអង្គុយ ទីដេក អាវ សំពត់ ដែលជាទិព្វជាដើមប្រាកដហើយ, ប្រាសាទជាន់ទី ២ មានកាមគុណទាំងនោះប្រណីតជាងជាន់ទី ១, ប្រាសាទជាន់ទី ៣ មានកាមគុណទាំងនោះប្រណីតជាងជាន់ទី ២, ប្រាសាទជាន់ទី ៤ មានកាមគុណទាំងនោះប្រណីតជាងគ្រប់ជាន់; ក្នុងប្រសាទទាំងនោះ ផ្ទៃរបស់ប្រាសាទ សូម្បីទាំង ៤ នោះ មិនមានសេចក្ដីផ្សេងគ្នាក៏ពិតមែនហើយ, តែថា ប្រាសាទជាន់លើៗ ក៏ប្រណីតជាងប្រាសាទជាន់ក្រោមៗ, ព្រោះវិសេសជាងដោយសមិទ្ធិនៃកាមគុណ ៥ និងប្រៀបដូចសំពត់សាដក ៤ ជាន់ ៣ ជាន់ ២ ជាន់ និង ១ ជាន់ នៃអំបោះយ៉ាងគ្រោតគ្រាត យ៉ាងល្អិត យ៉ាងល្អិតជាង យ៉ាងល្អិតបំផុត ដែលស្ត្រីម្នាក់ត្បាញទុកដោយទទឹង និងបណ្ដោយប៉ុនគ្នា, បណ្ដាសំពត់ទាំងនោះ សូម្បីទាំង ៤ ក៏មានបណ្ដោយ និងទទឹងប៉ុនគ្នា, គឺមិនប្លែកគ្នា; តែថា សំពត់ដែលត្បាញខាងក្រោយៗ ប្រណីតជាងសំពត់ដែលត្បាញមុនៗ ដោយមានសម្ផស្សសប្បាយ មានសាច់ល្អិត មានថ្លៃច្រើន យ៉ាងណា, សូម្បីក្នុងអរូបជ្ឈានសមាបត្តិទាំង ៤ នេះ ក៏យ៉ាងនោះដែរ អង្គឈានទាំងនេះ មានត្រឹមតែ ២ យ៉ាងគឺ ឧបេក្ខា និងឯកគ្គតាចិត្តប៉ុណ្ណោះក៏ពិតមែនហើយ, តែថា ក្នុងទីនេះ គប្បីជ្រាបថា អង្គឈានក្រោយៗប្រណីតជាង ដោយសេចក្ដីប្រណីត និងប្រណីតជាងអង្គឈានទាំងនោះ ព្រោះការចម្រើនពិសេសដោយពិត ក៏ឈានទាំងនេះប្រណីត និងប្រណីតដោយលំដាប់ ដោយប្រការដូច្នេះ (គប្បីជ្រាបឧបមាដូចតទៅ)៖

**អសុចិម្ហិ មណ្ឌបេ លគ្គោ ឯកោ តន្និស្សិតោ បរោ**

អញ្ញោ ពហិ អនិស្សាយ តំ តំ និស្សាយ ចាបរោ
ឋិតោ ចតូហិ ឯតេហិ បុរិសេហិ យថាក្កមំ
សមានតាយ ញាតព្វា ចតស្សោបិ ទិភាទិនា ។

បុរសម្នាក់ ស្ថិតនៅជាប់មណ្ឌបក្នុងទីមិនស្អាត ម្នាក់ទៀតអាស្រ័យនៅនឹងបុរសនោះ ម្នាក់ទៀតមិនអាស្រ័យនៅខាងក្រៅ ម្នាក់ទៀតអាស្រ័យមនុស្សដែលនៅខាងក្រៅ បណ្ឌិតអ្នកមានប្រាជ្ញា (បរិញ្ញា)* គប្បីចូលសូម្បីអរូបទាំង ៤ ដោយសេចក្ដីជាសភាវៈស្មើគ្នា ដូចបុរស ៤ នាក់នេះ ដោយលំដាប់ [១៤] ។

ក្នុងគាថានោះ គប្បីជ្រាបការប្រកបសេចក្ដីដូចតទៅ ៖

បានឮមកថា មណ្ឌបមួយខ្ពង់តាំងនៅក្នុងទីមិនស្អាត; ខាងក្រោយមកបុរសម្នាក់ដើរចេញមកពីបុរស ៤ នាក់នោះដោយលំដាប់ រង្កៀសនៅទីកន្លែងដែលមិនស្អាតនោះ ទើបយកដៃចាប់មណ្ឌបនោះ ហើយឈរនៅហាក់ដូចជាជាប់នៅត្រង់មណ្ឌបនោះ; ខាងក្រោយមក ម្នាក់ទៀត ឈរផ្អែកបុរសដែលជាប់នៅត្រង់មណ្ឌបនោះ; តមកម្នាក់ផ្សេងទៀតមកហើយគិតថា "បុគ្គលដែលឈរតោងមណ្ឌបនិងបុរសដែលឈរផ្អែកទាំងពីរនាក់នេះឈរមិនល្អ ឯគេទាំងពីរនាក់នោះ នឹងធ្លាក់ទៅក្នុងអណ្ដូងដែលមិនស្អាតរបស់មណ្ឌប ណ្ហើយចុះយើងឈរនៅខាងក្រៅមណ្ឌបចុះ" ដោយហេតុនោះ គេទើបមិនអាស្រ័យមនុស្សដែលឈរផ្អែកនោះ ហើយទៅ

---

* ពាក្យនេះក៏ជាឈ្មោះនៃបញ្ញាដែរ ។

[១៤] វិសុទ្ធិ. ២ (អារុប្បនិទ្ទេស) ។

ឈរនៅខាងក្រៅមណ្ឌបឯណោះ; តមកមានបុរសម្នាក់ទៀតមកហើយគិតឃើញថា បុរសដែលឈរជាប់មណ្ឌប និងបុរសដែលឈរផ្អែកបុរសនោះ មិនមានសេចក្តីក្សេមក្សាន្ត ដឹងថាមនុស្សដែលឈរនៅខាងក្រៅមណ្ឌបឈរល្អហើយ ទើបបានឈរផ្អែកនឹងបុរសនោះ ។

ក្នុងពាក្យនោះ បណ្ឌិតគប្បីយល់ឃើញអាកាសដែលបើកកសិណឡើង ដូចមណ្ឌបក្នុងប្រទេសដែលមិនស្អាត ។ អាកាសានញ្ចាយតនជ្ឈានដែលមានអាកាសជាអារម្មណ៍ ព្រោះរង្កៀសរូបនិមិត្ត គប្បីយល់ឃើញដូចបុរសដែលឈរជាប់មណ្ឌប ព្រោះរង្កៀសរបស់មិនស្អាត ។ វិញ្ញាណញ្ចាយតនជ្ឈានដែលប្រារព្ធអាកាសានញ្ចាយតនជ្ឈានដែលមានអាកាស ជាអារម្មណ៍ប្រព្រឹត្តទៅហើយ គប្បីយល់ឃើញដូចបុរសឈរផ្អែកមនុស្ស ដែលឈរជាប់មណ្ឌប ។ អាកិញ្ចញ្ញាយតនជ្ឈាន មិនធ្វើអាកាសានញ្ចាយតនជ្ឈានឱ្យជាអារម្មណ៍ ធ្វើសេចក្តីមិនមាននៃអាកាសានញ្ចាយតនៈនោះឱ្យជាអារម្មណ៍ ប្រៀបដូចបុរសគិតដល់សេចក្តីមិនក្សេមក្សាន្តរបស់បុរសសូម្បីទាំងពីរនាក់នោះ, ទើបមិនអាស្រ័យបុរសនោះហើយទៅឈរនៅខាងក្រៅ ។ នេវសញ្ញានាសញ្ញាយតនជ្ឈានដែលប្រារព្ធអាកិញ្ចញ្ញាយតនៈ ដែលតាំងនៅក្នុងប្រទេសខាងក្រៅ ពោលគឺសេចក្តីមិនមានវិញ្ញាណប្រព្រឹត្តទៅហើយ គប្បីយល់ឃើញដូចបុរសគិតថា បុរសអ្នកឈរតោងមណ្ឌប និងបុរសអ្នកឈរផ្អែកទាំងពីរនោះ មិនមានសេចក្តីក្សេមក្សាន្ត ដឹងថាបុរសអ្នកឈរខាងក្រៅ ជាអ្នកឈរល្អហើយ ទើបឈរផ្អែកបុរសនោះដូច្នោះដែរ ។ ក៏នេវសញ្ញានាសញ្ញាយតនៈ កាលបើនឹងប្រព្រឹត្តទៅយ៉ាងនេះ ៖

អារម្មណំ ករោតេវ អញ្ញាភាវេន តំ ឥទំ
ទិដ្ឋទោសម្បិ រាជានំ វុត្តិហេតុ ជនោ យថា ។

(ព្រះយោគី) រមែងធ្វើអរូបជ្ឈានឱ្យជាអារម្មណ៍ ព្រោះភាវៈមិនមានអារម្មណ៍ដទៃដូចប្រជាជនលើកព្រះរាជាឡើងគ្រងរាជ្យ សូម្បីដែលខ្លួនយល់ឃើញថា មិនល្អ ព្រោះហេតុនៃការរស់នៅ [១៥] ។

ពិតណាស់ នេវសញ្ញានាសញ្ញាយតនៈនេះ រមែងធ្វើអាកិញ្ចញ្ញាយតនៈនោះ សូម្បីដែលឃើញហើយមិនល្អយ៉ាងនេះថា "អាកិញ្ចញ្ញាយតនសមាបត្តិនេះ មានវិញ្ញាណញ្ចាយតនៈជាសត្រូវជិតជាអារម្មណ៍" ព្រោះមិនមានអារម្មណ៍ដទៃ ។

សួរថា ដូចជាអ្វី ?

ឆ្លើយថា ដូចប្រជាជនលើកព្រះរាជាដែលខ្លួនយល់ឃើញថាមិនល្អ ឡើងគ្រងរាជ្យ ព្រោះហេតុនៃការរស់នៅជាអាទិភាព, ដូចយ៉ាងថា ព្រះរាជាជាធំក្នុងទ្វីបទាំងអស់មួយអង្គ មិនសង្រួម មានការប្រព្រឹត្តិផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្តគ្រោតគ្រាត ប្រជាជនឃើញទោសយ៉ាងនេះថា "ព្រះរាជាអង្គនេះ មានវាចាគ្រោតគ្រាត" តែថា កាលបើមិនបានការរស់នៅក្នុងទីដទៃ ទើបត្រូវអាស្រ័យព្រះរាជាអង្គនោះ ព្រោះហេតុនៃការរស់នៅយ៉ាងណា, នេវសញ្ញានាសញ្ញាយតនៈនេះ កាលបើមិនបានអារម្មណ៍ដទៃ ក៏នឹងធ្វើអាកិញ្ចញ្ញាយតនៈ សូម្បីដែលខ្លួនយល់ឃើញហើយថា មិនល្អនោះ ឱ្យជាអារម្មណ៍ដូច្នោះដែរ ។ ម្យ៉ាងទៀត ឈាន គឺនេវសញ្ញានាសញ្ញាយតនៈនេះ កាលបើកំពុងធ្វើដោយអាការយ៉ាងនេះ ៖

---

[១៥] វិសុទ្ធិ. ២ (អារុប្បនិទ្ទេស) ។

អារុឡ្ហោ ធីយនិស្សេណី យថា និស្សេណិពាហុកំ
បព្វតគ្គញ្ច អារុឡ្ហោ យថា បព្វតមត្ថកំ ។
យថា ខា គិរិមារុឡ្ហោ អត្តនោយេវ ជន្នុកំ
ឱលុព្ភតិ តថេវេតំ ឈានមោលុព្ភ វត្តតីតិ ។

(ព្រះយោគី) រមែងអាស្រ័យអរូបជ្ឈានទី ៣ នេះ ទើបប្រព្រឹត្តទៅបាន ហាក់បីដូចបុគ្គលឡើងជណ្តើរវែង គប្បីតោងមេជណ្តើរទុក និងដូចបុគ្គលឡើងកាន់កំពូលភ្នំ គប្បីតោងកំពូលភ្នំ; ឬដូចបុគ្គលឡើងកាន់ភ្នំសិលា ក៏ត្រូវអាស្រ័យជង្គង់របស់ខ្លួនប៉ុណ្ណោះ [១៦] ៕

អរូបាវចរកុសលចប់

---

[១៦] វិសុទ្ធិ.។

# អដ្ឋកថាចិត្តុប្បាទកណ្ឌ

## អធិប្បាយកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣

ឥឡូវនេះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ សូម្បីទាំងអស់នេះ រមែងប្រព្រឹត្តទៅដោយប្រភេទ ៣ មានប្រភេទទាបជាដើម ព្រោះហេតុណា, ព្រោះហេតុនោះ ក៏ដើម្បីសម្តែងប្រភេទនៃធម៌ទាំងនោះ ទើបទ្រង់ផ្តើមពាក្យជាដើមថា **“កតមេ ធម្មា កុសលា”** ទៀត ។

បណ្តាបទទាំងនោះ បទថា **ហីនំ** (ទាប) បានដល់លាមក គឺគ្រោតគ្រាត, គប្បីជ្រាបកុសលទាបដោយអំណាចនៃការប្រមូលមក; កុសលដែលមានក្នុងកណ្តាលនៃហីនៈ និងឧត្តមៈ ឈ្មោះថា មជ្ឈិមៈ (យ៉ាងកណ្តាល); កុសលដែលនាំទៅកាន់សេចក្តីព្យាយាម ឈ្មោះថា ប្រណីត បានដល់ កុសលដែលខ្ពស់, បណ្ឌិតគប្បីជ្រាបសូម្បីកុសលទាំងនោះដោយអំណាចនៃការប្រមូលមកនោះឯង ។

ពិតណាស់ ក្នុងខណៈដែលប្រមូលមកនូវកុសលណាជាមួយនឹងឆន្ទៈ ឬវិរិយៈ ឬចិត្តៈ ឬវិមំសា ជាហីនៈ (យ៉ាងទាប) កុសលនោះ ឈ្មោះថា ទាប ។ ធម៌ទាំងនោះជាមជ្ឈិម ជាប្រណីតនៃកុសលណា, កុសលនោះ ឈ្មោះថា **មជ្ឈិមៈ** និង **បណីតៈ** ។ ក៏កុសលណាប្រមូលមកនូវឆន្ទៈ គឺភាពជាអ្នកប្រាថ្នានឹងធ្វើឆន្ទៈ ឱ្យជាធុរៈ ឱ្យជាធំ ឱ្យជាប្រធាន, កុសលនោះ ឈ្មោះថា **ឆន្ទាធិបតេយ្យ** ព្រោះជាកុសលមកហើយ ដោយឆន្ទាធិបតី; ឯវិរិយាធិបតេយ្យជាដើម ក៏ន័យនេះដែរ ។

តែក្នុងទីនេះ គប្បីកាន់យកន័យទាំងឡាយដែលតាំងទុកហើយ គឺន័យដែល

ចែកទុកមុនជាន័យ ១, ពាក្យថា **ហីនៈ** ជាន័យ ១, ពាក្យថា **មជ្ឈិម** ជាន័យ ១, ពាក្យថា **បណីតៈ** ជាន័យ ១, និងពាក្យថា **ឆន្ទាធិបតេយ្យ** ជាន័យ ១, ន័យទាំង ៥ នេះ ក្នុងឆន្ទាធិបតេយ្យប៉ុណ្ណោះសិនចុះ ។ សូម្បីក្នុងវិរិយាធិបតេយ្យជាដើម ក៏យ៉ាងនេះ ព្រោះហេតុដូច្នោះ បញ្ចកន័យទាំង ៤ ទើបជា ២០ ន័យ ។ ម្យ៉ាងទៀត ជា ២០ ន័យ សូម្បីយ៉ាងនេះ គឺន័យដំបូងជាសុទ្ធិកន័យ ១, ន័យ ៣ មានពាក្យថា **ហីនៈ** ជាដើម (មជ្ឈិមៈ និងបណីតៈ), ន័យ ៤ មានពាក្យថា ឆន្ទាធិបតេយ្យជាដើម (វិរិយៈ ចិត្តៈ វីមំសា), និងន័យ ១២ មានពាក្យថា **ឆន្ទាធិបតេយ្យ ហីនំ** (ឆន្ទៈជាដើម មួយអន្លើដោយហីនៈជាដើម) ន័យទាំងនេះ ជាមហាន័យ ២០ សិន។

**សួរថា** ទ្រង់ចែកន័យទាំងនេះទុកក្នុងទីណា ?

ឆ្លើយថា ក្នុងហីនត្តិកៈ[១៧] ត្រង់ **មហាបករណ៍** ។

តែក្នុងឋាននេះ គប្បីកាន់យកកងធម៌មជ្ឈិម ពីហីនត្តិកៈហើយ បែងជា ៣ ចំណែកដោយអំណាចនៃហីនៈ មជ្ឈិមៈ និងបណីតៈ; គប្បីវៀរកងធម៌មជ្ឈិម សូម្បីពីហីនត្តិកៈនោះហើយកាន់យកហីនៈ និងបណីតៈ ទើបបែងចេញមួយយ៉ាងៗ ៩ ចំណែក; ព្រោះថា ក្នុងហីនៈនោះឯង កុសលធម៌ដែលទាបក៏មាន, កុសលធម៌ដែលជាកណ្តាលក៏មាន, កុសលធម៌ដែលប្រណីតក៏មាន; ដល់សូម្បីក្នុងបណីតសោត កុសលធម៌ដែលទាបក៏មាន, កុសលធម៌ដែលជាកណ្តាលក៏មាន កុសលធម៌ដែលប្រណីតក៏មាន ។ ម្យ៉ាង ក្នុងធម៌ដែលហីនៈ និងហីនៈ កុសលធម៌ដែលជាហីនៈ

---

[១៧] អភិ.។

(ទាប) ក៏មាន, ក្នុងធម៌ដែលជាហីនៈ និងហីនៈ កុសលដែលជាមជ្ឈិមៈក៏មាន, ក្នុងធម៌ដែលជាហីនៈ និងហីនៈ កុសលធម៌ដែលជាបណីតៈក៏មាន; ក្នុងធម៌ដែលជាហីនៈ និងមជ្ឈិមៈ កុសលធម៌ដែលជាហីនៈក៏មាន, ក្នុងធម៌ដែលជាហីនៈ និងមជ្ឈិម កុសលធម៌ដែលជាមជ្ឈិមក៏មាន; ក្នុងធម៌ដែលជាហីនៈ និងបណីតៈ កុសលធម៌ដែលជាហីនៈក៏មាន, ក្នុងធម៌ដែលជាហីនៈ និងបណីតៈ កុសលធម៌ដែលជាមជ្ឈិមក៏មាន, ក្នុងធម៌ដែលជាហីនៈ និងបណីតៈ កុសលធម៌ដែលជាបណីតៈក៏មាន; នេះហៅថា **នវកៈ**មួយ ។

សូម្បីក្នុងធម៌ដែលជាបណីតៈ និងហីនៈ ឈ្មោះថា **កុសលធម៌ដែលទាប** ក៏មាន, ក្នុងធម៌ដែលជាបណីតៈ និងហីនៈ កុសលធម៌ដែលមជ្ឈិមក៏មាន, ក្នុងធម៌ដែលជាបណីតៈ និងហីនៈ កុសលធម៌ដែលជាបណីតៈក៏មាន ។ម្យ៉ាងទៀត ក្នុងធម៌ដែលជាបណីតៈ និងមជ្ឈិម កុសលធម៌ដែលទាបក៏មាន, ក្នុងធម៌ដែលជាបណីតៈ និងមជ្ឈិម ឈ្មោះថា កុសលធម៌ដែលប្រណីតក៏មាន, ក្នុងធម៌ដែលជាបណីតៈ និងបណីតៈ កុសលធម៌ដែលជាហីនៈ (ទាប) ក៏មាន, ក្នុងធម៌ដែលជាបណីតៈ និងបណីតៈ កុសលធម៌ដែលជាមជ្ឈិមក៏មាន, ក្នុងធម៌ដែលជាបណីតៈ និងបណីតៈ កុសលធម៌ដែលប្រណីតក៏មាន; នេះជានវកៈទី ២ រួមនឹងនវកៈទាំង ២ ជាធម៌ ១៨ ។ ធម៌ទាំង ១៨ នេះ ឈ្មោះថា **កម្មទ្វារ** ។ ពោលដោយកម្មទ្វារនេះ គប្បីជ្រាបថា ក្សត្រ ១៨, ព្រាហ្មណ៍ ១៨, វៃឡ្យ ១៨, សូទ្រ ១៨, គោត្តចរណៈ ៤៨ ព្រោះភាពជាអ្នកអប់រំហើយដោយកម្មទ្វារទាំង ១៨ នេះ ។

បណ្ដាកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នេះ កាមាវចរកុសល

ជាតិហេតុកៈខ្លះ ជាទុហេតុកៈខ្លះ ដោយអំណាចនៃញាណសម្បយុត្ត និងញាណវិប្បយុត្ត ។ តែរូបាវចរ និងអរូបាវចរ ជាតិហេតុកៈតែម្យ៉ាង គឺជាញាណសម្បយុត្តប៉ុណ្ណោះ ។ ក៏ក្នុងកុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នេះ កាមាវចរកុសលរមែងកើតរួមនឹងអធិបតីខ្លះ វៀរចាកអធិបតីខ្លះ; តែរូបាវចរ និងអរូបាវចរ កុសលចិត្តរមែងសម្បយុត្តដោយពិត ។ ឯក្នុងកុសលដែលប្រកបដោយភូមិ ៣ នេះ ក្នុងកាមាវចរ រមែងបានអធិបតីត្រឹមតែ ២ ប៉ុណ្ណោះ គឺអារម្មណាធិបតី សហជាតាធិបតី ។ ក្នុងរូបាវចរកុសល និងអរូបាវចរកុសល រមែងមិនបានអារម្មណាធិបតីឡើយ, រមែងបានចំពោះសហជាតាធិបតីប៉ុណ្ណោះ; ក្នុងសហជាតាធិបតីនេះ ត្រាស់សភាពជាចិត្តាធិបតីរបស់ចិត្តទុកដោយអំណាចនៃសម្បយុត្តធម៌ទាំងឡាយ ។ តែព្រោះចិត្ត ២ ដួង មិនមានការព្រមព្រៀងគ្នា ឈ្មោះថា **ចិត្តាធិបតី** របស់សម្បយុត្តចិត្តក៏មិនមាន ។ ម្យ៉ាងទៀត ឆន្ទាធិបតីជាដើម នៃធម៌មានឆន្ទៈជាដើមក៏ដូចគ្នា; តែអាចារ្យពួកខ្លះ រមែងប្រាថ្នាឈ្មោះ **អធិបតី** ដោយអំណាចនៃការមកយ៉ាងនេះថា “កុសលចិត្តដួងដទៃទៀត ធ្វើចិត្តណាឱ្យជាធុរៈ ឱ្យជាធំ ប្រមូលមកហើយយ៉ាង

នេះថា ‘ បើកុសលធម៌កំពុងមានដល់បុគ្គលអ្នកមានចិត្តសោត កុសលធម៌ក៏នឹងមានដល់យើង’ ដូច្នេះ, ចិត្តដួងដំបូងនោះ របស់បុគ្គលនោះ ឈ្មោះថា **ជាចិត្តាធិបតី**; ចិត្តនេះឈ្មោះថា **ចិត្តាធិបតេយ្យ** ព្រោះមកអំពីដួងចិត្តនោះ” ។ ក៏ន័យនេះមិនប្រាកដក្នុងព្រះបាលី និងអដ្ឋកថាទេ ព្រោះហេតុដូច្នោះ គប្បីជ្រាបភាពជាអធិបតេយ្យ ដោយន័យដែលពោលហើយនោះចុះ ។

ក៏ក្នុងមហាន័យ ១៩ នេះ ចិត្តទាំងឡាយប្រមាណដែលពោលក្នុងសុទ្ធិកន័យដើម មាននវកៈទាំងឡាយ និងវារៈនៃព្រះបាលីទាំងឡាយ ព្រោះហេតុដូច្នោះ គប្បីជ្រាបប្រភេទនៃចិត្ត នវកៈ និងវារៈដែលគុណដោយ ២០ មានប្រមាណដែលពោលក្នុងញាណសម្បយុត្ត និងគុណដោយ ១៦ ក្នុងញាណវិប្បយុត្ត ៤ ដូច្នេះ នេះឈ្មោះថា **បកិណ្ណកកថា** ក្នុងកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូច្នេះឯង ៕

**កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចប់**

# អដ្ឋកថាចិត្តុប្បាទកណ្ឌ

## អធិប្បាយលោកុត្តរកុសល

ព្រះភគវាទ្រង់សម្ដែងកុសល ដែលញ៉ាំងភពនៃសម្បត្តិ ឱ្យកើតឡើងយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងលោកុត្តរកុសល ដើម្បីឈានកន្លងភពទាំងអស់ ទើបផ្ដើមព្រះបាលីមានជាអាទិ៍ថា **"កតមេ ធម្មា កុសលា** = ធម៌ជាកុសលតើដូចម្ដេច?" ទៀត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **កតមេ ធម្មា** ជាដើមតទៅ ៖

បទថា **"លោកុត្តរំ"** សួរថា ធម៌ដែលឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថាដូចម្ដេច ? ឆ្លើយថា ដែលឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា រមែងឆ្លងចាកលោក = **លោកំ តរតីតិ លោកុត្តរំ**, ឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ឆ្លងផុតពីលោកទៅ = **លោកំ ឧត្តរតីតិ លោកុត្តរំ**, ឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ឈានកន្លងហើយ គឺគ្របសង្កត់នូវលោកទាំង ៣ (ហើយ) ទើបតាំងនៅ **លោកត្តយំ សមតិក្កម្ម អភិភុយ្យ តិដ្ឋតីតិ លោកុត្តរំ** [១៨] ។

បទថា **"ឈានំ ភាវេតិ** = ចម្រើនឈានលោកុត្តរ" បានដល់ ព្រះយោគាវចរញ៉ាំងអប្បនាឈាន ដែលប្រកបដោយខណៈចិត្តមួយដួងឱ្យកើតឡើង គឺឱ្យចម្រើន ។ អធិប្បាយថា លោកុត្តរជ្ឈាន ឈ្មោះថា **និយ្យានិក** ព្រោះអត្ថថា

---

[១៨] ខុ. បដិ. ។

ចេញទៅចាកលោក, គឺចេញទៅចាកវដ្តៈ; ន័យមួយទៀត ដែលឈ្មោះថា **និយ្យានិក** ព្រោះអត្ថថា ជាគ្រឿងចេញចាកលោក និងចាកវដ្តៈនោះ; ពិតណាស់ បុគ្គលអ្នកព្រមព្រៀងដោយលោកុត្តរជ្ឈាននោះ កាលបើកំណត់ដឹងទុក្ខ ឈ្មោះថា រមែងចេញទៅ, កាលបើលះសមុទយៈ ឈ្មោះថា រមែងចេញទៅ, កាលបើធ្វើឱ្យជាក់ច្បាស់នូវនិរោធ ឈ្មោះថា រមែងចេញទៅ, កាលបើចម្រើនមគ្គ ក៏ឈ្មោះថា រមែងចេញទៅ; ព្រោះហេតុដូច្នោះ លោកុត្តរជ្ឈាននោះ ទើបឈ្មោះថា **និយ្យានិក** ។

ក៏កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ រមែងបង្ករ (កពូន) ចុតិ និងបដិសន្ធិ ធ្វើឱ្យច្រើនក្នុងវដ្តៈ ព្រោះហេតុដូច្នោះ កុសលនោះទើបឈ្មោះថា **អាចយគាមី** យ៉ាងណា, លោកុត្តរកុសលនេះ មិនមែនជាយ៉ាងនោះទេ, ក៏លោកុត្តរកុសលនេះ រើហើយទម្លាយនូវចុតិ និងបដិសន្ធិដែលកុសលក្នុងភូមិ ៣ សាងទុកដោយធ្វើឱ្យដាច់អស់ទៅនូវបច្ច័យ ឧបមាដូចកាលបើបុរសម្នាក់សាងកំពែងកម្ពស់ ១៨ ហត្ថ, តែម្នាក់ទៀតយកញញួរ ធ្វើឱ្យខ្ចាត់ខ្ចាយនូវទីដែលបុរសនោះកសាងហើយៗ គប្បីទៅដូច្នោះ ព្រោះហេតុនោះ លោកុត្តរជ្ឈាននោះ ទើបឈ្មោះថា **អាបចយគាមី** = នាំទៅកាន់ព្រះនិព្វាន ។

ក្នុងបទថា **“ទិដ្ឋិគតានំ បហានាយ** = ដើម្បីលះទិដ្ឋិ” នេះ ទិដ្ឋិទាំងឡាយនោះឯង ឈ្មោះថា ទិដ្ឋិគតៈ ដូចពាក្យជាដើមថា **“គូថគតំ** = គូថ, **មុត្តគតំ** = មូត្រ”[១៩] ។ មួយវិញទៀត ឈ្មោះថា **ទិដ្ឋិគតៈ** សូម្បីព្រោះអត្ថថា ទៅហើយក្នុងទិដ្ឋិទាំងឡាយ ព្រោះដាក់ចុះខាងក្នុងទិដ្ឋិ ៦២ ។ មួយវិញទៀត ធម្មជាតដែល

---

[១៩] អំ. នវក. ។

ឈ្មោះថា **ទិដ្ឋិគតៈ** សូម្បីព្រោះអត្ថថា មានទិដ្ឋិប្រព្រឹត្តទៅ, អធិប្បាយថា សភាវៈដែលមានការទៅដូចនឹងទិដ្ឋិ គឺសភាវៈដែលប្រព្រឹត្តទៅសព្វជាទិដ្ឋិ ។ **សួរថា** ក៏សភាវៈដែលប្រព្រឹត្តទៅសព្វ ដូចនឹងទិដ្ឋិនោះ តើដូចម្តេច ? ឆ្លើយថា បានដល់ **សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាសៈ** និងអកុសល មានរាគៈ, ទោសៈ និង មោហៈព្រមទាំងសម្បយុត្តធម៌របស់ទិដ្ឋិនោះ ដែលញុំាងសត្វឱ្យទៅកាន់អបាយ; ព្រោះសភាវធម៌ទាំងនោះ លោកហៅថាសភាវៈ ដែលមានការទៅដូចនឹងទិដ្ឋិ ព្រោះមានសភាពប្រព្រឹត្តទៅរហូតដល់មគ្គទី ១; ព្រោះហេតុដូច្នោះ ទិដ្ឋិទាំងឡាយផង សភាវៈដែលមានការទៅរបស់ទិដ្ឋិទាំងឡាយផង ទើបឈ្មោះថា **ទិដ្ឋិគតៈ** ។ បទថា "**បហានាយ** = ដើម្បីលះ" បានដល់ ដើម្បីលះទិដ្ឋិគតៈទាំង នោះដោយអំណាច នៃសមុច្ឆេទប្បហាន ។

បទថា "**បឋមាយ** = ខាងដើម" បានដល់ ឈ្មោះថា ខាងដើម ដោយអំណាចនៃការរាប់ខ្លះ ដោយអំណាចនៃការកើតឡើងគ្រាដំបូងខ្លះ ។ បទថា "**ភូមិយា** = ភូមិ" សេចក្តីថា មហាបឋវីនេះ លោកហៅថា "ភូមិ" មែនពិត ដូចក្នុងប្រយោគមានជាអាទិ៍ថា "**អនន្តរហិតាយ ភូមិយា** = លើផ្ទៃដែលប្រាសចាកគ្រឿងក្រាល"[២០] ។ **ចិត្តុប្បាទ** (ការកើតឡើងនៃចិត្ត) ក៏ហៅថា ភូមិ ដូចក្នុងប្រយោគមានជាអាទិ៍ថា "**សុខភូមិយំ កាមាវចរេ** = ក្នុងកាមាវចរជាភូមិនៃ

[២០] វិនយ. ១/ ម. ម. ។

សេចក្ដីសុខ”[២១] ; តែក្នុងទីនេះ ទ្រង់បំណងយកសាមញ្ញផល; ព្រោះសម្បយុត្តធម៌ទាំងនោះ រមែងកើតក្នុងសាមញ្ញផលនេះ ព្រោះហេតុដូច្នោះ សាមញ្ញផលនេះទើបឈ្មោះថា *ភូមិ* ព្រោះជាទីអាស្រ័យរបស់សម្បយុត្តធម៌ទាំងនោះ ។ ម្យ៉ាងទៀត កាលបើសេចក្ដីជាលោកុត្តរមាន សូម្បីសាមញ្ញផល ក៏កើតឡើងប្រាកដបានឯង, មិនមែនមិនប្រាកដដូចនិព្វានទេ, ព្រោះហេតុដូច្នោះ ទើបហៅថា ***ភូមិ*** ។

***សួរថា*** ព្រោះហេតុអ្វី ទើបត្រាស់ពាក្យថា ***ភូមិ*** នេះ ? ឆ្លើយថា ដើម្បីសម្ដែងការពន្លុះភូមិខាងដើម ក្នុងខនេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ដើម្បីពន្លុះ គឺដើម្បីប្រយោជន៍ការបានចំពោះសាមញ្ញផលទី ១ ពោលគឺសោតាបត្តិផល ។ បទថា **“ទិដ្ឋិ = ស្វាត់”** គឺស្វាត់ហើយ វៀរហើយ ដោយអំណាចនៃសមុច្ឆេទវិវេក ។

ឥឡូវនេះ ព្រោះភាពជាអ្នកប្រាថ្នានឹងសម្ដែងដល់លោកិយជ្ឈាន វៀរបដិបទារមែងមិនសម្រេចដោយពិត លុះសេចក្ដីមិនសម្រេចសូម្បីមាននៅក្នុងលោកុត្តរកុសលនេះ ទើបទ្រង់លះសុទ្ធិកន័យចេញហើយធ្វើលោកុត្តរជ្ឈានឱ្យធ្ងន់ ព្រមជាមួយនឹងបដិបទានោះឯង ទើបត្រាស់ពាក្យជាដើមថា **“ទុក្ខាបដិបទំ ទន្ធាភិញ្ញំ”** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា **“ទុក្ខាបដិបទា”** នោះតទៅ ៖

យោគាវចរបុគ្គលណា កាលបើសង្កត់កិលេសទាំងឡាយតាំងអំពីដើម កាល

---

[២១] អភិ. ។

លំបាកដោយការខ្វល់ខ្វាយព្រមជាមួយសង្ខារដ៏លំបាក ទើបសង្កត់ទុកបាន, បដិបទារបស់លោកនោះទើបជា **ទុក្ខាបដិបទា**; ចំណែកយោគាវចរបុគ្គលណា មានកិលេសសង្កត់ទុកហើយ កាលបើអប់រំវិបស្សនានៅអស់កាលយូរ ទើបដល់សេចក្ដីប្រាកដនៃមគ្គ, ការត្រាស់ដឹងរបស់លោកនោះជា **ទន្ធាភិញ្ញា**; ដោយប្រការដែលពោលហើយវារៈយ៉ាងណានីមួយ ឈ្មោះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** ជាដើម លោកអធិប្បាយទុកហើយ ។

***សួរថា*** ក៏វារៈណាព្រះអដ្ឋកថាចារ្យពេញចិត្ត ? ឆ្លើយថា ក្នុងវារៈណាកិលេសទាំងឡាយ ដែលព្រះយោគាវចរសង្កត់ទុកម្ដងហើយ ក៏ផុសឡើងទៀតសង្កត់គ្រាទី ២ ក៏ផុសឡើងទៀត, តែកាលបើសង្កត់គ្រាទី ៣ ទើបធ្វើការសង្កត់ទុកបាន យ៉ាងនោះដែរ ហើយទើបឱ្យដល់ការដកឡើងដោយមគ្គ, ក៏វារៈនេះព្រះអដ្ឋកថាចារ្យពេញចិត្ត; លោកតាំងឈ្មោះវារៈនេះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** ។

ក៏ដោយហេតុត្រឹមតែប៉ុណ្ណេះ វារៈនេះក៏នៅតែមិនទាន់ជាក់ច្បាស់; ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ គប្បីជ្រាបការអធិប្បាយតាំងអំពីដើមយ៉ាងនេះថា ក៏យោគាវចរបុគ្គលណា កំណត់មហាភូតរូប ៤ ហើយ ទើបកំណត់ឧបាទាយរូប, គឺកំណត់អរូបបាន; តែកាលបើកំណត់រូប និងអរូប ក៏តែងលំបាកដោយសេចក្ដីទុក្ខដោយសេចក្ដីលំបាក ទើបអាចដើម្បីកំណត់បាន, បដិបទារបស់លោកទើបឈ្មោះថា **ទុក្ខាបដិបទា** ។ ចំណែកយោគាវចរបុគ្គលណាមានរូប និងអរូបកំណត់បានហើយ

ក្នុងការចម្រើនវិបស្សនា ព្រោះសេចក្ដីយឺតយូរនៃការប្រាកដដល់មគ្គអភិញ្ញារបស់យោគាវចរបុគ្គលនោះ ទើបឈ្មោះថា **ទន្ធាភិញ្ញា** ។

សូម្បីយោគាវចរបុគ្គលណាកំណត់រូប និងអរូបបានហើយ កាលបើកំណត់ញែកនាមរូប លំបាកនៅដោយសេចក្ដីទុក្ខ ដោយសេចក្ដីលំបាក ទើបកំណត់ញែកបាន និងកាលបើកំណត់ញែកនាមរូបបានហើយ ចម្រើនវិបស្សនាអស់កាលយូរ ទើបអាចឱ្យមគ្គកើតឡើងបាន, សូម្បីបដិបទារបស់លោកនោះទើបជា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** ។

ម្យ៉ាងទៀត កំណត់នាមរូបបានហើយ សូម្បីកំណត់បច្ច័យទាំងឡាយ ដែលចាក់ធ្លុះរហូតដល់លក្ខណៈទាំងឡាយ លំបាកនៅដោយសេចក្ដីទុក្ខ សេចក្ដីលំបាក ទើបកំណត់បាន, គ្រាកំណត់បច្ច័យចាក់ធ្លុះរហូតដល់លក្ខណៈបានហើយ ចម្រើនវិបស្សនាអស់កាលយូរ ទើបញ៉ាំងមគ្គឱ្យកើតឡើង, សូម្បីដោយអាការយ៉ាងនោះក៏ឈ្មោះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញាដែរ** ។

រូបដទៃទៀត សូម្បីកំណត់បច្ច័យទាំងឡាយហើយ ចាក់ធ្លុះរហូតដល់លក្ខណៈទាំងឡាយ កាលលំបាកដោយសេចក្ដីទុក្ខ សេចក្ដីត្រដាប់ត្រដួស ទើបចាក់ធ្លុះបាន និងលោកដែលមានលក្ខណៈចាក់ធ្លុះហើយ ចម្រើនវិបស្សនាអស់កាលយូរ ទើបញ៉ាំងមគ្គឱ្យកើត, សូម្បីដោយអាការយ៉ាងនេះ ក៏ឈ្មោះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញាដែរ** ។

រូបដទៃទៀត ចាក់ធ្លុះរហូតលក្ខណៈទាំងឡាយនាំវិបស្សនាញាណ ដែលចាស់ក្លា និងភ្លឺថ្លាមក កាលគ្របសង្កត់និក្កន្តិនៃវិបស្សនាដែលកើតឡើង កាលលំបាក

ដោយសេចក្ដីទុក្ខ ដោយសេចក្ដីត្រដាប់ត្រដួស ទើបគ្របសង្កត់បាន, ពេលគ្រប សង្កត់និក្កន្តិបានហើយ ចម្រើនវិបស្សនាអស់កាលយូរញ៉ាំងមគ្គឱ្យកើត, សូម្បីដោយ អាការយ៉ាងនេះ ក៏ឈ្មោះថា **ទុក្ខាបដិបទា ទន្ធាភិញ្ញាដែរ** ។ វារៈនេះ ព្រះអដ្ឋ កថាចារ្យពេញចិត្ត និងតាំងឈ្មោះវារៈនេះទុកហើយ, គប្បីជ្រាបបដិបទា ៣ ខាង មុខ (ដ៏សេស) ដោយឧបាយនេះចុះ ។

បណ្ដាបទទាំងឡាយមានបទជាដើមថា "**ផស្សោ ហោតិ** = ផស្សៈរមែង មាន" មានអធិកបទ ៤ គឺអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១, សម្មាវាចា ១, សម្មា កម្មន្តៈ ១, សម្មាអាជីវៈ ១ និងបទដែលមានពាក្យជាដើមថា "**មគ្គង្គំ**" ក្នុង និទ្ទេសទាំងឡាយមានវិតក្កនិទ្ទេសជាដើម ក្នុង**និទ្ទេសវារៈ**ជាអធិកបទ ។ ពាក្យ ដ៏សេសទាំងអស់ដូចនឹងពាក្យ ដែលពោលហើយក្នុងខាងក្រោយ; តែអធិការនេះ មានសេចក្ដីប្លែកគ្នាដោយអំណាចនៃសេចក្ដីផ្សេងគ្នានៃភូមិ ព្រោះជាលោកុត្តរ ។

បណ្ដាអធិកបទទាំង ៤ នោះ បទថា "**អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ**" បាន ដល់ ឥន្ទ្រិយដែលកើតឡើង ដោយចំណែកខាងដើមនេះ របស់យោគីអ្នកបដិបត្តិ ដោយមនសិការថា "យើងនឹងដឹងសព្វនូវអមតបទ គឺសច្ចធម៌ ៤ នោះឯង ដែល នៅមិនធ្លាប់ដឹងហើយនៅក្នុងសង្សារវដ្ដមានខាងដើម និងខាងចុងដែលបុគ្គលដឹង មិនបានហើយ" ។ ចំណែកពាក្យមានលក្ខណៈជាដើមរបស់អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ នោះ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងបញ្ញិន្ទ្រិយខាងក្រោយនោះចុះ ។

វាចាល្អ ឬវាចាដែលបណ្ឌិតសរសើរ ឈ្មោះថា **សម្មាវាចា**, ពាក្យថា "សម្មាវាចា" នេះ ជាឈ្មោះនៃការវៀរចាកមិច្ឆាវាចា ព្រោះជាវាចាដកឡើងនូវ

វចីទុច្ចរិត ។ សម្មាវាចានោះ មានការកំណត់ជាលក្ខណៈ = **បរិគ្គហលក្ខណា**, មានការវៀរចាកជាកិច្ច = **វិរមណរសា**, មានការលះមិច្ឆាវាចា ជាបច្ចុប្បដ្ឋាន = **មិច្ឆាវាចប្បហានបច្ចុប្បដ្ឋានា** ។

ការងារដែលល្អ ឬដែលបណ្ឌិតសរសើរ ឈ្មោះថា **សម្មាកម្មន្តៈ**, ពាក្យថា "សម្មាកម្មន្តៈ" នេះ ជាពាក្យនៃការវៀរចាកបាណាតិបាតជាដើម ព្រោះជាការងារដែលដកឡើងនូវមិច្ឆាកម្មន្តៈ; សម្មាកម្មន្តៈនោះ មានការតាំងឡើងជាលក្ខណៈ = **សមុដ្ឋានលក្ខណា**, មានការវៀរចាកជាកិច្ច = **វិរមណរសា**, មានការលះមិច្ឆាកម្មន្តៈជាបច្ចុប្បដ្ឋាន = **មិច្ឆាកម្មន្តបច្ចុប្បដ្ឋានោ** ។

អាជីវៈល្អ ឬដែលបណ្ឌិតសរសើរ ឈ្មោះថា សម្មាអាជីវៈ, ពាក្យថា "សម្មាអាជីវៈ" នេះ ជាឈ្មោះនៃការវៀរចាកមិច្ឆាអាជីវៈ; សម្មាអាជីវៈនោះ មានសេចក្ដីផូរផង់ជាលក្ខណៈ = **វោទានលក្ខណោ**, មានការប្រព្រឹត្តទៅនៃអាជីវៈត្រូវតាមធម៌ជាកិច្ច = **ញាយាជីវប្បវត្តិរសោ**, មានការលះមិច្ឆាអាជីវៈជាបច្ចុប្បដ្ឋាន = **មិច្ឆាជីវប្បហានបច្ចុប្បដ្ឋានោ** ។

ម្យ៉ាងវិញទៀត គប្បីជ្រាបគោលធម៌មានលក្ខណៈជាដើម ក្នុងសម្មាវាចាជាដើមនេះ ដោយអំណាចនៃពាក្យដែលពោលហើយក្នុងវិរតិ ៣ ក្នុងខាងក្រោយ; គប្បីជ្រាបមគ្គ ៥ ដែលពោលទុកខាងក្រោយ ដោយអំណាចនៃធម៌ (វិរតិ) ៣ នេះ ដោយប្រការដូច្នេះ ក្នុងទីនេះ គប្បីជ្រាបមគ្គ ៨ និងក្នុង **យេវាបនកធម៌** ទាំងឡាយ មិនមានសម្មាវាចាជាដើមទាំងនេះទេ, ករុណា និងមុទិតា ក៏មិនដូចគ្នាដែរ; ព្រោះថា ធម៌ទាំង ៣ (មានសម្មាវាចាជាដើម) នេះ ព្រោះការដែលពោលទុកក្នុង

បាលីនេះ ទើបមិនកាន់យកក្នុងយេវាបនកធម៌ទាំងឡាយឡើយ; ចំណែកករុណា និងមុទិតាមានសត្វជាអារម្មណ៍, ក៏ធម៌ (ករុណា និងមុទិតា) នេះ ជាអតីតៈនៃអារម្មណ៍ដែលត្រជាក់ស្ងប់ លោកមិនកាន់យកក្នុងលោកុត្តរនេះទេ; សេចក្ដីដែលផ្សេងគ្នាក្នុងឧទ្ទេសវារៈមានត្រឹមតែប៉ុណ្ណេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា “**មគ្គង្គំ** = ជាអង្គនៃមគ្គ, **មគ្គបរិយាបន្នំ** = រាប់បញ្ចូលក្នុងមគ្គ” ក្នុងនិទ្ទេសវារៈសិនចុះ ។

ធម៌ដែលឈ្មោះថា **មគ្គង្គ** ព្រោះអត្ថថា ជាអង្គនៃមគ្គ, អធិប្បាយថា ជាចំណែកនៃមគ្គ; ដូចយ៉ាងថា វត្ថុដែលរាប់បញ្ចូលក្នុងព្រៃ ឈ្មោះថា **អរញ្ញបរិយាបន្នៈ** យ៉ាងណា, ធម៌ដែលរាប់បញ្ចូលក្នុងមគ្គ ឈ្មោះថា **មគ្គបរិយាបន្នៈ** យ៉ាងនោះ, អធិប្បាយថា អាស្រ័យមគ្គ ។

ក្នុងខថា “**បីតិសម្ពោជ្ឈង្គ**” នេះ សម្ពោជ្ឈង្គ គឺបីតិនេះឯង ឈ្មោះថា បីតិសម្ពោជ្ឈង្គ ។ ម្យ៉ាងទៀត ក្នុងពាក្យថា បីតិសម្ពោជ្ឈង្គទាំងនោះ ធម៌ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថថា ជាអង្គនៃធម្មសាមគ្គីគ្រឿងត្រាស់ដឹង ឬរបស់បុគ្គលអ្នកត្រាស់ដឹង ពាក្យនេះមានអធិប្បាយថា ធម្មសាមគ្គីនេះ ត្រាស់ហៅថា **ពោធិ** ព្រោះធ្វើអធិប្បាយថា ព្រះអរិយសាវ័កអ្នកត្រាស់ដឹងដោយធម្មសាមគ្គីពោលគឺសតិ, ធម្មវិចយៈ, វីរិយៈ, បីតិ, បស្សទ្ធិ, សមាធិ និងឧបេក្ខាដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គ ដែលជាបដិបក្សចំពោះឧបទ្រវៈមិនមែនតិចទេ ដែលមានសេចក្ដីសៅហ្មង, ថីនៈ, ឧទ្ធច្ចៈ, បតិដ្ឋាន គឺកិលេសជាគ្រឿងក្រសោបទុក,

អាយូហនៈ គឺកិលេសជាគ្រឿងប្រកបទុក, កាមសុខល្លិកានុយោគ, អត្តកិលមថានុយោគ និងអភិនិវេស គឺប្រកាន់មាំក្នុងសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិជាដើម ។ ពាក្យថា **រមែងត្រាស់ដឹង** គឺរមែងក្រោកឡើងចាកការដេកលក់ ពោលគឺសេចក្ដីបន្តនៃកិលេស, ឬរមែងត្រាស់ដឹងអរិយសច្ច ៤, ឬថា ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង, អង្គនៃពោធិពោលគឺធម្មសាមគ្គីនោះតែងមាន, ហេតុនោះ ធមិនោះ ទើបឈ្មោះថា **ពោជ្ឈង្គ** ដូចអង្គឈាន និងអង្គនៃមគ្គជាដើម ។ សូម្បីព្រះអរិយសាវ័កនោះ ក៏ហៅថា **ពោធិ** ព្រោះធ្វើអធិប្បាយថា រមែងត្រាស់ដឹងដោយធម្មសាមគ្គីមានប្រការតាមដែលពោលហើយនោះ ។ សូម្បីអង្គនៃពោធិ គឺព្រះអរិយសាវ័កអ្នកត្រាស់ដឹងនោះ លោកហៅថា **ពោជ្ឈង្គ** ដូចអង្គនៃសេនា និងអង្គនៃរថជាដើម; ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ ទើបត្រាស់ថា "ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃបុគ្គលអ្នកត្រាស់ដឹង" ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃពោជ្ឈង្គនេះ សូម្បីដោយន័យបដិសម្ភិទាមគ្គថា "ពាក្យថា '**ពោជ្ឈង្គ**" *សួរថា* ធមិដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថាដូចម្ដេច ? ឆ្លើយថា ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងប្រព្រឹត្តទៅព្រមដើម្បីការត្រាស់ដឹង, ឈ្មោះថា **សម្ពោជ្ឈង្គ** ព្រោះអត្ថថា រមែងត្រាស់ដឹងព្រម"[២២] ។ ពោជ្ឈង្គដែលបណ្ឌិតសរសើរហើយផង ជាពោជ្ឈង្គដ៏ល្អផង ឈ្មោះថា **សម្ពោ**

---

[២២] ខុ. បដិ. ។

**ជ្ឈង្គ** ។ ដោយប្រការដូច្នេះ **សម្ពោជ្ឈង្គ** គឺបីតិនោះឯង ទើបឈ្មោះថា **បីតិសម្ពោជ្ឈង្គ** ។ សូម្បីក្នុងនិទ្ទេសនៃឯកគ្គតាចិត្តជាដើម បណ្ឌិតគប្បីជ្រាបដោយន័យនេះចុះ ។

បទថា "**តេសំ ធម្មានំ** = ធមិពួកនោះ" បានដល់ ធមិ គឺសច្ចៈ ៤ រមែងដល់ការចាក់ធ្លុះក្នុងសម័យនោះ ឈ្មោះថា **ធមិពួកនោះ** ។ បទថា "**អញ្ញាតានំ** = ដែលនៅមិនធ្លាប់ដឹង" សេចក្តីថា ធមិទាំងនោះដែលព្រះយោគាវចរឈ្មោះថាដឹងហើយដោយបឋមមគ្គក៏ពិតមែន, តែលោកក៏ពោលឧបមាទុកថា បុគ្គលមកកាន់វិហារដែលមិនធ្លាប់មកតាមប្រក្រតី សូម្បីឋិតនៅក្នុងកណ្តាលវិហារ ក៏រមែងពោលថា "ខ្ញុំមកកាន់ទីដែលមិនធ្លាប់មក" ព្រោះអាស្រ័យភាពជាអ្នកមិនមកតាមប្រក្រតីយ៉ាងណា, និងដូចបុគ្គលប្រដាប់ផ្កាឈើមិនធ្លាប់ប្រដាប់តាមប្រក្រតី, ស្លៀកសំពត់ដែលនៅមិនធ្លាប់ស្លៀក (សំពត់ថ្មី), បរិភោគអាហារដែលមិនធ្លាប់បរិភោគ ព្រោះអាស្រ័យសេចក្តីជាអ្នកមិនធ្លាប់បរិភោគតាមប្រក្រតី ទើបពោលថា "ខ្ញុំបរិភោគអាហារដែលនៅមិនធ្លាប់បរិភោគ" យ៉ាងណា, សូម្បីក្នុងខនេះ ក៏យ៉ាងនោះដែរ ព្រោះធមិទាំងនេះដែលបុគ្គលនេះមិនដឹងតាមប្រក្រតី, ព្រោះហេតុដូច្នោះទើបពោលថា "**ដែលនៅមិនធ្លាប់ដឹង**"។

សូម្បីក្នុងពាក្យថា **ដែលនៅមិនធ្លាប់ឃើញជាដើម** ក៏ន័យនេះដែរ ។

បណ្តាបទទាំងនោះ បទថា "**អទិដ្ឋានំ** = ដែលនៅមិនធ្លាប់ឃើញ" បានដល់ មិនធ្លាប់ឃើញដោយបញ្ញាចក្ខុក្នុងកាលមុនអំពីកាលនេះ ។ បទថា "**អប្បត្តានំ** = ដែលមិនធ្លាប់ពន្លុះ" គឺដែលនៅមិនធ្លាប់សម្រេចដោយអំណាចនៃសេចក្តីដឹង ។

បទថា **"អទិដ្ឋានំ** = ដែលនៅមិនធ្លាប់ជ្រាប" គឺដែលនៅមិនប្រាកដ ដោយញាណ ។ បទថា **"អសច្ឆិកតានំ** = ដែលនៅមិនធ្វើឱ្យជាក់ច្បាស់" គឺដែលនៅមិនប្រាកដដោយញាណ ។ បទថា **"សច្ឆិកិរិយាយ** = ដើម្បីធ្វើឱ្យជាក់ច្បាស់" គឺដែលមិនធ្លាប់ធ្វើឱ្យប្រចក្ស ។ គប្បីប្រកបសេចក្តីសូម្បីជាមួយបទដ៏សេស នឹងបទនេះ យ៉ាងនេះថា "ដើម្បីដឹងធម៌ដែលនៅមិនធ្លាប់ដឹង, ដើម្បីឃើញធម៌ដែលនៅមិនធ្លាប់ឃើញ, ដើម្បីពន្លុះធម៌ដែលនៅមិនធ្លាប់ពន្លុះ, ដើម្បីជ្រាបធម៌ដែលនៅមិនធ្លាប់ជ្រាប"។

ក្នុងបទទាំងឡាយមានជាអាទិ៍ថា **"ចតូហិ វចីទុច្ចរិតេហិ** = វចីទុច្ចរិត ៤" បទថា **វចី** គប្បីជ្រាបថា ជាគ្រឿងសម្គាល់ឱ្យដឹងដោយវាចា (វចីវិញ្ញត្តិ); ធម៌ដែលឈ្មោះថា **ទុច្ចរិត** ព្រោះអត្ថថា សេចក្តីប្រព្រឹត្តដែលទោស ៣ យ៉ាងណានីមួយប្រទូស្តរ៉ាយហើយ ។ ទុច្ចរិតដែលប្រព្រឹត្តទៅតាមវាចា ឈ្មោះថា **វចីទុច្ចរិត** ។ ម្យ៉ាងទៀត ទុច្ចរិតដែលសម្រេចដោយពាក្យពោលហៅថា **វចីទុច្ចរិត** ។ ចេតនាដែលឈ្មោះថា **អារតី** ព្រោះរមែងឃ្លាតឆ្ងាយចាកវចីទុច្ចរិតទាំងនោះ ។ ឈ្មោះថា **វិរតិ** ព្រោះរមែងវៀរឃ្លាតឆ្ងាយចាកទុច្ចរិតទាំងនោះ; ឈ្មោះថា **បដិវិរតិ** (ការលែងលះ) ព្រោះជាអ្នកវៀរចាកវចីទុច្ចរិតនោះៗ និងថយចាកវចីទុច្ចរិតទាំងនោះ ។ ម្យ៉ាងទៀត បទទាំង ៣ នេះ លោកបន្ថែមឧបសគ្គចូលមក, បទទាំង ៣ នេះ ជាឈ្មោះនៃការវៀរចាកទាំងអស់ ។

ឈ្មោះថា **វេរមណី** ព្រោះអត្ថថា ការញ៉ាំញីនូវពៀរ គឺញុំាងពៀរឱ្យវិនាសទៅ = វេរំ មនតិ វិនសេតីតិ **វេរមណី** ។ សូម្បីពាក្យថា **"វេរមណី"** នេះ ក៏ជាឈ្មោះនៃការវៀរចាកនោះដែរ, ក៏បុគ្គលកាលបើពោលមុសាវាទជាដើម ឈ្មោះថា រមែងធ្វើដោយចេតនា, វិរតិក្នុងលោកុត្តរមគ្គនេះកើតឡើងហើយ រមែងមិនឱ្យដើម្បីនឹងធ្វើកិរិយានោះ, រមែងកាត់ផ្តាច់ផ្លូវនៃការធ្វើ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អកិរិយា** = ការមិនធ្វើ ។ មួយទៀត ការមិនឱ្យដើម្បីធ្វើនោះ, រមែងកាត់ផ្តាច់ផ្លូវជាគ្រឿងធ្វើ ព្រោះហេតុនោះ ទើបឈ្មោះថា **អករណៈ** = ការមិនប្រកប ។ម្យ៉ាងវិញទៀត បុគ្គលកាលបើពោលវចីទុច្ចរិត ៤ យ៉ាង ដោយចេតនា ឈ្មោះថា រមែងកន្លងល្មើស, វិរតិក្នុងលោកុត្តរមគ្គកើតឡើងហើយ រមែងមិនឱ្យដើម្បីកន្លងល្មើសដូចយ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អនជ្ឈាបត្តិ** = ការមិនកន្លងល្មើស ។

ក្នុងបទនេះថា **"វេលាអនតិក្កមោ** = ការមិនកន្លងល្មើសខេត្ត" អធិប្បាយថា កាលត្រាស់ហៅថា **វេលា** ដូចក្នុងប្រយោគមានជាអាទិ៍ថា **"តាយ វេលាយ** = ក្នុងកាលនោះ"[២៣] ដូច្នេះសិន ។ **រាសិ** (គំនរ) ត្រាស់ហៅថា **វេលា** ក្នុងពាក្យនេះថា **"ឧរុវេលាយំ វិហរតិ** = ប្រថាប់នៅត្រង់តំបន់ឧរុវេលា (គំនរខ្សាច់)"[២៤] ។

---

[២៣] វិនយ., ទី. ម., ខុ. ឧ.។

[២៤] វិនយ., សំ. ស. ។

**សីមា** (ខេត្តដែន) ត្រាស់ថា វេលាក្នុងពាក្យនេះថា “**ឋិតធម្មោ វេលំ នាតិវត្តតិ** = អ្នកមានធមិតាំងនៅ រមែងមិនប្រព្រឹត្តកន្លងខេត្ត”[២៥] ; សូម្បីក្នុងអធិការនេះ ទ្រង់បំណងយកវេលា គឺខេត្តប៉ុណ្ណោះ; ពិតណាស់ វចីទុច្ចរិត ៤ ទ្រង់បំណងយក វេលា (គឺខេត្ត) ព្រោះអត្ថថា មិនគួរឈានកន្លង; ដោយប្រការដូច្នេះ បុគ្គលកាល ពោលវចីទុច្ចរិត ៤ ដោយចេតនាណា ឈ្មោះថា រមែងឈានកន្លងខេត្ត, វិរតិក្នុង លោកុត្តរមគ្គនេះកើតឡើងហើយ រមែងមិនឱ្យដើម្បីឈានកន្លងខេត្តនោះ ព្រោះ ហេតុនោះ ទើបត្រាស់ថា “ការមិនកន្លងល្មើសខេត្ត” ។ម្យ៉ាងទៀត ឈ្មោះថា **វេលា** ព្រោះអត្ថថា រមែងឱ្យលាយអស់ទៅ * អធិប្បាយថា ធ្វើឱ្យវិនាស ឱ្យខ្ចាត់ ខ្ចាយទៅ ។ **សួរថា** ធ្វើអ្វីឱ្យវិនាសអស់ទៅ ? ឆ្លើយថា ធ្វើទុច្ចរិត ៤ ។ ដោយ ប្រការដូច្នេះ ទើបឈ្មោះថា **វេលា** ព្រោះធ្វើឱ្យវិនាសអស់ទៅ ។ ដែលឈ្មោះថា **អនតិក្កមៈ** (ការមិនឈានកន្លង) ព្រោះអត្ថថា មិនឈានកន្លងប្រយោជន៍នៃសេចក្តី សុខ របស់បុគ្គលឱ្យប្រព្រឹត្តទៅ ។ គប្បីជ្រាបអត្ថសូម្បីដោយអំណាចនៃបទទាំងពីរ ក្នុងពាក្យថា **វេលាអនតិក្កមោ** នេះ ដោយប្រការដូច្នេះ ។

ធមិដែលឈ្មោះថា **សេតុឃាត** ព្រោះអត្ថថា រមែងសម្លាប់នូវហេតុ (សេតុ), គឺសម្លាប់ផ្លូវនៃវចីទុច្ចរិត ៤, អធិប្បាយថា សម្លាប់បច្ច័យ ។ ពិតមែន

---

[២៥] អំ. អដ្ឋក. ។

* វេលយតីតិ វេលា ។

ហើយ បច្ច័យត្រាស់ហៅថា **“សេតុ”** ក្នុងទីនេះ; ក្នុងពាក្យថា **សេតុឃាត** នោះ មានសេចក្តីសម្គាល់វចនត្ថៈដូចតទៅនេះ ៖

បច្ច័យនៃវចីទុច្ចរិត ៤ មានរាគៈជាដើម រមែងផ្សារ (ទាក់) រមែងចង បុគ្គលទុកក្នុងវដ្តៈ ព្រោះហេតុនោះ **បច្ច័យនោះ** ទើបឈ្មោះថា **សេតុ**, ពាក្យថា **“សេតុឃាត”** នេះ ជាឈ្មោះរបស់វិរតិ ព្រោះដកឡើងនូវបច្ច័យនៃវចីទុច្ចរិត ៤ ។ តែវិរតិនេះគឺ **សម្មាវាចា** រមែងបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម; ព្រោះថា បុគ្គលរមែងវៀរចាកមុសាវាទ ដោយចិត្តមួយដួង, រមែងវៀរចាកបិសុណាវាទជាដើមដោយចិត្តដួងដទៃ; **តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានក្នុងចិត្តមួយដួងប៉ុណ្ណោះ**, ព្រោះថា វិរតិ គឺសម្មាវាចាមួយដួង កើតឡើងក្នុងការផ្តាច់ផ្លូវរបស់ចេតនាក្នុងវចីទុច្ចរិត ៤ ញ៉ាំងអង្គមគ្គឱ្យបរិបូណ៌ ។

បទថា **“កាយទុច្ចរិតេហិ”** បានដល់ ទុច្ចរិតដែលប្រព្រឹត្តទៅតាមផ្លូវកាយ ឬទុច្ចរិតមានបាណាតិបាតជាដើម ឱ្យសម្រេចដោយកាយ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននោះចុះ ។ សូម្បីវិរតិទាំងនេះពោលគឺសម្មាកម្មន្តៈ រមែងបានក្នុងចិត្តផ្សេងៗ ក្នុងកាលខាងដើម ព្រោះថា បុគ្គលរមែងវៀរចាកបាណាតិបាត ដោយចិត្តមួយដួង, វៀរចាកអទិន្នាទាន និងកាមេសុមិច្ឆាចារដោយចិត្តដួងដទៃ; តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានចិត្តតែមួយដួងប៉ុណ្ណោះ; ព្រោះថា វិរតិមួយដួងកើតឡើងធ្វើការផ្តាច់ផ្លូវនៃចេតនា ក្នុងកាយទុច្ចរិត ៣ យ៉ាង ញ៉ាំងអង្គមគ្គឱ្យបរិបូណ៌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **អកិរិយា** (ការមិនធ្វើ) ក្នុងនិទ្ទេសនៃសម្មាអាជីវៈដូចតទៅ ៖

បណ្ឌិតគប្បីប្រកបសេចក្ដីដោយន័យនេះថា បុគ្គលកាលចិញ្ចឹមជីវិត ឈ្មោះថា រមែងធ្វើកិរិយាមិច្ឆាជីពដោយចេតនាណា, លោកុត្តរចេតនានោះ កើតឡើងហើយ រមែងមិនឱ្យដើម្បីធ្វើកិរិយានោះ ព្រោះហេតុនោះ ចេតនានោះ ទើបឈ្មោះថា **អកិរិយា** = ការមិនធ្វើ; មួយទៀត ឈ្មោះថា **អាជីវៈ** នេះចំពោះតែចំណែកមួយមិនបានមានទេ, កាលបើសម្មាវាចា និងសម្មាកម្មន្តៈ ព្រះយោគាវចរកាន់យកហើយ សម្មាអាជីវៈក៏ជាការដែលកាន់យកហើយដូចគ្នា ព្រោះសម្មាអាជីវៈនោះប្រព្រឹត្តទៅក្នុងចំណែកនៃវាចា និងកាយនោះ, តែអាជីវៈនោះ ព្រះអង្គទ្រង់នាំចេញចាកវាចា និងកាយនោះហើយ សម្ដែងទុកដោយអំណាចនៃការសេពអាស្រ័យនៅជានិច្ច; កាលបើដូច្នោះ សម្មាអាជីវៈក៏មិនមាននាទីរបស់ខ្លួន, អង្គនៃមគ្គ ៨ ក៏គប្បីបរិបូណ៌; ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ គប្បីជ្រាបន័យដូចតទៅនេះ ៖

ធម្មតា **អាជីវៈ** សូម្បីកាលបើបែកធ្លាយ ក៏រមែងបែកធ្លាយ ក្នុងកាយទ្វារ និងវចីទ្វារប៉ុណ្ណោះ, ឈ្មោះថាការបែកធ្លាយអាជីវៈក្នុងមនោទ្វារ រមែងមិនមានឡើយ; សូម្បីកាលបើបរិបូណ៌ក្នុងទ្វារពីរនោះឯង ឈ្មោះថា សេចក្ដីបរិបូណ៌នៃអាជីវៈ មិនបានមានតាមមនោទ្វារឡើយ; ព្រោះហេតុដូច្នោះ សម្មាអាជីវៈ ក៏គប្បីធ្វើកិច្ចរបស់ខ្លួន អង្គនៃមគ្គ ៨ ក៏គប្បីបរិបូណ៌ នេះជាន័យក្នុងអាជីវៈនោះ, ក៏ការឈានកន្លងក្នុងកាយទ្វារ មានអាជីវៈជាហេតុខ្លះ មិនមានអាជីវៈជាហេតុខ្លះ ក្នុងវចីទ្វារ ក៏ដូចគ្នាដែរ ។

បណ្ដាទ្វារទាំងពីរនោះ ព្រះរាជា និងមហាអាមាត្យរបស់ព្រះរាជា ជាអ្នកខ្វល់ខ្វាយក្នុងការលេង កាលបើនឹងសម្ដែងភាពជាអ្នកក្លាហាន រមែងធ្វើការសម្លាប់ម្រឹគខ្លះ ប្លន់មនុស្សដើរផ្លូវខ្លះ កន្លងល្មើសភរិយារបស់អ្នកដទៃខ្លះៗ នេះ ឈ្មោះថាកាយកម្មជាអកុសល, សូម្បីវិរតិវៀរចាកអកុសលកាយកម្មហើយ ក៏ឈ្មោះថា **សម្មាកម្មន្តៈ**, មួយទៀត ព្រះរាជា និងមហាអាមាត្យរបស់ព្រះរាជា រមែងពោលវចីទុច្ចរិត ៤ មិនមែនមានអាជីវៈជាហេតុណា, នេះក៏ឈ្មោះថា វចីកម្មដែលជាអកុសល, សូម្បីវិរតិវៀរចាកវចីកម្មដែលជាអកុសលនោះ ក៏ឈ្មោះថា **សម្មាវាចា** ។

តែថា នាយព្រាន និងអ្នកប្រមង់ជាដើម ព្រោះអាជីពជាហេតុ រមែងសម្លាប់សត្វ, រមែងកាន់យកវត្ថុរបស់ដែលគេមិនបានឱ្យ, រមែងប្រព្រឹត្តមិច្ឆាចារណា, នេះឈ្មោះថា **មិច្ឆាអាជីវៈ**, ការវៀរចាកមិច្ឆាអាជីវៈនោះ ឈ្មោះថា **សម្មាអាជីវៈ**; សូម្បីពួកជនដែលទទួលថ្លៃឈ្នួលណាហើយពោលមុសា, រមែងញុំាងបិសុណាវាទ ផរុសវាទ សម្ផប្បលាបៈឱ្យប្រព្រឹត្តទៅ, សូម្បីកម្មនេះ ក៏ឈ្មោះថា **មិច្ឆាអាជីវៈ**, សូម្បីការវៀរចាកមិច្ឆាអាជីវៈនោះ ក៏ឈ្មោះថា **សម្មាអាជីវៈ** ។

ក៏**ព្រះមហាសិវត្ថេរ**ពោលទុកថា "ការឈានកន្លងកាយទ្វារ និងវចីទ្វារមានអាជីវៈជាហេតុ ឬមិនមានអាជីវៈជាហេតុក៏ដោយ, រមែងរាប់ថាជាកាយកម្ម និងវចីកម្មខាងអកុសលដោយពិត, សូម្បីការវៀរកាយកម្ម និងវចីកម្មខាង អកុសលទើបហៅថា **សម្មាកម្មន្តៈ សម្មាវាចា**" ដូច្នេះបាន; ក៏បើមានគេសួរថា "អាជីវៈទៅណាបាត់អស់?" ក៏ពោលថា "បុគ្គលណាអាស្រ័យកុហនវត្ថុ (រឿងកុហក) ៣

យ៉ាង ញុំាងបច្ច័យ ៤ ឱ្យកើតឡើងហើយ ទើបបរិភោគបច្ច័យនោះ” ; ក៏សេចក្តីនេះ ជាមិច្ឆាអាជីវៈដល់ទីបំផុត, ការវៀរចាកមិច្ឆាអាជីវៈឈ្មោះថា **សម្មាអាជីវៈ** ។

សូម្បីសម្មាអាជីវៈនេះ ក្នុងចំណែកខាងដើមរមែងបានចិត្តផ្សេងៗ; ព្រោះការវៀរចាកការឈានកន្លងផ្លូវកាយទ្វារក៏បានដោយចិត្តម្យ៉ាង, ចាកវចីទ្វារក៏បានដោយចិត្តម្យ៉ាង; តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានតែចិត្តមួយដួងប៉ុណ្ណោះ; ព្រោះវិរតិមួយកើតឡើងធ្វើការផ្តាច់ផ្លូវរបស់ចេតនា ភាពជាអ្នកទ្រុស្តសីល គឺមិច្ឆាអាជីវៈដែលកើតឡើង ដោយអំណាចនៃកម្មបទ ៧ គឺកាយកម្ម និងវចីកម្ម ក្នុងកាយទ្វារ និងវចីទ្វារញុំាងអង្គមគ្គឱ្យបរិបូណ៌ ព្រោះហេតុដូច្នោះ សេចក្តីនេះទើបប្លែកគ្នា ក្នុងនិទ្ទេសវារៈ ។

តែក្នុងឥន្ទ្រិយទាំងឡាយ ទ្រង់បន្ថែមអនញ្ញតញ្ញស្សាមីតិន្ទ្រិយ និងក្នុងអង្គនៃមគ្គ ទ្រង់បន្ថែមសម្មាវាចាជាដើមនោះហើយត្រាស់ថា “ឥន្ទ្រិយ ៩ [២៦] មគ្គមានអង្គ ៨” ក្នុងសង្គហវារៈដោយអំណាចនៃអនញ្ញតញ្ញស្សាមីតិន្ទ្រិយ និងសម្មាវាចាជាដើមទាំងនោះ ។ សុញ្ញតវារៈប្រព្រឹត្តទៅតាមប្រក្រតីនោះឯង ក៏សេចក្តីខាងដើមនេះ ប្លែកគ្នាក្នុងវិសុទ្ធិកបដិបទា ៕

## ចប់សុទ្ធិកបដិបទា

[២៦] ត្រង់សេចក្តីនេះអដ្ឋកថាច្បាប់ថៃជា **សង្គហវារេន វីរិយិន្ទ្រិយានិ អដ្ឋង្គិកោ មគ្គោ** ។ ច្បាប់ភូមាជា **សង្គហវារេ នវិន្ទ្រិយានិ អដ្ឋង្គិកោ មគ្គោ** ។

## កថាសម្តែងអំពីសុញ្ញតាជាដើម

ខាងមុខពីនេះទៅប្រភេទនៃទេសនាគឺ ៖

**- សុទ្ធិកសុញ្ញតា ១ - សុទ្ធិកអប្បណិតៈ ១**

**- សុញ្ញតបដិបទា ១ - អប្បណិហិតបដិបទា ១។**

បណ្តាប្រភេទនៃទេសនាទាំង ៤ នោះ ពាក្យថា **សុញ្ញតា** នេះជាឈ្មោះរបស់លោកុត្តរមគ្គ ។ ពិតមែនហើយ លោកុត្តរមគ្គនោះ រមែងបានឈ្មោះព្រោះហេតុ ៣ យ៉ាងគឺ ព្រោះការពន្លុះ ១, ព្រោះគុណរបស់ខ្លួន ១, ព្រោះអារម្មណ៍ ១ ។

**សួរថា** ហេតុនេះជាយ៉ាងណា ?

ឆ្លើយថា ភិក្ខុក្នុងធម្មវិន័យនេះ អាស្រ័យនៅដោយសេចក្តីជាអនត្តា រមែងឃើញសង្ខារដោយសេចក្តីជាអនត្តាតែធម្មតាថា ការចេញចាកសង្ខតធម៌ដោយមគ្គ (មគ្គវុដ្ឋាន) រមែងមិនមានដោយត្រឹមតែឃើញសេចក្តីជាអនត្តាប៉ុណ្ណោះទេ, ការឃើញដោយសេចក្តីជារបស់មិនទៀងខ្លះ ដោយសេចក្តីជាទុក្ខខ្លះ ទើបសមគួរ, ព្រោះហេតុដូច្នោះ លោកគប្បីលើកឡើងកាន់អនុបស្សនា ៣ យ៉ាងគឺ **“អនិច្ចំ ទុក្ខំ និង អនត្តា”** ពិចារណាហើយទើបត្រាច់ទៅ ក៏វិបស្សនាដែលជាវុដ្ឋានគាមិនីរបស់ភិក្ខុនោះ រមែងឃើញសង្ខារទាំងឡាយសូម្បីដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយសេចក្តីជារបស់សូន្យ (ស្រឡះទទេ) តែម្តង, វិបស្សនានេះ ឈ្មោះថា **សុញ្ញតា**; វិបស្សនានោះ តាំងនៅក្នុងឋានដែលគួរពន្លុះ ទើបឱ្យឈ្មោះមគ្គរបស់ខ្លួនថា **“សុញ្ញតៈ”** ។ មគ្គរមែងបានឈ្មោះថា **សុញ្ញតៈ ព្រោះការពន្លុះ** ដោយប្រការដូច្នេះ ។ តែព្រោះមគ្គនោះសូន្យចាករាគៈជាដើមដូច្នោះ ទើបបានឈ្មោះថា សុញ្ញតៈ

**ដោយគុណរបស់ខ្លួន** ។ សូម្បីព្រះនិព្វានលោកក៏ហៅឈ្មោះថា **“សុញ្ញតៈ”** ព្រោះជាសភាវៈសូន្យចាករាគៈជាដើម ។ មគ្គរមែងបានឈ្មោះសុញ្ញតៈ **ដោយអារម្មណ៍** ព្រោះសេចក្តីដែលមគ្គនោះ ធ្វើព្រះនិព្វាននោះ ឱ្យជាអារម្មណ៍ហើយកើតឡើង ។ បណ្តាហេតុទាំង ៣ នោះ លោកុត្តរមគ្គរមែងបានឈ្មោះដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ តាមបរិយាយដែលមានក្នុងព្រះសុត្តន្តៈ ។ ព្រោះបរិយាយនេះ ជាបរិយាយទេសនា ។ ចំណែកអភិធម្មកថាជានិប្បរិយាយទេសនា ។ ព្រោះហេតុដូច្នោះ ក្នុងអភិធម្មកថានេះ លោកុត្តរមគ្គរមែងមិនបានឈ្មោះ ដោយគុណរបស់ខ្លួន ឬដោយអារម្មណ៍, រមែងបានដោយការពន្លុះតែប៉ុណ្ណោះ ។ ព្រោះថាការពន្លុះនោះជាធុរៈ[២៧] (កិច្ច) ។ ការពន្លុះនោះមាន ២ យ៉ាងគឺ ការពន្លុះដោយវិបស្សនា, ការពន្លុះដោយមគ្គ ។ ក្នុងការពន្លុះទាំងពីរនេះ ការពន្លុះដោយវិបស្សនាជាធុរៈក្នុងឋាននៃមគ្គដល់ហើយ ។ ការពន្លុះដោយមគ្គជាធុរៈ ក្នុងឋាននៃផលមកហើយ ក្នុងអភិធម្មនេះ ព្រោះសេចក្តីដែលមគ្គមកហើយ ការពន្លុះដោយវិបស្សនាប៉ុណ្ណោះ ទើបជាធុរៈកើតឡើង ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងពាក្យថា **អប្បណិហិតៈ** តទៅ ៖

ពាក្យថា **អប្បណិហិតំ** នេះ ជាឈ្មោះរបស់មគ្គ ។ សូម្បីមគ្គក៏រមែងបានឈ្មោះនេះដោយហេតុ ៣ ដូចគ្នាដែរ ។ បានយ៉ាងណា ? គឺភិក្ខុក្នុងព្រះធម្មវិន័យនេះ អាស្រ័យនៅដោយសេចក្តីជាទុក្ខតាំងអំពីដើមម្លេះ រមែងឃើញសង្ខារទាំងឡាយដោយសេចក្តីជាទុក្ខប៉ុណ្ណោះ ក៏ព្រោះធម្មតា មគ្គវុដ្ឋាន (ការចេញចាកសង្ខតធមិ

---

[២៧] អត្ថយោជនា កែពាក្យធុរៈនេះថា បានដល់ប្រធាន = **ធុរន្តិ បធានំ** ។

ដោយមគ្គ) រមែងមានត្រឹមតែការឃើញដោយសេចក្តីជាទុក្ខប៉ុណ្ណោះ, ការឃើញដោយសេចក្តីមិនទៀងខ្លះ ដោយអនត្តាខ្លះ ទើបសមគួរ, ព្រោះហេតុដូច្នោះ ទើបលោកលើកឡើងកាន់អនុបស្សនា ៣ យ៉ាង គឺ "សេចក្តីមិនទៀង ជាទុក្ខ ជាអនត្តា" ពិចារណាហើយទើបត្រាច់ទៅ ។ ក៏វិបស្សនាដែលជាវុដ្ឋានគាមិនីរបស់ភិក្ខុនោះ ញុំាំងបណិធិ (សេចក្តីប្រាថ្នា) ក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឱ្យហួតហែង គឺឱ្យអស់ទៅ ទើបលះបង់ចោល ។ វិបស្សនានេះឈ្មោះថា **អប្បណិហិតះ"** ; វិបស្សនានោះ តាំងនៅក្នុងឋានគួរពន្លុះ ទើបឱ្យឈ្មោះមគ្គរបស់ខ្លួនថា "**អប្បណិហិតះ ព្រោះការពន្លុះយ៉ាងនេះ** ក៏ការតាំងទុកនូវរាគះ ទោសះ និងមោហះក្នុងមគ្គនោះមិនបានមានព្រោះហេតុណា, ព្រោះហេតុនោះ មគ្គនោះទើបបានឈ្មោះដោយ**គុណរបស់ខ្លួននោះឯងថា អប្បណិហិតះ**ដូច្នេះ ។ សូម្បីព្រះនិព្វានក៏ត្រាស់ហៅថា "**អប្បណិហិតះ**" ព្រោះមិនមែនជាទីតាំងនៃរាគះជាដើមនោះ, មគ្គរមែងបានឈ្មោះថា **អប្បណិហិតះ** ដោយអារម្មណ៍ ព្រោះធ្វើព្រះនិព្វាន នោះឱ្យជាអារម្មណ៍ហើយកើតឡើង ។ បណ្តាហេតុទាំង ៣ នោះ មគ្គរមែងបានឈ្មោះដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ តាមបរិយាយនៃសុត្តន្តះ; ព្រោះទេសនានេះជាបរិយាយទេសនា តែអភិធម្មកថាជានិប្បរិយាយទេសនា; ព្រោះហេតុនោះ ក្នុងអភិធម្មកថានេះ លោកុត្តរមគ្គទើបមិនបានឈ្មោះដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ, រមែងបានឈ្មោះដោយការពន្លុះប៉ុណ្ណោះ ។ ក៏ការពន្លុះប៉ុណ្ណោះជាធុរះ; ការពន្លុះនោះមាន ២ យ៉ាងគឺ ការពន្លុះដោយវិបស្សនា, ការពន្លុះដោយមគ្គ; ក្នុងការពន្លុះ ២ យ៉ាងនោះ ការពន្លុះដោយវិបស្សនា ជាធុរះក្នុង

ឋាននៃមគ្គដែលមកហើយ; ការពន្លុះដោយមគ្គ ជាធុរៈក្នុងឋាននៃមគ្គផលដែលមកហើយ; ក្នុងអភិធម្មកថានេះ ព្រោះសេចក្ដីដែលមគ្គមកហើយ ការពន្លុះដោយវិបស្សនាប៉ុណ្ណោះ ទើបជាធុរៈកើតឡើង ។

**សួរថា** ក៏មគ្គនេះមានមគ្គ ៣ យ៉ាងគឺ សុញ្ញតៈ, អនិមិត្ត និងអប្បណិហិតៈ មិនមែនទេឬ ?; ដូចយ៉ាងដែលត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ វិមោក្ខនេះ មាន ៣ យ៉ាង តើដូចម្ដេច? គឺសុញ្ញតវិមោក្ខ ១, អនិមិត្តវិមោក្ខ ១, អប្បណិហិតវិមោក្ខ ១” [២៨]; បណ្ដាមគ្គដែលមានឈ្មោះ ៣ យ៉ាងនោះ ក្នុងអភិធម្មនេះកាន់យកមគ្គ ២ ព្រោះហេតុអ្វីទើបមិនកាន់យកអនិមិត្តវិមោក្ខទៅវិញ ? ។

ឆ្លើយថា ព្រោះមិនមានការពន្លុះ ។

ពិតណាស់ អនិមិត្តវិបស្សនាតាំងនៅក្នុងឋានដែលគួរពន្លុះដោយខ្លួនឯង មិនអាចឱ្យឈ្មោះមគ្គរបស់ខ្លួនបានទេ ។ ក៏ព្រះសម្មាសម្ពុទ្ធបានត្រាស់អនិមិត្តវិបស្សនាដល់ព្រះរាហុលត្ថេរ ជាឱរសរបស់ព្រះអង្គថា ៖

**“អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ**
**តតោ មានាភិសមយា ឧបសន្តោ ចរិស្សសិ**

លោកចូរចម្រើនអនិមិត្តវិបស្សនា (ពិចារណាដោយសេចក្ដីជារបស់មិនទៀង) ចូរលះមានានុស្ស័យចេញ តពីនោះ អ្នកនឹងជាអ្នកចូលទៅស្ងប់ត្រាច់ទៅ ព្រោះលះមានះចេញបាន” [២៩] ។

---

[២៨] ខុ. បដិ. ។

[២៩] ខុ. សុ. ។

ពិតមែនហើយ វិបស្សនារមែងដកឡើងនូវនិមិត្តថាទៀង, នូវនិមិត្តថាយឺតយូរ, នូវនិមិត្តថាអត្តា, នូវនិមិត្តថាជាសុខ; ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **អនិមិត្ត** (មិនមាននិមិត្ត); សូម្បីវិបស្សនានោះ រមែងដកឡើងនូវនិមិត្តនោះ ក៏ពិតមែនហើយ, ប៉ុន្តែថា វិបស្សនានោះដែលមានឈ្មោះថា និមិត្តនោះឯង ព្រោះរមែងត្រាច់ទៅក្នុងនិមិត្តធម៌ទាំងឡាយដោយខ្លួនឯង; ព្រោះហេតុដូច្នោះ ខ្លួនឯងតាំងនៅក្នុងឋានដែលគប្បីពន្លុះ ទើបមិនអាចដើម្បីឱ្យឈ្មោះមគ្គរបស់ខ្លួនបាន ។

ន័យមួយទៀត ធម្មតាព្រះអភិធម្មជាបរមត្ថទេសនា, ឯអនិមិត្តរបស់មគ្គជាការខ្សត់ខ្សោយនៃហេតុដោយបរមត្ថមែនពិត ។ មានការខ្សត់ខ្សោយយ៉ាងណា? គឺអនិមិត្តវិមោក្ខត្រាស់ទុកដោយអំណាចនៃអនិច្ចានុបស្សនា, ឯសទ្ធិន្ទ្រិយ មានប្រមាណក្រៃលែងដោយវិមោក្ខនោះ ។ សទ្ធិន្ទ្រិយនោះមិនមែនជាអង្គសូម្បីតែក្នុងអរិយមគ្គ, ព្រោះមិនមែនជាអង្គមគ្គ ទើបមិនឱ្យឈ្មោះរបស់ខ្លួនដោយបរមត្ថបាន; ចំណែកវិមោក្ខ ២ ក្រៅនេះ សុញ្ញតវិមោក្ខត្រាស់ទុកដោយអំណាចនៃអនត្តានុបស្សនា, អប្បណិហិតវិមោក្ខ ត្រាស់ទុកដោយអំណាចនៃទុក្ខានុបស្សនា ។ បណ្តាវិមោក្ខទាំងនោះ បញ្ញិន្ទ្រិយមានកម្លាំងក្រៃលែងដោយសុញ្ញតវិមោក្ខ, សមាធិន្ទ្រិយមានកម្លាំងក្រៃលែងដោយអប្បណិហិតវិមោក្ខ, បញ្ញិន្ទ្រិយ និងសមាធិន្ទ្រិយទាំងនោះ ព្រោះជាអង្គនៃអរិយមគ្គ ទើបអាចឱ្យឈ្មោះមគ្គរបស់ខ្លួនដោយបរមត្ថបាន ។

ពិតមែនហើយ ក្នុងវេលាដែលឆន្ទៈ និងចិត្តៈ ជាអធិបតីក្នុងការចែកធម៌នៃមគ្គាធិបតី សូម្បីក្នុងមគ្គារម្មណត្តិកៈ ព្រះអង្គមិនបានត្រាស់សេចក្តីជាមគ្គាធិបតីទុក ព្រោះសេចក្តីដែលធម៌គឺ ឆន្ទៈ និងចិត្តៈទាំងនោះមិនមែនជាអង្គមគ្គទេ គប្បីជ្រាប

ពាក្យពេចន៍ដែលដល់ព្រមហើយយ៉ាងនោះចុះ, សេចក្ដីនេះជាការវិនិច្ឆ័យ ដោយចំពោះរបស់អាចារ្យមួយរូបក្រៅពីអដ្ឋកថាក្នុងរឿងនេះ ។ សូម្បីអនិមិត្តវិបស្សនាដោយប្រការទាំងពួងយ៉ាងនេះ តាំងនៅក្នុងឋានដែលពន្លះបានឯង ទើបមិនអាចឱ្យឈ្មោះមគ្គរបស់ខ្លួនបាន ព្រោះហេតុដូច្នោះ ព្រះអង្គទ្រង់មិនបានកាន់យកមគ្គដែលជាអនិមិត្ត ។

តែអាចារ្យពួកខ្លះពោលថា "មគ្គដែលកើតដោយអនិមិត្ត សូម្បីមិនបានឈ្មោះដោយការពន្លះ តែក៏បានឈ្មោះដោយគុណរបស់ខ្លួន និងដោយអារម្មណ៍តាមបរិយាយនៃព្រះសូត្រ" ; លុះអាចារ្យពួកនោះ ពោលពាក្យនេះ ក៏ត្រូវអាចារ្យសកវាទីជំទាស់ថា ៖

កាលបើមគ្គដែលកើតឡើងដោយអនិមិត្ត បានឈ្មោះដោយគុណរបស់ខ្លួន និងដោយអារម្មណ៍ សូម្បីមគ្គដែលកើតអំពីសុញ្ញតៈ និងអប្បណិហិតៈ ក៏គប្បីបានឈ្មោះនេះតាមគុណរបស់ខ្លួន និងអារម្មណ៍, តែក៏នៅមិនបាន; ព្រោះហេតុអ្វី ? ព្រោះថា ធម្មតាមគ្គនេះ រមែងបានឈ្មោះដោយហេតុ ២ យ៉ាងគឺដោយនាទីរបស់ខ្លួន និងដោយបច្ចនិក; គឺថាដោយសភាវៈ និងដោយការបដិសេធ ។ ក្នុងហេតុទាំង ២ យ៉ាងនោះ មគ្គដែលកើតឡើងដោយសុញ្ញតៈ និងអប្បណិហិតៈ រមែងបានឈ្មោះដោយកិច្ចរបស់ខ្លួនខ្លះ ដោយជាបច្ចនិកៈខ្លះ; ពិតណាស់ មគ្គដែលកើតដោយសុញ្ញតៈ និងអប្បណិហិតៈ រមែងបានឈ្មោះដោយកិច្ចរបស់ខ្លួនយ៉ាងនេះគឺ ឈ្មោះថា **សុញ្ញ** គឺសូន្យចាករាគៈជាដើម និងព្រោះមិនមានទីតាំងនៃរាគៈជាដើម; និងរមែងបានឈ្មោះដោយបច្ចនិកយ៉ាងនេះ គឺមគ្គដែលកើតឡើងជាសុញ្ញតៈ ជាបដិបក្ស

ចំពោះការប្រកាន់អត្តា, មគ្គដែលកើតជាអប្បណិហិតៈ ជាបដិបក្សចំពោះធម៌ជាទីតាំង; ចំណែកមគ្គដែលកើតឡើងជាអនិមិត្ត រមែងបានឈ្មោះដោយកិច្ចរបស់ខ្លួនប៉ុណ្ណោះ ព្រោះមិនមាននិមិត្តនៃរាគៈជាដើម និងនិមិត្តថាទៀងជាដើម, មិនមែនបានឈ្មោះដោយសេចក្តីជាសត្រូវទេ; ព្រោះថា មគ្គអនិមិត្តនោះ ជាបដិបក្សចំពោះអនិច្ចានុបស្សនា ដែលមានសង្ខារនិមិត្តជាអារម្មណ៍មិនបាន; ក៏អនិច្ចានុបស្សនាតាំងនៅក្នុងសេចក្តីជាអនុលោមដល់មគ្គនោះ ព្រោះហេតុដូច្នោះ មគ្គដែលកើតឡើងដោយអនិមិត្តនោះ ទើបមិនមានដោយបរិយាយនៃព្រះអភិធម្ម សូម្បីដោយប្រការទាំងពួងដូច្នេះឯង ។

តែថា ដោយបរិយាយនៃព្រះសូត្រ មគ្គដែលកើតឡើងដោយអនិមិត្តនោះ ព្រះអង្គនាំមកសម្តែងទុកយ៉ាងនេះ ÷

ក៏ក្នុងវារៈណាមានការចេញចាកកិលេសដោយមគ្គ, លក្ខណៈទាំង ៣ រមែងមកកាន់គន្លងអាវជ្ជនៈជាមួយគ្នា, ក៏ឈ្មោះថា ការមកកាន់គន្លងនៃលក្ខណៈទាំង ៣ ព្រមគ្នាមិនបាន; តែដើម្បីសម្តែងសេចក្តីជាក់ច្បាស់នៃកម្មដ្ឋាន ព្រះអង្គទើបត្រាស់ទុកយ៉ាងនេះ; សេចក្តីប្រកាន់ឯណានីមួយតាំងតែពីដើមចូរលើកទុកសិនចុះ, តែថា វិបស្សនា ដែលជាវុដ្ឋានគាមិនីពិចារណាធម៌ណាៗ ហើយរមែងចេញចាកកិលេសដែលតាំងនៅក្នុងឋានដែលគួរពន្លុះដោយអំណាចនៃធម៌នោះៗឯង រមែងឱ្យឈ្មោះមគ្គរបស់ខ្លួន សេចក្តីនេះតើយ៉ាងណា ?

ក៏ព្រះយោគាវចរអាស្រ័យធម៌ណានីមួយ ក្នុងលក្ខណៈមានសេចក្តីមិនទៀងជាដើម ក៏សមគួរឃើញលក្ខណៈទាំង ២ ក្រៅនេះមែនពិត ។ ពិតណាស់ ធម្មតា

ការចេញចាកកិលេសដោយមគ្គត្រឹមតែការឃើញលក្ខណៈតែមួយនោះ រមែងមិនមាន. ព្រោះហេតុដូច្នោះ ភិក្ខុតាំងមាំហើយដោយសេចក្តីមិនទៀង រមែងចេញទៅ សូម្បីចាក (កិលេស) ដោយសេចក្តីជារបស់មិនទៀង, សូម្បីដោយសេចក្តីជាទុក្ខ តែម្យ៉ាងមិនបាន, រមែងចេញទៅចាក (កិលេស) ដោយសេចក្តីជាអនត្តានោះឯង; សូម្បីក្នុងសេចក្តីតាំងមាំនៅដោយសេចក្តីទុក្ខ ក៏ន័យនេះដែរ ។

ដោយប្រការដូច្នេះ ការប្រកាន់វត្ថុណានីមួយជាអារម្មណ៍តាំងតែពីដើមចូរលើកទុកសិនចុះ, ក៏វិបស្សនាដែលជាវុដ្ឋានគាមិនីពិចារណាធម៌ណា១ ហើយរមែងចេញទៅ, តាំងនៅក្នុងឋានដែលគួរពន្លុះ ដោយអំណាចនៃនោះ១ហើយឱ្យឈ្មោះមគ្គរបស់ខ្លួន ។ បណ្តាលក្ខណៈទាំងនោះ កាលបើព្រះយោគាវចរចេញចាកអនិច្ចលក្ខណៈមគ្គជាអនិមិត្ត; កាលបើចេញចាកទុក្ខលក្ខណៈ មគ្គក៏ជាអប្បណិហិតៈ, កាលបើចេញចាកអនត្តលក្ខណៈ មគ្គក៏ជាសុញ្ញតៈដូច្នេះ ទ្រង់នាំអនិមិត្តមគ្គមកសម្តែងតាមបរិយាយនៃព្រះសូត្រមានប្រការដូច្នេះ ។

**សួរថា** ក៏វិបស្សនាដែលជាវុដ្ឋានគាមិនីមានអ្វីជាអារម្មណ៍ ?

ឆ្លើយថា មានលក្ខណៈជាអារម្មណ៍ ។

ឈ្មោះថា **លក្ខណៈ**មានគតិជាបញ្ញត្តិ ជាធម៌ដែលមិនគួរពោលដល់ តែថាភិក្ខុណាកំណត់លក្ខណៈ ៣ គឺ **"អនិច្ចំ ទុក្ខំ អនត្តា"** , ខន្ធ ៥ របស់ភិក្ខុនោះ រមែងហាក់បីដូចជាសាកសពដែលចងត្រង់ក, ញាណមានសង្ខារជាអារម្មណ៍នោះឯង រមែងចេញទៅចាកសង្ខារ ។ ដូចយ៉ាងភិក្ខុមួយរូប ត្រូវការនឹងទិញបាត្រ ឃើញបាត្រដែលឈ្មួញបាត្រនាំមកហើយ ក៏មានសេចក្តីត្រេកអររីករាយដោយគិតថា

"យើងនឹងកាន់យកបាត្រ" ដូច្នេះ កាលបើពិចារណាមើល ទើបឃើញប្រហោងធ្លុះ ៣ កន្លែង ភិក្ខុនោះអស់សេចក្ដីអាល័យក្នុងប្រហោងធ្លុះទាំងឡាយក៏មិនមែន, ដោយពិត គឺអស់សេចក្ដីអាល័យក្នុងបាត្រយ៉ាងណា, ភិក្ខុកំណត់លក្ខណៈទាំង ៣ ហើយ ទើបជាអ្នកអស់សេចក្ដីអាល័យក្នុងសង្ខារទាំងឡាយយ៉ាងនោះដែរ, គប្បីជ្រាបថា វិបស្សនានោះ រមែងចេញទៅចាកសង្ខារ ដោយញាណមានសង្ខារជាអារម្មណ៍នោះឯងដូច្នេះ ។ **សូម្បីឧបមាដោយសំពត់** ក៏មានន័យដូចគ្នានេះដែរ ។

ព្រះមានព្រះភាគកាលបើចែកលោកុត្តរ ទើបទ្រង់នាំន័យសូម្បីទាំង ២ គឺ ចតុក្កន័យ និងបញ្ចកន័យ ពីសុទ្ធិកបដិបទាមកដោយប្រការដូច្នេះ ។ ក្នុងវិសុទ្ធិសុញ្ញតា ក្នុងសុញ្ញតបដិបទា ក្នុងសុទ្ធិកអប្បណិហិតៈ ក្នុងអប្បណិហិតបដិបទា ក៏ទ្រង់នាំន័យទាំង ២ គឺ ចតុក្កន័យនិងបញ្ចកន័យមកសម្ដែងទុកដូចគ្នាដែរ ។

**សួរថា** ព្រោះហេតុអ្វី ទើបទ្រង់នាំមកយ៉ាងនេះ ?

ឆ្លើយថា ព្រោះអធ្យាស្រ័យរបស់បុគ្គល និងព្រោះសេចក្ដីល្អនៃទេសនា ។ គប្បីជ្រាបសូម្បីន័យទាំងពីរនោះ ដោយន័យដែលពោលហើយក្នុងខាងក្រោយចុះ ។

ក្នុងពាក្យថា ចម្រើនលោកុត្តរជ្ឈាននេះ យ៉ាងនេះ ព្រះអង្គទ្រង់ចែកន័យទាំងពីរដោយអំណាចចតុក្កន័យ និងបញ្ចកន័យពីសុទ្ធិកបដិបទា, ក្នុងទីដ៏សេសក៏ដូចគ្នា ព្រោះហេតុដូច្នោះ ទើបចែកន័យទាំង ១០ ក្នុងចំណែកទាំងអស់ ៥ ។

ក្នុងលោកុត្តរជ្ឈាននោះ គប្បីជ្រាបធម្មបកិណ្ណកៈដូច្នេះ ៖

**ធម៌ខាងក្នុង (អជ្ឈត្តញ្ច), ធម៌ខាងក្រៅ (ពហិទ្ធា), ក្នុងរូប និងអរូបទាំង ៥, ការផ្លាស់អង្គ ៧ និង ៨, និមិត្ត, បដិបទា និងអធិបតិ ។**

ពិតណាស់ លោកុត្តរមគ្គ ភិក្ខុអាស្រ័យធម៌ខាងក្នុង រមែងចេញចាកធម៌ខាងក្នុង, អាស្រ័យធម៌ខាងក្នុងហើយរមែងចេញចាកធម៌ខាងក្រៅ, អាស្រ័យធម៌ខាងក្រៅហើយ រមែងចេញចាកធម៌ខាងក្រៅ, អាស្រ័យធម៌ខាងក្នុងហើយ រមែងចេញចាកធម៌ខាងក្នុង ។ ភិក្ខុអាស្រ័យរូបហើយរមែងចេញចាករូប ភិក្ខុអាស្រ័យរូបហើយរមែងចេញចាកអរូប, ភិក្ខុអាស្រ័យអរូបហើយរមែងចេញចាកអរូប, ភិក្ខុអាស្រ័យអរូបហើយរមែងចេញចាករូប រមែងចេញចាកខន្ធទាំងឡាយ ៥ ព្រមគ្នា ។

ពាក្យថា **អង្គមគ្គ ៧ និង ៨** អធិប្បាយថា ក៏មគ្គនោះឯងមានអង្គ ៨ ខ្លះមានអង្គ ៧ ខ្លះ សូម្បីពោជ្ឈង្គជា ៧ ក៏មាន ជា ៦ ក៏មាន ។ ឯឈានមានអង្គ ៥ ក៏មាន មានអង្គ ៤ ក៏មាន មានអង្គ ៣ ក៏មាន មានអង្គ ២ ក៏មាន, គប្បីជ្រាបការផ្លាស់អង្គមាន ៧ និង ៨ ជាដើមយ៉ាងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា **និមិត្ត, បដិបទា, និង អធិបតី** អធិប្បាយថា ពាក្យថា និមិត្តបានដល់ដែនជាទីចេញ ។ ពាក្យថា **បដិបទា និងអធិបតី** បានដល់ គប្បីជ្រាបសេចក្ដីញាប់ញ័រ និងមិនញាប់ញ័រនៃបដិបទា និងអធិបតីប៉ុណ្ណោះ ។

បណ្ដាពាក្យទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា **អាស្រ័យធម៌ខាងក្នុងហើយចេញចាកធម៌ខាងក្នុងនោះសិន** ។ ក៏ភិក្ខុរូបខ្លះ ក្នុងព្រះសាសនានេះ រមែងអាស្រ័យខន្ធ ៥ ដែលជាខាងក្នុងចាប់ផ្ដើមអំពីដើម លុះអាស្រ័យហើយរមែងឃើញខន្ធ ៥ ពួកនោះដោយសេចក្ដីជារបស់មិនទៀងជាដើម ដោយមនសិការថា "ភិក្ខុក្នុងធម្មវិន័យនេះ ខាងដើមរមែងចេញចាកធម៌ខាងក្នុង" តែព្រោះការចេញដោយមគ្គ រមែងមានត្រឹមតែការឃើញធម៌ខាងក្នុងសុទ្ធៗប៉ុណ្ណោះមិនបាន,

គប្បីឃើញសូម្បីធម៌ខាងក្រៅផង ព្រោះហេតុដូច្នោះ ទើបពិចារណាខន្ធរបស់អ្នកដទៃខ្លះ សង្ខារក្ខន្ធដែលមិនមានចិត្តគ្រប់គ្រងខ្លះថាជា **"អនិច្ចំ ទុក្ខំ អនត្តា"** ។ ភិក្ខុនោះរមែងពិចារណាឃើញធម៌ខាងក្នុងដោយកាលដ៏គួរ, រមែងពិចារណាធម៌ខាងក្រៅតាមកាលដ៏គួរ កាលបើលោកពិចារណាហើយយ៉ាងនេះ ក្នុងកាលដែលពិចារណាធម៌ខាងក្នុង រមែងផ្សារភ្ជាប់ជាមួយនឹងមគ្គ ដោយវិបស្សនា ។ ដោយអាការដូច្នេះ ឈ្មោះថា អាស្រ័យធម៌ខាងក្នុង ចេញចាកធម៌ខាងក្នុង ។ ក៏បើក្នុងវេលាពិចារណាធម៌ខាងក្រៅរបស់លោក រមែងផ្សារភ្ជាប់ជាមួយមគ្គដោយវិបស្សនា, ដោយអាការយ៉ាងនេះ ឈ្មោះថា **អាស្រ័យធម៌ខាងក្នុង រមែងចេញចាកធម៌ខាងក្រៅ ។ សូម្បីក្នុងការចេញ ព្រោះអាស្រ័យធម៌ខាងក្រៅហើយ រមែងចេញចាកធម៌ខាងក្រៅ និងធម៌ខាងក្នុង ក៏ន័យនេះដែរ** ។

ក៏ភិក្ខុមួយរូបទៀត រមែងអាស្រ័យរូបតាំងពីដើម, លុះអាស្រ័យហើយ ក៏កំណត់ភូតរូប និងឧបាទាយរូប រមែងឃើញដោយសេចក្ដីមិនទៀងជាដើម ។ តែព្រោះការចេញដោយមគ្គ រមែងមានត្រឹមតែការឃើញរូបសុទ្ធៗក៏មិនមែន, គប្បីឃើញសូម្បីអរូបដោយពិត ។ ព្រោះហេតុដូច្នោះ ភិក្ខុនោះធ្វើរូបនោះឱ្យជាអារម្មណ៍ហើយ កំណត់វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលកើតឡើងហើយថា "នេះជាអរូប" ដូច្នេះ រមែងឃើញដោយសេចក្ដីមិនទៀងជាដើម, ភិក្ខុនោះពិចារណាឃើញរូបដោយកាលដ៏គួរ, ឃើញអរូបដោយកាលដ៏គួរ ។ កាលបើលោកពិចារណាហើយយ៉ាងនេះ ក្នុងការពិចារណារូប រមែងផ្សារភ្ជាប់ជាមួយនឹងមគ្គដោយវិបស្សនា ដោយអាការយ៉ាងនេះ ឈ្មោះថា **អាស្រ័យរូបហើយ រមែងចេញចាករូប** ។ ក៏

បើក្នុងការពិចារណាអរូបរបស់លោក រមែងផ្សារភ្ជាប់ជាមួយនឹងមគ្គវិបស្សនា, ដោយអាការយ៉ាងនេះ ឈ្មោះថា **អាស្រ័យរូបហើយរមែងចេញចាក** ។ **សូម្បីក្នុងការចេញចាកអរូប និងរូបព្រោះអាស្រ័យអរូប** ក៏មានន័យដូចគ្នានេះដែរ ។ ក៏ក្នុងកាលដែលភិក្ខុអាស្រ័យធម៌យ៉ាងនេះថា "ធម្មជាតិណានីមួយមានការកើតឡើងជាធម្មតា, ធម្មជាតិនោះទាំងអស់ មានការរលត់ជាធម្មតា"[៣០] ដូច្នេះ ហើយចេញទៅចាក (សង្ខតៈ) ធម៌យ៉ាងនេះនោះដែរ ឈ្មោះថា **រមែងចេញចាកខន្ធ ៥ ព្រមគ្នាតែម្តង** ។ នេះជាវិបស្សនារបស់ភិក្ខុអ្នកមានបញ្ញាច្រើន អ្នកឃើញច្បាស់ដោយបញ្ញាដ៏ចាស់ក្លា ។

ដូចយ៉ាងថា បុគ្គលដាក់ដុំលាមកត្រង់កណ្តាលភោជនហើយ បង្អោនថាសដែលពេញដោយភោជនមានរសដ៏ឆ្ងាញ់ផ្សេងៗ ទៅឱ្យបុរសអ្នកមានសេចក្តីស្រេកឃ្លាន ។ បុរសអ្នកមានសេចក្តីស្រេកឃ្លាននោះ យកដៃកាយម្ហូបចេញឃើញដុំលាមក នោះហើយពោលថា "នេះអ្វី" កាលបើគេពោលថា "ដុំលាមក" ដូច្នេះ ទើបពោលថា "ថ្វើយៗ, ចូរយកចេញទៅ" ជាអ្នកអស់សេចក្តីអាល័យទាំងក្នុងអាហារទាំងក្នុងថាសយ៉ាងណា, ពាក្យឧបមាដែលនាំមកប្រៀបធៀបនេះ គប្បីជ្រាបដូច្នោះដែរ ។

ពិតណាស់ កាលដែលភិក្ខុនេះប្រកាន់ខន្ធ ៥ ថាជាយើង របស់យើង ក្នុងកាលដែលនៅជាបុថុជ្ជន, គប្បីជ្រាបដូចកាលដែលបុរសស្រេកឃ្លាននោះ មានចិត្តរីករាយក្នុងការឃើញថាសភោជន, កាលដែលកំណត់លក្ខណៈ ៣ គប្បីជ្រាបដូច

---

[៣០] វិនយ. មហាវគ្គ ៦ ។

បុរសនោះឃើញដុំលាមក ។ កាលដែលភិក្ខុអ្នកមានបញ្ញាច្រើន អ្នកមានសេចក្ដីឃើញច្បាស់ដោយបញ្ញាដ៏ក្លៀវក្លាយល់ថា វត្ថុណានីមួយមានការកើតឡើងជាធម្មតា, វត្ថុនោះទាំងអស់ សុទ្ធតែមានការរលត់ទៅវិញជាធម្មតា" ដូច្នេះ ហើយចេញចាកខន្ធ ៥ ព្រមគ្នានោះឯង គប្បីជ្រាបដូចកាលបុរសស្រេកឃ្លាននោះ អស់សេចក្ដីអាល័យទាំងក្នុងភោជន ទាំងក្នុងថាសដូច្នោះដែរ ។

ក្នុងពាក្យថា **ការផ្លាស់អង្គមគ្គ ៧ និង ៨** នេះ គប្បីជ្រាបការផ្លាស់អង្គធម៌មានប្រភេទដែលពោលនេះដោយប្រការដែលមានហើយ។ ពិតណាស់ សង្ខារុបេក្ខាញាណប៉ុណ្ណោះ រមែងកម្មាត់សេចក្ដីផ្សេងគ្នានៃពោជ្ឈង្គ (អង្គធម៌ជាគ្រឿងត្រាស់ដឹង) អង្គមគ្គ (**មគ្គង្គ**) និងអង្គឈាន (**ឈានង្គ**) ។ តែព្រះថេរៈពួកខ្លះពោលថា "ឈានដែលជាបាទ រមែងកំណត់សេចក្ដីផ្សេងគ្នានៃពោជ្ឈង្គ អង្គមគ្គ និងអង្គឈាន" ដូច្នេះ, ព្រះថេរៈពួកខ្លះពោលថា ខន្ធទាំងឡាយដែលជាអារម្មណ៍របស់វិបស្សនារមែងកំណត់ ។ ព្រះថេរពួកខ្លះពោលហៅថា "អធ្យាស្រ័យរបស់បុគ្គល រមែងកំណត់" ។

សូម្បីក្នុងវាទៈទាំងឡាយរបស់ព្រះថេរៈទាំងនោះ គប្បីជ្រាបថា វិបស្សនាដែលជាបុព្វភាគពោលគឺសង្ខារុបេក្ខាញាណ និងវិបស្សនាដែលជាវុដ្ឋានគាមិនីនេះរមែងកំណត់ក្នុងសេចក្ដីនេះ មានពាក្យពេចន៍តាមលំដាប់ដូច្នេះ ៖

ពិតមែនហើយ ពោលដោយការកំណត់អត្ថនៃវិបស្សនា មគ្គដែលកើតឡើងដល់ព្រះសុខវិបស្សកៈក្ដី, មគ្គដែលកើតឡើងដល់បុគ្គលអ្នកមានសមាបត្តិដែលធ្វើ

ឈានឱ្យជាបាទក្តី, មគ្គដែលកើតឡើងព្រោះធ្វើបឋមជ្ឈានឱ្យជាបាទ តែពិចារណាបកិណ្ណកសង្ខារក្តី រមែងជាមគ្គប្រកបដោយបឋមជ្ឈានទាំងអស់ ក្នុងមគ្គចិត្តទាំងអស់ មានពោជ្ឈង្គ ៧ មគ្គមានអង្គ ៨ និងអង្គឈាន ៥ ។ ព្រោះថា សូម្បីវិបស្សនាដែលជាបុព្វភាគនៃមគ្គនោះជាសភាវៈសហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ តែក្នុងកាលជាទីចេញទៅ (វុដ្ឋានគាមិនីវិបស្សនា) ដល់សេចក្តីជាសង្ខារុបេក្ខាញាណ រមែងសហគតៈដោយសោមនស្សតែប៉ុណ្ណោះ ។

ក្នុងបញ្ចកន័យ ឈានក្នុងមគ្គដែលកើតឡើងព្រោះធ្វើទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានឱ្យជាបាទ មានអង្គ ៤ អង្គ ៣ អង្គ ២ ដោយលំដាប់នោះឯង, ក៏សូម្បីក្នុងមគ្គទាំងអស់ រមែងមានអង្គ ៧, ក្នុងឈានទី ៤ មានពោជ្ឈង្គ ៦ ។ នេះជាសេចក្តីផ្សេងគ្នាដោយការកំណត់ធ្វើឈានឱ្យជាបាទ និងដោយការកំណត់នៃវិបស្សនា, ព្រោះវិបស្សនាដែលជាបុព្វភាគនៃមគ្គទាំងនោះ សហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ, តែវិបស្សនាដែលជាវុដ្ឋានគាមិនីជាធម៌សហគតៈដោយសោមនស្សតែម្យ៉ាង ។

ចំណែកក្នុងមគ្គដែលព្រះយោគាវចរធ្វើបឋមជ្ឈានឱ្យបានជាបាទ ហើយឱ្យកើតឡើង អង្គឈានមាន ២ ដោយអំណាចនៃឧបេក្ខា និងឯកគ្គតាចិត្ត, បានពោជ្ឈង្គ ៦ មគ្គមានអង្គ ៧ ប៉ុណ្ណោះ ។ សូម្បីសេចក្តីប្លែកគ្នានេះ រមែងមានដោយអំណាចនៃការកំណត់ទាំង ២ យ៉ាង ។ ព្រោះក្នុងន័យនេះ វិបស្សនាដែលជាបុព្វភាគរមែងសហគតៈដោយសោមនស្ស ឬសហគតៈដោយឧបេក្ខា, វិបស្សនាដែលជាវុដ្ឋានគាមិនី សហគតៈដោយឧបេក្ខាប៉ុណ្ណោះ សូម្បីក្នុងមគ្គដែលព្រះយោគាវចរធ្វើ

អរូបជ្ឈាន ឱ្យជាបាទហើយឱ្យកើតឡើង ក៏ន័យនេះដែរ ។ សមាបត្តិដែលព្រះយោគាវចរចេញក្នុងចំណែកដ៏ជិតនៃមគ្គដែលលោកចេញចាកឈាន ជាបាទដោយអាការយ៉ាងនេះ ហើយពិចារណាសង្ខារយ៉ាងណានីមួយឱ្យកើតហើយ រមែងធ្វើភាវៈហាក់បីដូចជាដល់ខ្លួន, ដូចពណ៌ផ្ទៃដីធ្វើសម្បុរនៃសត្វទន្សងឱ្យមានពណ៌ដូចគ្នាដែរ ។

តែក្នុងវាទៈរបស់ព្រះថេរៈរូបទី ២ មានអធិប្បាយថា មគ្គដែលព្រះយោគាវចរចេញចាកសមាបត្តិណាៗ ហើយពិចារណាក្នុងសមាបត្តិណាៗ កើតឡើង, មគ្គក៏ដូចជាសមាបត្តិនោះដែរ, គឺដូចនឹងសមាបត្តិដែលលោកពិចារណាហើយ ។ ក៏បើលោកពិចារណាធម៌ដែលជាកាមាវចរទាំងឡាយ មគ្គក៏ជាការប្រកបដោយបឋមជ្ឈាន ។ គប្បីជ្រាបការកំណត់សូម្បីវិបស្សនានេះ ដោយន័យដែលពោលហើយ ក្នុងវាទៈនោះចុះ ។

ក៏ក្នុងវាទៈរបស់ព្រះថេរៈរូបទី ៣ មានអធិប្បាយថា មគ្គដែលព្រះយោគាវចរធ្វើឈានណាៗ ឱ្យជាបាទ ឬពិចារណាធម៌ណាៗ ក្នុងឈានសមគួរដល់អធ្យាស្រ័យរបស់ខ្លួនថា “ឱហ្ន៎ យើងគប្បីពន្លុះមគ្គប្រកបដោយអង្គ ៧, ឬអង្គ ៨” ដូច្នេះហើយឱ្យកើតឡើង, មគ្គក៏ហាក់ដូចនឹងឈាននោះៗដែរ ។ ក៏ប៉ុន្តែថា មគ្គនោះវៀរឈានដែលជាបាទ ឬឈានដែលពិចារណាហើយ រមែងមិនសម្រេចដោយហេតុត្រឹមតែអធ្យាស្រ័យម្យ៉ាងទេ ។ សេចក្ដីនេះឯង បណ្ឌិតគប្បីសម្ដែងដោយ **នន្ទកោវាទសូត្រ** (ក្នុងមជ្ឈិមនិកាយសឡាយតនវគ្គ) ។

មែនពិត ព្រះតម្រាស់នេះ ព្រះមានព្រះភាគត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថ ១៥ កើតនោះ ជនជាច្រើនមិនមានសេចក្ដីងឿងឆ្ងល់ ឬ

សង្ស័យថា "ដួងចន្ទខ្វះ ឬពេញហ្ន៎ តែដែលពិតទៅតែងសម្គាល់ថា ដួងចន្ទពេញហើយ" តែម្តងយ៉ាងណា; ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងនោះជាអ្នកពេញចិត្តធម្មទេសនារបស់នន្ទកៈ និងមានសេចក្តីត្រិះរិះពេញបរិបូរណ៍ហើយយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុនីទាំង ៥០០ នោះ នាង (ភិក្ខុនី) ដែលទ្រទ្រង់គុណដ៏ទាបគង់ជាសោតាបន្ន, មានសេចក្តីមិនធ្លាក់ចុះជាធម្មតា ពិតតែនឹងត្រាស់ដឹងក្នុងកាលខាងមុខមិនខានឡើយ" ។

បណ្តាភិក្ខុនីទាំងនោះ ភិក្ខុនីរូបណាមានឧបនិស្ស័យនៃសោតាបត្តិផល, ភិក្ខុនីរូបនោះ ក៏បានមានសេចក្តីត្រិះរិះ (សង្កប្បៈ) បរិបូរណ៍ហើយដោយសោតាបត្តិផលប៉ុណ្ណោះ ។ ល ។ រូបណាមានឧបនិស្ស័យនៃព្រះអរហត្ត, រូបនោះក៏មានសេចក្តីត្រិះរិះបរិបូរណ៍ហើយដោយព្រះអរហត្តប៉ុណ្ណោះ ។

មគ្គដែលព្រះយោគាវចរណា។ ធ្វើឈានឱ្យជាបាទ ឬពិចារណាធម៌ ក្នុងឈានណា។ ដោយសមគួរដល់អធ្យាស្រ័យរបស់ខ្លួនកើតឡើងហើយយ៉ាងនោះឯង, រមែងហាក់បីដូចជានឹងឈាននោះដែរ ។ ក៏មគ្គដែលហាក់បីដូចនឹងឈាននោះ។ វៀរឈានដែលជាបាទ ឬវៀរឈានដែលពិចារណាហើយ រមែងមិនសម្រេចដោយគ្រាន់តែជាអធ្យាស្រ័យប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ គប្បីជ្រាបការកំណត់វិបស្សនាដោយន័យដែលពោលហើយក្នុងវាទៈនេះចុះ ។

បណ្តាវាទៈនៃព្រះថេរៈទាំងនោះ **ព្រះចូឡនាគត្ថេរលោកទ្រទ្រង់ព្រះត្រ័យបិដក** (តិបិដកចូឡនាគត្ថេរ) មានវាទៈយ៉ាងនេះថា "ឈានដែលជាបាទប៉ុណ្ណោះរមែងកំណត់" ដូច្នេះ បានត្រូវអន្តេវាសិកសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុង

ទីណាដែលមានឈានជាបាទនៅមុន, ក្នុងទីនោះឈានដែលជាបាទនោះ ក៏កំណត់បាន ។ តែក្នុងទីណា (អរូបភព) ឈានដែលជាបាទមិនមាន, ក្នុងទីអរូបភពនោះ អ្វីទៅរមែងកំណត់ ?; ព្រះថេរៈឆ្លើយថា "ម្នាលអាវុសោ សូម្បីក្នុងទីនោះ ឈានដែលជាបាទប៉ុណ្ណោះ ក៏រមែងកំណត់ ព្រោះថា ភិក្ខុណាបានសមាបត្តិ ៨ ធ្វើបឋមជ្ឈានឱ្យជាបាទ ញ៉ាំងសោតាបត្តិមគ្គ និងផល ឱ្យកើតឡើងហើយ ជាអ្នកមានឈានមិនវិនាស ធ្វើកាលៈ (ចុតិ) ហើយកើតក្នុងអរូបភព, ចេញចាកសមាបត្តិនៃសោតាបត្តិផលដែលប្រកបដោយបឋមជ្ឈាន ផ្ដើមតាំងវិបស្សនាញ៉ាំងមគ្គ និងផល ៣ ខាងលើឱ្យកើតឡើង, មគ្គ និងផលទាំងនោះរបស់លោក ក៏ប្រកបដោយបឋមជ្ឈានប៉ុណ្ណោះ, សូម្បីក្នុងមគ្គផលដែលប្រកបដោយទុតិយជ្ឈានជាដើម ក៏ន័យនេះដែរ ។ ឈានដែលជាពួក ៣ និងពួក ៤ ក្នុងអរូបរមែងកើតឡើង, ក៏ឈានពួក ៣ និងពួក ៤ នោះឯងជាលោកុត្តរ, មិនមែនជាលោកិយទេ ។ ម្នាលអាវុសោ សូម្បីដោយអាការយ៉ាងនេះក៏ដូចគ្នាដែរ ឈានដែលជាបាទប៉ុណ្ណោះ រមែងកំណត់" ។ ពួកអន្តេវាសិកពោលថា "បពិត្រលោកម្ចាស់ បញ្ហាលោកពោលល្អហើយ" ។

**សូម្បីព្រះមហាទត្តត្ថេរលោកនៅត្រង់មោរវាបីវិហារ** មានវាទៈយ៉ាងនេះថា "ខន្ធទាំងឡាយដែលជាអារម្មណ៍របស់វិបស្សនារមែងកំណត់ ព្រោះថាពិចារណាបញ្ចក្ខន្ធណា១ ហើយទើបចេញ, មគ្គបាក់បីដូចជាធមិន្ទុំះដែរ" ត្រូវពួកអន្តេវាសិកសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងវាទៈរបស់លោក ខគួរដំណិះរមែងប្រាកដ, ព្រោះថា ភិក្ខុអ្នកពិចារណារូបហើយទើបចេញ (ចាកសង្ខតារម្មណ៍) បាន មគ្គក៏គប្បីជាអព្យាកតៈដូចរូបដែរ, ព្រះយោគាវចរកំណត់នេវសញ្ញានាសញ្ញា

យតនៈដោយន័យហើយទើបចេញទៅ ក៏គប្បីជាមគ្គដល់សភាពជានេវសញ្ញានាសញ្ញាយតនៈ ដូចគ្នានឹងនេវសញ្ញានាសញ្ញាយតនៈនោះដែរ” ព្រះថេរៈឆ្លើយថា “ម្នាលអាវុសោ ដូចនោះមិនបានទេ, ព្រោះលោកុត្តរមគ្គឈ្មោះថា មិនដល់**អប្បនា** មិនបានមាន (ត្រូវតែដល់) ព្រោះហេតុដូច្នោះ ភិក្ខុពិចារណារូបហើយចេញទៅបានមគ្គប្រកបដោយអង្គ ៨ រមែងសហគតៈដោយសោមនស្ស, កាលបើពិចារណានេវសញ្ញានាសញ្ញាយតនៈហើយ សូម្បីចេញទៅបានដូច្នោះ ដោយអាការទាំងពួងមិនបាន, ចំណែកមគ្គដែលសហគតៈដោយឧបេក្ខា រមែងជាមគ្គមានអង្គ ៧” ។

សូម្បី**ព្រះចូឡាភយត្ថេរ** លោកទ្រទ្រង់ព្រះត្រ័យបិដក (តិបិដកចូឡាភយត្ថេរ) ដែលមានវាទៈថា “អធ្យាស្រ័យនៃបុគ្គលរមែងកំណត់” បានត្រូវពួកអន្តេវាសិកនាំវាទៈរបស់លោកទៅសួរចូឡនាគត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ។ ព្រះចូឡនាគត្ថេរទើបពោលថា “ឈានដែលជាបាទតែងមានដល់បុគ្គលណា, អធ្យាស្រ័យបុគ្គលរមែងកំណត់ដល់បុគ្គលនោះ ។ ឈានដែលជាបាទនោះមិនមានដល់ភិក្ខុណា, អធ្យាស្រ័យអ្វីទៅនឹងកំណត់ដល់ភិក្ខុនោះ, ព្រោះហេតុដូច្នោះ សភាវៈនោះ រមែងហាក់បីដូចជាវេលាស្វែងរកកម្រៃរបស់បុគ្គលឥតទ្រព្យដូច្នោះដែរ ។

ពួកអន្តេវាសិក បាននាំរឿងនោះមកប្រាប់ដល់ព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក, ព្រះថេរៈនោះពោលថា “ម្នាលអាវុសោទាំងឡាយ ពាក្យសម្តីនេះលោកពោលសម្រាប់បុគ្គលអ្នកមានឈានជាបាទ” ។ ដូចយ៉ាងថា អធ្យាស្រ័យរបស់បុគ្គលសូម្បីអ្នកមានឈានជាបាទយ៉ាងណា, សូម្បីបុគ្គលអ្នកមានឈានដែលពិចារណាហើយ ក៏គប្បីជ្រាបយ៉ាងនោះដែរ ។ ព្រោះមគ្គដែលបុគ្គលចេញចាក

បឋមជ្ឈានហើយកើតឡើង ដោយពិចារណាបឋមជ្ឈានជាដើម ជាមគ្គប្រកប ដោយបញ្ចមជ្ឈាន ក៏រមែងស្របតាមវាទៈរបស់ព្រះថេរៈរូបដំបូង, ឯមគ្គដែល ប្រកបដោយបឋមជ្ឈានជាដើម ក៏រមែងស្របតាមវាទៈរបស់ព្រះថេរៈរូបទី ២ ព្រោះហេតុនោះ សូម្បីវាទៈទាំងពីររមែងខុស; តែឈានពួកនេះ ក្នុងវាទៈរបស់ ព្រះថេរៈទី ៣ ថា ព្រះយោគាវចររមែងប្រាថ្នាឈានណា មគ្គក៏ប្រកបដោយឈាន នោះ ព្រោះហេតុដូច្នោះ វាទៈទាំងនោះរបស់លោកទើបមិនខុស, ឯភិក្ខុនោះ ក៏ជា អ្នកមានអធ្យាស្រ័យប្រព្រឹត្តទៅមួយអន្លើដោយប្រយោជន៍ដូច្នេះ ។ សូម្បីព្រះថេរៈ ទាំង ៣ រូប ជាបណ្ឌិត ជាអ្នកឆ្លាត ជាអ្នកសម្បូរណ៏ដោយគុណធម៌ដ៏ច្រើន, ដោយ ហេតុនោះ អន្តេវាសិកទាំងនោះ ទើបធ្វើវាទៈរបស់ព្រះថេរៈទាំង ៣ ពួកនោះ ឱ្យ ជាបែបផែន ។ ក៏ក្នុងអភិធម្មនេះ ខ្ញុំទើបលើកអត្ថនោះឯងសម្តែងឡើងថា ក៏ វិបស្សនារមែងកំណត់វាទៈទាំង ៣ នេះដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **និមិត្តប្បដិបទាបតី** (និមិត្ត + បដិបទា + អធិបតី) តទៅ ៖

**សួរថា** កាលកើតឡើងនៃមគ្គដែលផ្លាស់អង្គយ៉ាងនេះ គោត្រភូរមែងចេញ ទៅពីទីណា, មគ្គរមែងចេញពីទីណា ? ឆ្លើយថា គោត្រភូរមែងចេញចាកនិមិត្ត មុន, តែមិនអាចកាត់ (កិលេស) ដែលប្រព្រឹត្តទៅបាន ។ ព្រោះគោត្រភូនោះ មាន ការចេញទៅតែម្យ៉ាង ។ មគ្គរមែងចេញចាកនិមិត្ត, រមែងកាត់ (កិលេស) ដែល ប្រព្រឹត្តទៅបាន ។ ព្រោះមគ្គនេះមានការចេញទៅ ២ យ៉ាង ។ បណ្តាការចេញទៅ នៃគោត្រភូ និងមគ្គនោះ គប្បីជ្រាបន័យដែលកើតឡើងដូចតទៅនេះ ៖

ក៏ក្នុងវារៈ (គឺក្នុងមគ្គវីថិ) ណា មានការចេញទៅដោយមគ្គ, ក្នុងវារៈនោះ មិនមានអនុលោមតែមួយដួង, មិនមានអនុលោមដួងទី ៥ ទេ ។ ព្រោះអនុលោមមានតែមួយដួង រមែងមិនបានអាសេវនប្បច្ច័យ, អនុលោមដួងទី ៥ រមែងញាប់ញ័រ ព្រោះជិតធ្លាក់ចុះកាន់ភវង្គ ។ ព្រោះថា ក្នុងគ្រា (ខណៈ) ជវនជិតភវង្គដួងទី ៥ នោះ ឈ្មោះថា ចិត្តធ្លាក់ទៅហើយ, ព្រោះហេតុដូច្នោះ អនុលោមទើបមានតែមួយដួង, មិនមានដួងទី ៥ ទេ ។ ក៏បុគ្គលអ្នកមានបញ្ញាច្រើនមានអនុលោម ២ ដួង ។ ដួង ទី ៣ ជាគោត្រភូ, ដួងទី ៤ ជាមគ្គចិត្ត, មានផលចិត្ត ៣ ដួង, តពីនោះ ចិត្តចុះកាន់ភវង្គ ។

ចំណែកបុគ្គលអ្នកមានបញ្ញាកណ្ដាលអនុលោមមាន ៣ ដួង, ដួងទី ៤ ជាគោត្រភូ, ដួងទី ៥ ជាមគ្គចិត្ត, មានផលចិត្ត ២ ដួង, តពីនោះ ចិត្តក៏ចុះកាន់ភវង្គ ។

សម្រាប់បុគ្គលអ្នកមានបញ្ញាតិច (មន្ទប្បញ្ញា) អនុលោមមាន ៤ ដួង ដួងទី ៥ ជាគោត្រភូ, ដួងទី ៦ ជាមគ្គចិត្ត, ដួងទី ៧ ជាផលចិត្ត, តពីនោះ ចិត្តក៏ចុះកាន់ភវង្គ ។

បណ្ដាព្រះយោគាវចរ ៣ ប្រភេទនោះ ខ្ញុំមិនពោលដោយអំណាចនៃលោកអ្នកមានបញ្ញាច្រើន និងមានបញ្ញាតិចទេ តែគប្បីពោលដោយអំណាចនៃលោកអ្នកមានបញ្ញាជាកណ្ដាល ។ ព្រោះក្នុងវារៈ គឺ (វិថីនៃមគ្គ) ណា មានការចេញទៅដោយមគ្គ, មនោវិញ្ញាណធាតុជាអហេតុកកិរិយា ជាធម៌សហគតៈដោយឧបេក្ខា ជាមនោទ្វារាវជ្ជនចិត្តឱ្យភវង្គឃ្លាតទៅ ព្រោះធ្វើខន្ធទាំងឡាយដែលជាអារម្មណ៍នៃវិបស្សនាឱ្យជាអារម្មណ៍ ក្នុងវារៈ គឺ (វីថិនៃមគ្គ) នោះ ។ ផុតពីនោះទៅ ជវនដួង

ដំបូងឈ្មោះ **អនុលោមញ្ញាណ** ក៏កើតឡើងកាន់យកខន្ធដែលមនោទ្វារាវជ្ជនចិត្តនោះ កាន់យកអារម្មណ៍ហើយ, អនុលោមញ្ញាណនោះ ក៏ប្រព្រឹត្តទៅក្នុងខន្ធពួកនេះថា "មិនទៀង" ខ្លះ "ជាទុក្ខ" ខ្លះ "ជាអនត្តា" ខ្លះ បន្ទោបង់សេចក្ដីងងឹត ដែលគ្រោតគ្រាត១ ដែលបិទបាំងសច្ចៈ ធ្វើលក្ខណៈទាំង ៣ ឱ្យជាក់ច្បាស់ក្រៃលែងឡើងហើយក៏រលត់ទៅ ។ បន្ទាប់ពីនោះ អនុលោមញ្ញាណ ដួងទី ២ ក៏កើតឡើង ។ បណ្ដាអនុលោមញ្ញាណ ២ ដួងនោះ ដួងដំបូងមិនមានអាសេវនប្បច្ច័យទេ ដួងទី ២ មានដួងដំបូងជាអាសេវនប្បច្ច័យ, ដួងទី ២ នោះមានអាសេវនប្បច្ច័យបានហើយ ទើបជាញាណចាស់ក្លា ផូរផង់ ប្រព្រឹត្តទៅក្នុងអារម្មណ៍នោះនុ៎ះឯង ដោយអាការនោះដូចគ្នា បន្ទោបង់សេចក្ដីងងឹតថ្នាក់កណ្ដាលដែលបិទបាំងសច្ចៈទុកហើយធ្វើលក្ខណៈ ៣ ឱ្យជាក់ច្បាស់ក្រៃលែងឡើងហើយរលត់ទៅ, លំដាប់នោះ អនុលោមញ្ញាណដួងទី ៣ ក៏កើតឡើង មានអនុលោមញ្ញាណដួងទី ២ ជាអាសេវនប្បច្ច័យ ដល់អនុលោមញ្ញាណទី ៣ នោះ ។ សូម្បីអនុលោមញ្ញាណទី ៣ នោះ ព្រោះមានអាសេវនប្បច្ច័យបានហើយ ទើបចាស់ក្លា ផូរផង់ ប្រព្រឹត្តទៅក្នុងអារម្មណ៍នុ៎ះឯង ដោយអាការនោះដូចគ្នាហើយ បន្ទោបង់សេចក្ដីដ៏ល្អិតដ៏សេស ដែលបិទបាំងសច្ចៈនោះ ធ្វើឱ្យអស់ទៅហើយ ធ្វើលក្ខណៈ ៣ ជាក់ច្បាស់ក្រៃលែង១ ឡើង ហើយរលត់ទៅ ។ កាលបើអនុលោមញ្ញាណ ៣ បន្ទោបង់សេចក្ដីងងឹត ដែលបិទបាំងសច្ចៈយ៉ាងនេះហើយ លំដាប់នោះ គោត្រភូញាណក៏កើតឡើងធ្វើព្រះនិព្វានឱ្យជាអារម្មណ៍ ។

ក្នុងខនេះ មានសេចក្ដីឧបមាដូច្នេះ ÷

បានឮថា បុរសមានចក្ខុល្អម្នាក់គិតថា “យើងនឹងដឹងនូវការប្រកបនៃនក្ខត្តឫក្ស (មើលដួងជតា)” ទើបចេញទៅក្នុងវេលារាត្រីហើយងើយមើលដួងព្រះចន្ទ, ដួងព្រះចន្ទមិនប្រាកដដល់គេ ព្រោះ **វលាហកៈ** (ពពក) ទាំងឡាយបិទបាំងទុក ។ ខណៈនោះខ្យល់មួយតាំងឡើងហើយផាត់វលាហកៈក្រាស់ៗ (គ្រោតគ្រាត) ទាំងឡាយ ឱ្យខ្ចាត់ខ្ចាយទៅ, ខ្យល់ដទៃទៀតតាំងឡើងផាត់វលាហកៈយ៉ាងកណ្ដាល, ខ្យល់មួយទៀត ក៏តាំងឡើងផាត់វលាហកៈសូម្បីដែលល្អិត ឱ្យខ្ចាត់ខ្ចាយទៅ ។ លំដាប់នោះ បុរសនោះទើបឃើញដួងចន្ទនោះលើផ្ទៃអាកាស ដែលប្រាសចាកវលាហកៈទាំងឡាយបានដឹងហើយនូវការប្រកបនក្ខត្តឫក្ស ។

ក្នុងពាក្យឧបមាទាំងនោះ សេចក្ដីងងឹត គឺកិលេសយ៉ាងគ្រោតគ្រាត យ៉ាងកណ្ដាល យ៉ាងល្អិត ដែលបិទបាំងនូវសច្ចៈ ប្រៀបដូចវលាហកៈ (ពពក) ៣ ស្រទាប់, អនុលោមចិត្ត ៣ ដួង ប្រៀបដូចខ្យល់ ៣ ប្រភេទ, គោត្រភូញាណ ប្រៀបដូចបុរសអ្នកមានភ្នែកល្អ, ព្រះនិព្វានប្រៀបដូចព្រះចន្ទ, ការបន្ទោបង់សេចក្ដីងងឹតដែលបិទបាំងសច្ចៈរបស់អនុលោមចិត្តតែគ្រប់ដួង ប្រៀបដូចខ្យល់តែគ្រប់ប្រភេទទម្លាយពពក ៣ ស្រទាប់ដោយលំដាប់, កាលបើសេចក្ដីងងឹតដែលបិទបាំងសច្ចៈប្រាសចាកទៅហើយ គោត្រភូញាណក៏ធ្វើព្រះនិព្វានដ៏បរិសុទ្ធឱ្យជាអារម្មណ៍ ប្រៀបដូចកាលដែលបុរសនោះឃើញព្រះចន្ទដ៏បរិសុទ្ធលើផ្ទៃអាកាសដែលប្រាសចាកពពកដូច្នោះ ។

ដូចយ៉ាងថា ខ្យល់ ៣ ប្រភេទ រមែងអាចដើម្បីកម្ចាត់វលាហកៈ ដែលបិទបាំងដួងចន្ទនោះឯង គឺមិនអាចឱ្យបុរសឃើញព្រះចន្ទបាន យ៉ាងណា, អនុលោមញាណទាំងឡាយ ក៏អាចដើម្បីកម្ចាត់សេចក្ដីងងឹតដែលបិទបាំងសច្ចៈយ៉ាងនោះដែរ,

តែមិនអាចធ្វើព្រះនិព្វានឱ្យជាអារម្មណ៍បាន ។ បុរសរមែងអាចដើម្បីឃើញដួងចន្ទនោះដែរ, តែមិនអាចកម្ចាត់វលាហកៈទាំងឡាយបានយ៉ាងណា, គោត្រភូញាណ ក៏រមែងអាចធ្វើព្រះនិព្វានទុំះឯង ឱ្យជាអារម្មណ៍បាន, តែមិនអាចកម្ចាត់សេចក្តីងងឹតគឺកិលេសបានយ៉ាងនោះដែរ ។ អនុលោមញ្ញាណមានសង្ខារជាអារម្មណ៍, គោត្រភូញាណមានព្រះនិព្វានជាអារម្មណ៍ដោយអាការយ៉ាងនេះ ។ ក៏ប្រសិនបើគោត្រភូញាណ គប្បីទទួលអារម្មណ៍ដែលអនុលោមញ្ញាណទទួលទុកហើយ, អនុលោមញ្ញាណមួយដួងទៀត ក៏គប្បីជាប់តាមគោត្រភូញាណ (គឺមានអារម្មណ៍ជាមួយគ្នា) នោះព្រោះហេតុដូច្នោះ ការចេញដោយមគ្គទុំះឯង ក៏មិនគប្បីមាន ។ តែថា គោត្រភូញាណ មិនទទួលអារម្មណ៍របស់អនុលោមញ្ញាណហើយ ធ្វើអនុលោមញ្ញាណារម្មណ៍នោះឱ្យប្រព្រឹត្តទៅខាងក្រោយគោត្រភូញាណខ្លួនឯង សូម្បីមិនមែនជាអាវជ្ជនៈ តែក៏តាំងនៅក្នុងឋាននៃអាវជ្ជនៈ ហាក់ដូចជាឱ្យសញ្ញាដល់មគ្គនោះ ដោយពាក្យថា "លោកចូរកើតឡើងយ៉ាងនេះ ហើយក៏រលត់ទៅ" , សូម្បីមគ្គក៏មិនបានលះសញ្ញាដែលគោត្រភូនោះឱ្យហើយ ជាប់តាមទៅនូវញ្ញាណនោះ ដោយអំណាចនៃសេចក្តីបន្តដូចជាក្រសែរលក (ជាប់តគ្នាទៅមិនដាច់រយៈ) រមែងកើតឡើងចាក់ទម្លុះកិនទម្លាយនូវគំនរលោភៈ គំនរទោសៈ និងគំនរមោហៈដែលមិនធ្លាប់ចោះទម្លុះ មិនធ្លាប់ទម្លាយ ។

ក្នុងខនោះ មានសេចក្តីឧបមាដូចតទៅនេះ ៖

បានឮថា នាយខ្មាន់ធ្នូម្នាក់ឱ្យតាំងផែនក្តារទូក ១ រយផែនក្តារទូកក្នុងទីឆ្ងាយបំផុតមួយរយជួរធ្នូយកយសំពត់ចងមុខ ហើយឃើញកូនសរឋិតនៅជិតកង់យន្ត ។

មនុស្សប្រុសដទៃទេបង្វិលកង់យន្ត កាលណាផែនក្តារបែរមុខទៅរកនាយខ្មាន់ធ្នូ, ក្នុងកាលនោះក៏នឹងឱ្យសញ្ញាដោយកំណាត់ឈើតូចៗក្នុងទីនោះ ។ នាយខ្មាន់ធ្នូមិនលះសញ្ញាកំណាត់ឈើតូចៗឡើយ ព្រលែងកូនសរចេញទៅចោះផែនក្តារទាំងរយបាន ។

ក្នុងសេចក្តីឧបមានេះ គោត្រភូញាណប្រៀបដូចកំណាត់ឈើតូចៗ, មគ្គញ្ញាណប្រៀបដូចនាយខ្មាន់ធ្នូ, ការដែលមគ្គញ្ញាណមិនលះសញ្ញា ដែលគោត្រភូញាណឱ្យហើយនោះឯង ធ្វើព្រះនិព្វានឱ្យជាអារម្មណ៍មែនពិត និងចោះកិនទម្លាយគំនរលោភៈជាដើម ដែលមិនធ្លាប់ចោះហើយ មិនធ្លាប់ទម្លាយហើយ ប្រៀបដូចកាលដែលនាយខ្មាន់ធ្នូមិនលះសញ្ញាកំណាត់ឈើតូចៗ ហើយបាញ់ទម្លាយផែនក្តារទាំងរយបានដូច្នោះដែរ ។

សូម្បីការចោះកិនទម្លាយគំនរលោភៈជាដើមនេះ លោកក៏ពោលថា ការដកឡើងនូវកិលេសដែលបានភូមិហើយ គឺកិលេសដែលជាហេតុនៃវដ្តៈដូចគ្នាដែរ ។ ព្រោះកិច្ចរបស់មគ្គមានតែម្យ៉ាងប៉ុណ្ណោះ **គឺការលះអនុស័យ** ។ មគ្គនោះ កាលបើលះអនុស័យទាំងឡាយ ឈ្មោះថា **រមែងចេញចាកនិមិត្ត**, ឈ្មោះថា **រមែងកាត់សេចក្តីប្រព្រឹត្តទៅ** ។ ពាក្យថា **និមិត្ត** គឺនិមិត្តនៃរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ ពាក្យថា **បវត្តំ** (ការប្រព្រឹត្តទៅ) គឺសេចក្តីប្រព្រឹត្តទៅរបស់រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណនោះឯង ។ បវត្តៈគឺការប្រព្រឹត្តទៅនោះ មាន ២ យ៉ាង បានដល់ ឧបាទិន្នកៈ និងអនុបាទិន្នកៈ ។ ក្នុងពីរយ៉ាងនេះ អាចារ្យពួកខ្លះពោលថា ឆាយា (ស្រមោល) នៃការចេញទៅពីអនុបាទិន្នកៈ រមែងប្រាកដដល់មគ្គដូច្នេះ ហើយពោលថា "រមែងចេញចាកអនុបាទិន្នក្ខន្ធ" ។

ពិតណាស់ អកុសលចិត្ត ៥ ដួង ដែលសម្បយុត្តដោយទិដ្ឋិ ៤ ដួង និងសម្បយុត្តដោយវិចិកិច្ឆា ១ ដួង រមែងលះបានដោយសោតាបត្តិមគ្គ, អកុសលចិត្តទាំង ៥ ដួងនោះ រមែងញ៉ាំងរូបឱ្យតាំងឡើង ។ រូបនោះជាអនុបាទិន្នកៈ ជារូបក្ខន្ធ, ចិត្តទាំង ៤ ដួងនោះ គឺវិញ្ញាណក្ខន្ធ អរូបក្ខន្ធ ៣ គឺវេទនា សញ្ញា និងសង្ខារក្ខន្ធ ដែលសម្បយុត្តដោយវិញ្ញាណក្ខន្ធនោះ ។ បណ្តាមគ្គទាំងនោះ បើព្រះសោតាបន្នឹងមិនឱ្យសោតាបត្តិមគ្គកើតឡើងទេ, អកុសលចិត្តទាំង ៥ ពួកនេះ ក៏គប្បីដល់ការរួបរឹតក្នុងអារម្មណ៍ទាំង ៦ ។ ក៏**សោតាបត្តិមគ្គ** កាលបើនឹងហាមការកើតរួបរឹតរបស់អកុសលទាំងនោះ ទើបធ្វើការដកឡើងនូវសេតុ គឺហេតុឱ្យមិនមានភាវៈដែលគួរនឹងកើតឡើង ទើបឈ្មោះថា **រមែងចេញចាកអនុបាទិន្នក្ខន្ធ** ។

**សកទាគាមិមគ្គ** រមែងលះអកុសល ៦ ដួងដែលជាកាមរាគ និងព្យាបាទយ៉ាងគ្រោតគ្រាតគឺចិត្ត ៤ ដួង ដែលជាទិដ្ឋិវិប្បយុត្ត និងចិត្ត ២ ដួងដែលជាទោមនស្សសហគតៈ ។ **អនាគាមិមគ្គ** រមែងលះចិត្ត ៦ ដួងនុ៎ះឯង ដែលជាកាមរាគ និង ព្យាបាទយ៉ាងល្អិត ។ **អរហត្តមគ្គ** រមែងលះអកុសលចិត្ត ៥ ដួងគឺអកុសលចិត្ត ៤ ដួងដែលជាទិដ្ឋិវិប្បយុត្ត និងចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ។ បណ្តាអកុសលចិត្តទាំងនោះ បើព្រះអរិយទាំងនោះ មិនគប្បីចម្រើនឱ្យកើតឡើងទេ, អកុសលចិត្តទាំងនោះ ក៏គប្បីដល់ការរួមក្នុងអារម្មណ៍ ៦, តែមគ្គទាំងនោះ កាលបើហាមការកើតឡើងនូវការរួបរឹតនៃចិត្តពួកនោះ ទើបធ្វើការដកឡើងនូវសេតុ គឺហេតុឱ្យមានភាវៈដែលមិនគួរកើតឡើងបាន ទើបឈ្មោះថា **រមែងចេញចាកអនុបាទិន្នក្ខន្ធ** ។

អាចារ្យទាំងឡាយពោលថា "ឆាយានៃការចេញទៅចាកឧបាទិន្នក្ខន្ធនឹង

ប្រាកដ” ដូច្នេះ ហើយពោលថា “រមែងចេញចាកឧបាទិន្នក្ខន្ធ” ។ ក៏បើព្រះសោតាបន្ន នឹងមិនចម្រើនឱ្យសោតាបត្តិមគ្គកើតហើយ, ការប្រព្រឹត្តទៅនៃឧបាទិន្នក្ខន្ធក៏គប្បីប្រព្រឹត្តទៅក្នុងសង្សារវដ្តដែលមានខាងដើម និងទីបំផុតដែលបុគ្គលដឹងមិនបាន ហើយវៀរទុក ៧ ភពចេញ ។ ព្រោះហេតុអ្វី ? ព្រោះហេតុនៃការប្រព្រឹត្តទៅរបស់ឧបាទិន្នក្ខន្ធនោះនៅមាន ។ ក៏សោតាបត្តិមគ្គកាលកើតឡើងនោះឯង រមែងដកឡើងនូវកិលេស ៥ ពួកនេះ គឺ សញ្ញោជនៈ ៣ យ៉ាង, ទិដ្ឋានុស្ស័យ និងវិចិកិច្ឆានុស្ស័យ ។ ឥឡូវនេះ ការប្រព្រឹត្តទៅនៃឧបាទិន្នកៈនឹងប្រព្រឹត្តទៅក្នុងសង្សារវដ្តដែលមានខាងដើម និងទីបំផុតដែលបុគ្គលដឹងមិនបានហើយរបស់ព្រះសោតាបន្ន វៀរ ៧ ភពពីទីណា ? ។ សោតាបត្តិមគ្គកាលបើធ្វើការប្រព្រឹត្តទៅនៃឧបាទិន្នក្ខន្ធមិនឱ្យប្រព្រឹត្តទៅ ឈ្មោះថា **រមែងចេញចាកឧបាទិន្នក្ខន្ធ** ដោយប្រការដូច្នេះ ។

បើសកទាគាមីនឹងមិនចម្រើនសកទាគាមិមគ្គឱ្យកើតឡើងទេ, ការប្រព្រឹត្តទៅរបស់ឧបាទិន្នកៈ ក៏ប្រព្រឹត្តទៅក្នុងភពទាំង ៥ វៀរ ២ ភពចេញ ។ ព្រោះហេតុអ្វី ? ព្រោះហេតុនៃការប្រព្រឹត្តទៅរបស់ឧបាទិន្នកៈនោះនៅមាន ។ ក៏សកទាគាមិមគ្គនោះ កាលបើកើតឡើងនោះឯង រមែងដកឡើងនូវកិលេសទាំង ៤ គឺ

**១-កាមរាគសញ្ញោជនៈ** យ៉ាងគ្រោតគ្រាត

**២-បដិឃសញ្ញោជនៈ** យ៉ាងគ្រោតគ្រាត

**៣-កាមរាគានុស្ស័យ** យ៉ាងគ្រោតគ្រាត

**៤-បដិឃានុស្ស័យ** យ៉ាងគ្រោតគ្រាត ។

ឥឡូវនេះ ការប្រព្រឹត្តទៅនៃឧបាទិន្នក្ខន្ធរបស់សកទាគាមីនឹងប្រព្រឹត្តទៅក្នុង

ភពទាំង ៥ វៀរ ២ ភពពីទីណា ។ សកទាគាមិមគ្គ កាលបើធ្វើការប្រព្រឹត្តទៅនៃឧបាទិន្នកូន្នមិនឱ្យប្រព្រឹត្តទៅ ឈ្មោះថា **រមែងចេញចាកឧបាទិន្នកូន្ន** ដោយប្រការដូច្នេះ ។

កាលព្រះអនាគាមីនឹងមិនចម្រើនអនាគាមិមគ្គឱ្យកើតទេ, ការប្រព្រឹត្តទៅនៃឧបាទិន្នកៈ ក៏គប្បីប្រព្រឹត្តទៅក្នុងភពទី ២ វៀរ ១ ភពចេញ ។ ព្រោះហេតុអ្វី ? ព្រោះហេតុនៃការប្រព្រឹត្តទៅនៃឧបាទានកូន្ននោះនៅមាន ។ ក៏អនាគាមិមគ្គនោះ កាលបើកើតឡើងនោះឯង រមែងដកឡើងនូវកិលេស ៤ ពួកនេះ គឺ

**១-កាមរាគសញ្ញោជនៈ** យ៉ាងល្អិត

**២-បដិឃសញ្ញោជនៈ** យ៉ាងល្អិត

**៣-កាមរាគានុស្ស័យ** យ៉ាងល្អិត

**៤-បដិឃានុស្ស័យ** យ៉ាងល្អិត ។

ឥឡូវនេះ ការប្រព្រឹត្តទៅនៃឧបាទិន្នកូន្ន របស់ព្រះអនាគាមីនឹងប្រព្រឹត្តទៅក្នុងភពទី ២ វៀរភពមួយចេញពីទីណា ។ អនាគាមិមគ្គកាលបើធ្វើបវត្តៈនៃឧបាទិន្នកូន្ន មិនឱ្យប្រព្រឹត្តទៅ ឈ្មោះថា **រមែងចេញចាកឧបាទិន្នកូន្ន** ដោយប្រការដូច្នេះ ។

បើព្រះអរហន្តមិនអប់រំអរហត្តមគ្គឱ្យកើតទេ, ការប្រព្រឹត្តទៅនៃឧបាទិន្នកូន្ន ក៏គប្បីប្រព្រឹត្តទៅក្នុងរូបភព និងអរូបភព ។ ព្រោះហេតុអ្វី ? ព្រោះហេតុទាំងឡាយនៃសេចក្តីប្រព្រឹត្តទៅក្នុងឧបាទិន្នកូន្ននៅមាន ។ ក៏អរហត្តមគ្គនោះ កាលបើកើតឡើងនុ៎ះឯង រមែងដកឡើងនូវកិលេសទាំង ៨ នេះគឺ រូបរាគ ១, អរូបរាគ ១,

មានះ ១, ឧទ្ធច្ចៈ ១, អវិជ្ជា ១, មានានុស្ស័យ ១, ភវរាគានុស្ស័យ ១ និងអវិជ្ជានុស្ស័យ ១ ។ ឥឡូវនេះ បវត្តៈនៃឧបាទិន្នក្ខន្ធរបស់ព្រះខីណាស្រពនឹងប្រព្រឹត្តទៅក្នុងភពថ្មីបានពីទីណា ។ អរហត្តមគ្គកាលធ្វើបវត្តៈនៃឧបាទិន្នក្ខន្ធមិនឱ្យប្រព្រឹត្តទៅនុ៎ះឯង ឈ្មោះថា **រមែងចេញចាកឧបាទិន្នក្ខន្ធ** ដោយប្រការដូច្នេះ ។

ក៏បណ្ដាមគ្គទាំង ៤ នេះ សោតាបត្តិមគ្គរមែងចេញចាកអបាយភព, សកទាគាមិមគ្គរមែងចេញចាកដោយឯកទេសនៃសុគតិកាមភព, អនាគាមិមគ្គ រមែងចេញចាកកាមភព, អរហត្តមគ្គរមែងចេញចាករូបភព និងអរូបភព ។ អាចារ្យពួកខ្លះ ពោលថា "អរហត្តមគ្គរមែងចេញសូម្បីចាកភពទាំងពួង" ដូច្នេះមែនពិត ។

ក៏ដើម្បីការជាក់ច្បាស់សេចក្ដីនេះ គប្បីជ្រាបបាលីដូចតទៅនេះ ៖

"ធម៌ គឺនាម និងរូបឯណា គប្បីកើតឡើងក្នុងសង្សារវដ្ដដែលមានខាងដើម និងទីបំផុតដែលបុគ្គលដឹងមិនបាន ហើយវៀរ ៧ ភពចេញ ធម៌ទាំងនោះ រមែងរលត់ ស្ងប់ រមែងតាំងនៅមិនបាន រមែងរម្ងាប់ទៅក្នុងទីនោះ ព្រោះការរលត់ទៅនៃអភិសង្ខារវិញ្ញាណ **ដោយសោតាបត្តិមគ្គញ្ញាណ** ។ ធម៌ គឺនាម និងរូបឯណានោះឯង គប្បីកើតឡើងក្នុង ៥ ភព វៀរ ២ ភពចេញ, ធម៌ទាំងនោះ រមែងរលត់ទៅនៃអភិសង្ខារវិញ្ញាណ **ដោយសកទាគាមិមគ្គញ្ញាណ** ។ ធម៌ គឺនាម និងរូបឯណា គប្បីកើតឡើងក្នុងភព ២ វៀរភពមួយចេញ, ធម៌នោះ រមែងរលត់ គឺស្ងប់ រមែងដល់ការតាំងនៅមិនបាន រមែងស្ងប់រម្ងាប់ទៅក្នុងទីនោះ ព្រោះការរលត់ទៅនៃអភិសង្ខារវិញ្ញាណ **ដោយអនាគាមិមគ្គញ្ញាណ** ។ ធម៌ គឺនាម និងរូបឯណាគប្បីកើតឡើងក្នុងរូបធាតុខ្លះ អរូបធាតុខ្លះ, ធម៌នោះរមែងរលត់ គឺរមែងស្ងប់ រមែងដល់

ការតាំងនៅមិនបាន ព្រោះរម្ងាប់ទៅក្នុងទីនោះឯង ព្រោះការរលត់ទៅនៃអភិសង្ខារវិញ្ញាណ **ដោយអរហត្តមគ្គញ្ញាណ** ។ កាលបើព្រះអរហន្តកំពុងបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ធមិ គឺ បញ្ញា សតិ នាម និងរូប, រមែងរលត់ គឺ រមែងស្ងប់ រមែងដល់ការតាំងនៅមិនបាន រមែងរម្ងាប់ទៅក្នុងទីនោះ ព្រោះការរលត់ទៅនៃវិញ្ញាណចុងក្រោយ (គឺចុតិចិត្ត)"[៣១] ។ វិនិច្ឆ័យក្នុងនិមិត្ត (គឺការប្រព្រឹត្តទៅនៃខន្ធ ៥) ប៉ុណ្ណេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បដិបទា** និង **អធិបតី** នេះតទៅ ៖

**សួរថា** បដិបទារមែងញាប់ញ័រ ឬមិនញាប់ញ័រ ?

ឆ្លើយថា រមែងញាប់ញ័រ ។

ក៏សូម្បីមគ្គទាំង ៤ របស់ព្រះតថាគត និងព្រះសារីបុត្តត្ថេរ បានជាសុខាបដិបទា ខិប្បាភិញ្ញា ។ មគ្គដំបូងរបស់ព្រះមហាមោគ្គល្លានត្ថេរជាសុខាបដិបទា ខិប្បាភិញ្ញា, តែមគ្គ ៣ ខាងក្រោមរបស់លោកជាទុក្ខាបដិបទា ខិប្បាភិញ្ញា ។ ព្រោះហេតុអ្វី ? ព្រោះលោកត្រូវសេចក្តីងងុយគ្របសង្កត់ ។

បានឮថា ព្រះសម្មាសម្ពុទ្ធទ្រង់អភិបាលព្រះថេរៈដូចជាកូនក្មេងតូចរហូត ៧ ថ្ងៃ ។ សូម្បីព្រះថេរៈក៏អង្គុយលក់នៅរហូតទាំងថ្ងៃ គ្រានោះព្រះសាស្តា ទើបត្រាស់នឹងលោកថា "ម្នាលមោគ្គល្លាន លោកងោកងុយឬ?, ម្នាលមោគ្គលាន លោកងោកងុយឬហ្ន៎?"[៣២] ជាដើម ។ សូម្បីបដិបទារបស់ព្រះសាវ័កអ្នកពន្លុះមហាអភិញ្ញាបែប

---

[៣១] ខុ. (ចូឡនិទ្ទេស)។

[៣២] អំ. សត្តក. ។

នេះ នៅតែញាប់ញ័រ, បដិបទារបស់សាវ័កដ៏សេសនឹងមិនញាប់ញ័របានយ៉ាងណា ។

ពិតណាស់ **មគ្គ ៤** របស់ភិក្ខុរូបខ្លះជាទុក្ខាបដិបទាទន្ធាភិញ្ញា, រូបខ្លះ ជាខិប្បាភិញ្ញា ។ មគ្គទី ១ របស់ភិក្ខុរូបខ្លះជាទុក្ខាបដិបទាទន្ធាភិញ្ញា, មគ្គទី ២ របស់ភិក្ខុរូបខ្លះជាទុក្ខាបដិបទាខិប្បាភិញ្ញា, មគ្គទី ៣ របស់ភិក្ខុរូបខ្លះ ជាទុក្ខាបដិបទាទន្ធាភិញ្ញា, មគ្គទី ៤ ជាទុក្ខាបដិបទាខិប្បាភិញ្ញា ។

ម្យ៉ាងទៀត អធិបតីក៏រមែងញាប់ញ័រដូចបដិបទានោះដែរ ។ ពិតណាស់ សូម្បីមគ្គទាំង ៤ របស់ភិក្ខុរូបខ្លះ រមែងជាឆន្ទាធិបតេយ្យ, របស់ភិក្ខុរូបខ្លះជាវិរិយាធិបតេយ្យ, របស់ភិក្ខុរូបខ្លះជាចិត្តាធិបតេយ្យ, របស់ភិក្ខុរូបខ្លះជាវីមំសាធិបតេយ្យ ។ មួយទៀត មគ្គទី ១ របស់ភិក្ខុរូបខ្លះជាឆន្ទាធិបតេយ្យ, មគ្គទី ២ ជាវិរិយាធិបតេយ្យ, មគ្គទី ៣ ជាចិត្តាធិបតេយ្យ, មគ្គទី ៤ ជាវីមំសាធិបតេយ្យ ដូច្នេះឯង ៕

## ចប់បកិណ្ណកកថា

# អដ្ឋសាលិនី

## ពណ៌នាមហាន័យ ២០ ក្នុងបឋមមគ្គ

ឥឡូវនេះ ព្រះយោគាវចរកាលបើចម្រើនលោកុត្តរកុសល រមែងចម្រើនឈាន ដោយអត្ថថា ចូលទៅសំឡឹងតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន, ដោយពិតទៅរមែងចម្រើនសូម្បីមគ្គ ដោយអត្ថថា នាំចេញ, រមែងចម្រើនសូម្បីសតិប្បដ្ឋានដោយអត្ថថា តាំងមាំ, រមែងចម្រើនសូម្បីសម្មប្បធាន ដោយអត្ថថា ធ្វើសេចក្តីព្យាយាម, រមែងចម្រើនសូម្បីឥទ្ធិបាទ ដោយអត្ថថា ការសម្រេច, រមែងចម្រើនឥន្ទ្រិយ ដោយអត្ថថា ភាពជាធំ, រមែងចម្រើនសូម្បីពលៈ ដោយអត្ថថា មិនញាប់ញ័រ, រមែងចម្រើនសូម្បីពោជ្ឈង្គ ដោយអត្ថថា ការត្រាស់ដឹង, រមែងចម្រើនសូម្បីសច្ចៈ ដោយអត្ថថា ជាធមិពិត, រមែងចម្រើនសូម្បីសមថៈ ដោយអត្ថថា សេចក្តីមិនរវើរវាយ, រមែងចម្រើនសូម្បីធមិ ដោយអត្ថថា ជាសុញ្ញតៈ, រមែងចម្រើនសូម្បីខន្ធ ដោយអត្ថថា ជាគំនរ, រមែងចម្រើនសូម្បីអាយតនៈ ដោយអត្ថថា ជាទីកើត រមែងចម្រើនសូម្បីធាតុ ដោយអត្ថថា ជាសភាវៈសូន្យ និងជានិស្សត្តធមិ, រមែងចម្រើនសូម្បីអាហារ ដោយអត្ថថា ជាបច្ច័យ, រមែងចម្រើន សូម្បីផស្សៈ ដោយអត្ថថា ប៉ះខ្ទប់, រមែងចម្រើនសូម្បីវេទនា ដោយអត្ថថា សោយអារម្មណ៍, រមែងចម្រើនសូម្បីសញ្ញា ដោយអត្ថថា សេចក្តីចាំបាន, រមែងចម្រើន សូម្បីចេតនា ដោយអត្ថថា បំណងក្នុងចិត្ត, រមែងចម្រើនសូម្បីចិត្ត ដោយអត្ថថា ការដឹងច្បាស់ ព្រោះហេតុដូច្នោះ ដើម្បីទ្រង់សម្តែងន័យ ១៩ នៃធមិទាំងនោះ ទើបត្រាស់ពាក្យជាដើមថា **"កតមេ ធម្មា កុសលា"** ទៀត ។

ព្រះអង្គទ្រង់សម្តែងន័យ ២០ ដោយអធ្យាស្រ័យរបស់បុគ្គល និងដោយ

ទេសនាវិលាស ដោយព្រះតម្រាស់ថា "បុគ្គលរមែងចម្រើនសូម្បីធម៌នេះ, រមែងចម្រើនសូម្បីធម៌នេះ" ដោយប្រការដូច្នេះ ។

ពិតណាស់ ក្នុងទេពបរិស័ទអ្នកអង្គុយស្តាប់ធម៌ ទេពឯណា កាលបើព្រះអង្គត្រាស់ថា "ឈ្មោះថា **លោកុត្តរជ្ឈាន**" ព្រោះអត្ថថា ចូលទៅសំឡឹងដូច្នេះ រមែងត្រាស់ដឹងបាន, ព្រះអង្គក៏ត្រាស់ពាក្យថា "**ឈាន**" ដូច្នេះ ដោយអំណាចនៃការសប្បាយដល់ទេវតាទាំងឡាយ ។ល។ ទេពឯណាកាលបើព្រះអង្គត្រាស់ថា "សូម្បីចិត្ត" ព្រោះអត្ថថា ការដឹងច្បាស់ដូច្នេះ រមែងត្រាស់ដឹងបាន, ព្រះអង្គក៏ត្រាស់ពាក្យថា "ចិត្ត" ដោយអំណាចសប្បាយៈដល់ជនទាំងនោះ ។ នេះជា**អធ្យាស្រ័យនៃបុគ្គល** ក្នុងអធិការនេះ ។

ក៏ព្រះសម្មាសម្ពុទ្ធព្រោះការដែលព្រះអង្គត្រាស់ដឹងហើយ និងមានពោធិញ្ញាណដ៏ល្អ និងព្រោះប្រកបដោយទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ បដិសម្ភិទា ៤ និងអសាធារណញ្ញាណ ៦ ទើបទ្រង់កំណត់ទេសនាសម្តែងធម៌តាមគាប់ព្រះទ័យបាន, កាលបើព្រះអង្គទ្រង់ប្រាថ្នាក៏រមែងសម្តែងថា "**លោកុត្តរជ្ឈាន**" ដោយអត្ថថា ចូលទៅសំឡឹងដូច្នេះ, កាលបើប្រាថ្នា ក៏គប្បីទ្រង់សម្តែងថា "មគ្គ" ដោយអត្ថថា នាំចេញ ។ល។ កាលបើប្រាថ្នា ក៏គប្បីទ្រង់សម្តែងថា "**លោកុត្តរចិត្ត**" ដោយអត្ថថា ការដឹងច្បាស់នូវអារម្មណ៍ដូច្នេះ ។ នេះឈ្មោះថា **ទេសនាវិលាស** ។ ក្នុងទេសនាវិលាសនោះទ្រង់ចែកន័យទុក ១០ ក្នុងទីដែលត្រាស់ថា "**លោកុត្តរជ្ឈាន**" យ៉ាងណា, គប្បីជ្រាបន័យទាំងនោះ សូម្បីមានពាក្យថា មគ្គជាដើមដូច្នោះដែរ ។ ដោយប្រការដូច្នេះ រមែងជាការដែលទ្រង់ចែកន័យ ២០០ ន័យ ធ្វើក្នុងឋាន ២០

ន័យ ទុកជាឋានមួយៗ ១០ ន័យ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងប្រភេទនៃអធិបតី ទើបផ្តើមពាក្យថា **"កតមេ ធម្មា កុសលា"** ទៀត ។ បណ្តាពាក្យមានឈានជាដើមនោះ លោកុត្តរជ្ឈាន ដែលព្រះយោគាវចរធ្វើឆន្ទៈឱ្យជាធុរៈ ឱ្យជាធំ ឱ្យជាប្រធានហើយកើតឡើង ឈ្មោះថា **ឆន្ទាធិបតេយ្យ** ។ សូម្បីក្នុងពាក្យដ៏សេស ក៏ន័យនេះដែរ ។ ព្រះធម្មរាជាទ្រង់សម្តែងបឋមមគ្គចែកដោយពាន់ន័យ គឺក្នុង (**លោកុត្តរជ្ឈាន**) ខាងដើមសុទ្ធៗ ២០០ ន័យ និងធម៌មានឆន្ទាធិបតេយ្យជាដើម មួយយ៉ាងៗ ២០០ ន័យ (២០០ x ៤ = ៨០០) ដោយប្រការដូច្នេះ ៕

**ចប់មគ្គចិត្តដួងទី ១**

# អធិប្បាយមគ្គចិត្តដួងទី ២

ឥឡូវនេះ ដើម្បីទ្រង់សម្តែងមគ្គទី ២ ជាដើម ទើបផ្តើមត្រាស់ពាក្យថា **"កតមេ ធម្មា កុសលា"** ទៀត ។

បណ្តាពាក្យទាំងនោះ ពាក្យទាំងនេះថា **"កាមរាគព្យាបាទានំ តនុភាវាយ** = ដើម្បីបន្ថោបង់កាមរាគ និងព្យាបាទ" បានដល់ ដើម្បីបន្ថោបង់សង្កិលេសទាំងឡាយ ។ ក្នុងពាក្យថា ដើម្បីបន្ថោបង់សង្កិលេសទាំងនោះ គប្បីជ្រាបការធ្វើឱ្យស្រាលស្តើងដោយហេតុ ២ យ៉ាង គឺការកើតឡើងម្តងម្កាល និងការគ្របសង្កត់យ៉ាងធូរ ។

ពិតណាស់ កិលេសទាំងឡាយរមែងមិនកើតឡើងរឿយៗ ដល់ព្រះសកទាគាមីដូចមហាជនអ្នកត្រាច់ទៅក្នុងវដ្តៈទេ, រមែងកើតឡើងម្តងម្កាល, សូម្បីកាលកើតឡើង ក៏ជាការកើតឡើងដែលស្រាលស្តើង, ដូចគ្រាប់ពូជក្នុងស្រែដែលគេព្រោះទុកស្តើងៗ ។ សូម្បីកាលបើកើតឡើង ក៏ផ្សាយទៅបិទបាំងស្រាលស្តើង មិនកើតឡើងធ្វើការងងឹតស្លុប ដូចមហាជនអ្នកត្រេចទៅក្នុងវដ្តៈទេ ។ ក៏ព្រោះត្រូវមគ្គទាំងពីរប្រហារហើយទើបកើតឡើងស្រាសស្តើង, រមែងកើតឡើងជាសភាពស្រាលស្តើងដូចជាផ្ទៃពពកស្តើងៗ និងដូចស្លាបរុយដូច្នោះដែរ ។

ក្នុងសេចក្តីនេះ ព្រះថេរៈពួកខ្លះពោលថា "កិលេសកើតឡើងដល់ព្រះសកទាគាមីយូរៗ ម្តង ក៏ពិតមែនហើយ, ប៉ុន្តែថា ក៏ជាកិលេសដ៏មានកម្លាំងទើបកើតឡើង ។ ព្រោះថា ព្រះសកទាគាមីនោះនៅមានបុត្រ និងធីតាកំពុងប្រាកដ" ។ តែសេចក្តីនេះមិនជាប្រមាណ ។ ព្រោះថា បុត្រ និងធីតា រមែងមានដោយហេតុត្រឹមតែថា ការស្ទាបអង្អែលអវយវៈតូចធំក៏មាន, តែសេចក្តីដែលកិលេសនៅក្រាស់មិនមាន ព្រោះកិលេសទាំងឡាយ លោកលះដោយមគ្គទាំងពីរហើយ ។ គប្បីជ្រាបសេចក្តីស្រាលស្តើងនៃកិលេសទាំងឡាយ របស់លោកដោយហេតុទាំងពីរ គឺដោយការកើតឡើងគ្រាខ្លះ និងព្រោះគ្របសង្កត់យ៉ាងធូរដោយប្រការដូច្នេះ ។

ពាក្យថា **ទុតិយា** (ទី ២) បានដល់ ឈ្មោះថាទី ២ ដោយការរាប់ខ្លះ ដោយការកើតឡើងគ្រាទី ២ ខ្លះ ។

បទថា **ភូមិយា បត្តិយា** (ដើម្បីពន្លុះភូមិ) បានដល់ ដើម្បីប្រយោជន៍ ដល់ការបានសាមញ្ញផល ។ សូម្បីក្នុងពាក្យថា ដើម្បីពន្លុះភូមិទី ៣ ទី ៤ ក៏ន័យនេះ

ដែរ, តែខ្ញុំនឹងពោលចំពោះតែសេចក្តីដែលផ្សេងគ្នាប៉ុណ្ណោះ ។

បទថា **អញ្ញិន្ទ្រិយំ** (អញ្ញិន្ទ្រិយ) បានដល់ ឥន្ទ្រិយដែលដឹងសព្វ, មានអធិប្បាយថា ឥន្ទ្រិយដែលដឹងសច្ចធម៌ទាំង ៤ ពួកនុ៎ះឯង ដែលសកទាគាមិមគ្គនោះដឹងហើយមិនលើសព្រំដែនដែលបឋមមគ្គដឹងទេ ។ សូម្បីក្នុងនិទ្ទេសវារៈនៃអញ្ញិន្ទ្រិយនោះ ក៏គប្បីជ្រាបសេចក្តីដោយន័យនេះ ។ ក្នុងកោដ្ឋាសវារៈរួមជាមួយនឹងឥន្ទ្រិយនេះ ក៏ជាឥន្ទ្រិយ ៩ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុននោះចុះ ៕

## ចប់ទុតិយមគ្គ

ក្នុងមគ្គចិត្តដួងទី ៣ បទថា **អនវសេសប្បហានាយ** = ដើម្បីលះមិនឱ្យមានសល់, បានដល់ ដើម្បីប្រយោជន៏ដល់ការលះសំយោជនៈទាំងនុ៎ះឯង ដែលស្រាលស្តើងដោយអំណាចនៃសកទាគាមិមគ្គមិនឱ្យសល់ ។

ក្នុងមគ្គចិត្តដួងទី ៤ ពាក្យថា **ដើម្បីលះរូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈ** និង **អវិជ្ជា មិនឱ្យមានសល់** បានដល់ ដើម្បីប្រយោជន៏ដល់ការលះ ឧទ្ធម្ភាគិយសញ្ញោជនៈ ៥ ពួកនោះមិនឱ្យសល់ ។ បណ្តាឧទ្ធម្ភាគិយសញ្ញោជនៈពួកនោះ បទថា **រូបរាគោ** បានដល់ សេចក្តីត្រេកអរដោយអំណាចនៃការពេញចិត្តក្នុងរូបភព ។ បទថា **អរូបរាគោ** បានដល់ សេចក្តីត្រេអរដោយអំណាចនៃការពេញចិត្តក្នុងអរូបភព ។ បទថា **មានោ** បានដល់ មានះដែលព្រះអរហត្តគប្បីសម្លាប់នោះឯង ។ ឧទ្ធច្ចៈ និងអវិជ្ជាដែលព្រះអរហត្តគប្បីសម្លាប់ដូចគ្នា ។ ក្នុងមគ្គចិត្តទាំង ២ (ទី ៣ និងទី ៤) ពួកនេះជាអញ្ញិន្ទ្រិយទី ៩ ប៉ុណ្ណោះ ៕

## សម្តែងអំពីមគ្គចិត្តមួយពាន់ដោយន័យជាដើម

ក្នុងមគ្គទាំងអស់មានបទ ៦០ សុទ្ធ ដោយលំដាប់នៃបទរួមនឹងអង្គអបណ្ណកៈ (មិនខុសគ្នា) ៤ ជា ៦៤ បទ, ក៏បទដែលមិនលាយឡំគ្នា ៣៣ បទ ក្នុងកោដ្ឋាសវារៈ និងសុញ្ញតវារៈតាមប្រក្រតីនោះឯង ។ ព្រះធម្មរាជាទ្រង់ចែកមគ្គទាំង ៤ សម្តែងទុក ៤,០០០ ន័យ គឺសូម្បីក្នុងមគ្គចិត្តដួងទី ២ ជាដើម ក៏ជាមួយដួងមួយពាន់ន័យដូចបឋមមគ្គនោះដែរ ។

ក៏ក្នុងសច្ចវិភង្គ ព្រះអង្គទ្រង់តាំងលោកុត្តរទុក ៦ ហ្មឺនន័យដោយអំណាចនៃមគ្គចិត្តទាំងនេះនោះឯង ។ ក្នុងសតិប្បដ្ឋានវិភង្គត្រង់តាំងលោកុត្តរទុក ២ ហ្មឺនន័យ, ក្នុងសម្មប្បធានវិភង្គ ២ ហ្មឺនន័យ, ក្នុងឥទ្ធិបាទវិភង្គ ៣ ហ្មឺន ២ ពាន់ន័យ, ក្នុងពោជ្ឈង្គ ៣ ហ្មឺន ២ ពាន់ន័យ, ក្នុងមគ្គវិភង្គទ្រង់តាំងលោកុត្តរទុក ២ ហ្មឺន ៨ ពាន់ន័យ ដោយអំណាចនៃមគ្គចិត្តពួកនោះដែរ ។

តែក្នុងទីនេះ ទ្រង់តាំងលោកុត្តរទុក ៤ ពាន់ន័យ ក្នុងមគ្គចិត្តទាំង ៤ ដួង។ បណ្តាមគ្គចិត្តពួកនោះ មគ្គចិត្តដួងទីមួយប្រកបដោយបឋមជ្ឈាន ទ្រង់ចែកអង្គទុក ៨, ក្នុងទុតិយមគ្គជាដើមក៏ដូចគ្នា ។ បណ្តាអង្គមគ្គពួកនោះ សម្មាទិដ្ឋិក្នុងមគ្គទី ១ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា រមែងលះមិច្ឆាទិដ្ឋិ សូម្បីមគ្គមាន សម្មាសង្កប្បៈជាដើម ក៏គប្បីជ្រាប ព្រោះអត្ថថា មានការលះមិច្ឆាសង្កប្បៈជាដើមនោះដែរ ។

***សួរថា*** កាលបើដូចនេះ ឈ្មោះថា ទិដ្ឋិដែលមគ្គខាងលើ ៣ គប្បីលះក៏មិនមាន ព្រោះទិដ្ឋិ ៦២ ដែលមគ្គទីមួយប៉ុណ្ណោះ លះបានហើយ ឈ្មោះថា សម្មាទិដ្ឋិក្នុងមគ្គខាងលើ ៣ នោះ រមែងមានយ៉ាងណា ? ។

ឆ្លើយថា ពិសពស់មាននៅក៏ដោយ មិនមាននៅក៏ដោយ, ពស់ ក៏នៅតែលោកហៅថា "ពស់" នោះដែរ យ៉ាងណា, មិច្ឆាទិដ្ឋិមាននៅក៏ដោយ មិនមាននៅក៏ដោយ, **សម្មាទិដ្ឋិនេះ** ក៏ឈ្មោះថា **"សម្មាទិដ្ឋិ"** យ៉ាងនោះដែរ ។

***សួរថា*** ប្រសិនបើពាក្យថា មិច្ឆាទិដ្ឋិយ៉ាងនេះ ក៏គ្រាន់តែជាឈ្មោះប៉ុណ្ណោះ, ដែលសម្មាទិដ្ឋិមិនមានកិច្ចនៅក្នុងមគ្គ ៣ ខាងលើទេ, អង្គមគ្គក៏មិនបរិបូរណ៍[៣៣] ។ ព្រោះហេតុនោះ សម្មាទិដ្ឋិ ទើបគួរមានកិច្ចដែលត្រូវធ្វើ អង្គមគ្គទើបនឹងបរិបូរណ៍មិនមែនឬ ?

ឆ្លើយថា ក៏សម្មាទិដ្ឋិមានកិច្ចក្នុងមគ្គ ៣ ខាងលើនេះ គប្បីសម្ដែងដោយការកំណត់តាមដែលបាន ។ សេចក្ដីពិតថា នៅមានះមួយទៀតដែលមគ្គ ៣ ខាងលើគប្បីសម្លាប់, មានះនោះរមែងតាំងនៅក្នុងឋាននៃទិដ្ឋិ, សម្មាទិដ្ឋិនេះ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា រមែងលះមានះនោះបាន ។

ក៏សម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គរមែងលះមិច្ឆាទិដ្ឋិ តែមានះដែលសកទាគាមិមគ្គគប្បីសម្លាប់ តែងមានដល់ព្រះសោតាបន្ន ។ សម្មាទិដ្ឋិរបស់សកទាគាមីនោះឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា រមែងលះមានះនោះបាន ។ សង្កប្បៈដែលកើតឡើងព្រមជាមួយនឹងអកុសលចិត្ត ៧ ដួង ក៏នៅតែមានដល់ព្រះសោតាបន្ននោះដែរ, ការចម្រើនអង្គនៃវាចាក៏នៅមាន ដោយអកុសលចិត្តពួកនោះដែរ, ការកម្រើកនៃកាយ ក៏នៅមានដោយអកុសលចិត្តនោះដែរ, ការបរិភោគបច្ច័យ (មានចីវរប្បច្ច័យជាដើម) ក៏តែងមាន, សេចក្ដីព្យាយាមដែលកើតព្រមគ្នា ក៏តែងតែមាន, សេចក្ដី

---

[៣៣] ត្រង់នេះបាលីសៀមជា **មគ្គង្គានិ បន បរិបូរេន្តិ** ។ ភូមាជា **មគ្គង្គានិ ន បរិបូរេន្តិ** ។

មិនមានសតិក៏តែងមាន, ឯកគ្គតានៃចិត្តដែលកើតព្រមគ្នាក៏តែងមាន, ទាំងអស់នេះ ឈ្មោះថា **មិច្ឆាសង្កប្បៈ** ជាដើម ។ សម្មាសង្កប្បៈជាដើម ក្នុងសកទា គាមិមគ្គ គប្បីជ្រាបថា ព្រោះលះមិច្ឆាសង្កប្បៈជាដើមនោះ ។ អង្គមគ្គ ៨ ក្នុងសកទាគាមិមគ្គ មកធ្វើកិច្ចរបស់ខ្លួន ដោយប្រការដូច្នេះ ។

មានះរបស់ព្រះសកទាគាមី ដែលគប្បីសម្លាប់ដោយអនាគាមិមគ្គនៅមាន, មានះនោះ រមែងតាំងនៅក្នុងឋាននៃទិដ្ឋិ, សង្កប្បៈជាដើម ដែលកើតព្រមនឹងអកុសលចិត្ត ៧ ដួង **ក៏រមែងនៅមានដល់ព្រះអនាគាមីនោះឯង, គប្បីជ្រាបសេចក្តីដែលអង្គមគ្គ ៨** ក្នុងអនាគាមិមគ្គធ្វើកិច្ចរបស់ខ្លួន ដោយការលះមិច្ឆាសង្កប្បៈជាដើមនោះ ។ មានះរបស់អនាគាមីដែលគប្បីសម្លាប់ដោយអរហត្តមគ្គមាន, មានះនោះ រមែងតាំងនៅក្នុងឋាននៃទិដ្ឋិ, ក៏អកុសលចិត្ត ៥ ដួង[៣៤] ឯណា រមែងមានដល់អនាគាមីនោះ, មិច្ឆាសង្កប្បៈជាដើមដែលកើតរួមនឹងអកុសលចិត្តពួកនោះនៅមាន, គប្បីជ្រាបសេចក្តីដែលអង្គមគ្គ ៨ ក្នុងអរហត្តមគ្គ ធ្វើកិច្ចដោយការលះមិច្ឆាសង្កប្បៈជាដើមនោះ ។

***សួរថា*** បណ្តាមគ្គទាំង ៤ នេះ បឋមមគ្គឃើញសច្ចៈទាំង ៤, មគ្គ ៣ ខាងលើរមែងឃើញសច្ចៈដែលបឋមមគ្គឃើញហើយនោះឯង, ឬរមែងមិនឃើញសច្ចៈដែលបឋមមគ្គមិនឃើញហើយឬ ?

---

[៣៤] ៥ ដួង គឺលោភមូលចិត្តដែលជាទិដ្ឋិវិប្បយុត្ត ៤ ដួង មោហមូលចិត្តដែលវិប្បយុត្តដោយឧទ្ធច្ចៈ ១ ដួង ។

ឆ្លើយថា ពាក្យពេចន៍ដែលដូចគ្នារបស់ពួកអាចារ្យនេះថា មគ្គ ៣ ខាងលើ រមែងឃើញសច្ចៈដែលបឋមមគ្គឃើញហើយនោះដូច្នេះ ។

តែអាចារ្យវិតណ្ឌវាទីពោលថា “មគ្គ ៣ ខាងលើ រមែងឃើញសច្ចៈដែលបឋមមគ្គមិនបានឃើញ” ។ គប្បីដេញដោលអាចារ្យវិតណ្ឌវាទីនោះថា “ឥន្ទ្រិយក្នុងបឋមមគ្គជាយ៉ាងណាចូរបញ្ជាក់មកមើល” ។ កាលបើអាចារ្យវិតណ្ឌវាទីដឹងហើយ ក៏នឹងពោលថា “អនញ្ញតញ្ញស្សាមីតិន្ទ្រិយ” ។ សូម្បីកាលបើគេពោលថា “ក្នុងមគ្គខាងលើជាឥន្ទ្រិយណា” ដូច្នេះ ក៏រមែងប្រាប់ថា “អញ្ញិន្ទ្រិយ” ។ គប្បីពោលនឹងលោកវិតណ្ឌវាទីទៀតថា “កាលបើឃើញសច្ចៈដែលបឋមមគ្គមាន ក៏ចូរចែកអនញ្ញតញ្ញស្សាមីតិន្ទ្រិយសូម្បីក្នុងមគ្គខាងលើផង, ដោយអាការយ៉ាងនេះបញ្ហារបស់លោកក៏នឹងស្ងប់ ។

**សួរថា** ក៏មគ្គមួយយ៉ាង រមែងលះកិលេសដែលនៅមិនបានលះមិនមែនឬ ?

ឆ្លើយថា មែន, គឺមគ្គមួយយ៉ាង រមែងលះកិលេសមួយយ៉ាង ។

ប្រសិនបើថា មគ្គមួយយ៉ាងរមែងលះកិលេសដូច្នេះ ។ មគ្គមួយយ៉ាង ក៏លះកិលេសមួយយ៉ាងដែលនៅមិនបានលះសោត, បុគ្គលក៏គប្បីមានវាទៈយ៉ាងនេះថា មគ្គ ៣ ខាងដើម សូម្បីឃើញសច្ចៈទាំងឡាយ ដែលបឋមមគ្គមិនបានឃើញហើយនោះឯងដូច្នេះ, គប្បីសួរពាក្យនេះថា “ឈ្មោះថា សច្ចៈទាំងឡាយមានប៉ុន្មាន ?” កាលបើជ្រាបក៏នឹងឆ្លើយថា “មាន ៤” គប្បីផ្ទាន់លោកក្នុងវាទៈរបស់លោក សច្ចៈប្រាកដ ១៦ យ៉ាង, លោករមែងឃើញសច្ចៈ សូម្បីដែលព្រះពុទ្ធ ជាម្ចាស់មិនបានឃើញហើយ, **ឈ្មោះមានសច្ចៈច្រើន** លោកកុំកាន់យកយ៉ាងនេះ

ឡើយ ។ ការឃើញសច្ចៈដែលនៅមិនធ្លាប់ឃើញ រមែងមិនមាន, តែមគ្គរមែងលះកិលេសទាំងឡាយដែលនៅមិនទាន់បានលះដូច្នេះ ៕

## ការឧបមាដោយហិបរតនៈ

ក្នុងខដែលថាការឃើញសច្ចៈដែលមិនធ្លាប់ឃើញមកពីមុនមិនមានក្នុងអធិការនៃមគ្គនោះ លោកកាន់យកការប្រៀបធៀបដោយហិបរតនៈដូចតទៅនេះ ៖

បានឮថា មនុស្សប្រុសម្នាក់ដាក់ហិបរតនៈ ៤ ទុកក្នុងបន្ទប់ដែលជាទីឃុំគ្រងរតនៈដ៏ខ្ពង់ខ្ពស់, គេមាននាទីធ្វើការកើតឡើងក្នុងហិប ក្នុងវេលាយប់ទើបបើកទ្វារអុចប្រទីបឱ្យភ្លឺ កាលបើសេចក្តីងងឹតត្រូវប្រទីបកម្ចាត់ចេញហើយ ហិបទាំងឡាយក៏ប្រាកដ គេធ្វើធុរៈក្នុងហិបនោះហើយបិទទ្វារចេញទៅ, សេចក្តីងងឹតក៏ប្រាកដដូចដើម, សូម្បីក្នុងគ្រាទី ២ សូម្បីក្នុងគ្រាទី ៣ ក៏បានធ្វើយ៉ាងនោះដែរ ។ ក្នុងគ្រាទី ៤ កាលបើគេនឹងពិចារណាមើលថា កាលបើកទ្វារហើយ ហិបរតនៈនឹងប្រាកដ ហិបរតនៈនឹងប្រាកដក្នុងភាពងងឹត ឬមិនប្រាកដទេ ព្រះអាទិត្យក៏រះឡើង កាលបើសេចក្តីងងឹតត្រូវពន្លឺព្រះអាទិត្យកម្ចាត់ហើយ គេក៏ធ្វើធុរៈក្នុងហិបទាំងឡាយស្រេចហើយចេញទៅ, បណ្តាពាក្យទាំងនោះ សច្ចៈ ៤ ប្រៀបដូចហិបរតនៈ ៤, វេលាដែលវិបស្សនាឈានទៅកាន់សោតាបត្តិមគ្គប្រៀបដូចវេលាដែលបុរសនោះមានកិច្ចកើតឡើងក្នុងហិបរតនៈហើយបិទទ្វារ ។ សេចក្តីងងឹតបិទបាំងសច្ចៈ ប្រៀបដូចសេចក្តីងងឹតរបស់រាត្រី ។ ពន្លឺសោតាបត្តិមគ្គ ប្រៀបដូចពន្លឺនៃប្រទីប, សេចក្តីដែលសច្ចៈទាំងឡាយប្រាកដដល់មគ្គញ្ញាណ ប្រៀបដូចហិបរតនៈទាំងឡាយប្រាកដដល់

បុរសនោះ ព្រោះសេចក្តីងងឹតត្រូវកម្ចាត់ទៅ ។ សច្ចៈទាំងឡាយ ក៏ប្រាកដដល់មគ្គញ្ញាណ រមែងប្រាកដដល់បុគ្គលអ្នកព្រមព្រៀងដោយមគ្គនោះឯង ។ វេលាដែលសោតាបត្តិមគ្គលះកិលេស ដែលខ្លួនគួរលះហើយរលត់ទៅ ប្រៀបដូចវេលាដែលបុរសនោះធ្វើធុរៈក្នុងហិបរតនៈទាំងឡាយហើយទៅ ។ សេចក្តីងងឹតដែលបិទបាំងសច្ចៈ ដែលគប្បីសម្លាប់ដោយមគ្គ ៣ ខាងលើ ប្រៀបដូចសេចក្តីងងឹតដែលគ្របសង្កត់តទៅ ។

វេលាដែលវិបស្សនាឈានទៅកាន់សកទាគាមិមគ្គ ប្រៀបដូចវេលាដែលបុរសនោះ បើកទ្វារក្នុងគ្រាទី ២, ពន្លឺនៃសកទាគាមិមគ្គ ប្រៀបដូចពន្លឺនៃប្រទីប, វេលាដែលសកទាគាមិមគ្គ លះកិលេសដែលខ្លួនគប្បីលះហើយរលត់ទៅ ប្រៀបដូចវេលាដែលបុរសនោះធ្វើធុរៈក្នុងហិបរតនៈទាំងឡាយស្រេចហើយ, សេចក្តីងងឹតបិទបាំងសច្ចៈដែលមគ្គ ២ ខាងលើគប្បីសម្លាប់ ប្រៀបដូចសេចក្តីងងឹតដែលគ្របសង្កត់តទៅ ។

វេលាដែលវិបស្សនាឈានទៅកាន់អនាគាមិមគ្គ ប្រៀបដូចបុរសនោះបើកទ្វារក្នុងគ្រាទី ៣, ពន្លឺនៃអនាគាមិមគ្គប្រៀបដូចពន្លឺនៃប្រទីប, វេលាដែលអនាគាមិមគ្គលះកិលេសដែលខ្លួនគប្បីលះហើយរលត់ទៅ ប្រៀបដូចបុរសដែលធ្វើធុរៈក្នុងហិបទាំងឡាយហើយទៅ, សេចក្តីងងឹតបិទបាំងសច្ចៈដែលអរហត្ត ខាងលើគប្បីសម្លាប់ ប្រៀបដូចសេចក្តីងងឹតស្លប់ម្តងទៀត ។

វេលាដែលវិបស្សនាឈានទៅកាន់អរហត្តមគ្គ ប្រៀបដូចវេលាដែលបុរសបើកទ្វារគ្រាទី ៤, ការកើតឡើងនៃអរហត្តមគ្គ ប្រៀបដូចការកើតឡើងទៅនៃ

ព្រះអាទិត្យ, ការកម្ចាត់សេចក្តីងងឹតដែលបិទបាំងសច្ចៈនៃអរហត្តមគ្គ ប្រៀបដូចការកម្ចាត់សេចក្តីងងឹត, សេចក្តីដែលសច្ចៈទាំង ៤ ប្រាកដដល់អរហត្តមគ្គញ្ញាណប្រៀបដូចហិបរតនៈទាំងឡាយប្រាកដដល់បុរសនោះ ព្រោះភាពងងឹតត្រូវខ្ចាត់ចេញទៅ, ក៏សច្ចៈទាំងឡាយប្រាកដដល់ញាណ រមែងប្រាកដដល់បុគ្គលអ្នកព្រមព្រៀងដោយមគ្គនោះឯង ។ ការដែលអរហត្តមគ្គញ្ញាណ ញ៉ាំងកិលេសទាំងអស់ឱ្យអស់ទៅ ប្រៀបដូចវេលាដែលបុរសធ្វើកិច្ចក្នុងហិបរតនៈទាំងឡាយស្រេចហើយទៅ, ភាវៈមិនមានសេចក្តីងងឹតបិទបាំងសច្ចៈទៀត ចាប់ផ្តើមពីវេលាកើតឡើងនៃអរហត្តមគ្គ ប្រៀបដូចវេលាដែលពន្លឺនោះឯង ប្រព្រឹត្តទៅចាប់ផ្តើម ពីការភ្លឺឡើងនៃដួងអាទិត្យដូច្នោះ ។ នេះជាពាក្យឧបមាក្នុងការមិនឃើញសច្ចៈ ដែលនៅមិនធ្លាប់ឃើញត្រឹមតែប៉ុណ្ណេះ ។

ក្នុងខថា ក៏មគ្គខាងលើរមែងឃើញសច្ចៈដែលបឋមគ្គឃើញហើយនោះឯង តែថាមគ្គយ៉ាងដទៃរមែងលះកិលេសដទៃៗនេះ លោកកាន់យកឈ្មោះឧបមាដោយទឹកក្បុងដូចតទៅ ៖

បុរសម្នាក់បានប្រគល់សំពត់ដែលសៅហ្មងដល់ជាងជ្រលក់, ជាងជ្រលក់ ក៏ត្រាំក្នុងទឹកក្បុង ៣ ប្រភេទគឺ ទឹកក្បុងអំបិល, ទឹកក្បុងផេះ និងទឹកក្បុងគោម័យ ។ គេដឹងថាទឹកក្បុងកាត់វត្ថុស្មោកគ្រោកហើយ ក៏ចាក់ទឹកចោលដងជម្រះមន្ទិលគ្រោតគ្រាត ។ បន្ទាប់ពីនោះមក គេក៏ដឹងថា សំពត់នៅមិនស្អាតល្អម ទើបត្រាំក្នុងទឹកក្បុងយ៉ាងនោះដដែល ក្នុងគ្រាទី ២ ហើយចាក់ទឹកចោលជ្រលក់លាងមន្ទិល ដែលល្អិតជាងនោះ; បន្ទាប់មកគេក៏ដឹងថា “នៅមិនស្អាតល្អម” ទើបត្រាំទឹកក្បុងយ៉ាងនោះ

ទៀត ក្នុងគ្រាទី ៣ ចាក់ចោលហើយជ្រលក់លាងមន្ទិលដែលល្អិតជាងនោះ ។ បន្ទាប់មក ក៏ដឹងថា “សំពត់នៅមិនស្អាតល្អម” ទើបត្រាំក្នុងទឹកក្បុងនោះថែមទៀត សូម្បីគ្រាទី ៤ ចាក់ទឹកចោលហើយជ្រលក់លាងមន្ទិលមិនឱ្យមានសល់ សូម្បីប្រព្រឹត្តទៅក្នុងសរសៃអំបោះហើយទើបប្រគល់ឱ្យដល់ម្ចាស់របស់, ម្ចាស់របស់នោះក៏បត់ទុក ដាក់ក្នុងហិបអប់ក្លិនជ្រលក់ ស្លៀកដណ្តប់ក្នុងវេលាដែលខ្លួនប្រាថ្នាហើយៗ ។

បណ្តាពាក្យទាំងនោះ ចិត្តដែលប្រព្រឹត្តទៅតាមកិលេសប្រៀបដូចសំពត់ដែលប្រឡាក់ហើយ, វេលាដែលប្រព្រឹត្តទៅនៃការធ្វើអនុបស្សនាទាំង ៣ ប្រៀបដូចសំពត់ដែលប្រឡាក់ហើយ, វេលាដែលប្រព្រឹត្តទៅនៃការធ្វើអនុបស្សនាទាំង ៣ ប្រៀបដូចការត្រាំដោយទឹកក្បុង ៣ ប្រភេទ, ការញុំាងកិលេស ៥ យ៉ាង[៣៥] ឱ្យអស់ទៅ ដោយសោតាបត្តិមគ្គ ប្រៀបដូចការចាក់ទឹកចោលហើយលាងជម្រះមន្ទិលគ្រោតគ្រាត, ការដឹងថា “ចិត្តនេះនៅមិនបរិសុទ្ធល្អម” ហើយញុំាងការងារឱ្យប្រព្រឹត្តទៅក្នុងអនុបស្សនាទាំង ៣ នុ៎ះឯង ប្រៀបដូចការត្រាំទឹកក្បុងទាំងនោះសូម្បីគ្រាទី ២, ការញុំាងសញ្ញោជនៈយ៉ាងគ្រោតគ្រាត ២ យ៉ាងឱ្យអស់ទៅ ដោយសកទាគាមិមគ្គ ប្រៀបដូចការបោកលាងមន្ទិលដ៏ល្អិតជាងនោះ, ការដែលគេគិតថា “ចិត្តនេះបរិសុទ្ធមិនល្អម” ហើយនៅធ្វើការងារឱ្យប្រព្រឹត្តទៅក្នុងអនុបស្សនា ៣ ទាំងនុ៎ះឯង ប្រៀបដូចគេគិតថា “សំពត់នេះស្អាតមិនល្អម” ហើយដាក់ទឹកក្បុង ៣

---

[៣៥] អកុសលចិត្ត គឺលោភមូលចិត្តដែលជាទិដ្ឋិគតសម្បយុត្ត ៤ និងមោហមូលចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា ១ ។

យ៉ាងឱ្យកាត់ទៀត, ការញ៉ាំងសញ្ញោជនៈយ៉ាងល្អិត ២ យ៉ាងឱ្យអស់ទៅដោយអនាគាមិមគ្គ ប្រៀបដូចបោកលាងមន្ទិលសំពត់ដែលល្អិតជាងនោះ, ការដែលដឹងថា "ចិត្តនេះនៅមិនស្អាតល្អម" ហើយញ៉ាំងការងារឱ្យប្រព្រឹត្តទៅក្នុងអនុបស្សនាទាំង ៣ នុ៎ះឯង ឱ្យប្រព្រឹតទៅ ប្រៀបដូចជាងជ្រលក់ដឹងថា "សំពត់ នៅមិនទាន់ស្អាតល្អម" ទើបដាក់ត្រាំក្នុងទឹកក្បុង ៣ យ៉ាងទៀត, ការដែលចិត្តរបស់ព្រះខីណាស្រពបរិសុទ្ធ ព្រោះកិលេស ៨ យ៉ាងដែលអរហត្តមគ្គឱ្យអស់ទៅហើយ បញ្ឈប់នៅដោយវិហារធម៌ គឺផលសមាបត្តិក្នុងខណៈដែលប្រាថ្នាហើយៗ ប្រៀបដូចការស្លៀកដណ្តប់សំពត់ដែលបរិសុទ្ធ ព្រោះបោកគក់មន្ទិលដែលនៅខាងក្នុងសរសៃអំបោះចេញទៅ ដោយការគក់លាងពីសំពត់នោះដូចនឹងផែនប្រាក់ដែលដាក់ទុក ក្នុងប្រអប់ខណៈដែលខ្លួនប្រាថ្នាហើយៗ ។ នេះជាការឧបមាក្នុងខថា "មគ្គយ៉ាងដទៃ រមែងលះកិលេសយ៉ាងដទៃៗ" ។

ខនេះ សមដូចពាក្យដែលលោកព្រះខេមកៈពោលទុកថា ៖

"ម្នាលអាវុសោទាំងឡាយ សំពត់ស្មោកគ្រោកសៅហ្មង, ម្ចាស់របស់ទាំងឡាយគប្បីប្រគល់សំពត់នេះដល់ជាងជ្រលក់, ជាងជ្រលក់អ្នកឆ្លាតញីសំពត់នោះត្រាំក្នុងទឹកក្បុងអំបិល, ក្នុងទឹកក្បុងផេះ, ឬក្នុងទឹកក្បុងគោម័យ ហើយយកទៅគក់ក្នុងទឹកស្អាត, សំពត់នោះរមែងជារបស់ស្អាតផូរផង់ ក៏ពិតមែនហើយ, តែសំពត់នោះនៅមិនអស់ក្លិនទឹកក្បុងអំបិល, ក្លិនទឹកក្បុងផេះ ឬក្លិនគោម័យដ៏ល្អិត, ជាងបោកគក់ប្រគល់សំពត់នោះ ឱ្យដល់ម្ចាស់របស់ទាំងឡាយ, ម្ចាស់របស់ទាំងឡាយ ដាក់ទុកសំពត់នោះក្នុងហិបអប់ក្លិន សូម្បីសំពត់នោះនៅមិនអស់ក្លិនទឹក

ក្បុងអំបិល, ទឹកក្បុងផេះ ឬក្លិនគោម័យដ៏ល្អិត, សូម្បីក្លិននោះ រមែងអស់ទៅ យ៉ាងណា, ម្នាលអាវុសោទាំងឡាយ សញ្ញោជនៈខាងក្រោម ៥ អរិយសាវ័កលះបានហើយក៏ពិត, តែលោកក៏នៅដកមានះ ឆន្ទៈ អនុស្ស័យយ៉ាងល្អិតក្នុងឧបាទានក្ខន្ធ ៥ ថា យើងមានមិនបាន, សម័យតមកលោកពិចារណាឃើញសេចក្តីវិនាសក្នុងឧបាទានក្ខន្ធថា "រូបយ៉ាងនេះ, ការកើតឡើងនៃរូបយ៉ាងនេះ, ការរលត់ទៅនៃរូបយ៉ាងនេះ វេទនាយ៉ាងនេះ ។ល។ សញ្ញាយ៉ាងនេះ ។ល។ សង្ខារយ៉ាងនេះ ។ល។ វិញ្ញាណយ៉ាងនេះ, ការកើតឡើងនៃវិញ្ញាណយ៉ាងនេះ ។ ល ។ ការរលត់នៃវិញ្ញាណ" ។ កាលបើលោកពិចារណាឃើញការកើតឡើង និងការវិនាសក្នុងឧបាទានក្ខន្ធទាំង ៥ នេះហើយ សូម្បីលោកដកនូវមានះ ឆន្ទៈ អនុស្ស័យយ៉ាងល្អិតក្នុងឧបាទានក្ខន្ធ ៥ ថា 'យើងមាន', មិនបាន ។ តែមានះ ឆន្ទៈ និងអនុស្ស័យនោះរមែងមានដល់ការដកឡើងយ៉ាងនោះដែរ" ។

បណ្តាមគ្គទាំងនោះ សោតាបត្តិមគ្គរមែងលះអកុសលចិត្ត ៥ ដួង ព្រមនឹងបាបធម៌ដែលកើតឡើងដោយអំណាចនៃអង្គចិត្ត តែងបន្ទោបង់ដោយសកទាគាមិមគ្គ ។ ទោមនស្សសហគតចិត្ត ២ ដួងទាំងនុ៎ះឯង ព្រមនឹងសម្បយុត្តធម៌ រមែងលះដោយអនាគាមិមគ្គ ។ អកុសលចិត្ត ៥ ដួង ព្រមនឹងបាបធម៌ដែលកើតឡើងដោយអំណាចនៃអង្គចិត្ត រមែងលះដោយអរហត្តមគ្គ ។ ចាប់ផ្តើមពីកាលដែលអកុសលចិត្ត ១២ ដួងទាំងនេះលះបានហើយ ឈ្មោះថា កិលេសដែលជាប់តាមទៅទៀត ដោយអំណាចនៃអង្គចិត្ត រមែងមិនមានដល់ព្រះខីណាស្រពឡើយ ។

ក្នុងខដែលកិលេសមិនជាប់ទៅតាមទៀតនោះ មានឧបមាដូច្នេះ ៖

បានឮថា ព្រះមហារាជមួយអង្គ ព្រះរាជទានអារក្ខាបច្ចន្តជនបទហើយ សោយភាពជាឥស្សរិយយសក្នុងមហានគរ, ខាងក្រោយមក បច្ចន្តៈរបស់ព្រះអង្គកើតចលាចល ។ សម័យនោះ មានពួកមេចោរ ១២ នាក់ ព្រមនឹងបុរសច្រើនពាន់នាក់នាំគ្នាទៅប្លន់ដែនរដ្ឋ, មហាអាមាត្យអ្នកនៅបច្ចន្តប្រទេសបញ្ជូនដំណឹងក្រាបទូលដល់ព្រះរាជាថា "បច្ចន្តៈកើតចលាចល" ។ ព្រះរាជាបញ្ជូនព្រះរាជសាសន៍ទៅថា "ចូរបង្ក្រាបឱ្យអស់, យើងនឹងប្រគល់រង្វាន់ដល់ពួកលោក" ។ អាមាត្យទាំងនោះ សម្លាប់មេចោរ ៥ នាក់ និងចោរបុរសច្រើនពាន់នាក់ ដោយការប្រហារគ្រាដំបូងនោះឯង, មេចោរ ៧ នាក់ដ៏សេស នាំបរិវាររបស់ខ្លួន១ ចូលទៅកាន់ភ្នំ, ពួកអមាត្យ ក៏បញ្ជូនដំណឹងក្រាបទូលសេចក្ដីប្រព្រឹត្តទៅនោះដល់ព្រះរាជា ។ ព្រះរាជាទើបទ្រង់បញ្ជូនព្រះរាជទ្រព្យទៅដោយព្រះរាជសាសន៍ថា "យើងនឹងដឹងវត្ថុដែលគួរធ្វើដល់ពួកអ្នក, ពួកអ្នកចូរបង្ក្រាបចោរសូម្បីដ៏សេសទាំងនោះ" ។ ពួកអាមាត្យទាំងនោះ ក៏ប្រហារមេចោរ ២ នាក់ ដោយការប្រហារគ្រាទី ២, បានធ្វើសូម្បីបរិវាររបស់ពួកចោរទាំងនោះឱ្យទុព្វល ។ សូម្បីពួកចោរទាំងអស់នោះ ក៏នាំគ្នាចៀសចេញទៅកាន់ភ្នំ, ពួកអាមាត្យបញ្ជូនសាសន៍សេចក្ដីនោះទៅក្រាបទូលព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជូនព្រះរាជទ្រព្យដោយព្រះរាជសាសន៍ថា "ពួកលោកចូរបង្ក្រាបពួកចោរឱ្យអស់" ពួកអាមាត្យទាំងនោះសម្លាប់មេចោរពីនាក់ព្រមទាំងបក្សពួកបុរសចោរដោយការប្រហារគ្រាទី ៣ ហើយបញ្ជូនសាសន៍ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាក៏បញ្ជូនព្រះរាជទ្រព្យព្រមទាំងព្រះរាជសាសន៍ថា "ពួកលោក

ចូរបង្ក្រាបចោរកុំឱ្យសល់” ។ ពួកអាមាត្យទាំងនោះ ក៏សម្លាប់មេចោរ ៥ នាក់ ព្រមទាំងបរិវារចោរ ដោយការប្រហារគ្រាទី ៤ ។ ចាប់ដើមពីពួកមេចោរ ១២ នាក់ ត្រូវពួកអាមាត្យ បង្ក្រាបឱ្យងាប់ហើយ ឈ្មោះថា **ចោរអី១ មិនបានមានទេ** ។ ជនបទដល់សេចក្ដីក្សេមក្សាន្ត, រមែងតាំងនៅដូចឱ្យកូនរាំនៅលើទ្រូងដូច្នោះ ។ ព្រះរាជាទ្រង់ឱ្យចោមរោម ដោយយោធាពិជិតសង្គ្រាម ស្ដេចឡើងកាន់ប្រាសាទដ៏ប្រសើរ សោយមហាសម្បត្តិ ។

ក្នុងពាក្យទាំងនោះ ព្រះធម្មរាជា (ព្រះសម្មាសម្ពុទ្ធ) ប្រៀបដូចព្រះមហារាជា, កុលបុត្រអ្នកយោគាវចរប្រៀបដូចអាមាត្រអ្នកនៅបច្ចន្តជនបទ, អកុសលចិត្ត ១២ ដួង (ជាអកុសលចេតសិក ១៤ ដួង) ប្រៀបដូចមេចោរ ១២ នាក់, បាបធម៌ដែលកើតឡើងដោយអំណាចនៃអង្គចិត្ត ប្រៀបដូចបក្សពួកច្រើនពាន់របស់មេចោរទាំងនោះ, វេលាដែលកិលេសកើតឡើងក្នុងអារម្មណ៍ហើយក្រាបទូលព្រះសាស្ដាថា “បពិត្រព្រះអង្គដ៏ចម្រើន កិលេសទាំងឡាយកើតឡើងដល់ខ្ញុំព្រះអង្គ” ប្រៀបដូចអាមាត្យបញ្ជូនសារលិខិតក្រាបទូលព្រះរាជាថា “ជនបទកើតចលាចល” , ការដែលព្រះធម្មរាជាត្រាស់ប្រាប់កម្មដ្ឋានថា “ភិក្ខុអ្នកចូរសង្កត់កិលេសចេញ” ប្រៀបដូចការព្រះរាជទានព្រមនឹងព្រះរាជសាសនីថា “ពួកអ្នកចូរបង្ក្រាបឱ្យអស់” , ការលះអកុសលចិត្ត ៥ ដួងព្រមទាំងសម្បយុត្តដោយសោតាបត្តិមគ្គ ប្រៀបដូចវេលាដែលអាមាត្យសម្លាប់មេចោរ ៥ នាក់ ព្រមទាំងបរិវារ ។

ការក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះសម្មាសម្ពុទ្ធ ប្រៀបដូចការបញ្ជូនដំណឹងថ្វាយព្រះរាជា, ការដែលព្រះមានព្រះភាគប្រាប់វិបស្សនានៃសកទា

គាមិមគ្គ ប្រៀបដូចការព្រះរាជទានទ្រព្យទៀត ព្រមនឹងព្រះតម្រាស់ថា "ចូរបង្ក្រាបពួកចោរដ៏សេស" , កាលបន្ទោបង់ទោមនស្សចិត្ត ២ ដួង ព្រមទាំងសម្បយុត្តធម៌ដោយសកទាគាមិមគ្គ ប្រៀបដូចការធ្វើមេចោរ ២ នាក់ ព្រមទាំងបរិវារឱ្យទុព្វលភាពដោយការប្រហារគ្រាទី ២ ។

ការក្រាបទូលគុណដែលខ្លួនបានដល់ព្រះសាស្តា ប្រៀបដូចការបញ្ជូនដំណឹងថ្វាយព្រះរាជាឱ្យទ្រង់ជ្រាបសេចក្តីប្រព្រឹត្តទៅទៀត, ការដែលព្រះមានព្រះភាគត្រាស់ប្រាប់វិបស្សនានៃអនាគាមិមគ្គ ប្រៀបដូចការព្រះរាជទានទ្រព្យទៀត ព្រមនឹងដំណឹងសាសន៍ថា "ចូរបង្ក្រាបចោរឱ្យអស់រលីង" , ការលះចិត្តទោមនស្ស ២ ដួង ព្រមទាំងសម្បយុត្តធម៌ដោយអនាគាមិមគ្គ ប្រៀបដូចការសម្លាប់មេចោរ ២ នាក់ ព្រមទាំងបរិវារដោយការប្រហារគ្រាទី ៣ ។

ការក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះមានព្រះភាគ ប្រៀបដូចការបញ្ជូនដំណឹងថ្វាយព្រះរាជាឱ្យទ្រង់ជ្រាបទៀត, ការដែលព្រះមានព្រះភាគត្រាស់ប្រាប់វិបស្សនានៃអរហត្តមគ្គ ប្រៀបដូចការព្រះរាជទានទ្រព្យម្តងទៀត ព្រមនឹងព្រះតម្រាស់ទៅថា "ចូរបង្ក្រាបចោរឱ្យអស់" , សេចក្តីមិនមានអកុសលធម៌ដែលកើតឡើងដោយអំណាចនៃអង្គចិត្តទៀត ចាប់ដើមអំពីអកុសលចិត្ត ១២ ដួង ព្រោះអកុសលចិត្ត ៥ ដួង ព្រមទាំងសម្បយុត្តធម៌ដែលអរហត្តមគ្គលះហើយ ប្រៀបដូចវេលាដែលជនបទជាដែនក្សេមក្សាន្ត ចាប់ដើមពីកាលដែលអាមាត្យសម្លាប់មេចោរ ៥ នាក់ ព្រមទាំងបរិវារ ដោយការប្រហារគ្រាទី ៤, គប្បីជ្រាបការសោយសុខដោយផលសមាបត្តិតាមដែលព្រះយោគាវចរប្រាថ្នាហើយ ក្នុងសុខ

ទាំងឡាយមានសមាបត្តិដែលផ្សេងដោយសុញ្ញតៈ អនិមិត្តៈ អប្បណិហិតៈ របស់ព្រះធម្មរាជា ព្រះអង្គមានព្រះខីណាស្រពចោមរោមហើយ ប្រៀបដូចការសោយមហាសម្បត្តិរបស់ព្រះរាជាអ្នកពិជិតសង្គ្រាម អ្នកចោមរោមដោយអាមាត្យលើប្រាសាទដ៏ប្រសើរដូច្នោះដែរ ៕

**ចប់ការពណ៌នាបទធម៌ជាកុសលតែប៉ុណ្ណេះ**

---

# កថាសម្តែងធម្មុទ្ទេសវារៈក្នុងបទអកុសល

# អធិប្បាយអកុសលចិត្តដួងទី ១

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់បំណងចែកបទអកុសល ទើបទ្រង់ផ្តើមព្រះតម្រាស់ថា “**កតមេ ធម្មា អកុសលា** = ធមិជាអកុសល តើដូចម្តេច ?” ជាដើម ។

ក្នុងពាក្យថាអកុសលជាដើមទាំងនោះ គប្បីជ្រាបប្រភេទវារៈមានការកំណត់ធមិជាដើម និងការវិនិច្ឆ័យសេចក្តីនៃបទដែលមានមកហើយខាងក្រោយដោយន័យដែលពោលហើយនោះឯង, ក៏ខ្ញុំនឹងពណ៌នាបទដែលគ្រាន់តែផ្សេងគ្នា ក្នុងទីនោះៗប៉ុណ្ណោះ ។ ក្នុងអធិការនៃអកុសលនោះ នឹងវិនិច្ឆ័យក្នុងការកំណត់សម័យមុន ព្រោះអកុសលមិនផ្សេងភូមិគ្នាដូចកុសលទេ, ព្រោះហេតុដូច្នោះ អកុសលនេះសូម្បីជាកាមាវចរតែម្យ៉ាង ព្រះអង្គក៏មិនបានត្រាស់ថា “**ជាកាមាវចរ**” ឡើយ ៕

# វិនិច្ឆ័យពាក្យថាទិដ្ឋិគតសម្បយុត្ត

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ទិដ្ឋិគតសម្បយុត្តំ** នេះតទៅ ៖

ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋិគតៈ** ដូចក្នុងប្រយោគទាំងឡាយមានជាអាទិ៍ថា **“គូថគតំ** = គូថ, **មុត្តគតំ** = មូត្រ” ។ ម្យ៉ាងទៀត ធម៌ដែលឈ្មោះថា **ទិដ្ឋិគតៈ** ព្រោះអត្ថថា **ទិដ្ឋិ** នេះ គ្រាន់តែជាការប្រព្រឹត្តទៅរបស់ទិដ្ឋិប៉ុណ្ណោះ ព្រោះមិនមានវត្ថុដែលគួរដឹង ឬព្រោះមិនមានវត្ថុដែលគួរប្រព្រឹត្តទៅ ។ ដែលឈ្មោះថា **ទិដ្ឋិគតសម្បយុត្ត** ព្រោះអត្ថថា សម្បយុត្តដោយទិដ្ឋិនោះ ។

ក្នុងទិដ្ឋិគតសម្បយុត្តចិត្តនោះ បណ្ឌិតគប្បីជ្រាបការកើតឡើងនៃសេចក្ដីយល់ឃើញខុស ពោលគឺទិដ្ឋិគតៈនេះ ដោយហេតុទាំងឡាយមានអាទិ៍យ៉ាងនេះ គឺ

**-អសទ្ធម្មស្សវនំ** ការស្ដាប់តែអសទ្ធម្ម

**-អកល្យាណមិត្តតា** ភាពជាអ្នកមិនមានមិត្តល្អ

**-អរិយានំ អទស្សនកាមតាទីនិ** ភាពជាអ្នកមិនត្រូវការឃើញព្រះអរិយៈជាដើម ។

**-អយោនិសោមនសិការោ** ការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនង ។

ពិតមែនហើយ សេចក្ដីយល់ឃើញនោះ គប្បីជ្រាបថា រមែងកើតឡើងដោយការស្ដាប់, វៀរចាកសេចក្ដីត្រិះរិះ ឈានកន្លងភាពជាកណ្ដាល មានមានះច្រើនយ៉ាងជាប្រធាននៃអសទ្ធម្ម ដែលប្រកបដោយវាទៈខុសទាំងនោះ, ដោយភាពជាអ្នកមានអកល្យាណមិត្ត ពោលគឺភាពជាអ្នកសេពគប់មិត្តអាក្រក់ អ្នកមានទិដ្ឋិ

វិបត្តិទាំងនោះ, ដោយមិនត្រូវការឃើញព្រះអរិយៈទាំងឡាយ និងសប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម ដោយភាពជាអ្នកមិនឆ្លាតក្នុងអរិយធម៌ និងសប្បុរិសធម៌ ដែលផ្សេងដោយសតិប្បដ្ឋាន ៤ ជាដើម និងដោយការមិនមានវិន័យ ពោលគឺការបែកធ្លាយនៃសំវរៈក្នុងអរិយធម៌ និងសប្បុរិសធម៌ដែលមាន ៖

-**បាដិមោក្ខសំវរៈ** សង្រួមក្នុងបាតិមោក្ខ (សីល និងសិក្ខាបទក្នុងវិនយបិដកទាំងអស់) ។

-**ឥន្ទ្រិយសំវរៈ** សង្រួមក្នុងឥន្ទ្រិយ

-**សតិសំវរៈ** សង្រួមក្នុងសតិ (ស្មារតី)

-**ញាណសំវរៈ** ការសង្រួមក្នុងញាណ (បញ្ញា)

-**បហានសំវរៈ** សង្រួមក្នុងបហានៈ (ការលះបង់) ។

ដោយការធ្វើទុកក្នុងចិត្តតាមឧបាយដែលមិនត្រូវទំនង ព្រោះហេតុទាំងនោះឯង ដែលខ្លួនអប់រំហើយ និងព្រោះជាអ្នកខ្វល់ខ្វាយ ក្នុងមង្គលភ្ញាក់ផ្អើលជាដើម ។ ក៏គប្បីជ្រាបសេចក្ដីដែលចិត្តនេះ ជាអសង្ខារិក (មិនមានការដឹកនាំ) ដោយន័យដែលពោលហើយក្នុងខាងក្រោយនោះចុះ ៕

## សំដែងអំពីធម្មុទ្ទេសមានផស្សៈជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈនៃធម្មុទ្ទេស (គោលធម៌) តទៅ ៖

បទថា **ផស្សោ** បានដល់ ផស្សៈដែលកើតព្រមជាមួយនឹងអកុសលចិត្ត ។

សូម្បីក្នុងធម៌មានវេទនាជាដើម ក៏ន័យនេះដែរ ។ ធម៌មានផស្សៈជាដើមទាំងនេះ ផ្សេងពីធម៌ដែលសម្ដែងទុកពីមុនមក ដែលគ្រាន់តែជាអកុសលប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

បទថា **ចិត្តស្សេកគ្គតា ហោតិ** (ឯកគ្គតានៃចិត្តរមែងមាន) សេចក្ដីថា ឯកគ្គតា (សមាធិចិត្ត) រមែងមាន ព្រោះមិនរាយមាយក្នុងការបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃសូម្បីក្នុងបាណាតិបាតជាដើម ។ ពិតមែនហើយ មនុស្សទាំងឡាយតាំងចិត្តទុកមាំ មិនរាយមាយ ទើបញ៉ាំងសស្ត្រាឱ្យធ្លាក់ទៅក្នុងសរីរៈរបស់សត្វទាំងឡាយមិនឱ្យភ្លាត់ខុស, ជាអ្នកមានចិត្តតាំងមាំហើយ រមែងនាំវត្ថុដែលជារបស់មនុស្សដទៃទៅ, រមែងប្រព្រឹត្តមិច្ឆាចារដោយចិត្តមានសភាពរីករាយតែម្យ៉ាង ។ ឯកគ្គតានៃចិត្តរមែងមាន សូម្បីក្នុងការប្រព្រឹត្តអកុសលដោយប្រការដូច្នេះ ។

ពាក្យថា **មិច្ឆាទិដ្ឋិ** បានដល់ មិនមានការឃើញតាមសេចក្ដីពិត, ម្យ៉ាងទៀត ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ឃើញឃ្លៀងឃ្លាត ដោយប្រកាន់ខុស, ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ជាទិដ្ឋិដែលបណ្ឌិតខ្ពើម ព្រោះនាំមកតែសេចក្ដីវិនាស ។ សូម្បីក្នុងមិច្ឆាសង្កប្បៈជាដើម ក៏ន័យនេះដែរ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ជាហេតុឱ្យមនុស្សឃើញខុស, ឬឃើញខុសដោយខ្លួនឯង, ឬក៏ទិដ្ឋិនេះ គ្រាន់តែឃើញខុសប៉ុណ្ណោះ ។

## លក្ខណាទិចតុក្កៈនៃមិច្ឆាទិដ្ឋិ

**អយោនិសោ អភិនិវេសលក្ខណា** មិច្ឆាទិដ្ឋិនោះ មានការប្រកាន់មាំ

ដោយឧបាយមិនត្រូវទំនងជាលក្ខណៈ ។

**បរាមាសរសា** មានសេចក្ដីប្រកាន់មាំខុស ចាកសភាវៈជារស

**មិច្ឆាភិនិវេសនបច្ចុប្បដ្ឋានា** មានសេចក្ដីប្រកាន់ខុសជាបច្ចុប្បដ្ឋាន

**អរិយានំ អទស្សនកាមតាទិបទដ្ឋានា** មានសេចក្ដីមិនត្រូវការឃើញព្រះអរិយៈទាំងឡាយជាដើមជាបទដ្ឋាន ។

គប្បីជ្រាបថាជាទោសយ៉ាងក្រៃលែង ។ សូម្បីក្នុងមិច្ឆាសង្កប្បៈជាដើម មានសេចក្ដីផ្សេងគ្នាត្រឹមតែបទថា **មិច្ឆា** ប៉ុណ្ណោះ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយក្នុងអធិការកុសលនោះចុះ ។

សេចក្ដីនៃពលៈក្នុងខថា **អហិរិកពលៈ អនោត្តប្បពលៈ** នេះនឹងជាក់ច្បាស់ក្នុងនិទ្ទេសវារៈ ។ ចំណែកពាក្យក្រៅនេះ គប្បីជ្រាបវចនត្ថៈដូចតទៅនេះ ៖

បុគ្គលឈ្មោះថា **អហិរិកោ** ព្រោះអត្ថថា រមែងមិនខ្មាស់, ភាវៈនៃបុគ្គលអ្នកមិនខ្មាស់ ឈ្មោះថា **អហិរិកំ**[៣៦] (ភាពជាអ្នកមិនខ្មាស់) ។ សភាវធម៌ដែលមិនមែនជាឱត្តប្បៈឈ្មោះថា **អនោត្តប្បំ** (ភាពជាអ្នកមិនខ្លាច) ក្នុងធម៌ទាំងពីរនោះ ៖

**កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណំ អលជ្ជនលក្ខណំ វា** អហិរិកៈមានការមិនខ្ពើមកាយទុច្ចរិតជាដើមជាលក្ខណៈ ឬមានការមិនខ្មាស់កាយទុច្ចរិតជាដើមជាលក្ខណៈ ។

**តេហេវ អសារជ្ជលក្ខណំ អនុត្តាសនលក្ខណំ វា** អនោត្តប្បៈមានការ

---

[៣៦] បទនេះ ជាអហិរិក្កំ លោកលុបអក្សរ **ក** ទើបជាអហិរិកំ (អដ្ឋ. យោជនា) ។

មិនខ្លាចកាយទុច្ចរិតជាដើមទាំងនោះឯងជាលក្ខណៈ ឬមិនមានសេចក្តីតក់ស្លុតកាយទុច្ចរិតជាដើមទាំងនោះ ជាលក្ខណៈ។ ពលៈ គឺអហិរិកៈនោះឯង ឈ្មោះថា **អហិរិកពលៈ** ។ ពលៈ គឺអនោត្តប្បៈនោះឯង ឈ្មោះថា **អនោត្តប្បពលៈ** ។ សេចក្តីសង្ខេបក្នុងអធិការនៃអកុសលនេះមានប៉ុណ្ណេះ, ចំណែកសេចក្តីពិស្តារ គប្បីជ្រាបដោយអំណាចនៃភាពជាបដិបក្សនឹងគ្នា តាមដែលពោលហើយខាងក្រោយនោះចុះ ។

សភាវធម៌ដែលឈ្មោះថា **លោភៈ** ព្រោះអត្ថថា ជាហេតុឱ្យមនុស្សចង់បាន, ឬចង់បានដោយខ្លួនឯង, ឬក៏គ្រាន់តែចង់បានប៉ុណ្ណោះ ។ ឈ្មោះថា **មោហៈ** ព្រោះអត្ថថា ជាហេតុឱ្យមនុស្សវង្វេង, ឬវង្វេងដោយខ្លួនឯង, ឬក៏គ្រាន់តែជាសេចក្តីវង្វេងប៉ុណ្ណោះ ។ បណ្តាសភាវៈទាំងពីរនោះ ៖

## លក្ខណាទិចតុក្កៈនៃលោភៈ

**អារម្មណគ្គហណលក្ខណោ** លោភៈមានការប្រកាន់អារម្មណ៍ជាលក្ខណៈ ដូចស្វាជាប់ជ័រ ។

**អភិសង្គរសោ** មានសេចក្តីជាប់ក្នុងអារម្មណ៍ជារស ដូចដុំសាច់ដែលដាក់លើក្បឿងដែលក្តៅ ។

**អបរិច្ចាគបច្ចុបដ្ឋានោ** មានការមិនលះបង់ជាបច្ចុប្បដ្ឋាន ដូចប្រឡាក់ប្រេង និងថ្នាំបន្តក់ភ្នែក ។

**សញ្ញោជនិយធម្មេសុ អស្សាទនស្សនបទដ្ឋានោ** មានសេចក្តីពេញចិត្តក្នុងធម៌ជាអារម្មណ៍របស់សញ្ញោជនៈជាបទដ្ឋាន ។

លោភៈនោះ កាលបើចម្រើនឡើង ដោយសេចក្តីជាស្ទឹង គឺតណ្ហា គប្បីជ្រាបថា រមែងនាំទៅកាន់អបាយប៉ុណ្ណោះ ដូចស្ទឹងមានក្រសែទឹកដ៏លឿន រមែងហូរផាត់នាំទៅកាន់មហាសមុទ្រដូច្នោះដែរ ៕

## លក្ខណាទិចតុក្កៈនៃមោហៈ

**ចិត្តស្ស អន្ធភាវលក្ខណោ** មោហៈមានសេចក្តីងងឹតនៃចិត្តជាលក្ខណៈ

**អញ្ញាណលក្ខណោ វា** ឬមានសេចក្តីមិនដឹងជាលក្ខណៈ ។

**អសម្បដិវេធរសោ** មានសេចក្តីមិនចាក់ធ្លុះជារស

**អារម្មណសភាវច្ឆាទនរសោ វា** ឬមានសេចក្តីបិទបាំងសភាវៈនៃអារម្មណ៍ជារស ។

**អសម្មាបដិបត្តិបច្ចុប្បដ្ឋានោ** មានការមិនបដិបត្តិដោយប្រពៃជាបច្ចុប្បដ្ឋាន

**អន្ធការបច្ចុប្បដ្ឋានោ វា** ឬមានសេចក្តីងងឹតជាបច្ចុប្បដ្ឋាន

**អយោនិសោមនសិការបទដ្ឋានោ** មានការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនងជាបទដ្ឋាន គប្បីជ្រាបថាជា **មូលនៃអកុសលធម៌ទាំងពួង** ។

សភាវធម៌ដែលឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា ជាហេតុឱ្យមនុស្សសំឡឹងរំពៃ ឬរមែងសំឡឹងរំពៃដោយខ្លួនឯង, ឬធម៌នេះ គ្រាន់តែជាការ

សំឡឹងរំពៃប៉ុណ្ណោះ ៕

## លក្ខណាទិចតុក្កៈនៃអភិជ្ឈា

**បរសម្បត្តីនំ សក្កករណត្ថលក្ខណា** អភិជ្ឈានោះមានសេចក្ដីប្រាថ្នាធ្វើសម្បត្តិរបស់អ្នកដទៃឱ្យមកជារបស់ខ្លួនជាលក្ខណៈ ។

**តេនាការេន បសង្គភាវរសា** មានសេចក្ដីជាប់ជំពាក់ ដោយអាការយ៉ាងនោះជារស ។

**បរសម្បត្តិអភិមុខបច្ចុប្បដ្ឋានា** មានសេចក្ដីបែរមុខទៅរកសម្បត្តិរបស់អ្នកដទៃជាបច្ចុប្បដ្ឋាន ។

**បរសម្បត្តីសុ អភិរតិបទដ្ឋានា** មានសេចក្ដីត្រេកអរយ៉ាងក្រៃលែងក្នុងសម្បត្តិរបស់អ្នកដទៃជាបទដ្ឋាន ។

ពិតមែន អភិជ្ឈានោះ រមែងប្រាកដបែរមុខទៅរកសម្បត្តិរបស់អ្នកដទៃប៉ុណ្ណោះ ។ ក៏កាលបើសេចក្ដីរីករាយយ៉ាងក្រៃលែងរមែងមាន អភិជ្ឈានោះ ក៏រមែងប្រព្រឹត្តទៅក្នុងសម្បត្តិរបស់អ្នកដទៃ, គប្បីជ្រាបថា ដូចការលាតដៃនៃចិត្តទៅក្នុងសម្បត្តិរបស់អ្នកដទៃទាំងនោះដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា **សមថៈរមែងមាន** តទៅ ៖

សភាវធម៌ដែលឈ្មោះថា **សមថៈ** ព្រោះស្ងប់សេសចក្ដីរវើរវាយ ក្នុងកិច្ចដទៃៗ ។ ឈ្មោះថា **បគ្គាហៈ** ព្រោះផ្គងចិត្តឱ្យប្រព្រឹត្តទៅក្នុងអកុសល ។ ឈ្មោះ

ថា **អវិក្ខេបៈ** ព្រោះមិនរាយមាយទៅ ។ ក្នុងអកុសលចិត្តនេះ មិនកាន់យកធម៌ទាំងនោះ គឺ **សទ្ធា សតិ បញ្ញា** និងធម៌ ៦ គូរទេ ។ ព្រោះហេតុអ្វី ? ព្រោះឈ្មោះថា សេចក្ដីជ្រះថ្លា ក្នុងចិត្តដែលមិនមានសទ្ធារមែងមិនមានទេ, ព្រោះហេតុដូច្នោះខាងដើមនេះ ទើបមិនកាន់យកសទ្ធា ។ **សួរថា** ក៏មនុស្សអ្នកមានទិដ្ឋិទាំងឡាយមិនជឿសាស្ដារបស់ខ្លួនៗឬ ? ឆ្លើយថា ជឿ, តែការជឿនោះ មិនឈ្មោះថា សទ្ធាទេ, ពាក្យថា ជឿនេះគ្រាន់តែជាការស្របតាមពាក្យ (របស់គ្រូ) ប៉ុណ្ណោះ; ពោលដោយសេចក្ដីជឿនោះ រមែងជាសេចក្ដីជឿដែលប្រាសចាកការពិចារណាខ្លះ ជាទិដ្ឋិខ្លះ ។

**ឯសតិរមែងមិនមានក្នុងអកុសលចិត្ត** ព្រោះមិនជាទីពឹងនៃសតិ ព្រោះហេតុដូច្នោះ ព្រះអង្គទើបមិនកាន់យក ។ **សួរថា** បុគ្គលអ្នកមានទិដ្ឋិទាំងឡាយរមែងមិនរឭក[៣៧] ដល់ការងារដែលខ្លួននឹងធ្វើខ្លះឬ ? ឆ្លើយថា រមែងរឭក, តែការរឭកនោះមិនឈ្មោះថាជាសតិទេ, ព្រោះអាការរឭកនោះ ជាសេចក្ដីប្រព្រឹត្តទៅរបស់អកុសលចិត្តតែម្យ៉ាង ។ ព្រោះហេតុដូច្នោះ ទើបមិនទ្រង់កាន់យកថាជាសតិ ។ **សួរថា** កាលបើសេចក្ដីជាយ៉ាងនោះ ព្រោះហេតុអ្វីក្នុងព្រះសូត្រទើបត្រាស់ថា **"មិច្ឆាសតិ** ជាការរឭកទៅវិញ" ? ឆ្លើយថា ដើម្បីនឹងទ្រង់ញ៉ាំងមិច្ឆត្ត:នៃមិច្ឆាមគ្គឱ្យបរិបូរណ៍ ព្រោះអកុសលខន្ធទាំងឡាយជាសភាវៈវៀរចាកសតិ និងជាបដិបក្សចំពោះសតិ, ទើបទ្រង់ធ្វើទេសនាមិច្ឆាសតិទុកក្នុងព្រះសូត្រនោះ ដោយបរិយាយ, តែមិច្ឆាសតិនោះ ពោលដោយនិប្បរិយាយរមែងមិនមាន ព្រោះហេតុដូច្នោះ

---

[៣៧] ទី. បា., សំ. ម. ។

ទើបមិនទ្រង់កាន់យកឡើយ ។

ចំណែក **បញ្ញា** រមែងមិនមានក្នុងចិត្តរបស់អន្ធពាលនោះទេ ព្រោះហេតុដូច្នោះ ទើបមិនទ្រង់កាន់យកឡើយ ។ **សួរថា** សេចក្ដីដឹង (**បញ្ញា**) ជាគ្រឿងបោកបញ្ឆោតរបស់បុគ្គលអ្នកជាមិច្ឆាទិដ្ឋិ រមែងមិនមានឬ ? ឆ្លើយថា មាន, តែសេចក្ដីដឹងជាគ្រឿងបោកបញ្ឆោតនោះ មិនឈ្មោះថា **បញ្ញាទេ**, សេចក្ដីដឹងនោះឈ្មោះថាជា **មាយា** ។ ពោលដោយអត្ថ មាយានោះ ក៏គឺ **តណ្ហា** នោះឯង ។ ក៏ព្រោះចិត្តនោះជាចិត្តក្រវល់ក្រវាយ ធ្ងន់ គ្រោតគ្រាត រឹងចចេស មិនគួរដល់ការងារ ឈើ, ង, កោង, ព្រោះហេតុដូច្នោះ ធម៌ ៦ គូមានបស្សទ្ធិជាដើម ទើបព្រះអង្គមិនទ្រង់កាន់យកឡើយ ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្ដែងបទ ៣២ ដែលឡើងកាន់ព្រះបាលីដោយអំណាចនៃអង្គរបស់ចិត្ត តាមលំដាប់ត្រឹមតែប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងយេវាបនកធម៌ ទើបត្រាស់ព្រះពុទ្ធវចនៈមានជាអាទិ៍ថា **“យេ វា បន តស្មឹ សមយេ** = ឬថា នាមធម៌ដែលអាស្រ័យគ្នាហើយកើតឡើងសូម្បីដទៃណា រមែងមានក្នុងសម័យនោះ” ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យមានជាអាទិ៍ថា **យេវាបនកធម៌** នោះ តទៅ ៖

សូម្បីក្នុងអកុសលចិត្តទាំងអស់ ធម៌ទាំង ១០ នោះប៉ុណ្ណោះ គឺ ឆន្ទៈ អធិមោក្ខៈ មនសិការៈ មានៈ ឥស្សា មច្ឆរិយៈ ថីនៈ មិទ្ធៈ ឧទ្ធច្ចៈ និងកុក្កុច្ចៈ ជាយេវាបនកធម៌មានមកក្នុងព្រះសូត្រ, រមែងប្រាកដក្នុងបទនៃព្រះសូត្រ ។

ព្រោះហេតុដូច្នោះ ខ្ញុំទើបពោលទុកក្នុងទីនេះ, ចំណែកក្នុងអកុសលចិត្ត

នេះមានយេវាបនកធម៌ ៤ ប្រការ ពោលគឺជាអង្គដែលពិតប្រាកដ គឺ ឆន្ទៈ អធិមោក្ខៈ មនសិការៈ និងឧទ្ធច្ចៈ ។

ក្នុង**យេវាបនកធម៌**ទាំងនោះ ធម៌មាន**ឆន្ទៈ**ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយក្នុងខាងក្រោយនោះចុះ ក៏ធម៌មានឆន្ទៈជាដើម ( **ឆន្ទៈ ១ អធិមោក្ខ ១ មនសិការៈ ១ តត្រមជ្ឈត្តតា ១** តាមន័យដែលពោលហើយនោះ) ជាកុសលតែម្យ៉ាង, ធម៌មានឆន្ទៈជាដើម (គឺ **ឆន្ទៈ ១ អធិមោក្ខៈ ១ មនសិការៈ ១ ឧទ្ធច្ចៈ ១**) ទាំងនេះជា **អកុសល** ។ ចំណែកធម៌ក្រៅនេះ សេចក្ដីដែលចិត្តរាយមាយ ឈ្មោះថា **ឧទ្ធច្ចៈ** ៕

## លក្ខណាទិចតុក្កៈនៃឧទ្ធច្ចៈ

**អវូបសមនលក្ខណំ** ឧទ្ធច្ចៈនោះមានសេចក្ដីមិនចូលទៅស្ងប់ជាលក្ខណៈដូចរលកទឹករញ្ជួយព្រោះខ្យល់ផាត់ ។

**អនវដ្ឋានរសំ** មានសេចក្ដីមិនតាំងនៅមាំជារស ដូចទង់ជ័យ និងទង់ផ្ទាំងសំពត់ បោកទៅព្រោះខ្យល់ផាត់ ។

**ភន្តត្តបច្ចុប្បដ្ឋានំ** មានសេចក្ដីស្ទុះទៅជាបច្ចុប្បដ្ឋាន

**ចេតសោ អវូបសមោ អយោនិសោ មនសិការបទដ្ឋានំ** មានសេចក្ដីមិនចូលទៅស្ងប់ដូចផេះហុយថ្កោលឡើង ព្រោះផ្ទាំថ្មដែលធ្លាក់ចុះ, មានមនសិការដោយឧបាយមិនត្រូវទំនងជាបទដ្ឋាន ។ គប្បីជ្រាបថា ជាសេចក្ដីរវើរវាយនៃចិត្ត ។

បទធម៌ ៣២ មានផស្សៈជាដើម (មានអវិក្ខេបៈជាទីបំផុត) ជាមួយនឹងបទធម៌មានឆន្ទៈជាដើមដែលត្រាស់ដោយអំណាចនៃយេវាបនកធម៌ រួមទាំងអស់ជាបទធម៌ ៣៦ ក្នុងវារៈនៃធម្មុទ្ទេសនេះ, បទធម៌ដែលមកក្នុងបាលីទាំងនោះ ដកបទធម៌ជាយេវាបនកធម៌ដែលពិតប្រាកដ ៤ យ៉ាងចេញ សល់ ៣២ ប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ តែក្នុងនិទ្ទេសនៃអកុសលនេះ ព្រោះវៀរធម៌ដែលមិនកាន់យកទើបជាធម៌ ១៦ គឺពួកធម៌ ៥ មានផស្សៈជាដើម[៣៨] វិតក្កៈ ១ វិចារៈ ១ បីតិ ១ ឯកគ្គតាចិត្ត ១ វីរិយិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ មិច្ឆាទិដ្ឋិ ១ លោភៈ ១ មោហៈ ១ អហិរិកៈ ១ និងអនោត្តប្បៈ ១ ។

បណ្ដាធម៌ទាំង ១៦ នោះ ធម៌ ៧ ចែកមិនបាន, ធម៌ ៩ ចែកបាន ។ ធម៌ ៧ ដែលចែកមិនបានយ៉ាងណា ? ធម៌ដែលចែកមិនបានទាំងនេះ គឺ ផស្សៈ សញ្ញា ចេតនា វិចារៈ បីតិ ជីវិតិន្ទ្រិយ និងមោហៈ ។ ចំណែកធម៌ដែលចែកបានទាំង ៩ នេះគឺ វេទនា ចិត្តៈ វិតក្កៈ ឯកគ្គតាចិត្ត វីរិយិន្ទ្រិយ មិច្ឆាទិដ្ឋិ អហិរិកៈ អនោត្តប្បៈ និងលោភៈ ។

បណ្ដាធម៌ទាំង ៩ នោះ ធម៌ ៦ យ៉ាងចែកបាន ២ ឋាន, ធម៌មួយយ៉ាងចែកបាន ៣ ឋាន, ធម៌មួយយ៉ាងចែកបាន ៤ ឋាន, និងធម៌ម្យ៉ាងទៀត ចែកបាន ៦ ឋាន ។ ជាយ៉ាងណា ? ធម៌ ៦ យ៉ាងទាំងនេះគឺ ចិត្តៈ វិតក្កៈ មិច្ឆាទិដ្ឋិ អហិរិកពលៈ អនោត្តប្បពលៈ និងលោភៈ ចែកបាន ២ ឋាន ។ ពិតណាស់ បណ្ដាធម៌ទាំង ៦

---

[៣៨] ផស្សៈ វេទនា សញ្ញា ចេតនា និងចិត្ត ។

នោះសម្រាប់ **ចិត្ត**, សំឡឹងដល់ផស្សបញ្ចកៈហៅថា "ចិត្ត" , សំឡឹងដល់ឥន្ទ្រិយ ហៅថា "មនិន្ទ្រិយ" ។ វិតក្កសំឡឹងដល់អង្គឈានទាំងឡាយ ហៅថា "វិតក្កៈ", សំឡឹង ដល់អង្គមគ្គទាំងឡាយហៅថា "មិច្ឆាសង្កប្បៈ" ។ **មិច្ឆាទិដ្ឋិ** ក៏ជាមិច្ឆាទិដ្ឋិដូចគ្នា ទាំងក្នុងអង្គមគ្គ ទាំងក្នុងកម្មបថ ។ **អហិរិកៈ** សំឡឹងដល់ពលៈទាំងឡាយហៅថា "អហិរិកពលៈ" , សំឡឹងដល់ពួកពីរនៃធម៌ជាគ្រឿងញ៉ាំងលោកឱ្យវិនាស ហៅថា "អហិរិក" ។ សូម្បីក្នុងអនោត្តប្បៈក៏ន័យនេះដែរ ។ លោភៈ សំឡឹងដល់មូល ហៅថា "លោភៈ", សំឡឹងដល់កម្មបថ ហៅថា "អភិជ្ឈា" ។ ធម៌ ៦ យ៉ាងនេះ លោកចែកក្នុងឋានទាំងពីរដោយប្រការដូច្នេះ ។

ចំណែកវេទនា សំឡឹងដល់ផស្សបញ្ចកៈហៅថា "វេទនា" ។ សំឡឹងដល់អង្គឈានទាំងឡាយ ហៅថា "សុខ" ។ សំឡឹងដល់ឥន្ទ្រិយទាំងឡាយ ហៅថា "សោមនស្សិន្ទ្រិយ" ។ ធម៌ (វេទនា) តែម្យ៉ាង ចែកបាន ៣ ឋាន ដោយប្រការដូច្នេះ ។ ក៏វីរិយៈ សំឡឹងដល់ឥន្ទ្រិយទាំងឡាយ ហៅថា "វីរិយិន្ទ្រិយ" , សំឡឹងដល់អង្គមគ្គទាំងឡាយហៅថា "មិច្ឆាវាយាម" សំឡឹងដល់ពលៈហៅថា "វីរិយពលៈ" , សំឡឹងដល់ធម្មបិដ្ឋិទុកៈ ហៅថា "បគ្គាហៈ" ; ធម៌ (វីរិយៈ) តែម្យ៉ាងនេះ លោកចែកទុក ៤ ឋាន ដោយប្រការដូច្នេះ ។ ក៏**សមាធិ** សំឡឹងដល់អង្គឈានទាំងឡាយ ហៅថា "ឯកគ្គតាចិត្ត" , សំឡឹងដល់ឥន្ទ្រិយ ហៅថា "សមាធិន្ទ្រិយ", សំឡឹងដល់អង្គមគ្គទាំងឡាយហៅថា "សមាធិ" , សំឡឹងដល់ពលៈទាំងឡាយ ហៅថា "សមាធិពលៈ" , សំឡឹងដល់ធម្មបិដ្ឋិទុកៈហៅថា "សមថៈ" ដោយ

អំណាចនៃធម៌ពួកមួយក្នុងទុតិយទុកៈ ហៅថា “អវិក្ខេបៈ” ក្នុងទុកៈទី ៣ ។ ធម៌ (សមថៈ) នេះតែម្យ៉ាង លោកចែកទុក ៦ ឋាន ដោយប្រការដូច្នេះ ។

ក៏សូម្បីធម៌ទាំងអស់នេះចាត់ជា ៩ កងគឺ

**ផស្សបញ្ចកៈ ១ អង្គឈាន ១ ឥន្ទ្រិយ ១ អង្គមគ្គ ១ មូល ១ ពលៈ ១ កម្មបថ ១ លោកនាសកធម៌ ១ និងបិដ្ឋិទុកៈ ១ ។**

បណ្តាធម៌ ៩ កងនោះ ពាក្យណាដែលខ្ញុំគប្បីពោល ពាក្យនោះ ខ្ញុំបានពោលទុកក្នុងនិទ្ទេសនៃកុសលចិត្តដួងទី ១ ហើយ ៕

**ចប់កថាពោលដោយធម្មុទ្ទេសវារៈ**

## អដ្ឋកថាសម្តែងអំពីនិទ្ទេសវារៈ

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសឯកគ្គតានៃចិត្តក្នុងនិទ្ទេសវារៈជាមុន ៖

ពីរបទនេះដែលត្រាស់ថា **សណ្ឋិតិ** = ការតាំងនៅ, **អវដ្ឋិតិ** = ការតាំងនៅស៊ប់, ជាពាក្យវេវចនៈរបស់បទ **ឋិតិ** = ការតាំងនៅនោះឯង ។ ចំណែកពាក្យណាដែលត្រាស់ទុកក្នុងនិទ្ទេសនៃកុសលថា “ឈ្មោះថា **អវដ្ឋិតិ** = ការតាំងមាំ, ព្រោះអត្ថថា ស្ទង់ចុះ គឺចូលទៅកាន់អារម្មណ៍ហើយតាំងមាំ” ដូចនេះ, ពាក្យនោះ មិនបានក្នុងនិទ្ទេសនៃអកុសលនេះទេ ព្រោះថា ក្នុងអកុសលឯកគ្គតានៃចិត្តមានកម្លាំងខ្សោយ ព្រោះហេតុនោះ ពីរបទថា (**សណ្ឋិតិ** និង **អវដ្ឋិតិ**) នេះ ខ្ញុំសម្តែងទុកក្នុងបទក្រោយតាមដែលពោលហើយនោះឯង ។

ធម៌ដែលឈ្មោះថា **អវិសាហារោ** (ការមិនរាយមាយចិត្ត) ព្រោះជាសភាពផ្ទុយគ្នាជាមួយនឹងការរាយមាយ ដែលប្រព្រឹត្តទៅដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆា ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃអកុសលនេះ ទើបមិនបានអត្ថសូម្បីដូចនេះ ។ តែក្នុងសហជាតធម៌ ចិត្តឈ្មោះថា **អវិសារ** ព្រោះអត្ថថា រមែងមិនរំសាយទៅ ។ ដែលឈ្មោះថា **អវិក្ខេប:** = ការមិនរាយមាយ ព្រោះអត្ថថា រមែងមិនរាយមាយទៅ ។ ភាវៈនៃចិត្តដែលមិនរំសាយទៅដោយអំណាចនៃឯកគ្គតាចិត្ត ដែលជាអកុសល ឈ្មោះថា **អវិសាហដមានសតា** = ភាវៈនៃចិត្តមិនរំសាយទៅ ។ ឈ្មោះថា **សមាធិពលៈ** ព្រោះអត្ថថា រមែងមិនញាប់ញ័រ ក្នុងសហជាតធម៌ទាំងឡាយ ។ ឈ្មោះថា **មិច្ឆាសមាធិ** ព្រោះតាំងនៅមាំតាមសេចក្តីមិនពិត គប្បីជ្រាបសេចក្តីក្នុងអធិការនៃអកុសលនេះ យ៉ាងនេះចុះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវីរិយិន្ទ្រិយតទៅ ៖

ន័យមានជាអាទិ៍ថា "ក៏នេះជាសេចក្តីព្យាយាមដើម្បីបន្ទូរបន្ថយកាមទាំងឡាយ" , ចំណែកណាដែលខ្ញុំពោលខាងក្រោយ ន័យនោះរមែងមិនបានក្នុងនិទ្ទេសនៃអកុសលនេះទេ ។ គប្បីជ្រាបថា ឈ្មោះថា **វីរិយពលៈ** ដោយអត្ថថា មិនញាប់ញ័រក្នុងសហជាតធម៌ទាំងឡាយប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃមិច្ឆាទិដ្ឋិតទៅ ៖

សភាវៈដែលឈ្មោះថា **មិច្ឆាទិដ្ឋិ** ដោយអត្ថថា ឃើញតាមសេចក្តីមិនចម្រើន ។ ឈ្មោះថា **ទិដ្ឋិគតៈ** (ការឃើញទៅខាងទិដ្ឋិ) ព្រោះអត្ថថា ការឃើញនេះប្រព្រឹត្តទៅក្នុងទិដ្ឋិទាំងឡាយ, ព្រោះជាសភាពស្ទង់ចុះខាងក្នុងទិដ្ឋិ ៦២ ។

សូម្បីសេចក្ដីនៃទិដ្ឋិនេះ ខ្ញុំបានពោលហើយខាងក្រោយនោះឯង ។ ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋិគហណៈ** (ព្រៃក្រាស់ គឺទិដ្ឋិ) ព្រោះអត្ថថា ឈានកន្លងទៅដោយលំបាក ដូចស្មៅក្រាស់ ព្រៃក្រាស់ ភ្នំក្រាស់ ។ ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋិកន្តារ** (កន្តារគឺទិដ្ឋិ) ដោយអត្ថថា គួរសង្ស័យ និងមានភ័យចំពោះមុខ ដូចកន្តារចោរ កន្តារសត្វសាហាវ កន្តារខ្សាច់ កន្តារទឹក កន្តារទុព្ភិក្ខភ័យ ។ ឈ្មោះថា **ទិដ្ឋិវិសូកាយិកៈ** = ការឃើញជាសត្រូវចំពោះមិច្ឆាទិដ្ឋិ, ដោយអត្ថថា ជំទាស់ ផ្ទុយគ្នាជាមួយសម្មាទិដ្ឋិ ។ ពិតមែន ការឃើញខុស កាលកើតរមែងជំទាស់ និងផ្ទុយពីសម្មាទិដ្ឋិទៅ ។ ដែលឈ្មោះថា **ទិដ្ឋិវិប្ផន្ទិកៈ** = ការប្រែប្រួលនៃទិដ្ឋិ, ព្រោះអត្ថថា ប្រែប្រួលខុសនៃទិដ្ឋិ ព្រោះគ្រាខ្លះ ក៏កាន់យកការទៀង គ្រាខ្លះ ក៏កាន់យកការដាច់សូន្យ ។ ព្រោះថា អ្នកមានការឃើញខុស រមែងមិនអាចតាំងនៅក្នុងវត្ថុតែមួយ, គឺគ្រាខ្លះស្រេបតាមការទៀង, គ្រាខ្លះក៏ស្រេបតាមការដាច់សូន្យ ។ ទិដ្ឋិនោះឯង ឈ្មោះថា **សំយោជនៈ** ដោយអត្ថថា ជាគ្រឿងចង ព្រោះហេតុនោះ ទើបឈ្មោះថា **ទិដ្ឋិសំយោជនៈ** ។ ដែលឈ្មោះថា **គាហៈ** = ប្រកាន់, ព្រោះអត្ថថា រមែងប្រកាន់អារម្មណ៍ទុកមាំ ដូចសត្វសាហាវមានក្រពើជាដើម យកមាត់ចាប់ខាំមនុស្សទុកយ៉ាងមាំដូច្នោះ ។ ដែលឈ្មោះថា **បតិដ្ឋាហៈ**[៣៩] = ការតាំងមាំ, ព្រោះតាំងទុកដោយចំពោះ ។ ពិតមែន ការតាំងមាំនេះ តាំងមាំហើយប្រកាន់ទុកដោយការប្រព្រឹត្តទៅយ៉ាងមានកម្លាំង ។ ដែលឈ្មោះថា **អភិនិវេស** = ការប្រកាន់មាំ, ព្រោះ

---

[៣៩] ក្នុងធម្មសង្គណីជា បដិគ្គាហៈ តែច្បាប់ខ្លះថា បតិដ្ឋវាហៈ ។

អត្ថថា រមែងតាំងមាំដោយភាវៈជារបស់ទៀងជាដើម ។ ឈ្មោះថា **បរាមាសៈ** = ការប្រកាន់ខុស, ព្រោះអត្ថថា ឈានកន្លងសភាវធម៌ហើយ កាន់យកដោយអាការដទៃដោយអំណាចនៃការទៀងជាដើម ។ ដែលឈ្មោះថា **កុម្មគ្គៈ** = ផ្លូវអាក្រក់, ព្រោះអត្ថថា ជាផ្លូវដែលបណ្ឌិតខ្ពើម ព្រោះជាផ្លូវនាំសេចក្ដីវិនាសមកឱ្យ, ឬជាផ្លូវនៃអបាយទាំងឡាយដែលបណ្ឌិតគួរខ្ពើម ។ ដែលឈ្មោះថា **មិច្ឆាបថៈ** (ផ្លូវខុស) ព្រោះជាផ្លូវតាមសេចក្ដីមិនពិត ។ ដែលឈ្មោះថា **មិច្ឆត្តៈ** (ភាវៈដែលខុស) ព្រោះជាសភាវៈខុសដូចគ្នា ។ ដូចយ៉ាងថា អ្នកវង្វេងទិស សូម្បីប្រកាន់មាំថា "ផ្លូវនេះឈ្មោះថាជាផ្លូវរបស់ស្រុកនោះ" ដូចនេះ ក៏មិនញ៉ាំងបុគ្គលឱ្យដល់ស្រុកបាន យ៉ាងណា, បុគ្គលអ្នកមិច្ឆាទិដ្ឋិ សូម្បីប្រកាន់ថា "ផ្លូវនេះជាផ្លូវទៅកាន់សុគតិ" ដូចនេះ ក៏មិនអាចទៅកាន់សុគតិបានដូច្នោះដែរ ។ ឈ្មោះថា ផ្លូវខុស ព្រោះជាផ្លូវតាមសេចក្ដីមិនពិត ។ ផ្លូវនេះ ឈ្មោះថា **មិច្ឆត្តៈ** ព្រោះមានសភាពខុស ។ ឈ្មោះថា **តិត្ថៈ** (លទ្ធិដូចកំពង់) ព្រោះជាទីកន្លែងដែលពួកមនុស្សពាលឆ្លងទៅ ដោយការងារទៅមកក្នុងទីនោះៗឯង ។ តិត្ថៈ (គឺលទ្ធិ) នោះផង ជាអាយតនៈ (អណ្ដូងកើត) នៃ សេចក្ដីវិនាសផង ព្រោះហេតុនោះ ទើបឈ្មោះថា **តិត្ថាយតនៈ** (លទ្ធិជាអណ្ដូងកើតនៃសេចក្ដីវិនាស) ។ម្យ៉ាងទៀត ឈ្មោះថា តិត្ថាយតនៈ ព្រោះអត្ថថា ជាអាយតនៈ ដោយសេចក្ដីសម្គាល់ថា ជាចំណែកសញ្ជាតិ និងដោយសេចក្ដីសម្គាល់ថាជាទីអាស្រ័យនៃពួកតិត្ថិយខ្លះ ។ ដែលឈ្មោះថា **វិបរិយេសគ្គាហៈ** = ការកាន់យកដោយវិបល្លាស, ព្រោះអត្ថថា ជាការកាន់យកសភាវៈដែលពិចារណាខុស, ឬថាជាការកាន់យកសភាវៈដែលផ្ទុយគ្នា, អធិប្បាយថា កាន់យកវិបល្លាស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ**អហិរិកៈ** និង **អនោត្តប្បៈ**តទៅ ៖

បណ្ឌិតគប្បីជ្រាបសេចក្តីនៃអហិរិកៈ និងអនោត្តប្បៈដោយបរិយាយផ្ទុយគ្នាក្នុងនិទ្ទេសនៃហិរិ និងឱត្តប្បៈ ។ ក៏បណ្ឌិតគប្បីជ្រាបអហិរិកពលៈ និងអនោត្តប្បពលៈ ព្រោះអត្ថថា មិនញាប់ញ័រក្នុងសហជាតធម៌ទាំងឡាយប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **លោភៈ** និង **មោហៈ** តទៅ ៖

សភាវៈដែលឈ្មោះថា **លោភៈ** ព្រោះអត្ថថា ចង់បាន ។ អាការនៃលោភៈឈ្មោះថា **លុព្ភនា** (កិរិយាដែលលោភ), ចិត្តដែលសម្បយុត្តដោយលោភៈ, ឬភាវៈនៃបុគ្គលដែលប្រកបដោយសេចក្តីចង់បាន ឈ្មោះថា លុព្ភិតៈ, ភាវៈនៃចិត្តដែលសម្បយុត្តដោយលោភៈ ឬភាវៈនៃបុគ្គលអ្នកប្រកបដោយលោភៈ ឈ្មោះថា **លុព្ភិតត្តៈ** (លោភៈ); ឈ្មោះថា **សារាគៈ** (សេចក្តីស្រឡាញ់) ព្រោះរមែងស្រឡាញ់ ។ អាការនៃសេចក្តីស្រឡាញ់ ឈ្មោះថា **សារជ្ជនា** (កិរិយាដែលស្រឡាញ់); ភាវៈនៃចិត្តដែលស្រឡាញ់ ឈ្មោះថា **សារជ្ជិតត្តៈ** (សេចក្តីស្រឡាញ់), ឈ្មោះថា **អភិជ្ឈា** ដោយអត្ថថា សំឡឹងរំពៃ ។

**ការណៈ** (ហេតុ) ព្រះមានព្រះភាគត្រាស់ដោយសព្ទថា លោភៈទៀត; ព្រោះលោភៈជាអកុសលផង ជាមូលផង ទើបឈ្មោះថា អកុសលមូល; ម្យ៉ាងទៀត លោភៈនោះជាមូលរបស់អកុសលទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា **អកុសលមូល** ។

សភាវៈដែលឈ្មោះថា **អញ្ញាណ** (សេចក្តីមិនដឹង) ព្រោះបដិបក្សចំពោះ

ញាណ ។ ឈ្មោះថា **អទស្សនៈ** (ការមិនឃើញ) ព្រោះបដិបក្ខចំពោះការឃើញ ។ ឈ្មោះថា **អនភិសម័យ** (ការមិនត្រាស់ដឹង) ព្រោះអត្ថថា ជាសភាវៈប្រឈមមុខក៏មិនត្រាស់ដឹងតាមធម៌បាន គឺរមែងមិនដល់ដោយប្រពៃ ។ ឈ្មោះថា **អនុពោធ** (ត្រាស់ដឹងនូវធម៌ដោយសមគួរ) ព្រោះអត្ថថា រមែងត្រាស់ដឹងធម៌ដោយសមគួរ), ដែលឈ្មោះថា **អននុពោធ** (ការមិនត្រាស់ដឹងធម៌ដោយសមគួរ) ព្រោះសេចក្តីដែល**អននុពោធនោះ** ជាបដិបក្សចំពោះអនុពោធនោះ ។ ឈ្មោះថា **អសម្ពោធ** (មិនដឹងតាមសេចក្តីពិត) ព្រោះអត្ថថា មិនប្រកបជាមួយសភាវៈទាំងឡាយ មានការមិនទៀងជាដើម ហើយត្រាស់ដឹង ។ ឈ្មោះថា **អសម្ពោធ** ព្រោះអត្ថថា ត្រាស់ដឹងនូវធម៌មិនស្ងប់ មិនប្រពៃដូច្នេះខ្លះ ។ ឈ្មោះថា **អប្បដិវេធ** (មិនចាក់ធ្លុះ) ព្រោះអត្ថថា មិនត្រាស់ដឹងធម៌ គឺសច្ចៈ ៤ ។ ឈ្មោះថា **អសង្គាហណា** (មិនកាន់យកឱ្យត្រឹមត្រូវ) ព្រោះអត្ថថា មិនកាន់យកព្រម សូម្បីធម៌មួយក្នុងចំណោមធម៌ទាំងឡាយមានរូបជាដើម ដោយសាមញ្ញលក្ខណៈ មានការមិនទៀងជាដើម ។ ឈ្មោះថា **អបរិយោគាហណៈ** (មិនស្ទង់ចុះដោយជុំវិញ) ព្រោះអត្ថថា រមែងមិនស្ទង់ចុះកាន់ធម៌នោះៗ ឯង ។ ឈ្មោះថា **អសមបេក្ខនា** (ការមិនពិនិត្យ) ព្រោះអត្ថថា រមែងមិនសំឡឹងមើលដោយស្មើ ។ ឈ្មោះថា **អបច្ចវេក្ខណា** (ការមិនពិចារណា) ព្រោះអត្ថថា មិនសំឡឹងចំពោះសភាវធម៌ទាំងឡាយ ។ ឈ្មោះថា **អបច្ចក្ខកម្មំ** (ការមិនធ្វើឱ្យប្រចក្ស) ព្រោះអត្ថថា សូម្បីកម្មមួយខ ក៏មិនប្រចក្សដល់សភាវៈនេះ ក្នុងកុសលកម្ម និងអកុសលកម្មទាំងឡាយដែលប្រព្រឹត្តិទៅ ដោយវិបរិតខ្លះ ដោយមិនមានការកំណត់តាមសភាវៈខ្លះ, ម្យ៉ាងទៀត ឈ្មោះថា ការ

ធ្វើឱ្យប្រចក្សដល់ធម៌អ្វីៗដោយខ្លួនឯងមិនបាន ព្រោះហេតុនោះ ទើបឈ្មោះថា **អបច្ចក្ខកម្ម** ។ ឈ្មោះថា **ទុម្មេជ្ឈៈ** (ការខ្សោយបញ្ញា) ព្រោះអត្ថថា កាលបើមោហៈនៅមិនកើតឡើង ចិត្តសន្តានណា គប្បីជាចិត្តបរិសុទ្ធ គឺស្អាតផូរផង់, ចិត្តសន្តានដែលបរិសុទ្ធនោះ គឺមោហៈនេះ ប្រទូស្តរ៉ាយហើយ ។ ឈ្មោះថា **ពាល្យៈ** (សេចក្តីល្ងង់ខ្លៅ) ព្រោះអត្ថថា ជាសភាវៈរបស់ពួកពាល ។ ឈ្មោះថា **មោហៈ** (ការវង្វេង) ព្រោះអត្ថថា រមែងវង្វេង ។ មោហៈមានកម្លាំងឈ្មោះថា **បមោហៈ** (សេចក្តីវង្វេងស្លុង) ។ ឈ្មោះថា **សម្មោហៈ** (វង្វេងវង្វាន់) ព្រោះអត្ថថា រមែងវង្វេងដោយសព្វគ្រប់ ។ ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា មិនមែនវិជ្ជា ព្រោះជាបដិបក្សចំពោះវិជ្ជា ។ ការសម្គាល់របស់ **ឱឃៈ យោគៈ និងគន្ថៈ** ខ្ញុំពោលទុកហើយទាំងអស់ ។ ឈ្មោះថា **អនុស័យ** ព្រោះអត្ថថា ដេកសម្ងំ ដោយអត្ថថា មានកម្លាំង ។ ឈ្មោះថា **បរិយុដ្ឋាន** ព្រោះអត្ថថា រមែងរួបរឹត គឺគ្របសង្កត់ចិត្ត ។ ឈ្មោះថា **លង្គី** (សន្ទះ) ព្រោះអត្ថថា រមែងមិនអាចដើម្បីបែរមុខទៅរកប្រយោជន៍ រមែងកន្លងហួសដោយពិត ព្រោះមិនមានការកាន់យកប្រយោជន៍បាន គឺរមែងទៅបានលំបាក ម្យ៉ាងទៀត ឈ្មោះថា **លង្គី** ព្រោះអត្ថថា ដកឡើងបានលំបាក ។ ដូចយ៉ាងថា សន្ទះ ពោលគឺគន្លឹះដែកធំជារបស់ដកឡើងបានដោយលំបាកយ៉ាងណា, សូម្បីអវិជ្ជានេះ ក៏ដូច្នោះដែរ ប្រៀបដូចជាសន្ទះ ព្រោះហេតុនោះ អវិជ្ជានោះ ទើបឈ្មោះថា លង្គី (សន្ទះ) ។

ពាក្យដែលសល់មានសេចក្តីងាយស្រួលទាំងអស់ ព្រោះហេតុនោះ គប្បីជ្រាបសូម្បីសង្គហវារៈ និងសុញ្ញតវារៈ ដោយអត្ថ តាមន័យដែលពោលទុកក្នុងខាង

ក្រោយនោះឯង ៕

ចប់អកុសលចិត្តដួងទី ១

# អធិប្បាយអកុសលចិត្តដួងទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងអកុសលចិត្តដួងទី ២ តទៅ ៖

បទថា **សសំខារេន** (ដោយមានការបបួល) ជាបទដទៃពីគ្នា, ពាក្យថា ដោយមានការទាក់ទាញនោះ ខ្ញុំពោលទុកខាងក្រោយនោះហើយ ។ ក៏អកុសលចិត្តនេះ រមែងកើតឡើងដល់បុគ្គលអ្នកប្រកបដោយសោមនស្សក្នុងអារម្មណ៍ទាំង ៦ អ្នកញ៉ាំងលោភៈឱ្យកើតឡើង ហើយប្រកាន់ខុសដោយន័យជាអាទិ៍ថា "**នេះជាសត្វ, នេះជាសត្វ**" ក៏ពិតមែនហើយ, ប៉ុន្តែថា ក្នុងកាលណា កុលបុត្រប្រាថ្នាកុមារិការបស់ត្រកូលមិច្ឆាទិដ្ឋិ, ឯត្រកូលពួកនោះ រមែងមិនឱ្យកុមារិកា ដោយអាងថា "ពួកលោកមានទិដ្ឋិដទៃ" , តែខាងក្រោយមក ពួកញាតិដទៃប្រាប់ឱ្យយកឱ្យ ដោយការយល់ព្រមគ្នាថា "ពួកលោកចូរធ្វើវត្តដែលកុលបុត្រនេះនឹងធ្វើ" ដូច្នេះ, កុលបុត្រនោះព្រមនឹងពួកញាតិ ទើបនាំគ្នាចូលទៅរកពួកតិរ្ថិយនោះខាងក្រោយ, ដើមឡើយនៅជាអ្នកទាក់ទើចិត្ត តែបើកាលកន្លងទៅៗ ក៏ពេញចិត្តលទ្ធិរមែងដល់ទិដ្ឋិដោយគិតថា "កិរិយានៃពួកតិរ្ថិយទាំងនោះ ជាទីពេញចិត្ត ក្នុងកាលមានសភាពដូចនេះ គប្បីជ្រាបថា អកុសលចិត្តនេះ រមែងបាន" ព្រោះការកើតឡើង ដោយសម្បយោគ (ការប្រកបព្រមគ្នា) ព្រមដោយឧបាយ ព្រោះអកុសលចិត្តនោះជាសសង្ខារិក (មានការបបួលដឹកនាំ) ។

ចំណែកក្នុង**យេវាបនកធម៌**ទាំងឡាយ ថីនមិទ្ធជាធម៌ក្រៃលែង ក្នុងអកុសលចិត្តដួងទី ២ នេះ ។ បណ្តាអកុសលធម៌ទាំងនោះ សភាពនៃចិត្តរួញរា ឈ្មោះថា **ថីនៈ** ។ ការងងុយ ឈ្មោះថា **មិទ្ធៈ**, អធិប្បាយថា ការមិនឧស្សាហ៍ ការមិនអាច និងការសម្លាប់សតិ ។ ថីនៈផង មិទ្ធៈផង ឈ្មោះថា **ថីនមិទ្ធៈ** ។ ក្នុងអកុសលទាំងពីរនេះ **ថីនៈ** មិនមានសេចក្តីឧស្សាហ៍ជាលក្ខណៈ = **អនុស្សាហនលក្ខណំ**, មានការកម្ចាត់វិរិយៈជារស = **វីរិយវិនោទនរសំ**, មានសេចក្តីនឿយណាយ (លិចចុះ) ជាបច្ចុប្បដ្ឋាន = **សំសីទនបច្ចុប្បដ្ឋានំ** ។

មិទ្ធៈមានសេចក្តីមិនគួរដល់ការងារជាលក្ខណៈ = **អនុស្សាហនលក្ខណំ**, មានការបិទបាំងជារស = **ឱនហនរសំ**, មានសេចក្តីរួញរាជាបច្ចុប្បដ្ឋាន = **លីនតាបច្ចុប្បដ្ឋានំ**, ឬមានសេចក្តីងងុយ និងលង់លក់ជាបច្ចុប្បដ្ឋាន = **បចលាយិកនិទ្ទាបច្ចុប្បដ្ឋានំ** ។ ថីនមិទ្ធៈទាំងពីរនេះឯង មានមនសិការដោយឧបាយមិនត្រូវទំនងក្នុងសភាវៈទាំងឡាយមានសេចក្តីមិនត្រេកអរ មានសេចក្តីខ្ជិលច្រអូស សេចក្តីអផ្សុក និងមិតពាត់កាយជាដើមជាបទដ្ឋាន ៕

**អកុសលចិត្តដួងទី ២ ចប់**

---

## អធិប្បាយអកុសលចិត្តដួងទី ៣

អកុសលចិត្តដួងទី ៣ រមែងកើតឡើងដល់បុគ្គលអ្នកប្រកបដោយសោមនស្ស ក្នុងអារម្មណ៍ទាំង ៦ អ្នកដែលញ៉ាំងលោភៈឱ្យកើតឡើងហើយ មិន

ប្រកាន់ខ្ជាប់ដោយន័យថា **“នេះជាសត្វ នេះជាសត្វ”** ជាដើម សំឡឹងមើលនូវព្រះរាជា កីឡាចំបាប់ ការច្បាំងគ្នា និងការលេងរបាំជាដើម ឬមានការខ្វល់ខ្វាយក្នុងការស្តាប់សំឡេងដែលជាទីពេញចិត្តជាដើម ។ ក្នុងអធិការនៃអកុសលដួងទី ៣ នេះ មានអង្គដែលដូចគ្នា ៥ អង្គ ព្រមនឹងមានះ ។ បណ្តាអង្គទាំងនោះ សភាវៈដែលឈ្មោះថា **មានះ** ព្រោះអត្ថថា រមែងប្រកាន់ខ្លួន = **មញ្ញតីតិ មានោ** ។

**ឧន្នតិលក្ខណោ** មានះនោះ មានការឃោរឃៅជាលក្ខណៈ

**សម្បគ្គហនរសោ** មានការលើកតម្កើងសម្បយុត្តធម៌ក្រៃលែងជារស

**កេតុកម្យតាបច្ចុប្បដ្ឋានោ** មានសេចក្តីប្រាថ្នាខ្ពស់ ដូចទង់ដែលគេលើកឡើងហើយជាបច្ចុប្បដ្ឋាន ។

**ទិដ្ឋិវិប្បយុត្តលោភបទដ្ឋានោ** មានលោភៈមិនប្រកបដោយទិដ្ឋិជាបទដ្ឋាន ។

គប្បីជ្រាបថា ដូចជាមនុស្សឆ្កួត ៕

**អកុសលចិត្តដួងទី ៣ ចប់**

---

# អធិប្បាយអកុសលចិត្តដួងទី ៤

អកុសលចិត្តដួងទី ៤ រមែងកើតឡើងក្នុងឋានមានប្រការដូចពោលនោះឯង គឺក្នុងឋានទាំងឡាយមានអត្ថយ៉ាងនេះថា ក្នុងកាលណា ពួកជនស្តោះទឹកមាត់ទៅ ឬរោយធូលីជើងទៅលើក្បាល, ក្នុងកាលនោះ អកុសលចិត្តដួងទី ៤ រមែងកើតឡើងដល់បុគ្គលទាំងឡាយអ្នកមើលក្នុងចន្លោះៗ ដោយសេចក្តីឧស្សាហ៍ដើម្បីគេចចេញពីទឹកមាត់ និងធូលីជើងនោះ នឹងកើតដល់បុគ្គលទាំងឡាយ អ្នកមើលតាម

ចន្លោះនោះៗ បើសេចក្ដីក្រវល់ក្រវាយប្រព្រឹត្តទៅ ក្នុងកាលបើខ្លួនជារាជនាដកៈ (របាំព្រះរាជា) កំពុងចេញមកដូច្នេះ ។ ក្នុងអកុសលចិត្តដួងទី ៤ នេះ មានយេវាបនកធម៌ ៧ និង មានះ ថីនៈ មិទ្ធៈ សូម្បីអត្ថនៃអកុសលចិត្តទាំងពីរគឺ អកុសលចិត្តដួងទី ៣ និងទី ៤ រមែងបន្ថយមិច្ឆាទិដ្ឋិចេញ ។ គប្បីជ្រាបការគណនាធម៌ដោយអំណាចនៃធម៌ដែលសេសទាំងឡាយ ព្រោះវៀរមិច្ឆាទិដ្ឋិនោះឯង ដោយប្រការយ៉ាងនេះចុះ ៕

អកុសលចិត្តដួងទី ៤ ចប់

---

# អធិប្បាយអកុសលចិត្តដួងទី ៥

អកុសលចិត្តដួងទី ៥ រមែងកើតដល់បុគ្គលជាមជ្ឈត្តៈ (ព្រងើយ) ដោយអំណាចនៃវេទនាក្នុងអារម្មណ៍ទាំង ៦ អ្នកញ៉ាំងលោកឱ្យកើត អ្នកដែលប្រកាន់ខ្លួនដោយន័យមានជាអាទិ៍ថា **“នេះជាសត្វ, នេះជាសត្វ”** ។ ក៏ក្នុងអកុសលចិត្តដួងទី ៥ នេះ ជាឧបេក្ខាវេទនាដែលមានក្នុងឋាននៃសោមនស្ស (ជំនួសសោមនស្សវេទនា រមែងបន្ថយបទនៃបីតិ ។ ពាក្យដែលសេសទាំងអស់ដូចនឹងអកុសលចិត្តដួងទីមួយនោះឯង ៕

អកុសលចិត្តដួងទី ៥ ចប់

# អធិប្បាយអកុសលចិត្តដួងទី ៦, ៧, ៨

សូម្បីអកុសលចិត្តដួងទី ៦ ទី ៧ និងទី ៨ គប្បីជ្រាបក្នុងន័យ ដែលពោលទុកក្នុងអកុសលចិត្តដួងទី ២ ទី ៣ និងទី ៤ នោះឯង ដោយការប្តូរបទនៃវេទនា និងបន្ថយបទនៃបីតិ ។ សូម្បីអធិបតីទាំង ២ គឺ សហជាតាអធិបតី និងអារម្មណាធិបតី រមែងបានក្នុងចិត្តដែលសហគតៈដោយលោភៈ ៨ ដួង ប៉ុណ្ណោះ ៕

លោភមូលចិត្ត ៨ ដួងចប់

---

# អធិប្បាយអកុសលចិត្តដួងទី ៩

អកុសលចិត្តដួងទី ៩ រមែងកើតឡើងដល់បុគ្គលអ្នកប្រកបដោយទោមនស្សក្នុងអារម្មណ៍ ៦ អ្នកញ៉ាំងបដិឃៈឱ្យកើតឡើងនោះឯង នឹងមានវិនិច្ឆ័យក្នុងវារៈពោលដោយការកំណត់សម័យ ៣ សម័យនៃអកុសលចិត្តដួងទី ៩ ជាមុន ។

ចិត្តដែលប្រទូស្តហើយ ឬចិត្តដែលបណ្ឌិតស្អប់ ព្រោះមានវេទនាដែលអាក្រក់ ព្រោះហេតុនោះ ចិត្តនោះទើបឈ្មោះថា **ទុម្មនោ** = អ្នកមានចិត្តអាក្រក់, ភាវៈនៃបុគ្គលអ្នកមានចិត្តអាក្រក់ ឈ្មោះថា **ទោមនស្ស**, អកុសលចិត្តសហគតៈដោយទោមនស្សនោះ ព្រោះហេតុដូច្នោះ អកុសលចិត្តនោះ ទើបឈ្មោះថា **ទោមនស្សសហគតៈ** = ប្រកបដោយទោមនស្ស ។

សភាវៈដែលឈ្មោះថា **បដិឃៈ** ព្រោះអត្ថថា រមែងប៉ះទង្គិចក្នុងអារម្មណ៍ដោយភាវៈដែលមិនពេញចិត្ត, អកុសលចិត្តដែលសម្បយុត្តដោយបដិឃៈនោះឈ្មោះថា **បដិឃសម្បយុត្ត** ។ ក្នុងធម្មុទ្ទេស, ទោមនស្សវេទនាមានមកហើយ

ក្នុងឋានសូម្បីទាំង ៣; ក្នុងឋានទាំង ៣ មានវេទនាជាដើមនោះ បទថា **វេទនា** មានសេចក្តីតាមដែលពោលទុកនោះឯង, បទថា **ទុក្ខ និងទោមនស្ស** ក៏ពោលទុកហើយដូចគ្នាដែរ ។ តែថាបើសម្តែងដោយលក្ខណៈជាដើម ៖

## លក្ខណាទិចតុក្កៈនៃទោមនស្ស

**អនិដ្ឋារម្មណានុភវនលក្ខណំ** ទោមនស្សមានការសោយអារម្មណ៍ ដោយមិនពេញចិត្តជាលក្ខណៈ ។

**យថា តថា វា អនិដ្ឋាការសម្ភោគរសំ** មានការសោយអាការមិនល្អយ៉ាងណានីមួយជារស ។

**ចេតសោភាពាធបច្ចុប្បដ្ឋានំ** មានអាពាធផ្លូវចិត្តជាបច្ចុប្បដ្ឋាន

**ហទយវត្ថុបទដ្ឋានំ** មានហទយវត្ថុប៉ុណ្ណោះជាបទដ្ឋាន ។

ក្នុងមូលកម្មបទទាំងឡាយ ព្រះអង្គត្រាស់ថា "ទោសៈមាន ព្យាបាទមាន" ដូចព្រះតម្រាស់ដែលត្រាស់ដល់អកុសលចិត្តដួងមុនៗថា "លោភៈមាន អភិជ្ឈាមាន" ដែរ ។ បណ្តាទោសៈ និងព្យាបាទទាំងពីរនោះ សភាវៈដែលឈ្មោះថា **ទោសៈ** ព្រោះអត្ថថា ជាហេតុឱ្យមនុស្សប្រទូស្តរ៉ាយ, ឬប្រទូស្តរ៉ាយឯងៗ, ឬធម្មជាតិនោះ ត្រឹមតែថាជាគ្រឿងប្រទូស្តរ៉ាយប៉ុណ្ណោះ ៕

## លក្ខណាទិចតុក្កៈនៃទោសៈ

**ចណ្ឌិក្កលក្ខណោ** ទោសៈនោះមានសេចក្តីកាចជាលក្ខណៈ **បហដាសិវិសោ**

**ទិយ** គប្បីជ្រាបដូចអសិរពិសដែលត្រូវគេវាយ ។

**ទិបស្សនរសោ** មានការអន្ទះអន្ទែងជារស **ទិសនិបាតោ ទិយ** គប្បីជ្រាបដូចត្រូវថ្នាំពិស ។

**អត្តនោ និស្សយទហនរសោ វា** ម្យ៉ាងទៀត មានការដុតរោលនិស្ស័យរបស់ខ្លួនជារស **ទាវគ្គិ ទិយ** គប្បីជ្រាបដូចភ្លើងឆេះព្រៃ ។

**ទុស្សនបច្ចុប្បដ្ឋានោ** មានការប្រទូស្តរ៉ាយ ជាបច្ចុប្បដ្ឋាន **លទ្ធោកាសោ ទិយ សបត្តោ** គប្បីជ្រាបដូចសត្រូវដែលបានឱកាស ។

**អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុ ជាបទដ្ឋាន **វិសសំសដ្ឋបូតិមុត្តំ ទិយ** គប្បីជ្រាបដូចទឹកមូត្រស្អុយផ្សំដោយថ្នាំពិស ។

សភាវៈដែលឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ជាហេតុបៀតបៀន គឺរមែងចូលដល់ភាវៈអន់ចិត្ត, ឬថារមែងញ៉ាំងវិន័យអាចារៈរូបសម្បត្តិ និងហិតសុខជាដើមឱ្យដល់សេចក្តីវិបត្តិ, ក៏បើពោលដោយអត្ថ ព្យាបាទនេះ ក៏គឺទោសៈនោះឯង ។ តែក្នុងអកុសលចិត្តដួងទី ៩ នេះ ជាបទអកុសល ២៩ ដោយលំដាប់, គប្បីជ្រាបបទ ១៤ បទ ដោយការកាន់យកបទដែលនៅមិនបានកាន់យក និងគប្បីជ្រាបប្រភេទកងធម៌ដែលចែកទុកបាន និងចែកមិនបាន ដោយអំណាចនៃបទធម៌ទាំងឡាយនោះ ។

ក្នុង**យេវាបនកធម៌**ទាំងឡាយ សភាវធម៌ដែលជានិយតៈមានឆន្ទៈ អធិមោក្ខៈ មនសិការៈ និងឧទ្ធច្ចៈជាដើម (គឺចេតសិកប្រកបនឹងអកុសលចិត្តដួងទី ៩ ទៀង) ។ ធម៌ (ទាំង ៤) ប៉ុណ្ណេះ រមែងកើតឡើង ៥ គ្រា។ មួយអន្លើដោយធម៌

យ៉ាងណានីមួយក្នុងឥស្សា មច្ឆរិយៈ ឬកុក្កុច្ចៈ ។ ធមិទាំង ៣ មានឥស្សាជាដើម សូម្បីប៉ុណ្ណោះ ឈ្មោះថា អនិយតយេវាបនកៈ ដោយប្រការដូច្នេះ ។ បណ្តាធមិទាំង ៣ ពួកនោះ សភាវធមិដែលឈ្មោះថា **ឥស្សា** ព្រោះអត្ថថា រមែងច្រណែន ៕

## លក្ខណាទិចតុក្កៈនៃឥស្សា

**បរសម្បត្តីនំ ឧស្សូយនលក្ខណា** ឥស្សានោះ មានការច្រណែនសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ ។

**តត្ថេវ អនភិរតិរសា** មានសេចក្តីមិនត្រេកអរក្នុងសម្បត្តិរបស់អ្នកដទៃនោះឯងជារស ។

**តតោ វិមុខភាវបច្ចុប្បដ្ឋានា** មានការបែរមុខពីសម្បត្តិរបស់អ្នកដទៃជាបច្ចុប្បដ្ឋាន ។

**បរសម្បត្តិបទដ្ឋានា** មានសម្បត្តិរបស់អ្នកដទៃជាបទដ្ឋាន ។

គប្បីជ្រាបថាជា **សញ្ញោសជនៈ** ។

ភាវៈនៃសេចក្តីកំណាញ់ ឈ្មោះថា **មច្ឆរិយៈ** ។

## លក្ខណាទិចតុក្កៈនៃមច្ឆរិយៈ

**លទ្ធានំ វា លភិតព្វានំ វា អត្តនោ សម្បត្តីនំ និគូហណលក្ខណំ** មច្ឆរិយៈនោះ មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានមកហើយ ឬដែលគួរបាន

ជាលក្ខណៈ ។

**តាសំយេវ បរេហិ សាធារណភាវអក្ខមនរសំ** មានការមិនពេញចិត្ត ក្នុងសម្បត្តិរបស់ខ្លួននោះៗឯង ជារបស់ទូទៅដល់ជនដទៃជារស ។

**សំកោចនបច្ចុប្បដ្ឋានំ** មានមុខក្រញូវជាបច្ចុប្បដ្ឋាន

**កដុកញ្ចុកតាបច្ចុប្បដ្ឋានំ ទា** ឬថាមានការហួងហែងជាបច្ចុប្បដ្ឋាន

**អត្តនោ សម្បត្តិបទដ្ឋានំ** មានសម្បត្តិរបស់ខ្លួនជាបទដ្ឋាន ។

មច្ឆរិយៈនេះ គប្បីជ្រាបថាជាពិការរបស់ចិត្ត ។

កម្មដែលបណ្ឌិតវៀរចាក, ដែលបុគ្គលធ្វើហើយ ឈ្មោះថា **កុកតៈ** ។ សេចក្ដីនៃកុកតៈនោះ ឈ្មោះថា **កុក្កុច្ចៈ** ៕

## លក្ខណាទិចតុក្កៈនៃកុក្កុច្ចៈ

**បច្ឆានុតាបនលក្ខណំ** កុក្កុច្ចៈនោះ មានសេចក្ដីក្ដៅក្រហាយចិត្តខាងក្រោយជាលក្ខណៈ ។

**កតាកតានុសោចនរសំ** មានសេចក្ដីសោយសោករឿយៗ ដល់បាបដែលធ្វើហើយ និងបុណ្យដែលមិនបានធ្វើជាកិច្ច ។

**វិប្បដិសារបច្ចុប្បដ្ឋានំ** មានវិប្បដិសារ គឺការក្ដៅក្រហាយជាបច្ចុប្បដ្ឋាន

**កតាកតបទដ្ឋានំ** មានការធ្វើបាបហើយ និងមិនបានធ្វើបុណ្យទុកជាបទដ្ឋាន ។

គប្បីជ្រាបថាដូចជាទោសៈដូច្នោះដែរ ។

នេះជាសេចក្តីផ្សេងគ្នាក្នុងឧទ្ទេសវារៈមុន ។

ក្នុងនិទ្ទេសវារៈ គប្បីជ្រាប **សេចក្តីមិនពេញចិត្ត** ក្នុងវេទនានិទ្ទេស ដោយអំណាចនៃធម៌ជាប់ជាបដិបក្សចំពោះសេចក្តីពេញចិត្ត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទោសៈតទៅ ៖

សភាវៈដែលឈ្មោះថា **ទោសៈ** ព្រោះអត្ថថា រមែងគិតប្រទូស្តរ៉ាយ ។ អាការដែលគិតប្រទូស្តរាយឈ្មោះថា **ទុស្សនា** = កិរិយាដែលប្រទូស្ត ។ ភាវៈនៃសេចក្តីប្រទូស្ត ឈ្មោះថា **ទុស្សិតត្តៈ** = ការគិតប្រទូស្ត ។

សេចក្តីគិតបៀតបៀន ឈ្មោះថា **ព្យាបត្តិ** = ការគិតព្យាបាទ ដោយអត្ថថា កាលះបង់ភាពជាប្រក្រតី ។ អាការនៃការព្យាបាទ ឈ្មោះថា **ព្យាបជ្ជនា** = កិរិយាដែលព្យាបាទ, ឈ្មោះថា **វិរោធ** = សេចក្តីក្រោធខឹង ព្រោះអត្ថថា ប៉ងនឹងប្រទូស្ត ។ ឈ្មោះថា **បដិវិរោធ** = សេចក្តីចងគំនុំ ព្រោះអត្ថថា ពិរោធរឿយៗ ។ ម្យ៉ាងទៀត ពាក្យទាំងពីរនេះ ត្រាស់ទុកដោយអំណាចនៃអាការដែលក្រោធខឹងនឹងអាការដែលគំនុំ ។

បុគ្គលមានចិត្តរឹងត្អឹង ហៅថា **ចណ្ឌិកៈ**, ភាវៈនៃចណ្ឌិកៈនោះ ហៅថា **ចណ្ឌិក្កៈ** = សេចក្តីកាចសាហាវ ។ សំដីដែលមនុស្សកាចសាហាវលើកឡើងនិយាយយ៉ាងល្អមិនដែលមានទេ, ពាក្យនិយាយរបស់មនុស្សដូចនេះ ជាពាក្យនិយាយអាក្រក់ គឺមិនបរិបូរណ៍ទេ ព្រោះហេតុនោះ មនុស្សនេះទើបឈ្មោះថា **អសុរោបៈ** (មាត់ឆៅ) ។ ពិតណាស់ ក្នុងវេលាដែលបុគ្គលអ្នកកាចឃោរឃៅ

(ខឹងក្រោធ) ហើយ ឈ្មោះថា និយាយដែលបរិបូរណ៍ រមែងមិនមាន, សូម្បីនឹងមានដល់អ្នកខ្លះ ខនោះ ក៏មិនជាប្រមាណដែរ (ព្រោះមានចំនួនតិច មិនអាចយកជាប្រមាណបាន) ។

អាចារ្យពួកមួយទៀតពោលថា មនុស្សដូចនោះ ឈ្មោះថា **អសុរោបៈ** (មិនសុភាព) ព្រោះឱ្យកើតទឹកភ្នែក ដោយអត្ថថា ការហូរចេញទៅនៃទឹកភ្នែក, ខដែលថានោះ មិនមែនជាហេតុ ព្រោះតែសោមនស្ស ក៏ធ្វើឱ្យទឹកភ្នែកកើតបានដែរ ។

សភាវៈដែលឈ្មោះថា **អនត្តមនតា** (សភាពមិនមានចិត្តភ្លឺថ្លា) ព្រោះអត្ថថា សេចក្ដីជាអ្នកមិនមានចិត្តជារបស់ខ្លួន ព្រោះជាបដិបក្សចំពោះភាពជាអ្នក មានចិត្តជារបស់ខ្លួន តាមដែលពោលហើយខាងក្រោយ ។ តែព្រោះសេចក្ដីមិនមានចិត្តភ្លឺថ្លានោះ ជារបស់ចិត្តប៉ុណ្ណោះ, មិនមែនជារបស់សត្វ ព្រោះហេតុនោះ ទើបត្រាស់ថា “**ចិត្តស្ស** = របស់ចិត្ត” ។ ពាក្យដ៏សេស គប្បីជ្រាបក្នុងអកុសលចិត្តដួងទី ៩ នោះ និងក្នុងសង្គហវារៈ ក្នុងសុញ្ញតវារៈគប្បីជ្រាបដោយន័យដែលពោលទុកខាងក្រោយនោះឯង ៕

**អកុសលចិត្តដួងទី ៩ ចប់**

## អធិប្បាយអកុសលចិត្តដួងទី ១០

អកុសលចិត្តដួងទី ១០ រមែងកើតឡើងដល់បុគ្គលដែលអ្នកដទៃ១ ឱ្យកើតឧស្សាហ៍ខ្លះ ដែលអ្នកដទៃ១ ដាស់តឿនឱ្យនឹកដល់សេចក្ដីខុសខ្លះ ខ្លួនឯងនឹកដល់សេចក្ដីខុសរបស់អ្នកដទៃ១ ហើយក្រោធខឹងខ្លះ ព្រោះសេចក្ដីដែលអកុសលចិត្តនេះ

នឹងទៅជាការរួសទាញ ។ សូម្បីក្នុងអកុសលចិត្តនេះ ក៏មាន ២៩ បទ តាមលំដាប់បទ ។ ព្រោះកាន់យកបទដែលនៅមិនបានកាន់យក ទើបជា ១៤ បទប៉ុណ្ណោះ ។ តែព្រោះក្នុងយេវាបនកធម៌ទាំងឡាយ រមែងបានសូម្បីថីនៈ និងមិទ្ធៈ, ព្រោះហេតុនោះ ក្នុងអកុសលចិត្តដួងនេះទើបវៀរឥស្សា មច្ឆរិយៈ និងកុក្កុច្ចៈ ឬវៀរធម៌ ៦ នេះ គឺអង្គធម៌ដែលដូចគ្នា ៤ និងថីនមិទ្ធៈ, ក្នុងវេលាដែលឥស្សាជាដើម កើតឡើង ក៏នឹងជាយេវាបនកធម៌ ៧ ខន្ទ១ និងខណៈនីមួយបណ្ដាធម៌មានឥស្សាជាដើមនោះ កើតឡើងក្នុខណៈជាមួយគ្នា ( ព្រមគ្នា) ។ ពាក្យដ៏សេសទាំងអស់ រាល់វារៈហាក់ ដូចនឹងអកុសលចិត្តដួងទី ៩ ដែរ ។ ក៏ក្នុងទោមនស្សចិត្តដួងទី ២ នេះ រមែងបានសហជាតាធិបតីតែមួយយ៉ាង, មិនបានអារម្មណាធិបតីទេ ។ ព្រោះបុគ្គលក្រោធខឹងហើយ រមែងធ្វើអារម្មណ៍អ្វីៗ ឱ្យធ្ងន់ ( ជាអធិបតី) បានដូច្នោះឯង ៕

**អកុសលចិត្តដួងទី ១០ ចប់**

---

## អធិប្បាយអកុសលចិត្តដួងទី ១១

អកុសលចិត្តដួងទី ១១ រមែងកើតឡើងក្នុងវេលាសេចក្ដីសង្ស័យ ប្រព្រឹត្តទៅដល់បុគ្គលអ្នកព្រងើយដោយអំណាចនៃវេទនាក្នុងអារម្មណ៍ទាំង ៦ ។ ក្នុងការកំណត់សម័យរបស់អកុសលចិត្តដួងទី ១១ នោះ បទថា **វិចិកិច្ឆាសម្បយុត្តំ** = **សម្បយុត្តដោយវិចិកិច្ឆា** មិនមែនបទដែលកើតមុនទេ; សេចក្ដីនៃអកុសលចិត្តនោះថា ឈ្មោះថា **វិចិកិច្ឆាសម្បយុត្ត** ព្រោះអត្ថថា **សម្បយុត្តដោយវិចិកិច្ឆា** ។

ក្នុងធម្មុទ្ទេស បទថា **វិចិកិច្ឆា ហោតិ** (វិចិកិច្ឆារមែងមាន) តែមួយប៉ុណ្ណោះដែលប្លែកគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិចិកិច្ឆានោះ តទៅ ៖

សភាវធម៌ដែលឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ប្រាសចាកសេចក្ដីដោះស្រាយ ។ ម្យ៉ាងទៀត ឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ជាហេតុឱ្យមនុស្សកាលបើគិតសភាវធម៌ រមែងស្មុគស្មាញ គឺរមែងលំបាក ៕

## លក្ខណាទិចតុក្កៈនៃវិចិកិច្ឆា

**សំសយនលក្ខណា** វិចិកិច្ឆានោះ មានសេចក្ដីសង្ស័យជាលក្ខណៈ

**កម្បនរសា** មានសេចក្ដីញាប់ញ័រជារស

**អនិច្ឆយបច្ចុប្បដ្ឋានា** មានការកាត់ចិត្តមិនបានជាបច្ចុប្បដ្ឋាន

**អនេកំសគ្គាហបច្ចុប្បដ្ឋានា វា** ឬថា មានការមិនកាន់យកចំណែកតែម្ខាងជាបច្ចុប្បដ្ឋាន ។

**អយោនិសោ មនសិការបទដ្ឋានា** មានការធ្វើទុកក្នុងចិត្តដោយឧបាយមិនឆ្លាតជាបទដ្ឋាន ។

បណ្ឌិតគប្បីជ្រាបថា ជាការធ្វើអន្តរាយដល់ការបដិបត្តិ ។

ក្នុងអកុសលចិត្តដួងទី ១១ នេះ បានបទ ២៣ តាមលំដាប់បទ, ពោលដោយធម៌ដែលនៅមិនបានកាន់យកក៏ជាធម៌ ១៤ បទ ។ គប្បីជ្រាបវិនិច្ឆ័យកងធម៌

ដែលបែងចែកបាន និងបែងចែកមិនបាន ដោយអំណាចនៃធម៌ ១៤ បទទាំងឡាយនោះ ។ សូម្បីធម៌ទាំង ២ គឺមនសិការ និងឧទ្ធច្ចៈជាយេវាបនកធម៌ ។

ក៏ព្រោះក្នុងនិទ្ទេសឯកគ្គតាចិត្តនៃនិទ្ទេសវារៈ អកុសលចិត្តនេះ ផលវិបាកមានត្រឹមតែការតាំងនៅក្នុងបច្ចុប្បន្នប៉ុណ្ណោះ, ព្រោះហេតុនោះ ទើបមិនត្រាស់ថា **“សណ្ឋិតិ** = សេចក្តីស្ថិតនៅ” ជាដើម តែត្រាស់បទតែមួយថា **“ចិត្តស្ស ឋិតិ”** និងដោយហេតុនោះៗឯង សូម្បីក្នុងឧទ្ទេសវារៈ ព្រះអង្គមិនត្រាស់ពាក្យជាដើមថា **“សមាធិន្ទ្រិយំ** = សមាធិន្ទ្រិយ” ដូច្នេះទេ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិចិកិច្ឆានិទ្ទេសតទៅ ៖

ភាវៈដែលឈ្មោះថា **កង្ខា** ដោយអត្ថថា សេចក្តីសង្ស័យ ។ អាការប្រព្រឹត្តនៃសេចក្តីសង្ស័យ ឈ្មោះថា **កង្ខាយនា** = កិរិយាដែលសង្ស័យ ។ ពិតណាស់ ការសង្ស័យដំបូងឈ្មោះថានាំមកនូវសេចក្តីសង្ស័យតទៅ; ម្យ៉ាងទៀត ការសង្ស័យនេះត្រាស់ទុកដោយអំណាចនៃអាការ, ចិត្តដែលព្រមព្រៀងដោយការសង្ស័យ ឈ្មោះថា **កង្ខាយិតៈ** ព្រោះនាំមកនៅសេចក្តីសង្ស័យ, ភាវៈនៃកង្ខាយិតៈនោះ ឈ្មោះថា **កង្ខាយិតត្តៈ** (សេចក្តីសង្ស័យ) ។ សភាវៈដែលឈ្មោះថា **វិមតិ** ព្រោះសេចក្តីគិតឃើញផ្សេងៗ ។ **វិចិកិច្ឆា** (ការកាត់អារម្មណ៍មិនបាន) មានសេចក្តីតាមដែលពោលហើយនោះឯង ដែលឈ្មោះថា **ទ្វេឡ្ហកំ** (សេចក្តីឃើញថាពីរ) ព្រោះអត្ថថា រមែងឃើញពីរយ៉ាង ដោយអត្ថថា ញាប់ញ័រទៅ ។ ឈ្មោះថា **ទ្វេធាបថោ** (សេចក្តីយល់ឃើញដូចផ្លូវពីរ) ព្រោះអត្ថថា ដូចផ្លូវបែកជាពីរដោយការហាម ឃាត់ការ

បដិបត្តិ ។ ឈ្មោះថា **សំសយោ** (សេចក្តីសង្ស័យ) ព្រោះអត្ថថា រមែងដេកដោយជុំវិញ ព្រោះមិនអាចតាំងនៅក្នុងអាការតែមួយ ដែលប្រព្រឹត្តទៅថា “នេះទៀងឬហ្ន៎, ឬថាមិនទៀងឬហ្ន៎” ជាដើម ។ ឈ្មោះថា **អនេកំសគ្គាហោ** (សេចក្តីមិនអាចកាន់យកដោយចំណែកតែមួយ) ព្រោះអត្ថថា មិនមែនកាន់យកដោយចំណែកតែម្ខាង ។ ឈ្មោះថា **អាសប្បនា** (ការគិតគួរទៅ) ព្រោះអត្ថថា វិចិកិច្ឆានោះ កាលបើមិនអាចដើម្បីកាត់ផ្តាច់ ទើបត្រឡប់ពីអារម្មណ៍ ។ ឈ្មោះថា **បរិសប្បនា** = ការគិតមិនច្បាស់លាស់ ព្រោះអត្ថថា វិចិកិច្ឆានោះ កាលមិនអាចដើម្បីនឹងស្ទង់ចុះ (សម្រេចបាន) ទើបគិតវែងឆ្ងាយ ។ ឈ្មោះថា **អបរិយោគាហនា** = ការមិនប្រាថ្នានឹងចុះកាន់ទីបំផុតបាន ព្រោះជាសភាវៈមិនអាចដើម្បីចុះកាន់យកបាន ។ ឈ្មោះថា **ថម្ភិតត្តំ** (ភាពរឹងត្អឹង) ព្រោះសេចក្តីជាសភាវៈដែលមិនអាចដើម្បីប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយអំណាចនៃការកាត់ចិត្តបាន, អធិប្បាយថា សេចក្តីដែលចិត្តជាធម្មជាតិរឹងត្អឹង ។ ពិតណាស់ វិចិកិច្ឆាកើតឡើងហើយរមែងធ្វើចិត្តឱ្យរឹងត្អឹង ។ ក៏ព្រោះវិចិកិច្ឆានោះ កាលបើកើតហាក់ដូចជាចាប់អារម្មណ៍មកហើយញ៉ាំញី (គួសវាស) នូវចិត្ត, ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា “**មនោវិលេខោ** = គំនូសចិត្ត គឺសេចក្តីសាំញ៉ាំ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានសេចក្តីងាយស្រួលទាំងអស់ ៕

## អកុសលចិត្តដួងទី ១១ ចប់

## អធិប្បាយអកុសលចិត្តដួងទី ១២

គប្បីជ្រាបវិនិច្ឆ័យក្នុងអកុសលចិត្តដួងទី ១២ តទៅ ៖

ក្នុងការកំណត់សម័យនៃអកុសលចិត្តដួងទី ១២ ដែលឈ្មោះថា **ឧទ្ធច្ចសម្បយុត្ត** ព្រោះអត្ថថា អកុសលចិត្តនោះ សម្បយុត្តដោយឧទ្ធច្ចៈ ។ ពិតណាស់ អកុសលចិត្តដួងទី ១២ នេះ ជាកណ្តាល (**ឧបេក្ខា**) ដោយអំណាចនៃវេទនា ក្នុងអារម្មណ៍ ៦ ជាការរាយមាយ (**ឧទ្ធតំ**)។ ក្នុងអកុសលចិត្តដួងនេះ ចិត្តនេះ មកហើយក្នុងឋាននៃវិចិកិច្ឆាក្នុងធម្មុទ្ទេសថា **“ឧទ្ធច្ចំ ហោតិ** = ឧទ្ធច្ចរមែងមាន” រមែងមានបទ ២៨ តាមលំដាប់នៃបទ ពោលដោយបទដែលនៅមិនបានកាន់យកក៏បាន ១៤ បទ ។ គប្បីជ្រាបវិធីនៃការបែងចែកកងធម៌ទាំងពីរគឺ អធិមោក្ខ និងមនសិការប៉ុណ្ណោះជាយេវាបនកធម៌ ។

គប្បីវិនិច្ឆ័យក្នុងឧទ្ធច្ចនិទ្ទេសនៃនិទ្ទេសវារៈតទៅ ៖

បទថា **ចិត្តស្ស** = នៃចិត្ត គឺមិនមែនសត្វ, មិនមែនបុគ្គល ។ បទថា **ឧទ្ធច្ចំ** បានដល់ អាការដែលរវើរវាយ ។ សភាវៈដែលឈ្មោះថា **អវូបសមៈ** = សេចក្តីមិនស្ងប់ ព្រោះអត្ថថា ការមិនចូលទៅរម្ងាប់ចិត្ត ។ ឈ្មោះថា **ចេតសោ វិក្ខេបោ** = សេចក្តីក្រវល់ក្រវាយ ព្រោះអត្ថថា ចិត្តរវើរវាយទៅ ។ បទថា **ភន្តំ ចិត្តស្ស** = ចិត្តឆ្លេវឆ្លាទៅ បានដល់ សភាពដែលចិត្តងាកទៅ ។ ដោយបទនេះលោកពោលដល់ចិត្តស្ទុះទៅក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ ដូចយានដែលស្ទុះទៅ និងគោដែលស្ទុះទៅជាដើម, ព្រោះឧទ្ធច្ចៈស្ទុះទៅក្នុង**អារម្មណ៍តែមួយ** វិចិកិច្ឆាស្ទុះទៅក្នុងអារម្មណ៍ផ្សេងៗ ។ ពាក្យដែលសេសគ្រប់វារៈ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងខាង

ក្រោយនុ៎ះឯង ។

ឥឡូវនេះ មានខវិនិច្ឆ័យ **បកិណ្ណកៈ** ក្នុងចិត្ត ២ ដួងនេះ តទៅ ៖

ក៏កាលបើមានអ្នកណាពោលថា "ឈ្មោះថា ចិត្តដែលប្រព្រឹត្តទៅក្នុងអារម្មណ៍មានប៉ុន្មាន ?" គប្បីឆ្លើយបានថា "ចិត្តពួកនេះ មាន ២ ដួងប៉ុណ្ណោះ" ។ បណ្ដាចិត្ត ២ ដួងនោះ ចិត្តដែលសហគតៈដោយវិចិកិច្ឆារមែងប្រព្រឹត្តទៅតែម្យ៉ាង, ចំណែកចិត្តដែលសហគតៈដោយឧទ្ធច្ចៈបានទីអាស្រ័យហើយ បានទីតោងហើយ ក៏ប្រព្រឹត្តទៅតាមទីអាស្រ័យដែលបានហើយ ព្រោះមានអធិមោក្ខដែលបានហើយ ។ ដូចយ៉ាងថា កាលបើកែវមណី ២ ដួង, ដួង ១ មូល, ដួង ១ ទៀត បួនជ្រុង ។ កាលបើគេពន្លែងឱ្យរមៀលទៅក្នុងទីទួល កែវមណីដួងមូល រមែងរមៀលទៅៗបានមែនពិត, ចំណែកកែវមណី ៤ ជ្រុងរមៀលទៅហើយៗ រមែងតាំងនៅបានយ៉ាងណា, ពាក្យឧបមេយ្យជាគ្រឿងប្រៀបធៀបនេះ គប្បីជ្រាបដូច្នោះចុះ ។

សូម្បីក្នុងអកុសលចិត្តទាំងអស់ ព្រះអង្គទ្រង់មិនបានលើកឡើង សម្ដែងសេចក្ដីផ្សេងគ្នាដោយសេចក្ដីអាក្រក់ជាដើម, ព្រោះសភាពនៃអកុសលទាំងអស់ជាសភាវៈអាក្រក់តែម្យ៉ាង ។ សូម្បីបានសហជាតាធិបតីហើយ ក៏ទ្រង់មិនលើកឡើងសម្ដែង, ព្រោះសេចក្ដីដែលន័យទ្រង់សម្ដែងទុកខាងក្រោយហើយ ។ ក៏ក្នុងអកុសលទាំងអស់នេះ ឈ្មោះថា **វីមំសាធិបតី** រមែងមិនមាន ព្រោះមិនមានញាណ ។ ក្នុងចិត្ត ២ ដួងចុងក្រោយ (ដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ) មិនមានសេចក្ដីប្លែកគ្នា ព្រោះហេតុអ្វី ? ព្រោះកើតឡើងធ្វើធម៌អ្វីៗ ឱ្យជាធុរៈទើបទ្រង់បដិសេធទុកក្នុងបដ្ឋានប្បករណ៍នោះឯង ។

ក៏បើកម្មដែលអកុសលចិត្ត ១២ ដួងនេះប្រែប្រួលមកហើយ វៀរអកុសល

ចិត្តដែលសហគតៈដោយឧទ្ធច្ចៈ អកុសលចិត្តដួងទី ១១ នោះ រមែងនាំបដិសន្ធិមក (គឺឱ្យបដិសន្ធិ) ។

**សួរថា** កាលអកុសលចិត្តសហគតៈដោយវិចិកិច្ឆាមិនមាន អធិមោក្ខសូម្បីមានកម្លាំងខ្សោយក៏នាំបដិសន្ធិមកបាន, អកុសលចិត្តដែលសហគតៈដោយឧទ្ធច្ចៈមានអធិមោក្ខបានហើយមានកម្លាំង រមែងនាំបដិសន្ធិមកមិនបាន ។ ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមិនមានមគ្គដែលសោតាបត្តិមគ្គគប្បីលះ ។ ក៏ឧបមាចិត្តដែលសហគតៈដោយឧទ្ធច្ចៈគប្បីនាំបដិសន្ធិមកម្យ៉ាងដែរ ក៏នឹងគប្បីត្រាស់ទុកក្នុងវិភង្គនៃបទថា **ឧស្សនេន បហាតព្វា** ព្រោះហេតុនោះ អកុសលចិត្តដ៏សេស ១១ ដួង វៀរឧទ្ធច្ចសម្បយុត្តចិត្ត រមែងនាំបដិសន្ធិមកឱ្យ ។ ពិតណាស់ បើកម្មដែលអកុសលពួកណានីមួយ ក្នុងអកុសលធម៌ទាំងនោះប្រមូលមកហើយ បដិសន្ធិចិត្តរមែងមានក្នុងអបាយ ៤ ដោយចេតនានោះ ។ បណ្ដាអកុសលវិបាកទាំងឡាយសត្វរមែងបដិសន្ធិដោយចេតនាដែលសហគតៈដោយឧបេក្ខា គឺអហេតុកមនោវិញ្ញាណធាតុ សូម្បីការឱ្យបដិសន្ធិក្នុងអបាយទាំង ៤ នោះឯង ក៏គប្បីដល់ឧទ្ធច្ចសហគតចិត្ត តែព្រោះឧទ្ធច្ចសហគតចិត្តនោះមិនមានការឱ្យផល ឱ្យបដិសន្ធិទេ, ព្រោះហេតុនោះ ទើបព្រះអង្គមិនត្រាស់ទុកក្នុងវិភង្គពោលដោយបទថា **"ឧស្សនេន បហាតព្វា"** ដូច្នេះឡើយ ៕ ៚

**ពណ៌នាបទធម៌ដែលជាអកុសលចប់**

# អដ្ឋកថាព្រះអភិធម្មបិដក

## អធិប្បាយអំពីអព្យាកតធម៌

ឥឡូវនេះ ព្រះអង្គទ្រង់ប្រាថ្នានឹងសម្តែងបែងចែកបទអព្យាកតធម៌ ទើបផ្តើមពាក្យថា “**កតមេ ធម្មា អព្យាកតា** = ធម៌ដែលជាអព្យាកតៈ តើដូចម្តេច?” ជាដើម ។

ក្នុងព្រះបាលីនោះ អព្យាកតៈមាន ៤ យ៉ាង គឺ វិបាក កិរិយា រូប និង និព្វាន, បណ្តាអព្យាកតៈទាំងនោះ ព្រះអង្គទ្រង់មានបំណងយកអព្យាកតវិបាក, សូម្បីក្នុងអព្យាកតវិបាក ក៏ទ្រង់បំណងយកកុសលវិបាក, សូម្បីក្នុងកុសលវិបាកនោះ ក៏ទ្រង់បំណងយកបរិត្តវិបាក (កាមាវចរវិបាក), សូម្បីក្នុងកាមាវចរវិបាក ក៏ទ្រង់មានបំណងយកអហេតុកៈ, សូម្បីក្នុងអហេតុកៈ ក៏ទ្រង់មានបំណងយកបញ្ចវិញ្ញាណ (វិញ្ញាណ ៥), សូម្បីក្នុងបញ្ចវិញ្ញាណនោះ ក៏ទ្រង់មានបំណងយកចក្ខុវិញ្ញាណតាមលំដាប់ក្នុងទ្វារ, សូម្បីចក្ខុវិញ្ញាណនោះសោត ទ្រង់ប្រាថ្នានឹងសម្តែងការកើតឡើង ដោយអំណាចនៃកម្មប្បច្ច័យដែលមិនទូទៅប៉ុណ្ណោះ វៀរសាធារណប្បច្ច័យតាមទ្វារ និងអារម្មណ៍ជាដើមចេញ ទើបត្រាស់ព្រះតម្រាស់ថា “**ព្រោះកាមាវចរកុសលកម្ម** ដែលខ្លួនធ្វើហើយ” ។

បណ្តាបទទាំងនោះ បទថា “**កតត្តា** = ដែលបានធ្វើទុកហើយ” បានដល់ហេតុដែលធ្វើទុកហើយ ។ បទថា “**ឧបចិតត្តា** = ដែលសន្សំទុកហើយ” បានដល់

ធ្វើឱ្យចម្រើនឡើងហើយ ។ បទថា **"ចក្ខុវិញ្ញាណំ"** សេចក្តីថា ដែលឈ្មោះថា ចក្ខុវិញ្ញាណ ព្រោះអត្ថថា ជាវិញ្ញាណនៃចក្ខុ ដែលមានហេតុសម្រេចហើយ ឬ វិញ្ញាណដែលប្រព្រឹត្តទៅតាមចក្ខុ ឬថា ជាវិញ្ញាណដែលអាស្រ័យក្នុងចក្ខុ សូម្បីក្នុង សោតវិញ្ញាណជាដើមខាងមុខ ក៏មានន័យដូចគ្នានេះដែរ ៕

## ក្នុងវិញ្ញាណ ៥ ពួក ចក្ខុវិញ្ញាណ

**ចក្ខុសន្និស្សិតរូបវិជានលក្ខណំ** មានការដឹងរូប ដែលអាស្រ័យនឹង ចក្ខុបសាទ ជាលក្ខណៈ ។

**រូបមត្តារម្មណរសំ** មានអារម្មណ៍ត្រឹមតែរូបជារស

**រូបាភិមុខភាវបច្ចុបដ្ឋានំ** មានសេចក្តីចង់ឃើញជាបច្ចុប្បដ្ឋាន

**រូបារម្មណាយ កិរិយាមនោធាតុយា អបគមនបទដ្ឋានំ** មានការ ប្រាសចាកកិរិយាមនោធាតុ ដែលមានរូបារម្មណ៍ជាបទដ្ឋាន ។

សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ដែលនឹង មានមកខាងមុខ ក៏មានការដឹងសំឡេងជាដើម ដែលអាស្រ័យសោតៈជាដើម ជា លក្ខណៈ, មានអារម្មណ៍ត្រឹមតែសំឡេងជាដើមជារស, មានសេចក្តីប្រាថ្នាចំពោះ សំឡេងជាដើម ជាបច្ចុប្បន្ន, មានការមិនប្រាសចាកកិរិយាមនោធាតុ ដែលមាន

សទ្ទារម្មណ៍ជាដើម ជាបទដ្ឋាន ។

ក្នុងអព្យាកតវិបាកនេះ មានបទធម៌តាមលំដាប់ ១០ បទ, ពោលដោយការកាន់យកបទ ដែលនៅមិនទាន់បានកាន់យក ក៏បាន ៧ បទ ។ បណ្តាបទទាំង ៧ នោះ បទដែលចែកមិនបាន មាន ៥ បទ, បទដែលចែកបាន មាន ២ បទ, បណ្តាធម៌ដែលចែកបាននោះ ចិត្តដល់ការចែកក្នុងទីទាំង ២ គឺដោយអំណាចនៃផស្សបញ្ចកៈ និងឥន្ទ្រិយ, វេទនាដល់ការចែកក្នុងទីទាំង ៣ គឺដោយអំណាចនៃផស្សបញ្ចកៈ អង្គឈាន និងឥន្ទ្រិយ ។ សូម្បីក្នុងធម៌ទាំងនេះ ក៏មាន ៣ ដូចគ្នាដែរ, យេវាបនកធម៌មានតែមួយ គឺមនសិការប៉ុណ្ណោះ ។

ក្នុងនិទ្ទេសវារៈត្រាស់ចក្ខុវិញ្ញាណថា "**បណ្ឌរំ** = ស្រស់ថ្លាដោយវត្ថុ" ។ ពិតណាស់ កុសលឈ្មោះថា **បណ្ឌរំ** (ស្រស់ថ្លា) ព្រោះសេចក្តីដែលខ្លួនបរិសុទ្ធ, អកុសល ក៏ឈ្មោះថា **បណ្ឌរំ** (ស្រស់ថ្លា) ព្រោះជាផលដែលហូរចេញមកអំពីភវង្គ, វិបាក ក៏ឈ្មោះថា **បណ្ឌរំ** (ស្រស់ថ្លា) ព្រោះស្រស់ថ្លាដោយវត្ថុ ។

ក្នុងនិទ្ទេសនៃឯកគ្គតាចិត្ត ត្រាស់បទតែមួយប៉ុណ្ណោះថា "**ចិត្តស្ស ឋិតិ** = សេចក្តីតាំងនៅនៃចិត្ត" ព្រោះសូម្បីចិត្តនេះ ទុព្វលក្នុងអព្យាកតវិបាកនេះ រមែងបានត្រឹមតែការតាំងនៅក្នុងបច្ចុប្បន្នប៉ុណ្ណោះ រមែងមិនអាចដើម្បីដល់នូវភាពជា **សណ្ឋិតិ** (ការតាំងនៅ) និង **អវដ្ឋិតិ** (ការតាំងនៅមាំ) ឡើយ ។ ក្នុងសង្គហ-

វារៈទ្រង់មិនលើកអង្គឈាន និងអង្គមគ្គឡើងសម្ដែងទេ; ព្រោះហេតុអ្វី ? ព្រោះធម្មតាឈាន មានវិតក្កៈ ជាធម៌ថ្នាក់ទាប; ធម្មតាមគ្គ ក៏មានហេតុជាធម៌ថ្នាក់ទាបដែរ; អង្គឈាន រមែងមិនបានក្នុងចិត្ត ដែលមិនមានវិតក្កៈតាមប្រក្រតីទេ; អង្គមគ្គក៏មិនបានក្នុងអហេតុកចិត្ត (ចិត្តមិនប្រកបដោយហេតុ) ដែរ; ព្រោះហេតុដូច្នោះសូម្បីអង្គឈាន និងអង្គមគ្គទាំងពីរ ព្រះអង្គទ្រង់មិនលើកឡើងសម្ដែងក្នុងចក្ខុ-វិញ្ញាណនេះឡើយ; ក៏សង្ខារក្ខន្ធក្នុងចក្ខុវិញ្ញាណនេះ ជាធម៌ប្រកបដោយអង្គ ៤ (ផស្សៈ ចេតនា ឯកគ្គតា និងជីវិតិន្ទ្រិយ) នោះឯង ទើបទ្រង់ចែកទុក ។ សុញ្ញត-វារៈ ប្រព្រឹត្តទៅតាមប្រក្រតីនុ៎ះឯង; សូម្បីនិទ្ទេសនៃសោតវិញ្ញាណជាដើម គប្បីជ្រាបដោយន័យដូចគ្នានេះដែរ ។ ក៏ក្នុងវិញ្ញាណ ៥ នោះ មានសេចក្ដីប្លែកគ្នាតែម្យ៉ាង គឺក្នុងចក្ខុវិញ្ញាណជាដើម ទ្រង់ចែកជាឧបេក្ខា; ក្នុងកាយវិញ្ញាណ ទ្រង់ចែកជាសុខៈ ។ សូម្បីសេចក្ដីផ្សេងគ្នានោះ ក៏គប្បីជ្រាបថា រមែងមានដោយអំណាចនៃការប៉ះខ្ទប់; ព្រោះក្នុងទ្វារ ៤ មានចក្ខុទ្វារជាដើម ឧបាទាយរូប រមែងប៉ះខ្ទប់ឧបាយរូបប៉ុណ្ណោះ; កាលឧបាទាយរូបនោះឯង ប៉ះខ្ទប់នូវឧបាទាយរូបហើយ សេចក្ដីសង្កៀតកើតអំពីការប៉ះខ្ទប់ រមែងមិនមានកម្លាំង; រមែងមានត្រឹមតែការប៉ះគ្នាប៉ុណ្ណោះរមែងមិនប៉ះខ្ទប់ខ្លាំង ដូចវេលាដែលគេដាក់ប៉ុយ ដែលកើតឡើងអំពីកប្បាស ៤ ដុំទុកលើទ្រនាប់ដែក ៤ ដុំ ហើយប៉ុយនោះឯង ប៉ះគ្នាដូច្នោះទេ, វេទនាទើបតាំងនៅ

ក្នុងឋានៈកណ្ដាល (ឧបេក្ខា); តែក្នុងកាយទ្វារ អារម្មណ៍ដែលជាមហាភូតរូបខាងក្រៅ ប៉ះខ្ទប់កាយបសាទដែលជាខាងក្នុងហើយ ប៉ះខ្ទប់មហាភូតរូបទាំងឡាយដែលមានបសាទរូបជាបច្ច័យ, ដូចបុគ្គលដាក់ប៉ុយ លើទ្រនាប់ដែក ហើយយកញញួរដំ ញញួរក៏ហួសទៅប៉ះខ្ទប់ទ្រនាប់ដែក ព្រោះការសង្កៀតជាសភាវៈមានកម្លាំង សេចក្ដីនេះ យ៉ាងណា, ការប៉ះខ្ទប់មហាភូតរូបនឹងមហាភូតរូប ជាការសង្កៀតដែលមានកម្លាំងដូចគ្នាដែរ។ កាយវិញ្ញាណដែលសហគតៈដោយសុខ រមែងកើតឡើងក្នុងឥដ្ឋារម្មណ៍, កាយវិញ្ញាណដែលសហគតៈដោយទុក្ខ រមែងកើតឡើងក្នុងអនិដ្ឋារម្មណ៍ ។

ក៏វត្ថុទ្វារ និងអារម្មណ៍របស់ចិត្តទាំង ៥ នេះ រមែងជារបស់ទាក់ទងគ្នាដោយពិត, ឈ្មោះថា ការឆ្កឹះកកាយគ្នាដោយវត្ថុជាដើម ក្នុងទីនេះ រមែងមិនមាន; ព្រោះចក្ខុវិញ្ញាណដែលជាកុសលវិបាក ធ្វើចក្ខុបសាទឱ្យជាវត្ថុ (ទីអាស្រ័យកើត) ហើយញុំាងទស្សនកិច្ច (កិច្ចគឺការឃើញ) ឱ្យសម្រេចក្នុងរូបារម្មណ៍ ដែលមានសមុដ្ឋាន ៤ ក្នុងឥដ្ឋារម្មណ៍ និងក្នុងឥដ្ឋមជ្ឈត្តារម្មណ៍តាំងនៅក្នុងចក្ខុទ្វារហើយសម្រេចផល, សោតវិញ្ញាណជាដើម ធ្វើសោតបសាទជាដើម ឱ្យជាវត្ថុ ហើយឱ្យសម្រេចសវនកិច្ច ឃាយនកិច្ច សាយនកិច្ច និងផុស្សនកិច្ច ក្នុងអារម្មណ៍មានសំឡេងជាដើម ដែលជាឥដ្ឋារម្មណ៍ និងឥដ្ឋមជ្ឈត្តារម្មណ៍តាំងនៅក្នុងសោតទ្វារជាដើម

ហើយសម្រេចផល, ក៏ក្នុងអារម្មណ៍ទាំងនេះ សំឡេងមានតែសមុដ្ឋាន ២ ប៉ុណ្ណោះ៕

## អធិប្បាយអំពីមនោធាតុកុសលវិបាក

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃមនោធាតុ ដូចតទៅ ៖

ធាតុ គឺមនោនោះឯង ឈ្មោះថា មនោធាតុ ដោយអត្ថថា សូន្យចាកសភាវៈ និងមិនមែនសត្វ ។

**ចក្ខុវិញ្ញាណាទីនំ អនន្តរំ រូបាទិវិជាននលក្ខណា** មនោធាតុមានការដឹងនូវរូបារម្មណ៍ជាដើម ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើមជាលក្ខណៈ ។

**រូបាទីនំ សម្បដិច្ឆន្នរសា** មានការទទួលអារម្មណ៍ មានរូបជាដើមជារស

**តថាភាវបច្ចុប្បដ្ឋានា** មានសភាវៈដូចការទទួលអារម្មណ៍យ៉ាងនោះ ជាបច្ចុប្បដ្ឋាន ។

**ចក្ខុវិញ្ញាណាទិ អបគមនបទដ្ឋានា** មានការមិនប្រាសចាកចក្ខុ-វិញ្ញាណជាដើម ជាបទដ្ឋាន ។

ធម្មុទ្ទេសក្នុងមនោធាតុនេះ មាន ១២ បទ ពោលដោយការកាន់យកបទដែលនៅមិនទាន់បានកាន់យក ក៏បាន ៩ បទ, ក្នុង ៩ បទនោះ ៧ បទចែកមិនបាន,

២ បទចែកបាន ។ យេវាបនកធម៌មានពីរ គឺអធិមោក្ខ និងមនសិការ ។

និទ្ទេសនៃវិតក្កៈព្រះអង្គទ្រង់កំណត់ទុកដល់អភិនិរោបនៈ (គឺការលើកចិត្តឡើងកាន់អារម្មណ៍) ក៏ព្រោះចិត្ត (អព្យាកតវិបាក) ដូចនេះ ជាកុសល ក៏មិនមែនជាអកុសល ក៏មិនមែន, ព្រោះហេតុដូច្នេះ ទើបមិនត្រាស់ថា "ជាសម្មាសង្កប្បៈ" ឬ "ជាមិច្ឆាសង្កប្បៈ" ទេ សូម្បីអង្គឈានបានហើយក្នុងសង្គហវារៈ ក៏ធ្លាក់ហើយប្រព្រឹត្តិទៅក្នុងក្រសែនៃវិញ្ញាណ ៥ ព្រោះហេតុដូច្នេះ ទើបមិនលើកឡើងសម្ដែង, ចំណែកអង្គមគ្គ រមែងមិនបានដោយពិត ព្រោះហេតុដូច្នោះ ទើបទ្រង់មិនលើកឡើងសម្ដែង, សុញ្ញតវារៈប្រព្រឹត្តទៅតាមប្រក្រតីនោះឯង, ចិត្តនេះ ជាចិត្តជាប់ដោយវត្ថុ គឺទីអាស្រ័យត្រង់ហទយវត្ថុប៉ុណ្ណោះ, ទ្វារ និងអារម្មណ៍ ជាសភាពមិនជាប់គ្នា; បណ្ដាទ្វារ និងអារម្មណ៍ ដែលមិនជាប់គ្នាទាំងនោះ ទ្វារ និងអារម្មណ៍ សូម្បីនឹងឆ្កឹះកកាយ ក៏ពិតមែនហើយ, ប៉ុន្តែ ក៏មានវារៈតែមួយ, ព្រោះឋានៈនេះ មានសម្បដិច្ឆន្នកិច្ច (គឺមានតួនាទីទទួលអារម្មណ៍) ដូចគ្នាដែរ, មែនពិត ចិត្តដូចនេះ (អព្យាកតវិបាក) ជាសម្បដិច្ឆន្នចិត្ត (ចិត្តទទួលអារម្មណ៍) ក្នុងអារម្មណ៍ទាំងឡាយ ៥ ក្នុងបញ្ចទ្វារហើយទើបសម្រេចផល, កាលបើវិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាករលត់ហើយ សម្បដិច្ឆន្នចិត្ត (អព្យាកតវិបាក) នោះ ក៏ទទួលអារម្មណ៍ទាំងនោះៗ មានរូបារម្មណ៍ជាដើមដែលដល់ឋានៈជាលំដាប់លំដោយមែនពិត ៕

# អធិប្បាយអំពីមនោវិញ្ញាណធាតុ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃសន្តីរណៈ មនោវិញ្ញាណធាតុ ៖

បទថា **“បីតិ”** ជាបទអធិកៈ (លើស) ក្នុងមនោវិញ្ញាណធាតុដួងទី១ នេះ សូម្បីវេទនា ក៏ជាសោមនស្សវេទនា; ព្រោះមនោវិញ្ញាណធាតុ ដួងទី ១ នេះ រមែងប្រព្រឹត្តទៅក្នុងឥដ្ឋារម្មណ៍តែម្យ៉ាង; ឯមនោវិញ្ញាណធាតុដួងទី ២ រមែងប្រព្រឹត្តទៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍; ព្រោះហេតុដូច្នោះ ក្នុងមនោវិញ្ញាណធាតុដួងទី ២ នេះ ទើបជាឧបេក្ខាវេទនា ព្រោះហេតុនោះ បទទាំងឡាយ ក៏ដូចក្នុងនិទ្ទេសនៃមនោធាតុនុ៎ះដែរ; សូម្បីក្នុងមនោវិញ្ញាណធាតុទាំងពីរដួង ព្រះអង្គទ្រង់មិនបានលើកអង្គឈានឡើងសម្តែងទេ ព្រោះភាវៈនៃមនោវិញ្ញាណធាតុពីរដួងនោះ ជាធម្មជាតិធ្លាក់ចុះហើយប្រព្រឹត្តទៅក្នុងក្រសែនៃវិញ្ញាណ ៥ មែនពិត, អង្គមគ្គក៏ដូចគ្នា ទ្រង់មិនបានលើកឡើងសម្តែង ព្រោះមិនមានដោយពិតប្រាកដឡើយ ។ ពាក្យដ៏សេសក៏គប្បីជ្រាបដោយន័យដែលពោលហើយនុ៎ះឯង ។

ម្យ៉ាងទៀត ពោលដោយលក្ខណៈជាដើម សូម្បីមនោវិញ្ញាណធាតុទាំងពីរជាអហេតុកវិបាក (វិបាកចិត្តមិនមានហេតុប្រកប) គប្បីជ្រាបថា ៖

**ឆឡារម្មណាភិជាននលក្ខណា** មានការដឹងអារម្មណ៍ ៦ ជាលក្ខណៈ

**សន្តីរណាទិរសា** មានការពិចារណាអារម្មណ៍ជាដើម ជារស

**តថាភាវបច្ចុប្បដ្ឋានា** មានភាវៈយ៉ាងនោះ (មានការពិចារណាអារម្មណ៍ជាដើមយ៉ាងនោះ) ជាបច្ចុប្បដ្ឋាន ។

**ហទយវត្ថុបទដ្ឋានា** មានហទយវត្ថុជាបទដ្ឋាន ។

បណ្តាមនោវិញ្ញាណធាតុ ២ ដួងនោះ ដួងទី ១ រមែងឱ្យផលក្នុងឋានទាំង ២; ពិតមែនហើយ មនោវិញ្ញាណធាតុដួងទី ១ នោះ គឺមនោធាតុដែលជាវិបាក (សម្បដិច្ឆន្នចិត្ត) ទទួលអារម្មណ៍ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម ដែលជាកុសល-វិបាកក្នុងទ្វារ ៥ នោះរលត់ហើយ ក៏ញុំាងសន្តីរណកិច្ចឱ្យសម្រេចក្នុងអារម្មណ៍នោះឯង រមែងតាំងនៅហើយឱ្យផលក្នុងទ្វារ ៥, ថែមទាំងជាតទារម្មណ៍ ឱ្យផលក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារទាំង ៦, សេចក្តីនេះ យ៉ាងណា ? គឺប្រៀបបីដូចជាកាលទូកពាំងក្រសែទឹក ដែលហូរយ៉ាងត្របាញ់ ក្រសែទឹកបែកជាប់តាមទូកទៅកាន់ទីបានបន្តិចហើយ ក៏ទៅតាមសមគួរដល់ក្រសែនោះឯង យ៉ាងណា, សេចក្តីនេះ ក៏យ៉ាងនោះដែរ គឺកាលបើអារម្មណ៍មានកម្លាំងប្រាកដច្បាស់ក្នុងទ្វារទាំង ៦ ទៅកាន់គន្លងហើយ ជវនចិត្តរមែងស្ទុះទៅ (ប្រព្រឹត្តទៅ), កាលបើជវននោះ សេពអារម្មណ៍ហើយ ក៏ជាឱកាសរបស់ភវង្គ, តែថា ចិត្ត (សន្តីរណចិត្ត) នេះ មិនឱ្យឱកាសដល់ភវង្គ ទើបទទួលអារម្មណ៍ដែលជវនចិត្តទទួលហើយ ក៏ប្រព្រឹត្តទៅអស់ ១ វារៈ, ចិត្ត ២ វារៈ ក៏ធ្លាក់ចុះកាន់ភវង្គមែនពិត ។ បណ្ឌិតគប្បីញុំាងឧបមា ដោយអាការៈនេះឯង ឱ្យពិស្តារ សូម្បីក្នុងហ្វូងគោដែលកំពុងឆ្លងស្ទឹង ។ មនោវិញ្ញាណធាតុដួងទី ១

នេះ ឈ្មោះថា តទារម្មណចិត្ត ព្រោះសភាវៈនៃមនោវិញ្ញាណធាតុនោះឯង ទទួលអារម្មណ៍ដែលជវនចិត្តទទួលយកហើយ ទើបឱ្យផល ។

ចំណែកមនោវិញ្ញាណធាតុដួងទី ២ រមែងឱ្យផលក្នុងឋានៈ ៥, តើដូចម្តេច ? គឺខាងដើម ឱ្យផលជាបដិសន្ធិចិត្តក្នុងវេលាចាប់បដិសន្ធិ របស់មនុស្សខ្វាក់ពីកំណើត ថ្លង់ពីកំណើត គពីកំណើត ឆ្កួតពីកំណើត ជាឧភតោព្យញ្ជនកៈ និងខ្ទើយ ក្នុងមនុស្សលោក ជាប្រការ ១, កាលបដិសន្ធិកន្លងទៅហើយ ក៏ឱ្យផលជាភវង្គរហូតដល់អស់អាយុប្រការ ១, រមែងឱ្យផលជាសន្តីរណៈ (ពិចារណា) ក្នុងវីថិនៃអារម្មណ៍ ៥ ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ប្រការ ១, រមែងឱ្យផលជាតទារម្មណ៍ ក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារ ៦ ប្រការ ១, ក្នុងវេលាមរណៈ ឱ្យផលជាចុតិចិត្តប្រការ ១ មនោវិញ្ញាណធាតុដួងទី ២ នេះ រមែងអំណោយផលក្នុងឋានៈទាំង ៥ នេះ ដោយប្រការដូច្នេះ ៕

**ចប់មនោវិញ្ញាណធាតុ ២ ដួង**

## អធិប្បាយអំពីមហាវិបាកចិត្ត ៨ ដួង

ឥឡូវនេះ ព្រះអង្គទ្រង់បំណងនឹងសម្តែងមហាវិបាកចិត្ត ៨ ដួង ទើបទ្រង់ផ្តើមព្រះតម្រាស់មានពាក្យថា **“កតមេ ធម្មា អព្យាកតា** = ធម៌ជាអព្យាក្រឹត

តើដូចម្តេច” ជាដើមម្តងទៀត។

ក្នុងមហាវិបាកទាំង ៨ នោះ ទ្រង់សម្តែងត្រឹមតែន័យទុកក្នុងព្រះបាលី ហើយទ្រង់បំប្រួញវារៈទុកទាំងអស់; បណ្ឌិតគប្បីជ្រាបអត្ថនៃវារៈទាំងនោះ ដោយន័យដែលពោលទុកខាងក្រោយនោះចុះ; ឯសេចក្តីប្លែកគ្នាណា ក្នុងមហាវិបាកចិត្តទាំងនោះ ទ្រង់បំណងនឹងសម្តែងសេចក្តីប្លែកគ្នានោះ ទើបត្រាស់ព្រះពុទ្ធវចនៈ មានជាអាទិ៍ថា “**អលោភោ អព្យាកតមូលំ** = អព្យាក្រឹត គឺអលោភៈ” ។ ព្រះតម្រាស់ណា សូម្បីមិនបានត្រាស់ទុក, ព្រះតម្រាស់នោះ បណ្ឌិតគប្បីជ្រាបថា ៖

ក៏សេចក្តីផ្សេងគ្នានៃកម្ម ទ្វារ កម្មបថ និងបុញ្ញកិរិយាវត្ថុណា ដែលត្រាស់ទុកក្នុងកាមាវចរកុសលទាំងឡាយ; សេចក្តីផ្សេងគ្នានោះ មិនមានក្នុងមហាវិបាកទាំង ៨ នេះទេ; ព្រោះហេតុអ្វី ? ព្រោះមហាវិបាក ៨ ឱ្យវិញ្ញត្តិកើតមិនបាន គឺហេតុដែលមហាវិបាកមិនមានវិបាកជាធម្មតា និងព្រោះមហាវិបាកមិនប្រព្រឹត្តទៅ (ដូចបុញ្ញកិរិយាវត្ថុ) នោះទេ; សូម្បីករុណា និងមុទិតាណា ដែលត្រាស់ក្នុងយេវាបនកធម៌ទាំងឡាយ, ករុណា និងមុទិតានោះ ក៏មិនមាននៅក្នុងវិបាកទាំងឡាយ ព្រោះមានសត្វជាអារម្មណ៍, ព្រោះថា កាមាវចរវិបាកទាំងឡាយ ជាបរិត្តារម្មណ៍តែម្យ៉ាង, មិនមែនករុណា និងមុទិតាប៉ុណ្ណោះទេ, សូម្បីវិរតិទាំងឡាយ ក៏មិនមានក្នុងវិបាកនេះដែរ; សេចក្តីនេះ សមពិតដូចដែលត្រាស់ថា “សិក្ខាបទ ៥ ជាកុសលប៉ុណ្ណោះ”;

ក៏ក្នុងមហាវិបាកនេះ គប្បីជ្រាបវិធីរបស់ធម៌ ដែលជាអសង្ខារ ( មិនមានការដឹកនាំ) សសង្ខារ ( មានការដឹកនាំ) ដោយកុសល និងដោយសេចក្ដីផ្សេងគ្នានៃបច្ច័យចុះ ។

មែនពិត កុសលជាអសង្ខារិក វិបាកក៏ជាអសង្ខារិក; កុសលជាសសង្ខារិក វិបាកក៏ជាសសង្ខារិក ។ ម្យ៉ាងទៀត កុសលដែលជាអសង្ខារិក លើកឡើងដោយបច្ច័យដែលមានកម្លាំង; កុសលដែលកើតឡើងដោយបច្ច័យក្រៅនេះ ជាសសង្ខារិក ។ សូម្បីក្នុងសេចក្ដីផ្សេងគ្នានៃសេចក្ដីអាក្រក់ជាដើម មហាវិបាកទាំងនេះ មិនឈ្មោះថា អាក្រក់ កណ្ដាល និងប្រណីតទេ ព្រោះសេចក្ដីនៃធម៌មានឆន្ទៈជាដើម ដែលអាក្រក់ កណ្ដាល និងប្រណីត មិនឱ្យសម្រេចឡើយ, តែថា វិបាករបស់កុសលដែលអាក្រក់ ក៏រមែងអាក្រក់, វិបាករបស់កុសលជាកណ្ដាល ក៏រមែងជាកណ្ដាល, វិបាករបស់កុសលដែលប្រណីត ក៏រមែងជារបស់ប្រណីត; ក្នុងវិបាកទាំងនេះ សូម្បីធម៌ដែលជាអធិបតីទាំងឡាយ ក៏មិនបានមាន ។ សេចក្ដីនេះ មានទៅបាន ព្រោះហេតុអ្វី ? ព្រោះសេចក្ដីនៃវិបាកទាំងនេះ មិនធ្វើឆន្ទៈជាដើម ឱ្យជាធុរៈហើយកើតឡើងទេ ។ ពាក្យដ៏សេសទាំងអស់ ដូចពាក្យដែលពោលទុកក្នុងកុសលទាំង ៨ នេះឯង ។

ឥឡូវនេះ គប្បីជ្រាបស្ថានទីដែលនឹងឱ្យផលរបស់មហាវិបាកចិត្តទាំង ៨ នេះ ដូចតទៅ ៖

ពិតណាស់ មហាវិបាកពួកនេះ រមែងឱ្យផលក្នុងស្ថានទាំង៤ គឺក្នុងបដិសន្ធិ ១,

ភវង្គ ១, ចុតិ ១ និងតទាលម្ពណៈ ១; ឱ្យផលដូចម្តេច? គឺរមែងឱ្យផលជាបដិសន្ធិក្នុងវេលាចាប់បដិសន្ធិរបស់អ្នកមានបុណ្យទាំងឡាយ ជាទុហេតុកៈ និងតិហេតុកៈ ក្នុងពួកមនុស្ស និងក្នុងពួកទេវតាជាន់កាមាវចរជាមុន កាលបើបដិសន្ធិចិត្តកន្លងទៅហើយ ក៏ឱ្យផលទៅភវង្គក្នុងបវត្តិកាល រហូតអស់អាយុ ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ រហូតដល់ ១ អសង្ខេយ្យខ្លះ, រមែងឱ្យផលជាតទារម្មណ៍ ក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារ ៦ និងរមែងឱ្យផលជាចុតិក្នុងវេលាស្លាប់ មហាវិបាក រមែងឱ្យផលក្នុងស្ថានទី ៤ ដោយប្រការដូច្នេះ ។

ក្នុងកាលឱ្យផលរបស់មហាវិបាកចិត្តទាំង ៨ នោះ សូម្បីព្រះសព្វញ្ញូពោធិសត្វគ្រប់ព្រះអង្គ រមែងចាប់បដិសន្ធិដោយមហាវិបាកចិត្តដែលជាអសង្ខារិក ប្រកបដោយសោមនស្ស ជាតិហេតុកៈដួងទី ១ ក្នុងការចាប់បដិសន្ធិភពចុងក្រោយ; ក៏មហាវិបាកចិត្តដួងនោះ ជាវិបាករបស់ចិត្ត មានមេត្តាជាចំណែកខាងដើម; ក៏បដិសន្ធិចិត្តដែលមហាវិបាក មានមេត្តាជាចំណែកខាងដើមនោះ ឱ្យមានអាយុ ១ អសង្ខេយ្យ, តែរមែងប្រែប្រួលដោយអំណាចនៃកាល ។

ចំណែកព្រះមហាសិវត្ថេរពោលថា មហាវិបាកចិត្តដែលប្រកបដោយឧបេក្ខាមានកម្លាំងខ្លាំងជាងមហាវិបាក ដែលប្រកបដោយសោមនស្ស, ព្រះសព្វញ្ញូពោធិសត្វ រមែងចាប់បដិសន្ធិដោយមហាវិបាក ដែលប្រកបដោយឧបេក្ខានោះ, ព្រោះ

អ្នកចាប់បដិសន្ធិដោយមហាវិបាក ដែលប្រកបដោយឧបេក្ខានោះ រមែងជាអ្នកមានអធ្យាស្រ័យធំ, ព្រោះភាពជាអ្នកមិនញាប់ញ័រក្នុងអារម្មណ៍ទាំងឡាយ ដែលជាទិព្វ ដូចព្រះចូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកជាដើមដែរ ។ តែពាក្យនេះក្នុងអដ្ឋកថា លោកបដិសេធថា នេះជាសេចក្តីពេញចិត្តរបស់ព្រះថេរៈ; សេចក្តីនេះមិនដូច្នោះទេ ហើយពោលថា ការបំពេញប្រយោជន៍របស់ព្រះសព្វញ្ញូពោធិសត្វទាំងឡាយ ជាសភាវៈមានកម្លាំងច្រើន, ព្រោះហេតុដូច្នោះ ព្រះសព្វញ្ញូពោធិសត្វទាំងឡាយ រមែងចាប់បដិសន្ធិដោយអសង្ខារិកចិត្ត ដែលជាតិហេតុកៈ ប្រកបដោយកាមាវចរកុសលវិបាក មានមេត្តាជាចំណែកខាងដើម ៕

## អធិប្បាយអំពីទ្វារវិបាកមាតិកាកថា

ឥឡូវនេះ គួរនឹងតាំងមាតិកាក្នុងកថានៃទ្វារវិបាក ដូចតទៅ ៖

ព្រះចូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលទុកជាមុនថា “កុសលចេតនាតែមួយដួង រមែងកើតវិបាកចិត្ត ១៦ ដួង, ក្នុងកុសលចេតនាដួងនេះឯង ជាហេតុឱ្យកើតវិបាកចិត្ត ១២ ដួងខ្លះ ជាអហេតុកចិត្ត ៨ ដួងខ្លះ” ។

ក៏ព្រះមហាទត្តត្ថេរអ្នកនៅក្នុង **វិហារមោរវាបី** ពោលថា “កុសលចេតនា ១ ដួង រមែងកើតវិបាកចិត្ត ១២ ដួង, ក្នុងកុសលចេតនាដួងនេះឯង ជាហេតុឱ្យកើត

វិបាកចិត្ត ១០ ដួងខ្លះ អហេតុកចិត្ត ៨ ដួងខ្លះ” ។

**តែព្រះមហាធម្មរក្ខិតត្ថេរ** អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា កុសល-ចេតនាតែមួយដួង រមែងកើតវិបាកចិត្ត ១០ ដួង, ក្នុងកុសលចេតនាដួងនេះឯង ជាអហេតុកចិត្ត ៨ ។

ក្នុងឋានៈនេះ ព្រះថេរៈទាំងនោះកាន់យករឿងឈ្មោះថា **សាកេតកបញ្ហា** ។

បានឮថា ពួកឧបាសកអ្នកនៅក្នុងក្រុងសាកេត អង្គុយក្នុងសាលា សន្ទនាគ្នាដល់បញ្ហាថា ក្នុងចេតនាកម្មតែមួយដួងដែលប្រកបហើយ នឹងមានបដិសន្ធិតែម្យ៉ាង ឬច្រើនយ៉ាង, មិនអាចវិនិច្ឆ័យបាន ទើបនាំគ្នាទៅសួរព្រះថេរៈ អ្នកទ្រទ្រង់ព្រះអភិធម្ម។

ព្រះថេរៈទាំងឡាយ ឱ្យពួកឧបាសកទាំងនោះ ព្រមទទួល (យល់) ដោយពាក្យថា ពន្លកតែមួយប៉ុណ្ណោះ រមែងចេញអំពីគ្រាប់ស្វាយតែមួយ យ៉ាងណា, ចេតនាតែមួយ ក៏មានបដិសន្ធិតែមួយដូច្នោះដែរ ។ ក្នុងថ្ងៃតមក ក៏សន្ទនាគ្នាដល់បញ្ហាថា ក៏ចេតនាផ្សេងៗ ដែលធ្វើកម្មហើយ រមែងមានបដិសន្ធិផ្សេងៗ, ឬមានបដិសន្ធិតែមួយដូច្នេះ; កាលបើមិនអាចវិនិច្ឆ័យបាន ទើបនាំគ្នាទៅសួរព្រះថេរៈទាំងឡាយ ព្រះថេរៈទាំងឡាយ ញ៉ាំងឧបាសកទាំងឡាយនោះ ឱ្យព្រមទទួលដោយពាក្យថា “កាលបើគ្រាប់ស្វាយច្រើន ដែលគេបន្ដុះទុក ពន្លកជាច្រើន ក៏រមែង

ដុះឡើង យ៉ាងណា, ចេតនាច្រើន ក៏មានបដិសន្ធិច្រើនដូច្នោះដែរ” ។

ប្រការមួយទៀត ក្នុងឋានៈនេះ លោកកាន់យករឿងឈ្មោះថាការសម្ដែងដល់វត្ថុដែលមានច្រើនជាប្រមាណ; ព្រោះសត្វទាំងឡាយនេះ មានលោភៈច្រើនក្ដី, មានទោសៈច្រើនក្ដី, មានមោហៈច្រើនក្ដី, មានអលោភៈ អទោសៈ និងអមោហៈច្រើនក្ដី; **សួរថា** ធម៌អ្វីរមែងកំណត់សភាវៈនោះ របស់ពួកនោះដែលមានច្រើនបាន? ឆ្លើយថា បុព្វហេតុរមែងកំណត់, សេចក្ដីផ្សេងគ្នា រមែងមានក្នុងខណៈនៃការប្រកបកម្មនោះឯង, ខនេះ ជាយ៉ាងណា ? គឺក្នុងខណៈការប្រកបកម្មរបស់បុគ្គលណា លោភៈមានកម្លាំងខ្លាំង, អលោភៈមានកម្លាំងខ្សោយ, អទោសៈ និងអមោហៈមានកម្លាំងខ្លាំង, ទោសៈ និងមោហៈមានកម្លាំងខ្សោយ, អលោភៈខ្សោយរបស់បុគ្គលនោះ មិនអាចដើម្បីគ្របសង្កត់លោភៈបាន, តែថា អទោសៈ និងអមោហៈមានកម្លាំងខ្លាំង រមែងអាចដើម្បីគ្របសង្កត់ទោសៈ និងមោហៈបាន, ព្រោះដូច្នោះ បុគ្គលនោះ កើតដោយអំណាចនៃបដិសន្ធិ ដែលកម្មនោះឱ្យហើយ រមែងជាមនុស្សលោភច្រើន, មានសេចក្ដីសុខជាប្រក្រតី, ជាអ្នកមិនក្រោធ, តែមានបញ្ញា មានញាណ ប្រៀបដូចជាពេជ្រដូច្នោះដែរ ។

ម្យ៉ាងទៀត ក្នុងខណៈដែលប្រកបកម្មរបស់បុគ្គលណា លោភៈ និងទោសៈមានកម្លាំងខ្លាំង, អលោភៈ និងទោសៈមានកម្លាំងខ្សោយ, និងមានអមោហៈខ្លាំង

មានមោហៈខ្សោយ, បុគ្គលនោះជាអ្នកល្មោភច្រើន ដោយន័យមុនន៉ុះឯងផង ជាអ្នកប្រទូស្តរាយផង, តែជាមនុស្សមានបញ្ញា មានញាណប្រៀបដូចជាពេជ្រ ដូចព្រះទត្តាភយត្ថេរដែរ ។

ម្យ៉ាងទៀត ក្នុងខណៈប្រកបកម្មរបស់បុគ្គលណា លោភៈ អទោសៈ និងមោហៈមានកម្លាំងខ្លាំង, ក្រៅពីនេះ (អលោភៈ ទោសៈ និងអមោហៈ) មានកម្លាំងខ្សោយ, បុគ្គលនោះជាអ្នកល្មោភច្រើន ដោយន័យមុននោះឯងផង ជាមនុស្សល្ងង់ខ្លៅផង, តែជាមនុស្សមានសេចក្ដីសុខជាប្រក្រតី ជាអ្នកមិនក្រោធ ។

ម្យ៉ាងវិញទៀត ក្នុងខណៈប្រកបកម្មរបស់បុគ្គលណា សូម្បីលោភៈ ទោសៈ និងមោហៈទាំង ៣ មានកម្លាំងខ្លាំង, អលោភៈជាដើម មានកម្លាំងខ្សោយ, បុគ្គលនោះ ជាអ្នកល្មោភច្រើន តាមន័យមុនន៉ុះឯងផង ជាអ្នកប្រទូស្តរាយផង ជាអ្នកវង្វេងផង ។

ម្យ៉ាងវិញទៀត ក្នុងខណៈប្រកបកម្មរបស់បុគ្គលណា អលោភៈ អទោសៈ និងមោហៈ មានកម្លាំងខ្លាំង, ក្រៅពីនេះ (គឺលោភៈ ទោសៈ និងអមោហៈ) មានកម្លាំងខ្សោយ, បុគ្គលនោះ មានកិលេសតិច ដោយន័យមុននោះឯង សូម្បីគេឃើញអារម្មណ៍ដែលជាទិព្វ ក៏មិនញាប់ញ័រ តែជាអ្នកប្រទូស្តរាយ និងមានបញ្ញាអន់ថយ ។

មា្យ៉ាងវិញទៀត ក្នុងខណៈប្រកបកម្មរបស់បុគ្គលណា អលោភៈ អទោសៈ និងមោហៈ មានកម្លាំងខ្លាំង, ក្រៅពីនេះ (គឺលោភៈ ទោសៈ និងអមោហៈ) មានកម្លាំងខ្សោយ, បុគ្គលនោះ ជាមនុស្សមិនល្មោភច្រើន ជាមនុស្សមានសេចក្ដីសុខជាប្រក្រតី, តែជាមនុស្សល្ងង់ខ្លៅ តាមន័យមុននុ៎ះឯង ។

មា្យ៉ាងវិញទៀត ក្នុងខណៈដែលប្រកបកម្មរបស់បុគ្គលណា អលោភៈ ទោសៈ និងអមោហៈមានកម្លាំងខ្លាំង, ក្រៅពីនេះ (គឺលោភៈ អទោសៈ និងមោហៈ) មានម្លាំងខ្សោយ, បុគ្គលនោះ ជាអ្នកមិនល្មោភច្រើន ដោយន័យមុននោះឯង មានបញ្ញាដែរ, តែជាមនុស្សប្រទូស្តរាយ និងខឹងក្រោធ ។

មា្យ៉ាងវិញទៀត ក្នុងខណៈដែលប្រកបកម្មរបស់បុគ្គលណា សូម្បីមានអលោភៈជាដើមទាំង ៣ មានកម្លាំងខ្លាំង, មានលោភៈជាដើមខ្សោយ, បុគ្គលនោះជាអ្នកមិនល្មោភច្រើន មិនជាអ្នកប្រទូស្តរាយ និងមានបញ្ញា ដូចព្រះមហាសង្ឃរក្ខិតត្ថេរដូច្នោះឯង ។

មា្យ៉ាងទៀត ក្នុងឋានៈនេះ លោកកាន់យករឿង **ការលើកសរសើរហេតុ**, ពិតមែនហើយ កម្មដែលប្រកបដោយហេតុ ៣ រមែងឱ្យវិបាកជាតិហេតុកៈខ្លះ ទុហេតុកៈខ្លះ អហេតុកៈខ្លះ, កម្មដែលប្រកបដោយហេតុ ២ រមែងមិនឱ្យវិបាក

ជាតិហេតុកៈទេ, ឱ្យតែវិបាកក្រៅពីនេះ ដោយកម្មដែលប្រកបដោយហេតុ ៣, បដិសន្ធិរមែងជាតិហេតុកៈខ្លះ, ជាទុហេតុកៈខ្លះ, មិនមានអហេតុកៈ, ដោយកម្មដែលប្រកបដោយហេតុ ២ បដិសន្ធិរមែងជាទុហេតុកៈខ្លះ, រមែងជាអហេតុកៈខ្លះ, មិនជាតិហេតុកៈ ក្នុងកុសលកម្មដែលជាអសង្ខារិក រមែងឱ្យវិបាកជាអសង្ខារិកខ្លះ ជាសសង្ខារិកខ្លះ ។ កុសលដែលជាសសង្ខារិក រមែងឱ្យវិបាកជាសសង្ខារិកខ្លះ អសង្ខារិកខ្លះ ។ វេទនាគប្បីប្តូរផ្លាស់ទៅតាមអារម្មណ៍, **តទារម្មណ៍គប្បីកំណត់ដោយជវន** ៕

## សម្តែងអំពីវិបាកចិត្ត ១៦ ដួង តាមន័យរបស់ព្រះចូឡនាគត្ថេរ

ឥឡូវនេះ គប្បីជ្រាប **ហេតុកើតវិបាក ១៦ ដួង ជាដើម** ក្នុងវាទៈរបស់ព្រះថេរៈនោះៗ, ក៏សត្វអ្នកចាប់បដិសន្ធិដោយមហាវិបាកចិត្តដួងទី ១ ដូចកាមាវចរកុសលមួយដួង ចេញអំពីការនៅក្នុងគភ៌ហើយ ចូលដល់ភាពជាអ្នកអាចតាំងផ្តើមនៅក្នុងសំវរៈ និងអសំវរៈ, កាលបើឥដ្ឋារម្មណ៍មកកាន់គន្លងចក្ខុទ្វារហើយ មនោធាតុដែលជាកិរិយា មិនញុាំងភវង្គឱ្យផ្លាស់ទៅ ប្រមាណនៃអារម្មណ៍ដែលឈានកន្លងក៏មិនមាន, ព្រោះហេតុអ្វី ទើបបានជាដូច្នោះ ? ព្រោះអារម្មណ៍មាន

កម្លាំងខ្សោយ, នេះជាមោឃវារៈមួយសិន ។

ក៏បើចិត្តនោះ ស្ទុះទៅកាន់ភវង្គ, កាលមនោធាតុដែលជាកិរិយា ញ៉ាំងភវង្គឱ្យផ្លាស់ទៅ ចិត្តនោះមិនទាន់ដល់វោដ្ឋព្វនៈនៅឡើយ ចិត្តនោះនឹងត្រឡប់មកតាំងនៅក្នុងចក្ខុវិញ្ញាណ ឬសម្បដិច្ឆន្នៈ ឬក៏សន្តីរណៈដូច្នោះ សេចក្ដីនេះ មិនមែនឋានៈដែលមានបានទេ; តែថា ចិត្តមួយដួងខ្លះ ពីរដួងខ្លះ តាំងនៅក្នុងវោដ្ឋព្វនៈហើយប្រព្រឹត្តទៅ, តអំពីនោះ ក៏តាំងនៅក្នុងឋានៈនៃជវន ព្រោះបានអាសេវនៈហើយក៏ធ្លាក់ចុះកាន់ភវង្គទៀត, សូម្បីចិត្តនេះ ក៏រមែងមានដោយអាការយ៉ាងនេះ ព្រោះភាវៈនៃអារម្មណ៍ដែលទុព្វល, តែវារៈនេះ រមែងបានក្នុងវេលាដែលពោលពាក្យមានជាអាទិ៍ថា "រូបនេះ ដូចយើងបានឃើញហើយ, សំឡេងនេះ ដូចយើងបានស្ដាប់ហើយ" ; សូម្បីមោឃវារៈនេះ ជាវារៈទីពីរ ។

កាលបើមនោធាតុដែលជាកិរិយារបស់បុគ្គលដទៃទៀត ញ៉ាំងភវង្គឱ្យផ្លាស់ទៅហើយ វីថិចិត្តទាំងឡាយរមែងកើត, ជវនរមែងស្ទុះទៅ; ក្នុងវេលាទីបំផុតនៃជវន ក៏ជាវារៈរបស់តទារម្មណ៍, តែតទារម្មណ៍នោះ នៅមិនទាន់កើតហួស ក៏ធ្លាក់ចុះកាន់ភវង្គទៅ; ក្នុងសេចក្ដីនេះ មានឧបមាដូច្នេះ ៖

ដូចកាលបើគេសាងទំនប់ទប់ទឹកស្ទឹង ធ្វើឱ្យទឹកហូរបែរទៅកាន់ប្រឡាយធំ ទឹករមែងហូរបែរទៅពេញភ្លឺស្រែក្នុងត្រើយទាំងពីរ ហើយក៏ហៀរទៅតាមផ្លូវទាំង-

ឡាយ មានផ្លូវក្ដាមជាដើម ក៏ធ្លាក់ចុះកាន់ទឹកស្ទឹងនោះវិញ យ៉ាងណា, សេចក្ដីឧបមេយ្យនេះ គប្បីជ្រាបដូច្នេះចុះ ។ ក៏ក្នុងសេចក្ដីនេះ វេលាដែលភវង្គវីថិប្រព្រឹត្តទៅ ដូចវេលាប្រព្រឹត្តទៅនៃទឹកក្នុងស្ទឹង, វេលាមនោធាតុដែលជាកិរិយាញុំាងភវង្គឱ្យផ្លាស់ទៅ ដូចវេលាដែលគេសាងទំនប់ទប់ទឹកស្ទឹង, ការដែលវីថិចិត្តប្រព្រឹត្តទៅដូចវេលាដែលទឹកកំពុងហូរទៅក្នុងប្រឡាយធំ, ជវនដូចការពេញភ្លឺស្រែក្នុងត្រើយទាំងពីរ, ការស្ទុះទៅនៃជវនហើយ, តែតទារម្មណ៍នៅមិនទាន់កើតហួសជវនចិត្តនោះនៅឡើយ ក៏ធ្លាក់ចុះកាន់ភវង្គវិញ ដូចទឹកហូរអំពីផ្លូវទាំងឡាយ មានផ្លូវក្ដាមជាដើម ហើយទៅកាន់ស្ទឹងវិញ; គន្លងនៃការរាប់ចិត្តដែលធ្លាក់ចុះកាន់ភវង្គ ដោយអាការយ៉ាងនេះ មិនមានឡើយ; សូម្បីចិត្តនេះ រមែងមានយ៉ាងនេះ ក៏ព្រោះតែភាវៈនៃអារម្មណ៍ដែលទុព្វល; នេះជាមោឃវារៈទី ៣ ។

ក៏បើអារម្មណ៍ដែលមានកម្លាំងខ្លាំងមកកាន់គន្លងសោត, មនោធាតុដែលជាកិរិយាញុំាងភវង្គឱ្យផ្លាស់ទៅហើយ ចិត្តទាំងឡាយ មានចក្ខុវិញ្ញាណជាដើម រមែងកើតឡើង, ក៏ក្នុងឋានៈនៃជវន កាមាវចរកុសលចិត្តដួងទី ១ ជាជវនហើយ ក៏ស្ទុះទៅ ៦-៧ វារៈ ទើបឱ្យឱកាសដល់តទារម្មណ៍, តទារម្មណ៍បើតាំងនៅ ក៏តាំងនៅជាមហាវិបាកចិត្ត ដូចកាមាវចរកុសលចិត្តដួងទី ១ នោះឯង, មហាវិបាកចិត្តដួងទី១ នេះ បានឈ្មោះពីរ គឺមូលភវង្គ ព្រោះដូចចិត្តដែលបដិសន្ធិ និងឈ្មោះថា តទា-

រម្មណ៍ ព្រោះសភាវៈនៃចិត្តនោះ ទទួលអារម្មណ៍ដែលជវនចិត្តទទួលមកហើយ ។

ក្នុងឋានៈនេះ វិបាកចិត្ត រមែងដល់ការរាប់បាន ៤ យ៉ាង គឺចក្ខុវិញ្ញាណ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ តទារម្មណ៍ ១ ។

ម្យ៉ាងទៀត កាលណាកុសលចិត្តដួងទី ២ ជាជវន, កាលនោះ កុសលវិបាក-ចិត្តដួងទី ២ ដូចកុសលចិត្តដួងទី ២ នោះ ក៏តាំងនៅក្នុងឋានៈ ជាតទារម្មណ៍ ។ សូម្បីវិបាកចិត្តដួងទី ២ នេះ រមែងបានឈ្មោះពីរយ៉ាង គឺឈ្មោះថា អាគន្តុកភវង្គ ព្រោះមិនដូចគ្នានឹងបដិសន្ធិចិត្ត និងឈ្មោះថា តទារម្មណ៍ដោយន័យមុនទុំះដែរ, វិបាកចិត្តដួងមុន ៤ ដួង ជាមួយចិត្តដួងនេះ រួមជាចិត្ត ៥ ដួង ។ ក៏កាលណាកុសល-ចិត្តដួងទី ៣ ជាជវន, កាលនោះ កុសលចិត្តដួងទី ៣ ដូចនឹងកុសលចិត្តនោះ ក៏តាំងនៅក្នុងឋានៈជាតទារម្មណ៍, វិបាកចិត្តដួងទី ៣ នេះ បានឈ្មោះ ២ យ៉ាង គឺ អាគន្តុកភវង្គ និងតទារម្មណ៍ ដោយន័យដូចដែលបានពោលហើយនោះដែរ, វិបាក-ចិត្តដួងមុនៗ ៥ ដួង រួមជាមួយចិត្តនេះ ក៏ជាចិត្ត ៦ ដួង ។

ម្យ៉ាងវិញទៀត កាលណាកុសលចិត្តដួងទី ៤ ជាជវន, កាលនោះ វិបាក-ចិត្តដួងទី ៤ ដូចជាមួយកុសលចិត្តនោះ ក៏តាំងនៅក្នុងឋានៈជាតទារម្មណ៍; សូម្បីវិបាកចិត្តនេះ រមែងបានឈ្មោះ ២ គឺអាគន្តុកភង្គ និងតទារម្មណ៍ ដោយន័យដូច

ដែលបានពោលហើយនោះដែរ, វិបាកចិត្តដួងមុនៗ ៦ ដួង រួមជាមួយចិត្តដួងនេះ ក៏ជា ៧ ដួង ។

ក៏កាលណា ឥដ្ឋមជ្ឈត្តារម្មណ៍ មកកាន់គន្លងទ្វារនោះ កាលនោះ រមែងបានមោឃវារៈ ៣ ដោយន័យដែលបានពោលទុកសូម្បីក្នុងឥដ្ឋមជ្ឈត្តារម្មណ៍នោះ, តែព្រោះវេទនារមែងផ្លាស់ទៅតាមអារម្មណ៍, ព្រោះហេតុដូច្នោះ ក្នុងវេទនានោះសន្តីរណៈ ទើបប្រកបដោយឧបេក្ខា ។ ក្នុងទីបំផុតនៃមហាកុសលជវនដែលប្រកបដោយឧបេក្ខា ៤ ដួង មហាវិបាកចិត្តដែលប្រកបដោយឧបេក្ខា ៤ ដួង រមែងតាំងនៅដោយភាពជាតទារម្មណ៍, សូម្បីមហាវិបាកចិត្តដែលប្រកបដោយឧបេក្ខាទាំង ៤ នោះ ក៏បានឈ្មោះ ២ យ៉ាង គឺអាគន្តុកភវង្គ និងតទារម្មណ៍ ដោយន័យដូចដែលបានពោលហើយនុ៎ះដែរ, លោកហៅថា បិដ្ឋិភវង្គ (ភវង្គចុងក្រោយ) ដូច្នេះ ក៏មាន, វិបាកចិត្ត ៥ ជាមួយដួងនេះ និងវិបាកចិត្ត ៧ ដួងមុន រួមជា ១២ ដួង ដោយប្រការដូច្នេះ ។ វិបាកចិត្តក្នុងចក្ខុទ្វារមាន ១២ ដួង, ក្នុងសោតទ្វារជាដើម ក៏មានទ្វារនីមួយៗ ១២ ដួង ទើបរួមជាវិបាកចិត្ត ៦០ ដួងគត់ ដោយប្រការដូច្នេះ ។

កាលបើកុសលចេតនា ១ ដួង ប្រកបកម្មហើយ រមែងញុំាងវិបាកចិត្ត ៦០ គត់ ឱ្យកើតឡើង ដោយប្រការដូច្នេះ, តែថា កាលបើកាន់យកវិបាកដែលនៅមិនទាន់បានកាន់យក ក៏បានវិបាកចិត្ត ១៦ ដួង គឺវិបាកចិត្ត ១២ ដួង កើតក្នុងចក្ខុទ្វារ

និងវិបាកចិត្ត ៤ ដួង បានដល់ សោតវិញ្ញាណ ១, ឃានវិញ្ញាណ ១, ជិវ្ហាវិញ្ញាណ ១ និងកាយវិញ្ញាណ ១ ។

ក្នុងឋានៈនេះ លោកកាន់យករឿងឈ្មោះថា **អម្ពោបមា** គឺប្រៀបដូចជាផ្លែស្វាយ ៖

សន្មតិថា បុរសម្នាក់ដេកទទូរក្បាលក្រោមគល់ស្វាយ ដែលមានផ្លែទុំហើយលក់ទៅ ខណៈនោះ ផ្លែស្វាយទុំ ១ ជ្រុះចាកទង ធ្លាក់ចុះមកដី សំឡេងឮថា “ក្តុក” ហាក់បីដូចជាសង្កៀតប្រហោងត្រចៀករបស់គេ, គេភ្ញាក់ឡើងដោយសំឡេងរបស់ស្វាយនោះ ហើយបើកភ្នែកសំឡឹងមើល; ក្នុងពេលនោះ ទើបលូកដៃទៅចាប់ផ្លែស្វាយ ច្របាច់ហិតក្លិនហើយ ទើបបរិភោគ ។

ក្នុងពាក្យឧបមាទាំងនោះ វេលាដែលភវង្គព្រមព្រៀងគ្នា គប្បីជ្រាបថាដូចវេលាដែលបុរសនោះ ដេកលក់ក្រោមគល់ស្វាយ, វេលាដែលអារម្មណ៍ប៉ះខ្ទប់បសាទ ដូចវេលាដែលផ្លែស្វាយទុំជ្រុះធ្លាក់ចាកទងចុះទៅ ហើយសង្កៀតនូវប្រហោងត្រចៀក, វេលាដែលមនោធាតុ គឺកិរិយាញ៉ាំងភវង្គឱ្យផ្លាស់ទៅ ដូចវេលាដែលបុរសនោះភ្ញាក់ឡើងដោយសំឡេងស្វាយធ្លាក់, វេលាដែលចក្ខុវិញ្ញាណញ៉ាំងទស្សនកិច្ចឱ្យសម្រេច ដូចវេលាដែលបុរសនោះ បើកភ្នែកឡើងសំឡឹងមើល, វេលាដែលមនោធាតុ ជាវិបាកទទួលអារម្មណ៍ ដូចវេលាដែលបុរសលូកដៃទៅចាប់ផ្លែស្វាយ

នោះ, វេលាដែលមនោវិញ្ញាណធាតុ ជាវិបាកពិចារណាអារម្មណ៍ ដូចវេលាដែលបុរសចាប់ស្វាយមកច្របាច់, វេលាដែលមនោវិញ្ញាណធាតុជាកិរិយាកំណត់អារម្មណ៍ ដូចវេលាហិតក្លិនស្វាយ, វេលាជវនចិត្តសោយរសនៃអារម្មណ៍ ដូចវេលាដែលបុរសនោះ បរិភោគផ្លែស្វាយដូច្នោះ ។

**សួរថា** ឧបមានេះ សម្តែងដល់អត្ថអ្វី ?

ឆ្លើយថា សម្តែងដល់ការប៉ះខ្ទប់ប្រសាទជាកិច្ច[៤១] (នាទី) របស់អារម្មណ៍ប៉ុណ្ណោះ ។

គឺកាលបើអារម្មណ៍នោះ មកប៉ះខ្ទប់ប្រសាទហើយ ការផ្លាស់ទៅនៃភវង្គ

---

[៤១] លោកសម្តែងកិច្ចទាំងអស់មាន ១៤, ក្នុងទីនេះ លោកសម្តែងទុក ៨ គឺ

១-ការប៉ះខ្ទប់ប្រសាទ ជាកិច្ចរបស់អារម្មណ៍

២-ការរំពឹងដល់អារម្មណ៍ ជាកិច្ចរបស់អាវជ្ជនៈ

៣-ការឃើញ ជាកិច្ចរបស់ចក្ខុវិញ្ញាណ

៤-ការទទួលអារម្មណ៍ ជាកិច្ចរបស់សម្បដិច្ឆន្នៈ

៥-ការពិចារណា ជាកិច្ចរបស់សន្តីរណៈ

៦-ការវិនិច្ឆ័យអារម្មណ៍ ជាកិច្ចរបស់វោដ្ឋព្វនៈ

៧-ការសោយរសនៃអារម្មណ៍ ជាកិច្ចរបស់ជវនៈ

៨-ការសោយរសនៃអារម្មណ៍ដ៏សេសអំពីជវន ជាកិច្ចរបស់តទារម្មណ៍ ។

នោះ ជាកិច្ចរបស់កិរិយាមនោធាតុ កិច្ចរបស់ចក្ខុវិញ្ញាណ មានត្រឹមតែការឃើញប៉ុណ្ណោះ, កិច្ចនៃវិបាកមនោធាតុមានត្រឹមតែការទទួលអារម្មណ៍ប៉ុណ្ណោះ, កិច្ចរបស់វិបាកមនោវិញ្ញាណធាតុ មានត្រឹមតែការពិចារណាអារម្មណ៍ប៉ុណ្ណោះ, កិច្ចរបស់កិរិយាធាតុ មានត្រឹមតែការកំណត់អារម្មណ៍ប៉ុណ្ណោះ, ជវនប៉ុណ្ណោះ រមែងសោយរសនៃអារម្មណ៍តែម្យ៉ាង ។

ក៏ក្នុងការប្រព្រឹត្តទៅនៃចិត្តនេះ នរណាៗ ជាអ្នកធ្វើ ឬជាអ្នកបង្គាប់ ឱ្យធ្វើថា "លោកចូរឈ្មោះថា ភវង្គ, លោកចូរឈ្មោះថា អាវជ្ជនៈ, លោកចូរឈ្មោះថា ទស្សនៈ (ចក្ខុវិញ្ញាណ), លោកចូរឈ្មោះថា សម្បដិច្ឆន្នៈ, លោកចូរឈ្មោះថា សន្តីរណៈ, លោកចូរឈ្មោះថា វោដ្ឋព្វនៈ, លោកចូរឈ្មោះថា ជវនៈ, លោកចូរឈ្មោះថា តទារម្មណ៍" ដូច្នេះ មិនមានទេ ។ (ដើម្បីសេចក្តីជាក់ច្បាស់ ទើបសម្តែងដល់និយាម ៥ យ៉ាង) ៕

## សម្តែងអំពីនិយាម ៥ យ៉ាង

ក៏ក្នុងឋានៈនេះ លោកកាន់យករឿងឈ្មោះថា **និយាម ៥ យ៉ាង** គឺ

១- **ពីជនិយាម** សេចក្តីទៀងទាត់របស់ពូជ

២- **ឧតុនិយាម** សេចក្តីទៀងទាត់របស់រដូវកាល

៣- **កម្មនិយាម** សេចក្តីទៀងទាត់របស់កម្ម

៤- **ធម្មនិយាម** សេចក្ដីទៀងទាត់របស់ធម៌

៥- **ចិត្តនិយាម** សេចក្ដីទៀងទាត់របស់ចិត្ត ។

បណ្ដានិយាមទាំង ៥ នោះ ធម្មជាតិដែលពូជនោះៗ ឱ្យផលដូចគ្នានិងពូជនោះ គឺពូជសណ្ដែកប្រភេទមួយបោះទងទៅខាងឆ្វេង[៤២], វល្លិទៅខាងស្ដាំ ឡោមព័ទ្ធដើមឈើទៅខាងស្ដាំ, ផ្កាព្រះអាទិត្យ (ផ្កាឈូករ័ត្ន) បែរមុខទៅរកព្រះអាទិត្យ, វល្លិជ្រៃមានមុខឆ្ពោះទៅរកដើមឈើតែម្យ៉ាង, ផ្លែដូង មានប្រហោងខាងលើ ឈ្មោះថា **ពីជនិយាម** (ជាធម្មតារបស់ពូជ) ធម្មជាតិដែលដើមឈើនោះៗ បញ្ចេញផ្កាផ្លែ និងមានស្លឹកខ្ចីព្រមៗ គ្នា ក្នុងសម័យនោះៗ ឈ្មោះថា **ឧតុនិយាម**, សភាវៈដែលកម្មនោះៗ ឱ្យផលដូចគ្នានឹងកម្មនោះៗ យ៉ាងនេះ គឺកម្មដែលប្រកបដោយកុសលហេតុ ៣ រមែងឱ្យវិបាកជាតិហេតុកៈ, ទុហេតុកៈ និងអហេតុកៈ; កម្មដែលប្រកបដោយកុសលហេតុ ២ រមែងឱ្យវិបាកជាទុហេតុកៈ និងអហេតុកៈ, មិនឱ្យវិបាកជាតិហេតុកៈ ឈ្មោះថា **កម្មនិយាម** ។

ម្យ៉ាងទៀត ជាកម្មនិយាមដោយអំណាចនៃវិបាកដូចនឹងកម្មនុ៎ះឯង; ដើម្បីសម្ដែងកម្មនិយាមនោះ លោកអាចារ្យទាំងឡាយពោលរឿងទុកដូច្នេះ ៖

---

[៤២] បែរមុខទៅរកទិសបូព៌ា ក៏ជាដៃឆ្វេង ឬហៅថា ទិសឧត្តរ ។

ក្នុងសម័យនៃព្រះសម្មាសម្ពុទ្ធ ស្រុកជិតទ្វារនគរសាវត្ថី ត្រូវភ្លើងឆេះ; រង្វេលស្មៅ [៤៣] ជាប់ភ្លើងភ្លឺចិញ្ចាចអំពីស្រុកភ្លើងឆេះនោះ ហោះឡើងទៅពាក់ក ក្អែកដែលហើរតាមអាកាស ក្អែកនោះស្រែកធ្លាក់ស្លាប់លើផែនដី ។ ទូកមួយ បាន ឈប់នៅស្ងៀម អណ្តែតនៅក្នុងមហាសមុទ្រ ។

កាលបើពួកគេមិនឃើញផ្លូវ ដែលនរណាៗ នឹងរួចចាកភយន្តរាយ ខាង ក្រោយមក ទើបគិតចាប់ស្លាករកមនុស្សចង្រៃ (កាឡកណ្ណិ); ស្លាកនោះ បានធ្លាក់ ទៅក្នុងដៃភរិយាកំណាន់របស់នាយទូកនោះ ។

លំដាប់នោះ ជនទាំងឡាយទើបនិយាយថា "សូមអ្នកទាំងអស់គ្នា កុំនាំគ្នា វិនាស ព្រោះហេតុតែស្ត្រីម្នាក់, ពួកយើងនឹងចាប់នាងបោះចូលទៅក្នុងទឹក" ដូច្នេះ; នាយទូកនិយាយថា "យើងមិនអាចឃើញស្រីនេះ អណ្តែតទៅក្នុងទឹកបានទេ"; ទើបយកឆ្នាំងដាក់ដីខ្សាច់ចងជាប់កបោះចុះទៅ ក្នុងខណៈនោះឯង ទូកក៏ស្ទុះទៅ ហាក់បីដូចជាកូនសរដែលបាញ់ទៅដូច្នោះ ។

ភិក្ខុមួយរូបចូលទៅក្នុងល្អាង, កំពូលភ្នំធំធ្លាក់មកជិតទ្វារល្អាង, ក្នុងថ្ងៃទី ៧ កំពូលភ្នំនោះ ក៏របើកចេញឯងតែម្តង ។

---

[៤៣] រង្វេលស្មៅដែលគេចងធ្វើជារង្វង់មូលទ្រាប់ឆ្នាំង ។

ពួកភិក្ខុក្រាបទូលរឿងទាំង ៣ នេះ ចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលទ្រង់គង់ប្រថាប់សម្តែងធម៌ក្នុងវត្តជេតពន ដំណាលគ្នាទាំងអស់; ព្រះសាស្តាត្រាស់ថា "នុ៎ះមិនមែនអ្នកដទៃធ្វើទេ, នុ៎ះជាកម្មដែលគេទាំងនោះធ្វើហើយ" ដូច្នេះ, កាលនឹងទ្រង់នាំរឿងអតីតមកសម្តែងធម៌ ទើបទ្រង់ត្រាស់ថា ៖

ការកើតជាមនុស្សក្នុងអត្តភាពមុន មិនអាចដើម្បីហ្វឹកហាត់គោកាច ១ ក្បាលបាន ទើបបានចងរង្វេលចំបើងពាក់កគោហើយ ក៏ដុតភ្លើង, គោនោះងាប់ដោយហេតុនោះឯង, ឥឡូវនេះ កម្មនោះ ទើបមិនដោះលែងក្អែកនោះ សូម្បីហើរទៅតាមអាកាស ។ សូម្បីស្ត្រីនេះ ក៏ជាស្រីមួយនោះឯង ក្នុងអត្តភាពមុន; ឆ្កែមួយស្និទ្ធស្នាលគ្នា កាលបើនាងទៅព្រៃ ក៏ទៅតាម, កាលបើមក ក៏មកតាម; ពួកមនុស្សជិតខាងទាំងឡាយ រមែងចំអកឱ្យនាងថា "ពេលនេះអ្នកបរបាញ់ឆ្កែរបស់យើងចេញហើយ"; នាងធុញទ្រាន់ជាមួយឆ្កែនោះ កាលបើមិនអាចហាមឆ្កែបាន ទើបយកឆ្នាំងដាក់ដីខ្សាច់ចងកហើយបោះទៅក្នុងទឹក; កម្មនោះទើបមិនដោះលែងនាងត្រង់កណ្តាលសមុទ្រ ។ សូម្បីភិក្ខុនោះ ក៏ជានាយគោបាលក្នុងអត្តភាពមុន កាលបើទន្សងចូលទៅក្នុងរូង ក៏កាច់មែកឈើមួយក្តាប់បិទរូង, ក្រោយអំពីនោះមក ៧ ថ្ងៃ ទើបគេមកបើករូងខ្លួនឯងតែម្តង, ទន្សងនោះ ញ័រចំប្រប់ វាចេញមក; ដោយភាពករុណា ទើបគេមិនសម្លាប់វា; កម្មនោះ មិនឱ្យដើម្បីនឹងដោះលែងភិក្ខុនោះ

ដែលចូលទៅកាន់ញកភ្នំហើយអង្គុយ ។

កាលបើទ្រង់ប្រជុំរឿងទាំង ៣ នេះ ដោយប្រការដូច្នេះហើយ ទើបត្រាស់គាថានេះថា ៖

**“ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**
**ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតេ សោ ជគតិប្បទេសោ**
**យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។**

**មិនថាក្នុងទីណាៗ ទេ ទោះទាំងក្នុងអាកាស ក្នុងកណ្តាលសមុទ្រ ឬក្នុងញកភ្នំក៏ដោយ ចំណែកភូមិប្រទេស ដែលសត្វស្ថិតនៅហើយ នឹងគប្បីរួចទៅចាកបាបកម្មបាន មិនមានឡើយ”** [៤៤] ។

នេះក៏ឈ្មោះថា កម្មនិយាមដូចគ្នា ។ សូម្បីរឿងដទៃៗ ទៀត ក៏គួរតែសម្តែងដែរ ។

ម្យ៉ាងទៀត ក្នុងវេលាដែលព្រះពោធិសត្វទាំងឡាយ ទ្រង់ចាប់បដិសន្ធិ, ក្នុងវេលាទ្រង់ចេញចាកគភ៌ព្រះមាតា, ក្នុងវេលាដែលត្រាស់ដឹងអភិសម្ពោធិញ្ញាណ, ក្នុងវេលាដែលព្រះតថាគតទ្រង់ប្រកាសព្រះធម្មចក្រ, ក្នុងវេលាដែលទ្រង់ដាក់អាយុ

---

[៤៤] ខុ. ធ. ។

សង្ខារ, ក្នុងវេលាដែលស្តេចរំលត់ខន្ធបរិនិព្វាន ហ៊ឹនចក្រវាឡញាប់ញ័រ នេះឈ្មោះថា **ធម្មនិយាម** ។

ម្យ៉ាងទៀត កាលបើអារម្មណ៍ប៉ះខ្ទប់ប្រសាទ នរណា១ជាអ្នកធ្វើ ឬបង្គាប់ឱ្យធ្វើថា "ឯងចូរឈ្មោះថា អាវជ្ជនៈ ។ ល ។ ឯងចូរឈ្មោះថា អាវជ្ជនៈ" ដូច្នេះ មិនបានមានទេ ក៏ពោលដោយធម្មតារបស់ខ្លួនតាំងអំពីពេលដែលអារម្មណ៍ប៉ះខ្ទប់ប្រសាទហើយ ចិត្តដែលជាកិរិយាមនោធាតុ ក៏ញុំាងភវង្គឱ្យផ្លាស់ទៅ, ចក្ខុវិញ្ញាណក៏ធ្វើទស្សនកិច្ច (នាទីឃើញ), វិបាកមនោធាតុ ក៏ធ្វើសម្បដិច្ឆន្នកិច្ច (នាទីទទួលអារម្មណ៍), វិបាកមនោវិញ្ញាណធាតុ ក៏ធ្វើសន្តីរណកិច្ច (នាទីពិចារណាអារម្មណ៍), កិរិយាមនោវិញ្ញាណធាតុ ក៏ធ្វើវោដ្ឋព្វនកិច្ច (នាទីវិនិច្ឆ័យអារម្មណ៍), ជវនសោយរសនៃអារម្មណ៍ដូច្នេះ នេះឈ្មោះថា **ចិត្តនិយាម**, ក្នុងអធិការនេះ ទ្រង់បំណងយកចិត្តនិយាមនេះ ។

កុសលចិត្តប្រកបដោយតិហេតុកៈ ជាអសង្ខារិកក្តី, កុសលចិត្តដែលប្រកបដោយអសង្ខារិក និងសសង្ខារិក សហគតៈដោយឧបេក្ខាក្តី, ប្រកប (ធ្វើ) កម្មហើយបដិសន្ធិ ដែលវិបាកចិត្តដូចគ្នានឹងចិត្តដែលធ្វើកម្មនោះ ឱ្យផលហើយ ក៏មានន័យដូចគ្នានេះដែរ ។ ក៏ចិត្តដែលប្រកបដោយឧបេក្ខា ២ ដួង បណ្ឌិតគប្បីសម្តែងសេចក្តីប្រព្រឹត្តទៅគ្រាដំបូង ដោយអំណាចនៃឥដ្ឋមជ្ឈត្តារម្មណ៍ខាងក្រោយ ទើបគួរសម្តែង

ដោយអំណាចនៃឥដ្ឋារម្មណ៍ ។ ក្នុងទ្វារនីមួយៗ មានវិបាកចិត្ត ១២ ដួង រួមជាចិត្ត ៦០ ដួងគត់ ដោយប្រការដូច្នេះឯង ។ កាលបើពោលដោយការកាន់យកវិបាកចិត្ត ដែលនៅមិនទាន់បានកាន់យក ក៏បានវិបាកចិត្ត ១៦ ដួង ៕

## ឧបមាវិបាកចិត្តប្រៀបដូចមនុស្សគោះអំពៅ

ក្នុងឋានៈនេះ លោកកាន់យករឿងឈ្មោះ **បញ្ចុឧច្ឆុនាឡិយន្តោបនៈ**; ប្រៀបដោយន័យថា ក្នុងវេលាដែលគាបអំពៅ មានមនុស្សគាប ១១ នាក់ កាន់គ្រឿងគាបអំពៅចេញអំពីស្រុកមួយ ជួបកន្លែង (មជ្ឈមណ្ឌល) អំពៅ មួយកន្លែង ដឹងថា អំពៅនោះចាស់ហើយ ទើបចូលទៅរកម្ចាស់អំពៅ ហើយនិយាយថា "ពួកយើងស៊ីឈ្នួលគាបអំពៅ" ដូច្នេះ ម្ចាស់អំពៅឆ្លើយថា "យើងកំពុងរកពួកលោកដែរ" ហើយនាំជនទាំងនោះ ទៅកាន់រោងគាបអំពៅ ពួកមនុស្សស៊ីឈ្នួលទាំងនោះ ត្រៀមគ្រឿងគាបអំពៅ ហើយនិយាយថា "ពួកយើងមានគ្នា ១១ នាក់ បានម្នាក់ទៀត ក៏នឹងបានទទួលតំលៃឈ្នួលល្មម" ដូច្នេះ ម្ចាស់អំពៅនិយាយថា "យើងនេះឯង នឹងជាសំឡាញ់ជួយលោក" ហើយជញ្ជូនអំពៅទៅពេញរោង ទើបបានជាសំឡាញ់ជួយឈើឆ្កាលជនទាំងនោះ, ជនទាំងនោះធ្វើកិច្ចរបស់ខ្លួនៗ ហើយ

រម្ងាស់ទឹកអំពៅឱ្យរីងធ្វើជាស្ករផែន កាលបើម្ចាស់ពិចារណាឱ្យចំណែកបែងចែកហើយ ក៏កាន់យកចំណែករបស់ខ្លួនៗ ប្រគល់រោងអំពៅ ឱ្យដល់ម្ចាស់ ដោយឧបាយនេះឯង ធ្វើការងារក្នុងរោងអំពៅ ៤ កន្លែងដទៃទៀត ហើយគេចចេញទៅ ។

ក្នុងសេចក្តីនោះ ប្រសាទទាំង ៥ គប្បីជ្រាបដូចរោងគ្រឿងយន្ត ៥ កន្លែង, អារម្មណ៍ ៥ គប្បីជ្រាបដូចកន្លែងអំពៅ ៥ កន្លែង, វិបាកចិត្ត ១១ ដួង គប្បីជ្រាបដូចមនុស្សស៊ីឈ្នួលគាបអំពៅ ១១ នាក់ ហើយត្រេចទៅ, វិញ្ញាណ ៥ គប្បីជ្រាបដូចម្ចាស់រោងគាបអំពៅ ៥ នាក់, វេលាដែលវិបាកចិត្ត ១១ ដួង រួមនឹងចក្ខុវិញ្ញាណ ធ្វើកិច្ចរបស់ខ្លួនៗ ក្នុងរូបារម្មណ៍តាមចក្ខុទ្វារ គប្បីជ្រាបដូចវេលាដែលមនុស្សស៊ីឈ្នួលគាបអំពៅ ១១ នាក់ រួមនឹងម្ចាស់រោងគាបអំពៅក្នុងរោងដំបូង ហើយកាន់យកចំណែកការងារដែលត្រូវធ្វើ វេលាដែលចក្ខុវិញ្ញាណមិនកន្លងទ្វារទៅ គប្បីជ្រាបដូចវេលាដែលម្ចាស់រោងអំពៅ ទទួលអំពៅទុកក្នុងរោង, វេលាដែលវិបាកចិត្ត ១១ ដួងរួមនឹងកាយវិញ្ញាណ ធ្វើកិច្ចរបស់ខ្លួនៗ ក្នុងផោដ្ឋព្វារម្មណ៍តាមកាយទ្វារ កាលមិនឆ្កឹះកកាយទ្វាររបស់កាយវិញ្ញាណ គប្បីជ្រាបដូចវេលាដែលម្ចាស់រោងអំពៅទទួលអំពៅទុកក្នុងរោង ។ វារៈដែលលោកពោលទុកថា តិហេតុកបដិសន្ធិ (បដិសន្ធិប្រកបដោយហេតុ ៣) រមែងមានដោយកម្មដែលប្រកបដោយហេតុ ៣ មានត្រឹមតែប៉ុណ្ណោះ ។ ចំណែកទុហេតុកបដិសន្ធិ មានដោយកម្មដែលជាតិហេតុកៈ

នោះ នៅអាថ៌កំបាំងណាស់ ៕

## សម្តែងអំពីទុហេតុកបដិសន្ធិមានកម្មជាទុហេតុកៈ

ឥឡូវនេះ គួរពោលវារៈដែលជាទុហេតុកបដិសន្ធិ រមែងមាន **ដោយកម្មដែលជាទុហេតុកៈ**, មែនពិត កាលបើអសង្ខារិកចិត្ត ប្រកបដោយសោមនស្សធ្វើកម្មហើយ សត្វអ្នកចាប់បដិសន្ធិ ដោយវិបាកចិត្តដែលជាទុហេតុកៈ ដូចគ្នានឹងចិត្តដែលជាអសង្ខារិក ប្រកបដោយសោមនស្សធ្វើកម្មនោះឯង មាន ៣ មោឃវារៈ ក្នុងឥដ្ឋារម្មណ៍ដែលមកកាន់គន្លងក្នុងចក្ខុទ្វារ ដោយន័យដែលពោលហើយនុ៎ះឯង, ក្នុងទីបំផុតនៃអសង្ខារិកជវនចិត្ត ដែលសហគតៈដោយសោមនស្ស **តទា-រម្មណ៍ ពោលគឺមូលភវង្គ** ដូចគ្នានឹងចិត្តដែលធ្វើកម្មនោះឯង ក៏កើតឡើង ។ ក្នុងទីបំផុតនៃសសង្ខារិកជវនចិត្ត តទារម្មណ៍ ពោលគឺអាគន្តុកភវង្គដូចគ្នានឹងចិត្តដែលធ្វើកម្មនោះឯង ក៏កើតឡើង ។ ក្នុងទីបំផុតនៃជវនចិត្តដែលសហគតៈដោយឧបេក្ខា ២ ដួង ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ប៉ុណ្ណោះ តទារម្មណ៍ ២ ដួង ដូចនឹងចិត្តដែលធ្វើកម្មនោះឯង ហើយកើតឡើង ។ ក្នុងអធិការនេះប៉ុណ្ណោះ ទ្វារតែគ្រប់ទ្វារចែកចិត្ត ក្នុងទ្វារនីមួយៗ ៨ ដួង ទើបរួមជាចិត្ត ៤០ ដួងគត់, តែកាលបើកាន់យកចិត្តដែលនៅមិនទាន់បានកាន់យក ក៏បានចិត្តក្នុងចក្ខុទ្វារ ៨ ដួង, ៤ ដួងទៀត គឺសោតវិញ្ញាណ,

ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ទើបរួមជាចិត្ត ១២ ដួង, **កាលបើចេតនាតែមួយដួងប្រកបកម្មហើយ** រមែងឱ្យវិបាកចិត្ត ១២ ដួងកើតឡើងបានដោយប្រការដូច្នេះ; កថាពោលដោយការប្រៀបធៀបដូចផ្លែស្វាយ និងនិយាម ៥ ប្រព្រឹត្តទៅតាមប្រក្រតីនោះឯង ។ សូម្បីក្នុងបដិសន្ធិដែលសត្វកាន់យកដោយវិបាកដូចគ្នានឹងទុហេតុកៈ ចិត្តដ៏សេស ក៏មានន័យដូចគ្នានេះដែរ, ម្យ៉ាងទៀត ក្នុងទុ-ហេតុកបដិសន្ធិនេះ ពោលដោយការប្រៀបធៀបនឹងមនុស្សគាបអំពៅ ក៏បានមនុស្សគាបអំពៅ ៧ នាក់, ក្នុងការឧបមានោះ គប្បីជ្រាបការប្រកបដោយទំនងនៃន័យដែលពោលដល់មនុស្សស៊ីឈ្នួលគាបអំពៅ ៧ នាក់នោះ និងត្រៀមគ្រឿងគាប អំពៅហើយធ្វើម្ចាស់អំពៅឱ្យជាមនុស្សទី ៨ នោះឯង; ខ្ញុំពោលវារៈដែលថា "ទុហេតុកបដិសន្ធិ រមែងមានដោយកម្ម ដែលជាទុហេតុកៈ" ដូច្នេះ ទុកដោយពាក្យត្រឹមតែប៉ុណ្ណេះចុះ ៕

## សម្តែងអំពីអហេតុកបដិសន្ធិ

ឥឡូវនេះ **ជាកថាសម្តែងអំពីអហេតុកបដិសន្ធិ**, អធិប្បាយថា កាលបើកម្មដែលកុសលចិត្តជាទុហេតុកៈ ៤ ដួង ធ្វើហើយ បដិសន្ធិរបស់សត្វ អ្នកកាន់យកដោយចិត្ត ដែលជាអហេតុកមនោវិញ្ញាណធាតុ សហគតៈដោយឧបេក្ខជា

កុសលវិបាក មិនគួរពោលថាដូចគ្នានឹងកម្មដែលឱ្យបដិសន្ធិ, ព្រោះកម្មជាទុហេតុកៈ (ប្រកបដោយហេតុ ២) បដិសន្ធិជាអហេតុកៈ (ចិត្តដែលមិនប្រកបដោយហេតុ)។ កាលបើបុគ្គលអ្នកបដិសន្ធិដោយអហេតុកចិត្តនោះ ដល់សេចក្តីចម្រើនឡើងហើយ កាលបើឥដ្ឋមជ្ឈត្តារម្មណ៍ មកកាន់គន្លងប្រសាទក្នុងចក្ខុទ្វារហើយ ក៏គប្បីជ្រាប មោឃវារៈ ៣ វារៈ ដោយន័យមុននោះឯង, តែបើកុសលចិត្តដែលជាទុហេតុកៈ ដួងណានីមួយ ជាជវនចុងក្រោយ អហេតុកចិត្ត ក៏តាំងនៅក្នុងសភាពជាតទារម្មណ៍, អហេតុកចិត្តនោះ បានឈ្មោះ ២ យ៉ាង គឺមូលភវង្គ និងតទាលម្ពណៈ, ក្នុងអហេតុក-ចិត្តនេះ ចិត្ត ៤ ដួង គឺចក្ខុវិញ្ញាណ, សម្បដិច្ឆន្នៈ, សន្តីរណៈដែលសហគតៈដោយឧបេក្ខា, សូម្បីតទារម្មណ៍ ក៏សហគតៈដោយឧបេក្ខាដូចគ្នា មានប្រការដូច្នេះ; ក្នុងចិត្តទាំង ៤ នោះ កាន់យកមួយដួង ក៏នៅសល់ ៣ ដួងប៉ុណ្ណោះ ដែលចូលដល់ការរាប់យក ។ តែក្នុងឥដ្ឋារម្មណ៍ សន្តីរណៈក្តី តទារម្មណ៍ក្តី រមែងសហគតៈដោយសោមនស្សបានដូចគ្នា; បណ្តាចិត្តទាំងនោះ វិបាកចិត្ត ៣ ដួងមុន រួមនឹងដួង ១ ក៏ជាវិបាកចិត្ត៤ ដួង, កាលបើចេតនាដួងមួយធ្វើកម្មក្នុងទ្វារ ៥ ទ្វារនីមួយៗ ៤ ដួង គប្បីជ្រាបថា រមែងញ៉ាំងវិបាកចិត្ត ២០ ដួង ឱ្យកើតឡើង, តែកាលបើកាន់យកធម៌ដែលនៅមិនទាន់បានកាន់យក ក៏បានវិបាក ៤ ដួងក្នុងចក្ខុទ្វារ, សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ រួមជាវិបាកចិត្ត ៨ ដួង, នេះឈ្មោះថា

អហេតុកចិត្ត ៨ ដួង ។ អហេតុកចិត្ត ៨ ដួងនេះ ទ្រង់មិនកាន់យកដោយអំណាចនៃមនុស្សលោកទេ ។

ចំណែកក្នុងអបាយ ៤ រមែងបានចិត្ត ៨ ដួងនេះក្នុងបវត្តិកាល ។

មែនពិត កាលណាព្រះមោគ្គល្លាននិមិត្តផ្កាឈូកក្នុងនរក អង្គុយនៅត្រង់ស្រទាប់ផ្កាឈូក សម្ដែងធម្មកថាដល់សត្វនរក, កាលនោះ ចក្ខុវិញ្ញាណដែលជាកុសលវិបាក ក៏កើតឡើងដល់ពួកគេដែលឃើញព្រះថេរៈ, កាលបើស្ដាប់សំឡេងសោតវិញ្ញាណកុសលវិបាកក៏កើត, កាលបើព្រះថេរៈទៅអង្គុយស្នាក់នៅពេលថ្ងៃក្នុងព្រៃដើមចន្ទ (ក្បែរអនោត្តស្រះ) ឃានវិញ្ញាណ ក៏កើតឡើងក្នុងវេលាធំក្លិនចីវរ, ក្នុងវេលាដែលបណ្ដាលភ្លៀងឱ្យធ្លាក់រំលត់ភ្លើងនរក ហើយបានផឹកទឹកដែលគួរផឹក ជិវ្ហាវិញ្ញាណកុសលវិបាកក៏កើត, ក្នុងវេលាដែលបណ្ដាលខ្យល់ឱ្យបក់មកល្មើកៗ កាយវិញ្ញាណវិបាក ក៏កើតឡើង វិញ្ញាណមានចក្ខុវិញ្ញាណជាដើមយ៉ាងនេះ ៥ ដួង, សម្បដិច្ឆន្នៈ ១ ដួង, សន្តីរណៈ ១ ដួង, ព្រោះហេតុដូច្នេះ ទើបបានអហេតុកចិត្ត ៨ ដួង ។ សូម្បីបដិសន្ធិរបស់ពួកនាគគ្រុឌ និងវេមានិកប្រេត រមែងមានដោយអកុសល, តែកុសលរមែងឱ្យផលក្នុងបវត្តិកាល, បដិសន្ធិរបស់ដំរី សេះ មង្គលនៃស្ដេចចក្រពត្តិក៏ដូចគ្នា; នេះជាកថាមគ្គ (ការប្រពន្ធពាក្យ) ដោយអំណាចនៃកុសលជវនៈ ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ទាំងឡាយសិន ។

តែក្នុងឥដ្ឋារម្មណ៍ កាលបើអកុសលចិត្តដែលប្រកបដោយសោមនស្ស ៤ ដួងសេពជវនហើយ អហេតុកចិត្តដែលសហគតៈដោយសោមនស្ស ដែលជាកុសលវិបាក រមែងជាតទារម្មណ៍, ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ ចិត្ត ៤ ដួង ដែលសម្បយុត្តដោយលោភៈ សហគតៈដោយឧបេក្ខា សេពជវនហើយ អហេតុកចិត្តដែលហគតៈដោយឧបេក្ខា កុសលវិបាក ក៏ជាតទារម្មណ៍; ក៏ពាក្យណាដែលលោកពោលទុកថា "តទារម្មណ៍ដែលជវនគប្បីកំណត់" ដូច្នេះ, ពាក្យនោះ គប្បីជ្រាបថា លោកពោលសំដៅដល់កុសល ។

**សួរថា** តទារម្មណ៍កាលកើតឡើងក្នុងលំដាប់នៃជវន សហគតៈដោយទោមនស្ស រមែងកើតចិត្តអ្វី ?

ឆ្លើយថា ចិត្តដែលជាអហេតុកមនោវិញ្ញាណធាតុ ផ្នែកខាងអកុសលវិបាក រមែងកើតឡើង ។

**សួរថា** ជវននេះ សភាវៈអ្វី រមែងកំណត់ទុកដោយសេចក្តីជាកុសល ឬអកុសល ?

ឆ្លើយថា អាវជ្ជនៈ និងវោដ្ឋព្វនៈ រមែងកំណត់ទុក ។

មែនពិត កាលបើអាវជ្ជនៈផ្លាស់មកដោយឧបាយហើយ វោដ្ឋព្វនៈកំណត់ដោយមិនឧបាយ ជវននឹងជាអកុសលដូច្នេះ ខនេះប្រព្រឹត្តទៅមិនបានឡើយ; កាល

បើអាវជ្ជនៈផ្លាស់ទៅដោយមិនឧបាយហើយ វោដ្ឋព្វនៈកំណត់ដោយជវនៈ នឹងជាកុសលដូច្នេះ ខនេះប្រព្រឹត្តទៅមិនបាន ។ តែកាលអាវជ្ជនៈ និងវោដ្ឋព្វនៈទាំងពីរផ្លាស់មកកំណត់ដោយឧបាយ គប្បីជ្រាបថា ជវនជាកុសល, បើមិនឧបាយទេ ក៏ជាអកុសលដែរ ។

**សួរថា** ក្នុងឥដ្ឋារម្មណ៍ កាលបើសេចក្ដីសង្ស័យ និងឧទ្ធច្ចៈកើតឡើង តទារម្មណ៍រមែងជាចិត្តអ្វី ?

ឆ្លើយថា ក្នុងឥដ្ឋារម្មណ៍ នឹងមានសេចក្ដីសង្ស័យក៏ដោយ មិនមានក៏ដោយ ឬឧទ្ធច្ចៈ នឹងមានក៏ដោយ មិនមានក៏ដោយ, សោមនស្សចិត្ត អហេតុកៈខាងកុសលវិបាកទាំងនោះ រមែងជាតទារម្មណ៍; ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ ចិត្តប្រកបដោយឧបេក្ខា អហេតុកៈខាងកុសលវិបាក ជាតទារម្មណ៍; ក៏ក្នុងការកំណត់តទារម្មណ៍នេះ ការសម្ដែងសេចក្ដីសង្ខេបនេះ ឈ្មោះថា ជាវាទៈរបស់ព្រះមហាធម្មរក្ខិតត្ថេរ ក៏កាលជវនដែលសហគតៈ ដោយសោមនស្សសេពអារម្មណ៍ស្ទុះទៅហើយ គប្បីស្វែងរកតទារម្មណចិត្ត ដែលសហគតៈដោយសោមនស្ស ៥ ដួង, កាលបើជវនសហគតៈដោយឧបេក្ខា សេពអារម្មណ៍ស្ទុះទៅហើយ គប្បីស្វែងរកចិត្ត ៦ ដួង ដែលសហគតៈដោយឧបេក្ខាមែនពិត ។

**សួរថា** ក៏ក្នុងកាលណា បុគ្គលអ្នកចាប់បដិសន្ធិ សហគតៈដោយសោ-

មនស្ស ញ៉ាំងឈានឱ្យកើតក្នុងបវត្តិកាល ហើយមានឈានដែលវិនាស ដោយសេចក្ដីប្រមាទ ទើបពិចារណាថា “ធម៌ដែលប្រណីតរបស់យើងវិនាសហើយ”ដូច្នេះ ទោមនស្សរមែងកើតឡើង ដោយអំណាចនៃវិប្បដិសារី, ក្នុងកាលនោះ ចិត្តអ្វីរមែងកើតឡើង ព្រោះក្នុងគម្ពីរបដ្ឋាន លោកបដិសេធថា ទោមនស្សរមែងមិនកើតក្នុងលំដាប់នៃសោមនស្ស ឯសោមនស្ស ក៏មិនកើតក្នុងលំដាប់នៃទោមនស្សដែរ, កាលជវនចិត្តសេពអារម្មណ៍ហើយ ព្រោះប្រារព្ធមហគ្គតធម៌ សូម្បីតទារម្មណ៍ ក៏បដិសេធទុកក្នុងគម្ពីរបដ្ឋាននោះដូចគ្នាដែរ ?

ឆ្លើយថា អហេតុកមនោវិញ្ញាណធាតុ ជាកុសលវិបាក ឬអកុសលវិបាក ដែលសហគតៈដោយឧបេក្ខារមែងកើតឡើង ។

***សួរថា*** ចិត្តអ្វីជាអាវជ្ជនៈរបស់អហេតុកមនោវិញ្ញាណធាតុនោះ ?

ឆ្លើយថា អាវជ្ជនកិច្ចរបស់អហេតុកមនោវិញ្ញាណធាតុនោះមិនមាន ដូចការមិនមាននៃអាវជ្ជនៈរបស់ភវង្គ, អហេតុកមនោវិញ្ញាណធាតុទាំងនេះ រមែងកើតឡើង ព្រោះភាវៈនៃអារម្មណ៍ដែលខ្លួនធ្លាប់សេព និងព្រោះខ្លួនឯង ប្រព្រឹត្តទៅដោយច្រើន ។

***សួរថា*** អហេតុកមនោវិញ្ញាណធាតុនេះ រមែងកើតឡើងយ៉ាងណា ?

ឆ្លើយថា នេវសញ្ញានាសញ្ញាយតនៈ ដែលជាអនន្តរប្បច្ច័យដល់និរោធ

(រំលត់ចិត្ត និងចេតសិក) ១ ចិត្តដែលប្រកបដោយផលសមាបត្តិរបស់បុគ្គលអ្នកចេញចាកនិរោធ ១, អរិយមគ្គចិត្ត ១, ផលចិត្តដែលជាលំដាប់នៃមគ្គ ១, មិនមានអាវជ្ជនៈកើតបានយ៉ាងណា សូម្បីកាលអាវជ្ជនៈ (គឺការពិចារណាអារម្មណ៍) មិនមានហើយ អហេតុកមនោវិញ្ញាណធាតុទាំងឡាយ រមែងកើតឡើង ព្រោះការបង្អោនទៅដោយធ្លាប់សេព និងដោយសេចក្ដីដែលសេពហើយរឿយៗ ដូច្នោះ ។

ពិតមែនហើយ ចិត្តវៀរចាកអាវជ្ជនៈ (គឺការពិចារណាអារម្មណ៍) រមែងកើតឡើងបាន, តែចិត្តនោះ វៀរចាកអារម្មណ៍ រមែងកើតឡើងមិនបានឡើយ ។

**សួរថា** កាលបើដូច្នោះ អ្វីទៅជាអារម្មណ៍របស់ចិត្តនេះ ?

ឆ្លើយថា បានដល់ ធម៌យ៉ាងណានីមួយក្នុងបរិត្តធម៌ទាំងឡាយ មានរូបជាដើម, ពិតមែនហើយ ក្នុងបរិត្តធម៌ មានរូបជាដើមនោះ អារម្មណ៍ណា មកកាន់គន្លងក្នុងសម័យនោះឯង គប្បីជ្រាបថា ចិត្តនេះ កើតឡើង ប្រារព្ធអារម្មណ៍នោះ ។

ឥឡូវនេះ ដើម្បីជាក់ច្បាស់នៃចិត្តសូម្បីទាំងអស់នេះ ទើបលោកពោលន័យបកិណ្ណកៈទុកថា ៖

**"សុត្តំ ទោវារិកោ ច គាមិលកោ អម្ពោ កោលិយកេន ច**
**ជច្ចន្ធោ បីឋសប្បី ច វិសយគ្គាហោ ច ឧបនិស្សយមត្ថោ**
**រឿងសំបុកពីងពាង ១ រឿងនាយទ្វារ ១ រឿងក្មេងអ្នកស្រុក ១**

រឿងស្វាយ ជាមួយនឹងម្ចាស់របស់រោងគាបអំពៅ ១ រឿងមនុស្សខ្វិន ជាមួយនឹងមនុស្សខ្វាក់ ១ រឿងការទទួលអារម្មណ៍ ដោយឧបនិស្ស័យជាប្រយោជន៍ ១"។

ចិត្តប្រៀបដូចសំបុកពីងពាងជាដើម បណ្តាបកិណ្ណកន័យ មានរឿសំបុកពីង-ពាងជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យពាក្យថា **សុត្តំ** (សំបុកពីងពាង) តទៅ ៖

ក៏ពីងពាងមួយសន្ធឹងអំបោះទៅក្នុងទិសទាំង ៥ ធ្វើសំណាញ់ហើយ ដេកនៅត្រង់កណ្តាល, កាលបើអំបោះដែលសន្ធឹងទៅក្នុងទិសដំបូង ត្រូវប៉ះខ្ទប់ដោយសត្វតូចៗ ឬមមាច ឬថារុយ វាក៏នឹងឃ្លាតចេញចាកទី ជាទីដេក ទៅតាមសសៃអំបោះ ចោះក្បាលជញ្ជក់ឈាមរបស់សត្វនោះ ហើយត្រឡប់មកដេកត្រង់កណ្តាលសំបុកនោះឯងវិញ, សូម្បីក្នុងវេលាត្រង់ទិសទី ២ ជាដើម ត្រូវប៉ះខ្ទប់ហើយ ក៏ធ្វើយ៉ាងនោះដែរ ។

ក្នុងសេចក្តីនេះ ប្រសាទទាំង ៥ គប្បីជ្រាបថាដូចសំបុកពីងពាង ដែលសន្ធឹងទៅក្នុងទិសទាំង ៥, ចិត្តដូចពីងពាងដេកត្រង់កណ្តាល, វេលាដែលអារម្មណ៍មកប៉ះខ្ទប់ប្រសាទ ដូចវេលាដែលសត្វតូចៗ ជាដើម មកប៉ះខ្ទប់សំបុកពីងពាង វេលាដែលកិរិយាមនោធាតុ ទទួលអារម្មណ៍ដែលប៉ះខ្ទប់ប្រសាទហើយញ៉ាំងភវង្គឱ្យផ្លាស់ទៅដូចការកម្រើករបស់ពីងពាង ដែលដេកត្រង់កណ្តាល, ការប្រព្រឹត្តទៅរបស់វីថិចិត្ត

ដូចជាវេលាការទៅតាមសរសៃអំបោះរបស់ពីងពាង, វេលាដែលជវនចិត្តសេព អារម្មណ៍ ដូចការចោះក្បាលជញ្ជក់ឈាម, ការដែលចិត្តអាស្រ័យហទយវត្ថុប្រព្រឹត្ត ទៅ ដូចពីងពាងត្រឡប់មកដេកត្រង់កណ្តាលវិញ ។

**សួរថា** សេចក្តីឧបមានេះ រមែងសម្តែងឱ្យដឹងអ្វី ?

ឆ្លើយថា រមែងឱ្យដឹងថា កាលបើអារម្មណ៍ប៉ះខ្ទប់ប្រសាទហើយ ចិត្តដែល អាស្រ័យហទយរូបកើត រមែងកើតឡើងមុនជាងចិត្តដែលអាស្រ័យប្រសាទរូបកើត, គឺរមែងអធិប្បាយឱ្យយល់ថា អារម្មណ៍តែមួយៗ រមែងមកកាន់គន្លងក្នុងទ្វារទាំង ពីរបាន ៕

## ចិត្តប្រៀបដូចនាយទ្វារជាដើម

ព្រះរាជាមួយអង្គផ្ទំលក់នៅលើក្រឡាព្រះបន្ទំ, មហាតួក (អ្នកបំរើ) របស់ ព្រះអង្គ អង្អុយថ្វាយការច្របាច់ព្រះយុគលបាទ, មាននាយទ្វារអ្នកត្រចៀកថ្លង់ ឈរនៅជិតទ្វារ, មានទាហាននៅយាមគាល់ ៣ នាក់ ឈររៀងតាមលំដាប់, គ្រា នោះ មានអ្នកជនបទម្នាក់កាន់គ្រឿងបណ្ណាការមកគោះទ្វារហៅ; នាយទ្វារត្រចៀក ថ្លង់មិនបានឮសម្លេងទេ, មហាតួកអ្នកថ្វាយការច្របាច់ព្រះយុគលបាទ ឱ្យសញ្ញា ទើបគេបើកទ្វារដោយសញ្ញានោះ ហើយសំឡឹងមើល, ទាហានយាមម្នាក់ ទទួល

គ្រឿងបណ្ណាការ ហើយបង្គាប់ឱ្យអ្នកទី ២, អ្នកទី ២ បញ្ជូនឱ្យអ្នកទី ៣, អ្នកទី ៣ ថ្វាយដល់ព្រះរាជា, ទើបព្រះរាជាសោយ ។

ក្នុងខនោះ ជវនចិត្ត គប្បីឃើញដូចព្រះរាជាអង្គនោះ, អាវជ្ជនចិត្ត ដូចមហាតឹ្លកអ្នកច្របាច់ព្រះបាទ, ចក្ខុវិញ្ញាណដូចនាយទ្វារអ្នកត្រចៀកថ្លង់, វីថិចិត្ត ៣ ដួង មានសម្បដិច្ឆន្នចិត្តជាដើម ដូចនាយទាហានយាម ៣ នាក់, ការដែលអារម្មណ៍មកប៉ះខ្ទប់ប្រសាទ ដូចអ្នកជនបទកាន់គ្រឿងបណ្ណាការមកគោះទ្វារហៅ, វេលាដែលកិរិយាមនោធាតុផ្លាស់មកពីភវង្គ ដូចវេលាដែលមហាតឹ្លក អ្នកច្របាច់ព្រះយុគលបាទឱ្យសញ្ញា, វេលាដែលចក្ខុវិញ្ញាណ ធ្វើកិច្ចឃើញអារម្មណ៍ ដូចវេលាដែលនាយទ្វារ អ្នកត្រចៀកថ្លង់បើកទ្វារ ដោយសញ្ញាដែលមហាតឹ្លកឱ្យនោះ, វេលាដែលវិបាកមនោធាតុ ធ្វើសម្បដិច្ឆន្នកិច្ចគឺទទួលអារម្មណ៍ ដូចវេលាដែលទាហានយាមទី១ ទទួលបណ្ណាការ, វេលាដែលវិបាកមនោវិញ្ញាណធាតុ ធ្វើសន្តីរណកិច្ចគឺការពិចារណាអារម្មណ៍ ដូចវេលាដែលទាហានយាមទី ១ បញ្ជូនបណ្ណាការឱ្យទាហានទី ២, វេលាដែលកិរិយាមនោវិញ្ញាណធាតុ ធ្វើវោដ្ឋព្វនកិច្ច គឺការកំណត់អារម្មណ៍ ដូចវេលាដែលទាហានយាមទី ២ ឱ្យបណ្ណាការដល់ទាហានយាមទី ៣, វេលាដែលវោដ្ឋព្វនៈ មានការនាំចេញជាដើមនូវជវនៈ ដូចវេលាដែលទាហានយាមទី ៣ ថ្វាយបណ្ណាការដល់ព្រះរាជា, វេលាដែលជវនធ្វើជវនកិច្ច គឺសោយនូវរសនៃអារម្មណ៍ ដូចវេលាដែល

ព្រះរាជាសោយគ្រឿងបណ្ណាការដូច្នោះដែរ ។

**សួរថា** ឧបមានេះ រមែងសម្ដែងឱ្យដឹងអ្វី ?

ឆ្លើយថា រមែងសម្ដែងឱ្យដឹងដល់ពាក្យនេះថា **កិច្ចរបស់អារម្មណ៍ មានត្រឹមតែការប៉ះខ្ទប់ប្រសាទប៉ុណ្ណោះ,** កិច្ចនៃកិរិយាមនោធាតុមានត្រឹមតែការញ៉ាំងភវង្គឱ្យផ្លាស់ទៅប៉ុណ្ណោះ, កិច្ចទាំងឡាយរបស់វិញ្ញាណ មានចក្ខុវិញ្ញាណជាដើម មានត្រឹមតែការឃើញអារម្មណ៍, ការទទួលអារម្មណ៍, ការពិចារណាអារម្មណ៍ និងការកំណត់អារម្មណ៍ប៉ុណ្ណោះ, ជវនចិត្តប៉ុណ្ណោះ រមែងសោយនូវរសនៃអារម្មណ៍ដោយចំណែកតែមួយគត់ ៕

## ចិត្តប្រៀបដូចក្មេងអ្នកស្រុក

ពាក្យថា **"ក្មេងអ្នកស្រុក"** គឺពួកក្មេងអ្នកស្រុកជាច្រើន រមែងលេងអាចម៍ដីត្រង់ចន្លោះផ្លូវ, បណ្ដាពួកក្មេងទាំងនោះ កហាបណៈប៉ះដៃរបស់ក្មេងម្នាក់, ក្មេងនោះ និយាយថា "នោះអ្វីដែលប៉ះដៃរបស់យើង" ដូច្នេះ, លំដាប់នោះ ទើបក្មេងម្នាក់និយាយថា "នោះពណ៌ស" , ម្នាក់ទៀត ក៏កាន់យកទុកយ៉ាងមាំ ព្រមជាមួយនឹងអាចម៍ដី, អ្នកដទៃទៀត និយាយថា "នោះបួនជ្រុងក្រាស់" , អ្នកផ្សេងទៀត និយាយថា "នោះកហាបណៈ" លំដាប់នោះ ទើបពួកគេនាំយកនូវ

កហាបណៈនោះមកឱ្យមាតា, មាតាក៏នាំទៅប្រើប្រាស់ក្នុងកិច្ចការងារ ។

ក្នុងសេចក្ដីនោះ ការប្រព្រឹត្តទៅរបស់ភវង្គចិត្ត គប្បីយល់ដូចវេលាដែលពួកក្មេងច្រើនគ្នា អង្គុយលេងក្នុងចន្លោះផ្លូវ វេលាដែលប្រសាទពាល់ត្រូវអារម្មណ៍ប៉ះ-ខ្ទប់ហើយ ដូចដែលកហាបណៈប៉ះខ្ទប់ដៃ, វេលាដែលកិរិយាមនោធាតុ ញ៉ាំងភវង្គឱ្យផ្លាស់ទៅ ព្រោះទទួលអារម្មណ៍នោះ ដូចវេលាដែលក្មេងម្នាក់និយាយថា "នោះជាអ្វី ?" វេលាដែលចក្ខុវិញ្ញាណធ្វើទស្សនកិច្ច ដូចវេលាដែលក្មេងម្នាក់និយាយថា "នោះពណ៌ស" វេលាដែលវិបាកមនោធាតុធ្វើនាទីទទួលអារម្មណ៍ ដូចវេលាដែលក្មេងម្នាក់ កាន់យកកហាបណៈព្រមជាមួយនឹងអាចម៍ដីទុកយ៉ាងមាំ, វេលាដែលវិបាកមនោវិញ្ញាណធាតុ ធ្វើកិច្ចពិចារណាអារម្មណ៍ ដូចវេលាដែលក្មេងម្នាក់និយាយថា "នោះបួនជ្រុងក្រាស់" , វេលាដែលកិរិយាមនោវិញ្ញាណធាតុ ធ្វើនាទីកំណត់អារម្មណ៍ ដូចវេលាដែលក្មេងម្នាក់និយាយថា "កហាបណៈ" ដូច្នេះ, កាលដែលជវនចិត្តសោយរសនៃអារម្មណ៍ គប្បីជ្រាបដូចវេលាដែលមាតានាំយកនូវកហាបណៈទៅប្រើប្រាស់ក្នុងកិច្ចការងារដូច្នោះដែរ ។

***សួរថា*** សេចក្ដីឧបមានេះ រមែងសម្ដែងឱ្យដឹងដល់អ្វី ?

ឆ្លើយថា រមែងសម្ដែងឱ្យដឹងថា កិរិយាមនោវិញ្ញាណធាតុមិនទាន់បានឃើញនៅឡើយ ក៏ញ៉ាំងភវង្គឱ្យផ្លាស់ទៅ, វិបាកមនោធាតុ ក៏មិនឃើញ រមែងធ្វើ

នាទីទទួលអារម្មណ៍, វិបាកមនោវិញ្ញាណធាតុ ក៏មិនឃើញ រមែងធ្វើនាទីពិចារណាអារម្មណ៍; កិរិយាមនោវិញ្ញាណធាតុ ក៏មិនឃើញ រមែងធ្វើនាទីកំណត់អារម្មណ៍, ជវនចិត្ត ក៏មិនឃើញ រមែងធ្វើនាទីសោយនូវរសនៃអារម្មណ៍, ចំណែកចក្ខុវិញ្ញាណប៉ុណ្ណោះ រមែងធ្វើកិច្ចក្នុងការឃើញ (ទស្សនកិច្ច) ដោយចំណែកតែមួយដូច្នេះ ។

ពាក្យថា **"ស្វាយ និងម្ចាស់រោងគាបអំពៅ"** នេះ ខ្ញុំពោលទុកក្នុងខាងក្រោយហើយ ពាក្យនេះពោលសំដៅយកឧបមាដោយផ្លែស្វាយ និងឧបមាដោយម្ចាស់រោងគាបអំពៅ ៕

## នាមរូបប្រៀបដូចមនុស្សខ្វាក់ និង មនុស្សខ្វិន

ពាក្យថា **"មនុស្សខ្វាក់ និងមនុស្សខ្វិន"** សេចក្ដីថា បានឮថា ក្នុងសាលាជិតទ្វារនគរ មានមនុស្សខ្វាក់ភ្នែកអំពីកំណើត និងមនុស្សខ្វិនសន្ទនាគ្នា; ក្នុងបណ្ដាមនុស្សទាំងពីរនោះ មនុស្សខ្វិននិយាយថា "អាខ្វាក់ ព្រោះហេតុអ្វី ទើបឯងស្គមស្គាំងនៅក្នុងទីនេះ, ឯងត្រាច់ទៅប្រទេសឯណោះ ដែលមានភិក្ខាហាររកបានងាយមានបាយទឹកច្រើន, ឯងទៅក្នុងទីនោះ ក៏រស់នៅតាមសប្បាយ មិនសមគួរឬ"; មនុស្សភ្នែកខ្វាក់និយាយថា "ឯងប្រាប់យើងមុនហើយ, តែឯងវិញទៅក្នុងទីនោះក៏នៅយ៉ាងសប្បាយ មិនសមគួរឬ" ។

**មនុស្សខ្វិន :** ជើងរបស់យើងដើរមិនបានទេ ។

**មនុស្សខ្វាក់ :** ភ្នែករបស់យើងមើលមិនឃើញទេ ។

**មនុស្សខ្វិន :** បើដូច្នោះ ឯងមានជើង យើងមានភ្នែក ។

មនុស្សទាំងពីរនាក់ ក៏ទទួលពាក្យគ្នាថា "ល្អហើយ" ដូច្នេះ, អ្នកខ្វាក់ឱ្យអ្នកខ្វិនជិះកទៅ; មនុស្សខ្វិននោះ អង្គុយជិះករបស់មនុស្សខ្វាក់យកដៃឆ្វេងឱបក្បាលមនុស្សខ្វាក់ យកដៃស្តាំកំណត់ផ្លូវប្រាប់ថា "ក្នុងទីនេះ មានគល់ឈើធំ, ក្នុងទីនេះ មានថ្ម, លោកចូរលះផ្លូវខាងឆ្វេងដៃ កាន់យកផ្លូវខាងស្តាំដៃ, ចូរលះផ្លូវខាងស្តាំដៃ កាន់យកផ្លូវខាងឆ្វេងដៃ" ដូច្នេះ; ជើងជារបស់មនុស្សខ្វាក់ភ្នែកអំពីកំណើត, ភ្នែកជារបស់មនុស្សខ្វិន, សូម្បីមនុស្សទាំងពីរ ទៅហើយកាន់ទីដែលខ្លួនប្រាថ្នា ដោយសេចក្តីព្យាយាមរួមគ្នា ក៏រស់នៅជាសុខ ដោយប្រការដូច្នេះ ។

ក្នុងសេចក្តីឧបមានេះ ***រូបកាយ*** គប្បីឃើញដូចមនុស្សខ្វាក់អំពីកំណើត, ***អរូប*** (នាមកាយ) ដូចមុនស្សខ្វិន, រូបកាយវៀរនាមកាយចេញ ក៏មិនអាចឱ្យដល់ការកាន់យក ចាប់យក និងការកម្រើកបាន ដូចវេលាដែលមនុស្សខ្វាក់ភ្នែក តែវៀរមនុស្សខ្វិន ក៏មិនកើតសេចក្តីតាំងចិត្ត ដែលនឹងដើរផ្លូវទៅកាន់ទីផ្សារផ្សេងៗ បាន, អរូប (នាមកាយ) វៀររូបចេញ ក៏មិនអាចប្រព្រឹត្តទៅបានក្នុងបញ្ចវោការភព ដូចមនុស្សខ្វិនវៀរមនុស្សខ្វាក់ភ្នែកអំពីកំណើត ក៏មិនកើតការតាំងចិត្តដែលនឹងដើរទៅ

កាន់ទីផ្សេងៗ បាន, រូបធម៌ និងអរូបធម៌ មានសភាពក្នុងកិច្ចទាំងពួងបាន ដោយការប្រកបនូវគ្នានឹងគ្នា ដូចវេលាដែលមនុស្សខ្វាក់ភ្នែក និងមនុស្សខ្វិនសូម្បីទាំងពីរ ទៅកាន់ទីដែលខ្លួនប្រាថ្នា ដោយសេចក្ដីព្យាយាមរួមគ្នា ហើយរស់នៅយ៉ាងសប្បាយ ។ បញ្ហានេះ លោកអាចារ្យពោលបានដោយអំណាចនៃបញ្ចវោការភព ៕

## សម្ដែងអំពីការទទួលអារម្មណ៍ដែលមានឧបនិស្សយប្បច្ច័យ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ការទទួលអារម្មណ៍តទៅ ៖

ចក្ខុរមែងទទួលអារម្មណ៍បានចំពោះតែរូប សោតៈជាដើម ក៏ទទួលអារម្មណ៍បានចំពោះតែសំឡេងជាដើម ។ ពាក្យថា **ដោយមានឧបនិស្សយប្បច្ច័យ ជាប្រយោជន៍** គឺដោយឧបនិស្សយបច្ច័យ (ត្រូវអាស្រ័យយ៉ាងដាច់ខាត ដោយខានមិនបាន) និងដោយសេចក្ដីជាប្រយោជន៍ ៕

## ចក្ខុវិញ្ញាណអាស្រ័យបច្ច័យ ៤ ទើបកើតឡើងបាន

ក្នុងខថា **ដោយមានឧបនិស្សយប្បច្ច័យ និងដោយជាប្រយោជន៍** នោះ ចក្ខុវិញ្ញាណរមែងកើតឡើង ព្រមជាមួយនឹងសម្បយុត្តធម៌ទាំងឡាយបាន ព្រោះអាស្រ័យបច្ច័យ ៤ គឺ

**១-អសម្ភិន្នត្តា ចក្ខុស្ស** ព្រោះចក្ខុប្រសាទនៅមិនទាន់រលត់

**២-អាបាថគតត្តា រូបានំ** ព្រោះរូបមកកាន់គន្លង

**៣-អាលោកសន្និស្សិតំ** អាស្រ័យពន្លឺ

**៤-មនសិការហេតុកំ** អាស្រ័យមនសិការជាហេតុ ។

បណ្ដាបច្ច័យទាំង ៤ នេះ សូម្បីចក្ខុរបស់មនុស្សស្លាប់ រមែងជារបស់រលត់ទៅអស់, ចក្ខុរបស់មនុស្សមានជីវិតរលត់ទៅក្ដី ឬត្រូវទឹកប្រមាត់ ឬក៏ស្លេស្ម៍ ឬថាលោហិតរារាំងហើយក្ដី មិនអាចជាបច្ច័យដល់ចក្ខុវិញ្ញាណបាន ឈ្មោះថា រលត់ទៅហើយ, កាលបើអាចជាបច្ច័យបាន ឈ្មោះថា មិនរលត់ ។

សូម្បីក្នុងសោតវិញ្ញាណជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ក៏កាលបើចក្ខុប្រសាទ សូម្បីមិនទាន់រលត់ តែរូបារម្មណ៍ខាងក្រៅ នៅមិនទាន់មកកាន់គន្លងចក្ខុប្រសាទ ចក្ខុវិញ្ញាណ ក៏កើតមិនបាន កាលបើរូបនោះ មកកាន់គន្លងហើយ តែបច្ច័យទីអាស្រ័យ គឺពន្លឺមិនមាន ចក្ខុវិញ្ញាណក៏កើតមិនបាន, កាលបើពន្លឺដែលជាបច្ច័យនោះមាន តែកិរិយាមនោធាតុ មិនញុំាងភវង្គឱ្យផ្លាស់ទៅ ចក្ខុ-វិញ្ញាណក៏កើតមិនបាន, កាលបើកិរិយាមនោធាតុធ្វើភវង្គឱ្យផ្លាស់ទៅបាន ទើបចក្ខុ-វិញ្ញាណកើតឡើង (កើតការឃើញបាន)។ ចក្ខុវិញ្ញាណកាលបើកើតឡើង ដោយអាការយ៉ាងនេះ រមែងកើតឡើងព្រមជាមួយនឹងសម្បយុត្តធម៌ទាំងឡាយមែនពិត ព្រោះហេតុដូច្នេះ ទើបពោលថាចក្ខុវិញ្ញាណរមែងកើតឡើង ព្រោះបានបច្ច័យ ៤ នេះមែនពិត ។

សោតវិញ្ញាណ តែងកើតឡើងជាមួយនឹងសម្បយុត្តធម៌ទាំងឡាយ ព្រោះ

បច្ច័យទាំង ៤ នេះ គឺ

**១-អសម្ភិន្នត្តា សោតស្ស** ព្រោះសោតប្រសាទនៅមិនទាន់រលត់

**២-អាបាថគតត្តា សទ្ទានំ** ព្រោះសំឡេងទាំងឡាយមកកាន់គន្លង

**៣-អាកាសសន្និស្សិតំ** អាស្រ័យអាកាស

**៤-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នេះ ពាក្យថា **"អាស្រ័យអាកាស"** គឺសោតវិញ្ញាណនោះ បានអាស្រ័យហើយ ទើបអាកាសកើតឡើង, វៀរអាកាសចេញក៏មិនកើតឡើងបាន ព្រោះកាលបើបុគ្គលបិទប្រហោងត្រចៀកហើយ សោតវិញ្ញាណក៏មិនប្រព្រឹត្តទៅបាន ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុននោះចុះ, គឺសូម្បីឃានវិញ្ញាណជាដើមក្រៅអំពីនះ ក៏គប្បីជ្រាបសេចក្តីដូចសោតវិញ្ញាណនេះដែរ, ខ្ញុំនឹងពោលតែសេចក្តីដែលផ្សេងគ្នាប៉ុណ្ណោះ ។

ឃានវិញ្ញាណ រមែងកើតឡើងព្រមជាមួយនឹងសម្បយុត្តធម៌ទាំងឡាយ ព្រោះបច្ច័យទាំង ៤ នេះ គឺ

**១-អសម្ភិន្នត្តា ឃានស្ស** ព្រោះឃានប្រសាទនៅមិនទាន់រលត់

**២-អាបាថគតត្តា គន្ធានំ** ព្រោះក្លិនទាំងឡាយមកកាន់គន្លង

**៣-វាយោសន្និស្សិតំ** អាស្រ័យវាយោ (ខ្យល់)

**៤-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នេះ ពាក្យថា **"អាស្រ័យវាយោ"** អធិប្បាយថា

កាលបើវាយោនាំក្លិនទាំងឡាយ ចូលទៅកាន់ប្រហោងច្រមុះនោះឯង ឃានវិញ្ញាណទើបកើតឡើង; កាលបើខ្យល់មិនមាន ឃានវិញ្ញាណ ក៏មិនកើត ។

ជិវ្ហាវិញ្ញាណ រមែងកើតឡើងព្រមជាមួយនឹងសម្បយុត្តធម៌ទាំងឡាយ ព្រោះបច្ច័យទាំង ៤ នេះ គឺ

**១-អសម្ភិន្នត្តា ជិវ្ហាយ** ព្រោះជិវ្ហាប្រសាទនៅមិនទាន់រលត់

**២-អាបាថគតត្តា រសានំ** ព្រោះរសទាំងឡាយមកកាន់គន្លង

**៣-អាបោសន្និស្សិតំ** អាស្រ័យអាបោ (ទឹក)

**៤-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្ដាបច្ច័យទាំង ៤ នេះ ពាក្យថា **"អាស្រ័យអាបោ"** សេចក្ដីថា បានអាបោធ្វើឱ្យសើមហើយ ឃានវិញ្ញាណទើបកើត, វៀរអាបោចេញ ក៏មិនកើត; ព្រោះកាលបើបុគ្គលអណ្ដាតស្ងួត សូម្បីដាក់ខាទនីយៈដែលស្ងួតទុកលើអណ្ដាត ជិវ្ហាវិញ្ញាណ ក៏មិនកើតឡើង ។

កាយវិញ្ញាណ រមែងកើតឡើងព្រមជាមួយនឹងសម្បយុត្តធម៌ទាំងឡាយ ព្រោះបច្ច័យទាំង ៤ នេះ គឺ

**១-អសម្ភិន្នត្តា កាយស្ស** ព្រោះកាយប្រសាទនៅមិនទាន់រលត់

**២-អាបាថគតត្តា ផោដ្ឋព្វានំ** ព្រោះផោដ្ឋព្វៈមកកាន់គន្លង

**៣-បឋវីសន្និស្សិតំ** អាស្រ័យបឋវី (ដី)

**៤-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្ដាបច្ច័យទាំង ៤ នេះ ពាក្យថា **"អាស្រ័យបឋវី"** បានដល់ អាស្រ័យ

បវីដែលគួបផ្សំគ្នា គឺកាយប្រសាទជាបច្ច័យនោះឯង កាយវិញ្ញាណទើបកើតឡើង, វៀរកាយប្រសាទហើយ កាយវិញ្ញាណក៏មិនកើត, ព្រោះមហាភូតរូប ជាអារម្មណ៍ខាងក្រៅ ប៉ះខ្ទប់កាយបសាទខាងក្នុងកាយទ្វារ រមែងប៉ះខ្ទប់ត្រង់មហាភូតរូបទាំង-ឡាយ ដែលមានប្រសាទជាបច្ច័យ ។

មនោវិញ្ញាណ រមែងកើតឡើងព្រមជាមួយនឹងសម្បយុត្តធម៌ទាំងឡាយ ព្រោះបច្ច័យទាំង ៤ នេះ គឺ

**១-អសម្ភិន្នត្តា មនស្ស** ព្រោះមនោនៅមិនទាន់រលត់

**២-អាបាថគតត្តា ធម្មានំ** ព្រោះធម៌ទាំងឡាយមកកាន់គន្លង

**៣-វត្ថុសន្និស្សិតំ** អាស្រ័យវត្ថុ

**៤-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នេះ ពាក្យថា **មនោ** បានដល់ ភវង្គចិត្ត, អធិប្បាយថា ភវង្គចិត្តនោះរលត់ហើយក្តី, មានកម្លាំងខ្សោយមិនអាចជាបច្ច័យដល់អាវជ្ជនចិត្តឱ្យប្រព្រឹត្តទៅក្តី ឈ្មោះថា រលត់, តែដែលអាចជាបច្ច័យដល់អាវជ្ជនៈបាន ឈ្មោះថា នៅមិនទាន់រលត់ ។ ពាក្យថា **ព្រោះធម៌ទាំងឡាយមកកាន់គន្លង** បានដល់ កាលបើអារម្មណ៍មកកាន់គន្លង ។ ពាក្យថា **អាស្រ័យវត្ថុ** គឺបានហទយវត្ថុជាទីអាស្រ័យប៉ុណ្ណោះ ទើបកើតឡើង, វៀរហទយវត្ថុ ក៏មិនកើតឡើង ។ សូម្បីបញ្ហានេះ គឺព្រះថេរៈពោលហើយ សំដៅដល់បញ្ចវោការភព ។ ពាក្យថា **មានមនសិ-ការជាហេតុ** អធិប្បាយថា កិរិយាមនោវិញ្ញាណធាតុញ៉ាំងភវង្គឱ្យផ្លាស់ទៅសិន ទើបមនោវិញ្ញាណកើតឡើង ។ ពណ៌នាឧបនិស្សយប្បច្ច័យ ក្នុងខថា “**ការទទួល**

អារម្មណ៍ ដោយឧបនិស្សយប្បច្ច័យជាប្រយោជន៍” ដូច្នេះនេះ ចប់ត្រឹមតែប៉ុណ្ណេះ ។

ចក្ខុដោយអត្ថ ឈ្មោះថា **ទស្សនត្ថៈ** (មានការឃើញជាអត្ថ)

សោតៈដោយអត្ថ ឈ្មោះថា **សវនត្ថៈ** (មានការស្តាប់ជាអត្ថ)

ឃានៈដោយអត្ថ ឈ្មោះថា **ឃាយនត្ថៈ** (មានការហិតក្លិនជាអត្ថ)

ជិវ្ហាដោយអត្ថ ឈ្មោះថា **សាយនត្ថៈ** (មានការលិទ្ធរសជាអត្ថ)

កាយដោយអត្ថ ឈ្មោះថា **ផុស្សនត្ថៈ** (មានការពាល់ត្រូវជាអត្ថ)

មនោដោយអត្ថ ឈ្មោះថា **វិជាននត្ថៈ** (មានការដឹងជាអត្ថ) ។

គប្បីជ្រាបវិនិច្ឆ័យពាក្យថា **មានការឃើញជាអត្ថ** ជាដើមដូចតទៅ ៖

ការឃើញជាអត្ថរបស់ចក្ខុវិញ្ញាណនោះ, ព្រោះហេតុនោះ ចក្ខុវិញ្ញាណនោះទើបឈ្មោះថា ទស្សនត្ថៈមែនពិត ការឃើញនោះដែលចក្ខុ គប្បីឱ្យសម្រេច ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ទស្សនត្ថៈ (មានការឃើញជាអត្ថ), សូម្បីក្នុងសោត-វិញ្ញាណជាដើម ក៏នំយនេះឯង ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះជាការចប់វិបាកចិត្ត ១៦ ដួង ក្នុង**វាទៈរបស់ព្រះចូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក** ព្រមជាមួយនឹងវិបាកចិត្ត ១២ ដួង និងអហេតុកចិត្ត ៨ ដួង ត្រឹមតែប៉ុណ្ណេះ ៕

## វិបាកចិត្ត ១២ ដួង ក្នុងវាទៈនៃព្រះមហាទត្តត្ថេរ

ឥឡូវនេះ ជាកថាមគ្គនៃវិបាកចិត្ត ១២ ដួង ក្នុងវាទៈរបស់ **ព្រះមហាទត្ត-ត្ថេរ** អ្នកនៅក្នុងមោរវាបី ។ ក្នុងវាទៈនោះ បញ្ហាក្នុងក្រុងសាកេត ការកាន់យកចំណែកខាងច្រើន និងការសម្ដែងហេតុប្រព្រឹត្តទៅតាមប្រក្រតីមែនពិត, តែព្រះថេរៈនេះ ឃើញទោសក្នុងចិត្តដែលជាអសង្ខារិក និងសសង្ខារិក ទើបពោលថា “កម្មដែលជាអសង្ខារិក រមែងឱ្យវិបាកជាអសង្ខារិកប៉ុណ្ណោះ, មិនឱ្យវិបាកដែលជាសសង្ខារិកទេ, សូម្បីកម្មដែលជាសសង្ខារិក ក៏រមែងឱ្យវិបាកជាសសង្ខារិកប៉ុណ្ណោះ, មិនឱ្យវិបាកជាអសង្ខារិកឡើយ” , ឯព្រះថេរៈនេះ មិនពោលចិត្តនិយាមដោយជវនទេ, តែរមែងពោលនិយាមនៃវេទនាដោយអារម្មណ៍, ព្រោះហេតុនោះ ក្នុងវាទៈរបស់លោកនោះឯង សូម្បីវិបាកចិត្ត ១២ ដួងក្ដី, អហេតុកចិត្ត ៨ ដួងក្ដី ក៏ឈ្មោះថាគន្លងនៃវិបាកចិត្ត ១២ ដួងដែរ ។

ក្នុងលំដាប់នៃវិបាកចិត្តនោះ មានន័យដូចតទៅនេះ ៖

ក៏កាលបើអសង្ខារិកចិត្ត ជាតិហេតុកៈ សហគតៈដោយសោមនស្ស ធ្វើកម្មហើយ បុគ្គលដែលចាប់បដិសន្ធិដោយវិបាកចិត្តដូច្នោះនុ៎ះឯង ដល់ការចម្រើនវ័យហើយ កាលបើឥដ្ឋារម្មណ៍ មកកាន់គន្លងនៃចក្ខុទ្វារហើយ មោឃវារៈ ៣ រមែងមានដោយន័យដែលពោលទុកក្នុងខាងក្រោយដូចគ្នា, ក្នុងកថា ពោលអំពីចិត្តទាំងនោះ

ចិត្តទាំង ១៣ ដួងនេះ គឺកុសលវិបាក ៤ ដួង, អកុសលវិបាកដែលសហគតៈដោយសោមនស្ស ៤ ដួង និងកិរិយាចិត្ត ៥ ដួង ដួងណានីមួយ កាលបើជវនចិត្តសេពអារម្មណ៍ចុងក្រោយហើយ ក៏តាំងនៅជាតទារម្មណ៍ តិហេតុកចិត្តជាអសង្ខារិក ដែលសហគតៈដោយសោមនស្សក្តី អហេតុកចិត្តដែលជាទុហេតុកៈជាអសង្ខារិកក្តី ក៏រមែងតាំងនៅជាតទារម្មណ៍នោះឯង ដោយអាការយ៉ាងនេះ, ក្នុងចក្ខុទ្វាររបស់បុគ្គលនោះ ទើបជាវិបាកចិត្ត ៤ ដួង ចូលដល់ការរាប់ជា ៥ ដួង គឺវិបាកចិត្ត ៣ ដួង មានចក្ខុវិញ្ញាណជាដើម និងតទារម្មណចិត្ត ២ ដួង ។

ម្យ៉ាងទៀត នៅពេលផ្លាស់វេទនាទៅដោយអារម្មណ៍ហើយ ឧបេក្ខាសហគតៈដោយចិត្ត ១២ ដួង គឺកុសលវិបាក ៤ ដួង, អកុសលវិបាក ៤ ដួង, កិរិយាចិត្ត ៤ ដួង ដួងណានីមួយ កាលបើជវនសេពអារម្មណ៍ស្រេចហើយ ចិត្តដែលជាតិហេតុកៈអសង្ខារិក សហគតៈដោយឧបេក្ខាក្តី វិបាកចិត្ត អសង្ខារិក ជាទុហេតុកៈក្តី ក៏កើតឡើងជាតទារម្មណ៍, ដោយប្រការដូច្នេះ ក្នុងចក្ខុទ្វាររបស់បុគ្គលនោះ ក៏ចូលដល់ការរាប់បាន ៣ ដួង ទាំងនេះ គឺសន្តីរណចិត្ត សហគតៈដោយឧបេក្ខា និងតទារម្មណចិត្តទាំង ២ ដួងនេះ, ចិត្តទាំង ៣ ដួងនោះ និងចិត្ត ៥ ដួងមុន រួមជា ៨ ដួង, សូម្បីក្នុងសោតទ្វារជាដើម ក៏បានទ្វារនីមួយៗ ៨ ដួង កាលបើកម្មដែលចេតនាដួងមួយ

ធ្វើហើយ ចិត្ត ៤០ ដួងគត់ រមែងកើតឡើង ។ តែកាលបើកាន់យកចិត្តដែលនៅមិនទាន់បានកាន់យក ក៏បានចិត្ត ១២ ដួង គឺក្នុងចក្ខុទ្វារ ៨ ដួង និងក្នុងសោតវិញ្ញាណ ជាដើម ៤ ដួងទៀត។ ក្នុងសេចក្ដីនេះ គប្បីជ្រាបមូលភវង្គដែលប្រព្រឹត្តទៅ និងកថាដែលប្រៀបដោយផ្លែស្វាយ ព្រមទាំងនិយាមដោយន័យដែលពោលហើយនុ៎ះឯង, កាលបើកម្មដែលកុសលចិត្ត ជាសសង្ខារិក តិហេតុកៈសហគតៈដោយសោមនស្សធ្វើហើយក្ដី កាលបើកម្មដែលអសង្ខារិក និងសសង្ខារិក ជាតិហេតុកៈ សហគតៈដោយឧបេក្ខា ធ្វើហើយក្ដី ក៏មានន័យដូចគ្នានេះដែរ។ ក្នុងសេចក្ដីនេះ សូម្បីការឧបមាដោយគ្រឿងគាបអំពៅ ក៏ជាប្រក្រតីក្នុងទុតិយវាទៈនេះដែរ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ មានវារៈដែលលោកពោលទុកថា **“តិហេតុកបដិសន្ធិ រមែងមានដោយកម្មជាតិហេតុកៈ”**, តែក៏នៅមានវារៈដែលអាចឹកំបាំងថា “ទុហេតុកបដិសន្ធិ រមែងមានដោយកម្មជាតិហេតុកៈ” អធិប្បាយថា ៖

ឥឡូវនេះ ទុហេតុកបដិសន្ធិកថា រមែងមានដោយកម្មជាទុហេតុកៈ; ពិតណាស់ កាលបើកម្មដែលបុគ្គលធ្វើហើយ ដោយអសង្ខារិកចិត្ត ជាទុហេតុកៈ សហគតៈដោយសោមនស្ស កាលបើឥដ្ឋារម្មណ៍មកកាន់គន្លងក្នុងចក្ខុទ្វារដល់បុគ្គលអ្នកចាប់បដិសន្ធិ ដោយវិបាកចិត្តដូច្នោះឯង ដែលដល់នូវការចម្រើនវ័យហើយ មោឃវារៈ ៣ រមែងមានដោយន័យដែលពោលទុក ក្នុងខាងក្រោយដូចគ្នា, **តែជវន-**

**កិរិយា** រមែងមិនមានដល់បុគ្គលអ្នកបដិសន្ធិ ជាទុហេតុកៈទេ; ព្រោះហេតុដូច្នោះ ក្នុងទីបំផុតនៃការសោយដោយចិត្តទាំងឡាយ ៨ នេះ គឺដោយកុសលចិត្តដែលសហគតៈដោយសោមនស្ស ៤ ដួង, ដោយអកុសល ៤ ដួងណានីមួយ ចិត្តដែលជាទុហេតុកៈ អសង្ខារិក សហគតៈដោយសោមនស្សតែប៉ុណ្ណោះ កើតបានជាតទារម្មណ៍; ដោយអាការយ៉ាងនេះ ចិត្ត ៤ ដួង គឺវិញ្ញាណទាំងឡាយ ៣ មានចក្ខុវិញ្ញាណជាដើម និងតទារម្មណ៍នេះ ជាចិត្តចូលដល់ការរាប់បានដល់បុគ្គលនោះ; តែក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ក្នុងទីបំផុតនៃការសេព ដោយបណ្តាចិត្តទាំងឡាយ ៨ គឺដោយកុសល ៤ ដួង ដែលសហគតៈដោយឧបេក្ខា, ដោយអកុសល ៤ ដួងណានីមួយ ចិត្តដែលជាទុហេតុកៈ សហគតៈដោយឧបេក្ខា អសង្ខារិកប៉ុណ្ណោះ ទើបជាតទារម្មណ៍; ចិត្ត ២ ដួង គឺសន្តីរណៈ ដែលសហគតៈដោយឧបេក្ខា និងតទារម្មណ៍នេះ ជាចិត្តចូលដល់បុគ្គលនោះ ដោយអាការយ៉ាងនេះ; មែនពិត កាលបើកម្មដែលបុគ្គលធ្វើហើយ ដោយចេតនាមួយ ចិត្តទាំងឡាយនោះ រមែងកើតបានជាចិត្ត ៣០ ដួងគត់ គឺ ៦ និងចិត្តទាំងឡាយ ៤ ដួងមុន, សូម្បីក្នុងទ្វារទាំងឡាយ មានសោតទ្វារជាដើម មួយទ្វារៗ បាន ៦ ដួងៗ; តែចិត្ត ១០ ដួង គឺក្នុងចក្ខុទ្វារ ៦ ដួង, វិញ្ញាណទាំងឡាយ មានសោតវិញ្ញាណជាដើម ៤ ដួង ដោយចិត្តដែលលោកមិនបានកាន់យកហើយ;

កថាប្រៀបដោយផ្លែស្វាយ និងនិយាមជាកថាមានតាមប្រក្រតីមែនពិត, តែការឧបមាដោយគ្រឿងគាបអំពៅ រមែងមិនបានក្នុងអធិការនេះឡើយ ។

កាលបើកម្មដែលកុសលចិត្ត ជាសសង្ខារិក ទុហេតុកៈ សហគតៈដោយសោមនស្សធ្វើហើយក្តី, កាលបើកម្មដែលអសង្ខារិក និងសសង្ខារិក ដែលជាទុ-ហេតុកៈ សហគតៈដោយឧបេក្ខាធ្វើហើយក្តី ក៏មានន័យដូចគ្នានេះដែរ, ដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណេះ លោកពោលវារៈថា "ទុហេតុកបដិសន្ធិ រមែងមានដោយកម្មដែលជាទុហេតុកៈ" ដូច្នេះ ។

ចំណែកវារៈថា **"មានអហេតុកបដិសន្ធិ"** ដូច្នេះ គប្បីជ្រាបយ៉ាងនេះថា៖

កាលបើកម្មដែលកុសលញាណវិប្បយុត្ត ៤ ដួងធ្វើហើយ បណ្ឌិតមិនគួរពោលថាជាបដិសន្ធិ ដូចកម្មដែលអហេតុកមនោវិញ្ញាណធាតុ ជាកុសលវិបាកដែលសហគតៈដោយឧបេក្ខាចាប់បដិសន្ធិទេ, តាំងអំពីដើមទៅ គប្បីជ្រាបថា ការកើតឡើងនៃចិត្តដែលមានឥដ្ឋារម្មណ៍ខ្លះ ឥដ្ឋមជ្ឈត្តារម្មណ៍ខ្លះ តាមន័យដែលពោលទុកហើយក្នុងខាងក្រោយនុ៎ះឯង, មែនពិត ក្នុងវាទៈរបស់ព្រះថេរៈនេះ ជវនដែលប្រមូលមកជាពួកតែមួយ រមែងសេពអារម្មណ៍, ពាក្យដ៏សេសទាំងអស់មានជាអាទិ៍ថា "ជវននេះ ជាចិត្តុប្បាទអ្វី រមែងកំណត់ទុកដោយសេចក្តីជាកុសលឬអកុសល" ដូច្នេះ គប្បីជ្រាបដោយន័យដែលពោលទុកខាងក្រោយនុ៎ះឯង, លំដាប់កថា ពោល

ដោយវិបាក ១២ ដួង និងវិបាកចិត្ត ១០ ដួង អហេតុកៈ ៨ ដួង ក្នុងវាទៈរបស់ព្រះមហាទត្តត្ថេរ អ្នកនៅក្នុងមោរវាបីចប់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ៕

## វិបាកចិត្ត ១០ ដួង ក្នុងវាទៈនៃព្រះមហាធម្មរក្ខិតត្ថេរ

ឥឡូវនេះ ជារឿងពោលដោយវិបាកចិត្ត ១០ ដួង ក្នុងវាទៈរបស់ព្រះមហាធម្មរក្ខិតត្ថេរតទៅ ៖

ក្នុងវាទៈនោះ បញ្ហាក្នុងក្រុងសាកេត និងការសម្ដែងចំណែកខាងច្រើនប្រព្រឹត្តទៅតាមប្រក្រតីនោះឯង, ចំណែកការសម្ដែងនេះ ជាការផ្សេងគ្នាក្នុងការកំណត់នូវហេតុគឺ ៖

កម្មជាតិហេតុកៈរមែងឱ្យវិបាកជាតិហេតុកចិត្តខ្លះ ឱ្យវិបាកជាទុហេតុកចិត្តខ្លះ ឱ្យវិបាកជាអហេតុកចិត្តខ្លះ ។ កម្មដែលជាទុហេតុកៈ រមែងមិនឱ្យវិបាកជាតិហេតុកចិត្តប៉ុណ្ណោះទេ, តែឱ្យវិបាកចិត្តក្រៅនេះដែរ ។ ដោយកម្មដែលជាតិហេតុកៈបដិសន្ធិរមែងជាតិហេតុកចិត្តប៉ុណ្ណោះ, មិនជាទុហេតុកៈ ឬអហេតុកៈទេ ។ ដោយកម្មដែលជាទុហេតុកបដិសន្ធិ រមែងជាទុហេតុកៈ និងអហេតុកចិត្ត, មិនជាតិហេតុកចិត្តឡើយ ។ កម្មដែលជាអសង្ខារិក ក៏ឱ្យផលជាអសង្ខារិកប៉ុណ្ណោះ, មិនឱ្យវិបាក

ជាសសង្ខារិកទេ, សូម្បីកម្មដែលជាសសង្ខារិក ក៏ឱ្យវិបាកដែលជាសសង្ខារិកប៉ុណ្ណោះ, មិនឱ្យវិបាកជាអសង្ខារិកឡើយ, វេទនាគប្បីផ្លាស់ទៅដោយអារម្មណ៍, ជវនចិត្តក៏រមែងសេពអារម្មណ៍ហើយស្ទុះទៅក្នុងក្រុមតែមួយនោះឯង; បណ្ឌិតគប្បីពោលអធិប្បាយចិត្តទាំងឡាយ តាំងអំពីដើមដោយប្រការដូច្នេះ ។

ក្នុងសេចក្ដីនោះ គប្បីជ្រាបកថាដូចតទៅនេះ ៖

បុគ្គលម្នាក់ធ្វើកម្មដោយកុសលចិត្តដួងទី ១, គេរមែងចាប់បដិសន្ធិ ដោយវិបាកចិត្តដួងទីមួយប៉ុណ្ណោះ, បដិសន្ធិចិត្តនេះដូចគ្នានឹងកម្មដែលធ្វើ ។ កាលបើបុគ្គលនោះចម្រើនវ័យធំហើយ កាលឥដ្ឋារម្មណ៍មកកាន់គន្លងនៃចក្ខុទ្វារ មោឃវារៈ ៣ រមែងមានដោយន័យដែលបានពោលហើយនុ៎ះឯង, លំដាប់នោះ កាលដែលវេលាទីបំផុតនៃជវនចិត្ត ដែលសហគតៈដោយសោមនស្ស ១៣ តាមដែលពោលទុកក្នុងខាងដើមនោះឯង ដួងណានីមួយរបស់បុគ្គលនោះសេពហើយ វិបាកចិត្តដួងទីមួយប៉ុណ្ណោះ រមែងជាតទារម្មណ៍ ។ វិបាកចិត្តនោះ បានឈ្មោះពីរយ៉ាង គឺមូលភវង្គ និងតទារម្មណ៍, ដោយអាការយ៉ាងនេះ ចិត្តទាំងឡាយរបស់គេ រមែងចូលដល់ការរាប់បាន ៤ ដួង គឺវិបាកចិត្ត ៣ ដួង (តាមលំដាប់) មានចក្ខុវិញ្ញាណជាដើម និងតទារម្មណ៍; ក្នុងវេលាទីបំផុតនៃជវនចិត្តដែលសហគតៈដោយឧបេក្ខា ១២ ដួង ដោយន័យដែលបានពោលទុកក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ខាងក្រោយនុ៎ះឯង ដួងណានីមួយសេព

ហើយ ចិត្តដែលជាតិហេតុកអសង្ខារិកដែលសហគតៈដោយឧបេក្ខា ក៏តាំងនៅក្នុងសភាពជាតទារម្មណ៍, ចិត្តរបស់គេទើបរាប់បាន ២ យ៉ាង គឺអាគន្តុកភវង្គ និងតទារម្មណ៍ដូងនេះ, វិបាកចិត្ត ២ ដួងនេះ និងវិបាកចិត្ត ៤ ដួងមុន ទើបរួមជាវិបាកចិត្ត ៦ ដួង ដោយប្រការដូច្នេះ; សូម្បីក្នុងសោតទ្វារជាដើម ក៏បានវិបាកចិត្តមួយទ្វារ ៦ៗ, ព្រោះហេតុដូច្នេះ កាលបើកម្មចេតនាដួងតែមួយធ្វើកុសលហើយ វិបាកចិត្ត ៣០ ដួងគត់ រមែងកើតឡើងក្នុងទ្វារ ៥, ពោលដោយការរាប់ចិត្ត (កាន់យក) ដែលនៅមិនទាន់បានរាប់ រមែងបានវិបាកចិត្ត ១០ ដួង គឺក្នុងចក្ខុទ្វារ ៦ ដួង ក្នុងសោតវិញ្ញាណជាដើម ៤ ដួង ។ ឧប្រៀបធៀបដោយផ្លែស្វាយ និងនិយាមកថា គង់ប្រព្រឹត្តទៅតាមប្រក្រតីដើមនោះដែរ ។

កាលបើកម្មដែលជាកុសលចិត្តដួងទី ២ ទី ៣ និងទី ៤ សូម្បីធ្វើហើយ វិបាកចិត្តក៏មានប្រមាណប៉ុណ្ណោះ និងរមែងមានដោយប្រការដូច្នេះ; សូម្បីក្នុងកម្មដែលសហគតៈដោយឧបេក្ខាចិត្ត ៤ ដួងធ្វើហើយ ក៏នំយនេះដែរ ។

ក្នុងវាទៈនេះ គប្បីសម្តែងឥដ្ឋមជ្ឈត្តារម្មណ៍សិន, ខាងក្រោយទើបផ្លាស់វេទនាដោយឥដ្ឋារម្មណ៍ ។ ក្នុងសេចក្តីនោះ ការប្រៀបធៀបដោយផ្លែស្វាយ និងនិយាមកថា ប្រព្រឹត្តទៅដូចដើមដែរ, តែមិនបានការប្រៀបធៀបដែលសម្តែងអំពី

ការគាបអំពៅទេ, បណ្ឌិតគប្បីពោលអហេតុកចិត្ត ៨ ដួងទាំងអស់ ឱ្យពិស្តារតាំងអំពីនេះថា “ក៏កាលបើពោលដោយកុសល កាលបើកម្មដែលញាណវិប្បយុត្តចិត្ត ៤ ដួង ដួងណានីមួយធ្វើហើយ” ដូច្នេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ វិបាកចិត្ត ១០ ដួង និងអហេតុកចិត្ត ៨ ដួង ក្នុងវាទៈរបស់ព្រះមហារក្ខិតត្ថេរចប់ហើយ ដោយប្រការដូច្នេះ ។

***សួរថា*** វាទៈរបស់ព្រះថេរៈទាំង ៣ រូបនេះ របស់រូបណា គួរកាន់យក?

ឆ្លើយថា មិនគួរកាន់យករបស់លោករូបណានីមួយ ដោយចំណែកតែមួយឡើយ, តែគួរកាន់យកវាទៈរបស់លោកទាំងអស់ដែលត្រឹមត្រូវ ។

ព្រោះថា ក្នុងវាទៈរបស់ព្រះថេរៈដំបូង លោកបំណងចាត់ប្រភេទនៃចិត្តដែលជាសសង្ខារ ( មានការដឹកនាំ) និងអសង្ខារ ( មិនមានការដឹកនាំ) ដោយសេចក្តីផ្សេងគ្នានៃបច្ច័យ; ដោយហេតុនោះ ក្នុងវាទៈព្រះថេរៈរូបទី ១ នេះ ទើបលោកពោលដល់ផ្លូវនៃវិបាក ១៦ ដួង ដោយអំណាចនៃព្រះសេក្ខៈ និងបុថុជ្ជនកាន់យកវិបាកដែលជាសសង្ខាររបស់កុសល ជាអសង្ខារដែលកើតឡើងដោយបច្ច័យ ដែលទុព្វល និងវិបាកដែលជាអសង្ខារ របស់កុសលជាសសង្ខារដែលកើតឡើង ដោយបច្ច័យដែលមានកម្លាំង លះកិរិយាជវនទាំងឡាយ សូម្បីបានហើយកំណត់តទា-

រម្មណ៍ ដោយកុសលជវនទាំងឡាយ កំណត់វេទនាដោយអារម្មណ៍; ក៏ក្នុងវាទៈរបស់ព្រះថេរៈទី ១ នេះ លោកសម្តែងតទារម្មណ៍យ៉ាងណា ដែលជាអហេតុកវិបាក ប៉ុណ្ណោះ ក្នុងទីបំផុតនៃអកុសលជវនចិត្ត, តទារម្មណ៍នោះ លោកមិនសម្តែងទុកក្នុងវាទៈក្រៅនេះឡើយ; ព្រោះហេតុដូច្នោះ ក្នុងវាទៈរបស់លោកនោះ តទារម្មណ៍ដែលជាអហេតុកវិបាកនោះ ក្នុងវាទៈរបស់ព្រះថេរៈទី ១ នោះ និងតទារម្មណ៍ដែលជាសហេតុកវិបាក ដែលពោលទុកក្នុងវាទៈពីក្រៅនេះនោះ វាទៈទាំងអស់នោះ រមែងបានសូម្បីក្នុងអធិការនេះ ដូចគ្នាដែរ ។

សេចក្តីនោះ មានន័យដូចតទៅនេះ ៖

ក៏ក្នុងកាលណា អកុសលចិត្តសេពអារម្មណ៍ក្នុងចន្លោះៗ (ផ្លាស់វីថិគ្នា) នៃកុសលជវនចិត្តទាំងឡាយ, ក្នុងកាលនោះ តទារម្មណ៍ជាសហេតុកៈ ក៏គប្បីទទួលអារម្មណ៍ ក្នុងទីបំផុតនៃអកុសលជវនចិត្ត ដូចគ្នានឹងការទទួលអារម្មណ៍រឿយៗ ក្នុងទីបំផុតនៃកុសលជវនចិត្តនោះឯង ។ ក្នុងកាលណា អកុសលចិត្តកើតជាប់តគ្នាទៅមិនដាច់ខ្សែ, ក្នុងកាលនោះ អហេតុកវិបាក ទើបគួរជាតទារម្មណ៍; គប្បីកាន់យកខដែលត្រូវក្នុងវាទៈរបស់ព្រះថេរៈរូបទី ១ យ៉ាងនេះសិនចុះ ។

ក៏ក្នុងវាទៈរបស់ព្រះថេរៈរូបទី ២ លោកបំណងចាត់ប្រភេទនៃចិត្ត ដែលជាអសង្ខារ និងសសង្ខាររបស់កុសល, ដោយហេតុនោះ ក្នុងវាទៈទី ២ នេះ ទើបពោលដល់វិបាកចិត្ត ១២ ដួង ដោយអំណាចនៃជវនដែលរួមគ្នាប៉ុណ្ណោះ ដែលសមគួរដល់ការកើតឡើងនៃព្រះសេក្ខាសេក្ខៈ និងបុថុជ្ជនសូម្បីទាំងអស់ ដោយកាន់យកវិបាក-ចិត្ត ដែលជាអសង្ខារិករបស់កុសល ដែលជាសសង្ខារិកម្យ៉ាង និងវិបាកចិត្តដែលជាសសង្ខារិក របស់កុសលដែលជាសសង្ខារិកតែម្យ៉ាង មិនធ្វើការកំណត់តទារម្មណ៍ដោយជវនចិត្តទេ ។ តែក្នុងវាទៈទី ២ នេះ កាលបើជវនចិត្តជាទុហេតុកៈ ដល់ទីបំផុតចុងក្រោយ តទារម្មណ៍ក៏សមគួរជាតិហេតុកៈ, កាលបើជវនចិត្តជាទុហេតុកៈដល់ទីបំផុតចុងក្រោយ តទារម្មណ៍សមគួរជាទុហេតុកវិបាកចិត្ត, កាលបើជវនចិត្តដែលជាអហេតុកៈ ដល់ទីបំផុតចុងក្រោយ តទារម្មណចិត្ត សមគួរជាអហេតុក-វិបាកចិត្ត, តែខនេះ លោកមិនបានចែកទុកទេ ។ ក៏ពាក្យដែលគួរកាន់យកត្រឹមត្រូវក្នុងវាទៈទី ២ មានដោយប្រការដូច្នេះ ។

សូម្បីក្នុងវាទៈរបស់ព្រះថេរៈទី ៣ លោកក៏បំណងចាត់សសង្ខារិកចិត្ត និងអសង្ខារិកចិត្តរបស់កុសលនោះឯង, ព្រោះពាក្យដែលពោលថា “កម្មជាតិហេតុកៈរមែងឱ្យវិបាកជាតិហេតុកៈខ្លះ ឱ្យវិបាកជាទុហេតុកៈខ្លះ ឱ្យវិបាកជាអហេតុកៈខ្លះ” ដូច្នេះ គួរជាតទារម្មណ៍ សូម្បីដែលជាអសង្ខារិកហេតុកៈខ្លះ ជាអសង្ខារិកទុហេតុកៈ

ខ្លះ របស់បដិសន្ធិចិត្តដែលជាអសង្ខារិកតិហេតុកៈ; តែលោកមិនសម្តែងតទារម្មណ៍នោះ សម្តែងតែតទារម្មណ៍ដែលដូចគ្នានឹងតិហេតុកចិត្តប៉ុណ្ណោះ, តទារម្មណ៍នោះមិនសមនឹងលទ្ធិដែលសម្តែងហេតុជាច្រើនខាងដើមឡើយ ការដែលលោកពោលទុកយ៉ាងនេះ ដើម្បីអធិប្បាយដល់លំដាប់នៃវិបាក ១០ ដួងប៉ុណ្ណោះ, តែសូម្បីតទារម្មណ៍ក្រៅនេះ ក៏នៅបានដែរ ។

គួរកាន់យកខដែលត្រឹមត្រូវសូម្បីក្នុងវាទៈទី ៣ យ៉ាងនេះ ។

ម្យ៉ាងទៀត សូម្បីវាទៈទាំងអស់នេះ ជាពាក្យពោលដោយតទារម្មណ៍ សំដៅយកវិបាករបស់កម្មដែលឱ្យកើតបដិសន្ធិប៉ុណ្ណោះ; តែព្រោះព្រះបាលីថា **"សហេតុកំ ភវង្គំ អហេតុកស្ស ភវង្គស្ស អនន្តរប្បច្ចយេន បច្ចយោ** = សហេតុកភវង្គជាបច្ច័យដល់អហេតុកភវង្គ ដោយអនន្តរប្បច្ច័យ"[៤៥] ដូច្នេះ តទារម្មណចិត្តដែលជាសហេតុកវិបាក រមែងកើតឡើងសូម្បីដល់បដិសន្ធិ ដែលជាអហេតុកចិត្តដោយកម្មផ្សេងគ្នា, វិធីនៃការកើតឡើងរបស់តទារម្មណ៍នោះ នឹងជាក់ច្បាស់ក្នុងគម្ពីរមហាបករណ៍ឯណោះ ៕

*ចប់កថាពោលដោយកាមាវចរកុសលវិបាកចិត្ត*

---

[៤៥] អភិ. ។

# សម្ដែងអំពីរូបាវចរវិបាកជាដើម

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងសម្ដែងវិបាកចិត្ត ដែលជារូបា-វចរជាដើម ចាប់ផ្ដើមត្រាស់ថា **“កតមេ អព្យាកតា ធម្មា** = ធម៌ដែលជាអព្យាក្រឹត តើយ៉ាងណា ? ” ជាដើមទៀត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ដែលជាអព្យាក្រឹតដូចតទៅ ៖

កាមាវចរវិបាកដូចគ្នាខ្លះ, មិនដូចគ្នាខ្លះ ជាមួយកុសលចិត្តរបស់ខ្លួន, ព្រោះហេតុដូច្នោះ វិបាកចិត្តតាមប្រាថ្នានោះ ទើបលោកមិនបានចែកឱ្យជាវិបាកអនុលោមតាមកុសលទេ ។ ចំណែករូបាវចរវិបាក និងអរូបាវចរវិបាក ដូចគ្នាជាមួយនឹងកុសលរបស់ខ្លួន ដូចស្រមោលទាំងឡាយ មានស្រមោលដំរី សេះ និងដើមឈើជាដើម ដូចជាដំរី សេះ និងដើមឈើជាដើមនោះឯង ព្រោះហេតុដូច្នោះ ទើបលោកចែកធ្វើឱ្យអនុលោមតាមកុសល ។

ម្យ៉ាងទៀត កាមាវចរកុសលរមែងឱ្យវិបាកក្នុងកាលខ្លះ គ្រាខ្លះ ក៏បាន, ចំណែករូបាវចរកុសល និងអរូបាវចរកុសល រមែងឱ្យវិបាកចំពោះអត្តភាពក្នុងភពទីពីរតែម្ដង ដោយមិនមានអន្តរាយ ព្រោះហេតុនោះឯង ទើបលោកចែកឱ្យដូចជាកុសលនោះដែរ; ពាក្យដែលសល់ គប្បីជ្រាបដោយន័យដែលបានពោលទុក ក្នុង

កុសលនោះឯង, ចំណែកសេចក្ដីប្លែកគ្នាមានដូច្នេះ ៖

គប្បីជ្រាបប្រភេទមានបដិបទាជាដើម និងភាវៈជាហីនចិត្ត បណីតចិត្ត និងមជ្ឈិមចិត្ត ព្រោះការមកនៃឈានក្នុងរូបាវចរវិបាក និងអរូបាវចរវិបាកនេះ ។ តែវិបាកទាំងនេះ មិនមានអធិបតីទេ ព្រោះមិនធ្វើធម៌ មានឆន្ទៈជាដើមដួងណាមួយឱ្យជាធុរៈហើយកើតឡើងឡើយ ៕

*ចប់រូបាវចរវិបាក និងអរូបាវចរវិបាក*

# សម្ដែងអំពីលោកុត្តរវិបាក

សូម្បីលោកុត្តរវិបាក ក៏ព្រះអង្គទ្រង់ចែកធ្វើឱ្យអនុលោមតាមកុសលនុ៎ះឯង ព្រោះដូចគ្នានឹងលោកុត្តរកុសលដែរ ។ តែព្រោះតេភូមិកកុសល រមែងសន្សំ រមែងញុំាងវដ្ដៈឱ្យចម្រើន ដោយអំណាចនៃចុតិ និងបដិសន្ធិ, ព្រោះហេតុដូច្នោះ ក្នុងវិបាកនៃលោកុត្តរកុសលនោះ ទើបត្រាស់ទុកថា “ព្រោះកុសលជ្ឈានជាលោកុត្តរ ដែលបានធ្វើទុកហើយ បានសន្សំទុកហើយ” ដូចនេះ; ចំណែកលោកុត្តរ សូម្បីវិបាកនោះសន្សំទុក ក៏រមែងបន្ថូរការសន្សំ សូម្បីខ្លួនឯង ក៏មិនសន្សំដោយអំណាចនៃចុតិ និងបដិសន្ធិដែរ, ព្រោះហេតុនោះ ក្នុងវិបាកនៃលោកុត្តរកុសលនោះ ទើបមិនត្រាស់ទុក

ថា "ព្រោះបានធ្វើទុកហើយ បានសន្សំទុកហើយ" តែត្រាស់ថា "ព្រោះបានធ្វើទុកហើយ ព្រោះបានចម្រើនទុកហើយ" ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះបាលីមានពាក្យថា "**សុញ្ញតៈ**" ជាដើមថា "មគ្គរមែងបានឈ្មោះ ព្រោះហេតុ ៣ គឺព្រោះការសម្រេច ១, ព្រោះគុណរបស់ខ្លួន ១, ព្រោះអារម្មណ៍ ១" , សុញ្ញតៈនេះ ខ្ញុំឱ្យពិស្តារទុកក្នុងអធិការនៃកុសលក្នុងគ្រាក្រោយហើយ ។ ក្នុងអធិការនោះ មគ្គរមែងបានឈ្មោះ ដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ តាមបរិយាយនៃព្រះសូត្រ; ក៏បរិយាយនេះ ជាបរិយាយ-ទេសនា, ចំណែកអភិធម្មកថា ជានិប្បរិយាយទេសនា; ព្រោះហេតុដូច្នោះ ក្នុងនិប្បរិយាយទេសនានេះ ទើបមិនបានឈ្មោះដោយគុណរបស់ខ្លួន ឬដោយអារម្មណ៍, តែរមែងបានឈ្មោះ ដោយការពន្លុះតែម្យ៉ាង; ព្រោះការពន្លុះប៉ុណ្ណោះជាធុរៈ, ការពន្លុះនេះ មានពីរយ៉ាង គឺពន្លុះវិបស្សនា និងពន្លុះមគ្គ ។

ក្នុងការពន្លុះពីរយ៉ាងនោះ ការពន្លុះវិបស្សនាជាធុរៈក្នុងឋានដែលមគ្គប្រាកដហើយ, ការពន្លុះមគ្គជាធុរៈក្នុងឋានដែលផលប្រាកដហើយ; សូម្បីពាក្យទាំងពីរនេះ ខ្ញុំក៏ពោលទុកក្នុងខាងក្រោយដូចគ្នា។ បណ្ដាឋានទាំងពីរនោះ នេះជាឋានដែលផលប្រាកដហើយ; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ការពន្លុះមគ្គជាធុរៈក្នុងឋាននេះ ។

ក៏មគ្គនេះ ឈ្មោះថា **សុញ្ញតៈ** ព្រោះការពន្លុះហើយ ទើបបានឈ្មោះថា **អនិមិត្តៈ អប្បណិហិតៈ** ព្រោះគុណរបស់ខ្លួន និងអារម្មណ៍ ព្រោះហេតុដូច្នេះ ខ្លួនឯងតាំងនៅក្នុងឋានដែលពន្លុះបានហើយ ទើបឱ្យឈ្មោះ ៣ យ៉ាងដល់ផលរបស់ខ្លួន ។ ឱ្យឈ្មោះយ៉ាងណា ? គឺថាមគ្គនេះ ជាសុញ្ញតមគ្គ មានឈ្មោះដែលបានមក ដោយអំណាចនៃការចាក់ធ្លុះតែម្យ៉ាងប៉ុណ្ណោះ ព្រោះតាំងនៅក្នុងឋានដែលពន្លុះបានដោយខ្លួនឯង កាលនឹងឱ្យឈ្មោះដល់ផលរបស់ខ្លួន ទើបបានធ្វើឈ្មោះថា **"សុញ្ញតៈ"**។ ក៏**មគ្គសុញ្ញតៈ**និង**អនិមិត្តៈ** (គួរនឹងជាអនិមិត្តមគ្គតែម្យ៉ាង) ព្រោះតាំងនៅក្នុងឋានដែលពន្លុះបានដោយខ្លួនឯង កាលនឹងឱ្យឈ្មោះដល់ផលរបស់ខ្លួន ទើបបានធ្វើឈ្មោះថា អនិមិត្តៈ; **មគ្គសុញ្ញតៈ** និង **អប្បណិហិតៈ** ព្រោះតាំងនៅក្នុងឋានដែលគប្បីពន្លុះបានដោយខ្លួនឯង កាលនឹងឱ្យឈ្មោះផលរបស់ខ្លួន ទើបបានធ្វើឈ្មោះថា **"អប្បណិហិតៈ"** (គួរនឹងជាអប្បណិហិតមគ្គតែម្យ៉ាង)។ ក៏ឈ្មោះទាំង ៣ យ៉ាងនេះ រមែងបានដោយន័យនេះ ក្នុងផលចិត្តដែលជាលំដាប់នៃមគ្គប៉ុណ្ណោះ មិនបានក្នុងវេលាចូលផលសមាបត្តិក្នុងពេលដទៃទេ ។ តែថា ក្នុងពេលខាងក្រោយ រមែងអាចដើម្បីឃើញដោយវិបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម, ម្យ៉ាងទៀត ផលទាំង ៣ ពោលគឺអនិមិត្តៈ អប្បណិហិតៈ សុញ្ញតៈ រមែងកើតឡើងដោយអំណាច

នៃវិបស្សនារបស់ព្រះយោគាវចរដែលចេញហើយៗ, ញាណនោះៗ ឯង របស់ផលទាំង ៣ នោះ មានអនិច្ចានុបស្សនាជាដើម មានសង្ខារជាអារម្មណ៍ ឈ្មោះថា **អនុលោមញ្ញាណ**។

ក៏សូម្បីក្នុងអប្បណិហិតមគ្គ ដែលលោកពោលទុកក្នុងសុញ្ញតមគ្គ ក៏មានន័យដូចគ្នាដែរ, ពិតមែន អប្បណិហិតមគ្គនោះ មានឈ្មោះដែលបានហើយដោយអំណាចនៃការពន្លុះ តែម្យ៉ាងប៉ុណ្ណោះ ព្រោះតាំងនៅក្នុងឋានដែលគប្បីពន្លុះបានដោយខ្លួនឯង កាលនឹងឱ្យឈ្មោះផលរបស់ខ្លួន ទើបបានឈ្មោះថា “**អប្បណិហិតៈ**” មគ្គដែលជាអប្បណិហិតៈ និងអនិមិត្តៈ ព្រោះតាំងក្នុងឋានដែលគប្បីពន្លុះបានដោយខ្លួនឯង កាលនឹងឱ្យផលរបស់ខ្លួន ទើបបានឈ្មោះថា “អនិមិត្តៈ” មគ្គដែលជាអប្បណិហិតៈ និងសុញ្ញតៈ ព្រោះតាំងនៅក្នុងឋានដែលគប្បីពន្លុះបានដោយខ្លួនឯង កាលនឹងឱ្យឈ្មោះផលរបស់ខ្លួនទើបបានធ្វើឈ្មោះថា “**សុញ្ញតៈ**” ; សូម្បីឈ្មោះទាំង ៣ នេះ រមែងបានដោយន័យនេះ ក្នុងផលចិត្តដែលជាលំដាប់នៃមគ្គប៉ុណ្ណោះ, មិនមែនដោយកាលដទៃទៀតទេ គឺក្នុងវេលាចូលផលសមាបត្តិ ។

ក្នុងនិទ្ទេសនៃវិបាកចិត្តនេះ គប្បីជ្រាបវិបាកចិត្តទាំងឡាយ មានគុណ ៣ យ៉ាង ដោយកុសលចិត្តយ៉ាងនេះ ។ ដូចយ៉ាងថា កុសលចិត្តដែលប្រព្រឹត្តទៅក្នុង

ភូមិ ៣ រមែងមិនអាចញុំាងវិបាករបស់ខ្លួន ឱ្យបានអធិបតី យ៉ាងណា ។ លោកុត្តរ-កុសលទាំងឡាយ មិនជាយ៉ាងនោះឡើយ, ព្រោះហេតុអ្វី ? ព្រោះវេលាដែលប្រកបកម្មរបស់កុសលប្រព្រឹត្តទៅក្នុងភូមិ ៣ ម្យ៉ាង, ក្នុងវេលាឱ្យវិបាកម្យ៉ាង ព្រោះហេតុនោះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ទើបមិនញុំាងវិបាករបស់ខ្លួនឱ្យបាននូវអធិបតីទេ ។ ចំណែកលោកុត្តរទាំងឡាយ កាលសទ្ធា[៤៦] វីរិយៈ សតិ សមាបត្តិ និងបញ្ញានោះ មិនចូលទៅស្ងប់ (គឺនៅប្រព្រឹត្តទៅ) ក៏រមែងបានវិបាកក្នុងលំដាប់នៃមគ្គនោះឯង មិនទាស់ខុសឡើយ, ដោយហេតុនោះ លោកុត្តរ-កុសលនោះ ទើបអាចញុំាងវិបាករបស់ខ្លួន ឱ្យបាននូវអធិបតី ។

ដូចយ៉ាងថា ក្នុងទីដែលគេគរគំនរភ្លើងតូចទុក កាលភ្លើងរលត់ហើយ អាការៈក្តៅ ក៏រលត់ មិនមានអ្វីទេ, តែកាលគេយកអាចម៍គោរោយទៅជុំវិញៗ រលត់គំនរភ្លើងធំដែលត្រលោមឡើងហើយ អាការៈ គឺការក្តៅ រមែងមិនស្ងប់ចុះមួយរំពេច យ៉ាងណា, សេចក្តីនេះ ក៏យ៉ាងនោះដែរ គឺខណៈនៃកម្ម (ការធ្វើ)

---

[៤៦] សទ្ធា ក្នុងទីនេះ គឺសទ្ធាដែលប្រព្រឹត្តទៅជាលោកុត្តរ, សូម្បីវីរិយៈជាដើម ក៏ដូចគ្នាដែរ ។ (អត្ថយោជនា) ។

ក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៣ ម្យ៉ាង ខណៈនៃវិបាកម្យ៉ាង, ដូចវេលាដែលអាការៈ គឺភាពក្តៅនៃគំនរភ្លើងតូចរលត់ទៅ, ព្រោះហេតុដូច្នេះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ទើបមិនអាចដើម្បីញុំាងវិបាករបស់ខ្លួនឱ្យបាននូវអធិបតីឡើយ, ចំណែកលោកុត្តរកុសល កាលសទ្ធានោះ ។ល។ និងបញ្ញានោះ មិនចូលទៅស្ងប់ផលក៏កើតឡើង ក្នុងលំដាប់នៃមគ្គភ្លាម, ព្រោះហេតុដូច្នោះ លោកុត្តរកុសលនោះ បណ្ឌិតគប្បីជ្រាបថា រមែងញុំាងវិបាករបស់ខ្លួន ឱ្យបាននូវអធិបតីដូច្នេះ; ដោយហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា "អធិបតីមិនមានក្នុងវិបាកចិត្តទេ វៀរលែងតែលោកុត្តរចេញ ៕

## សម្តែងអំពីអញ្ញាតាវិន្ទ្រិយ ក្នុងលោកុត្តរវិបាកជួងទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃផលដែលកើតឡើងអំពីមគ្គទី ៤ តទៅ ៖

ពាក្យថា **អញ្ញាតាវិន្ទ្រិយ** បានដល់ ឥន្ទ្រិយរបស់លោកអ្នកដឹងទូទៅ គឺអ្នកមានញាណកិច្ចសម្រេចក្នុងសច្ចៈ ៤, ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះឱ្យសម្រេចអត្ថនៃភាវៈជាធំខាងក្នុងធម៌ទាំងឡាយ ដែលដឹងទូទៅ គឺមានកិច្ចដែលសម្រេចក្នុងសច្ចៈ ៤ ដែលដឹងហើយចាក់ធ្លុះសច្ចៈ ៤ ទើបតាំងនៅ ។

សូម្បីក្នុងនិទ្ទេសនៃអញ្ញាតាវិន្ទ្រិយនោះ ពាក្យថា **"ដឹងទូទៅហើយ"** បានដល់ ដឹងហើយស្ថិតនៅ ។ ពាក្យថា **ធម៌ទាំងឡាយ** បានដល់ ក្នុងខាងក្នុងនៃសម្បយុត្តធម៌ទាំងឡាយ ។ បទថា **"អញ្ញា = ការដឹងទូទៅ"** បានដល់ ការដឹងសព្វ ។ ពាក្យថា **"ការដឹងច្បាស់ កិរិយាដែលដឹងច្បាស់"** ជាដើម មានសេចក្តីដែលបានពោលហើយនោះឯង ។ បទថា **មគ្គង្គំ, មគ្គបរិយាបន្នំ** = អង្គនៃមគ្គរាប់បញ្ចូលក្នុងមគ្គ, អធិប្បាយថា ជាអង្គមគ្គក្នុងផល និងរាប់បញ្ចូលក្នុងអង្គមគ្គនៃផល ។

ម្យ៉ាងទៀត ក្នុងលោកុត្តរវិបាកនេះ មានបកិណ្ណកៈដូច្នេះ ៖

ឥន្ទ្រិយមួយដល់ឋានៈមួយ, ឥន្ទ្រិយមួយដល់ឋានៈ ៦, ឥន្ទ្រិយមួយ ដល់ឋានៈម្យ៉ាងទៀត, មានអធិប្បាយថា ក៏អនញ្ញតញ្ញស្សាមីតិន្ទ្រិយម្យ៉ាង ដល់ឋានៈមួយ គឺ **សោតាបត្តិមគ្គ**។ អញ្ញិន្ទ្រិយមួយដល់ឋានៈ ៦ គឺផលខាងក្រោម ៣, មគ្គខាងលើ ៣; អញ្ញាតាវិន្ទ្រិយមួយដល់ឋានៈមួយ គឺអរហត្តផល ។

ពោលដោយអត្ថក្នុងមគ្គ និងផលទាំងអស់ត្រាស់ឥន្ទ្រិយ ដែលជាលោកុត្តរ-ទុក ៦៤ គឺមគ្គ និងផលមួយ១ មាន ៨ ឥន្ទ្រិយ; តែក្នុងព្រះបាលីជាឥន្ទ្រិយ ៧២ ព្រោះធ្វើមគ្គ និងផលមួយ១ មាន ៩ ឥន្ទ្រិយ; ក្នុងមគ្គក៏ត្រាស់ថា មគ្គង្គៈ (អង្គនៃ

មគ្គ), សូម្បីក្នុងផល ក៏ត្រាស់ថា មគ្គង្គៈ (អង្គនៃមគ្គ), ក្នុងមគ្គត្រាស់ថា ពោជ្ឈង្គៈ ។ សូម្បីក្នុងផល ក៏ត្រាស់ថា ពោជ្ឈង្គៈ ។ សូម្បីក្នុងខណៈនៃមគ្គក៏ត្រាស់ថា "**អារតី វិរតី** = ការវៀរចាក", សូម្បីក្នុងខណៈនៃផល ក៏ត្រាស់ថា "**អារតី វិរតី**" ។

បណ្ដាមគ្គ និងផលនោះ មគ្គ ឈ្មោះថា **មគ្គ** ដោយភាវៈជាមគ្គនោះឯង, ចំណែកផល ឈ្មោះថា **មគ្គ** ព្រោះអាស្រ័យមគ្គ ។ សូម្បីនឹងពោលថា "អង្គនៃផល រាប់បញ្ចូលក្នុងផល" ដូច្នេះ ក៏គួរដែរ ។

ក្នុងមគ្គត្រាស់ថា សម្ពោជ្ឈង្គៈ ព្រោះអត្ថថា ជាអង្គនៃបុគ្គលអ្នកត្រាស់ដឹង ។ ក្នុងផលត្រាស់ហៅថា សម្ពោជ្ឈង្គៈ ព្រោះអត្ថថា ជាអង្គនៃបុគ្គលអ្នកត្រាស់ដឹងហើយ ។ ក្នុងមគ្គត្រាស់ថា "**អារតី វិរតី**" ដោយអំណាចនៃការវៀរចាកអារម្មណ៍នោះឯង, ក្នុងផលត្រាស់ថា **អារតី វិរតី** ដោយអំណាចនៃការវៀរនោះឯង ៕

*ចប់កថាពោលដោយលោកុត្តរវិបាក*

---

## សម្ដែងអំពីអកុសលវិបាក

ខាងមុខអំពីលោកុត្តរវិបាកនេះទៅ ជាអកុសលវិបាកចិត្ត ៧ ដួងនេះ គឺ

សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ រួមជា ៥ ដួង, មនោធាតុ ១ ដួង និងមនោវិញ្ញាណធាតុ ១ ដួង ដោយព្រះបាលី និងអដ្ឋកថា ដូចជាមួយកុសលវិបាកចិត្ត តាមដែលពោលទុកខាងក្រោយនុ៎ះឯង ។

ពិតមែន កុសលវិបាកនោះ មានកម្មជាបច្ច័យតែម្យ៉ាង, អកុសលវិបាកនោះ ក៏មានអកុសលកម្មជាបច្ច័យដែរ ។

ម្យ៉ាងទៀត កុសលវិបាកនោះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ដែលជា ឥដ្ឋារម្មណ៍ និងឥដ្ឋមជ្ឈត្តារម្មណ៍, អកុសលវិបាកនេះ រមែងប្រព្រឹត្តទៅក្នុងអនិដ្ឋា-រម្មណ៍ និងអនិដ្ឋមជ្ឈត្តារម្មណ៍ ។

ម្យ៉ាងទៀត ក្នុងកុសលវិបាកនោះ កាយវិញ្ញាណចិត្ត សហគតៈដោយសុខ, តែក្នុងអកុសលវិបាកនោះ កាយវិញ្ញាណចិត្ត សហគតៈដោយទុក្ខ ។

ម្យ៉ាងទៀត ក្នុងកុសលវិបាកពួកនោះ មនោវិញ្ញាណធាតុ សហគតៈដោយ ឧបេក្ខា រមែងឱ្យផលក្នុងឋានទាំង ៥ ចាប់ផ្ដើមអំពីបដិសន្ធិ របស់មនុស្សខ្វាក់អំពី កំណើតជាដើមក្នុងពួកមនុស្ស, តែក្នុងអកុសលវិបាកនេះ កាលអកុសលចិត្ត ១១ យ៉ាង [៤៧] ប្រកបដោយអារម្មណ៍ហើយ រមែងឱ្យផលក្នុងឋានទាំង ៥ យ៉ាងនេះ គឺ

---

[៤៧] វៀរមោហមូលចិត្ត សម្បយុត្តដោយឧទ្ធច្ចៈ ។

១-ឱ្យបដិសន្ធិក្នុងអបាយ ៤

២-ឱ្យផលជាភវង្គរហូតអាយុតាំងអំពីវារៈទី ២ [៤៨]

៣-ឱ្យផលជាសន្តីរណៈ ក្នុងបញ្ចវិញ្ញាណវីថិ ក្នុងអនិដ្ឋារម្មណ៍ និងអនិដ្ឋ-មជ្ឈត្តារម្មណ៍ ។

៤-ឱ្យផលជាតទារម្មណ៍ ក្នុងទ្វារទាំង ៦ ក្នុងអារម្មណ៍ដែលមានកម្លាំងខ្លាំង

៥-ឱ្យផលជាចុតិ ក្នុងមរណកាល ៕

*ចប់កថាពោលដោយអកុសលវិបាក*

---

## សម្តែងអំពីកិរិយាអព្យាកតៈ

## ពោលដោយមនោធាតុដែលជាកិរិយាចិត្ត

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់បំណងនឹងចែកកិរិយា អព្យាកតៈ (មនោ-ធាតុដែលជាកិរិយាចិត្ត) ទើបត្រាស់បាលីជាដើមថា **“កតមេ ធម្មា អព្យាកតា** = ធម៌ដែលជាអព្យាក្រឹត តើយ៉ាងណា? ” ដូចតទៅ ៖

---

[៤៨] វារៈដំបូង បានដល់ បដិសន្ធិកាល ។

បណ្ដាអព្យាកតៈទាំងនោះ បទថា **កិរិយា** បានដល់ ត្រឹមតែការធ្វើ ។ ពិតមែន ក្នុងកិរិយាចិត្តគ្រប់ដួងទាំងអស់ កិរិយាចិត្តណា មិនដល់ភាវៈជាជវន កិរិយាចិត្តនោះ រមែងមិនមានផល ដូចផ្កាឈើខ្យល់ (សំដៅដល់ផ្កាឈើគ្មានប្រយោជន៍) កិរិយាចិត្តណា ដល់ភាវៈជាជវន កិរិយាចិត្តនោះ ក៏មិនមានផលដូចផ្កាឈើដែលមានឫសដាច់ហើយ មានត្រឹមតែជាការធ្វើប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅដោយអំណាចនៃការញុំាងកិច្ចនោះៗ ឱ្យសម្រេច; ព្រោះហេតុដូច្នោះ ទើបត្រាស់ថា កិរិយា (ការធ្វើ) ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"នេវ កុសលា នាកុសលា** = មិនមែនកុសល មិនមែនអកុសលទេ" ជាដើមតទៅ ៖

សភាវធម៌ ដែលឈ្មោះថា មិនមែនកុសល ព្រោះភាវៈមិនមានកុសលហេតុ ពោលគឺកុសលមូល, ដែលឈ្មោះថា មិនមែនជាអកុសល ព្រោះភាវៈមិនមានអកុសលហេតុ ពោលគឺអកុសលមូល, ដែលឈ្មោះថា មិនមែនកុសល មិនមែនអកុសល (**នេវ កុសលា នាកុសល**) ព្រោះភាវៈមិនមានកុសល និងអកុសលជាបច្ច័យ ពោលគឺយោនិសោមនសិការ និងអយោនិសោមនសិការ; ឈ្មោះថា មិនមែនកម្មវិបាក ព្រោះមិនមានហេតុឱ្យកើតឡើង ពោលគឺកុសល និងអកុសល ។

ក្នុងនិទ្ទេសនៃឯកគ្គតាចិត្ត សូម្បីដែលជាកិរិយាមនោធាតុនេះ រមែងបាន ត្រឹមតែជាការតាំងនៅក្នុងបវត្តិកាលប៉ុណ្ណោះ, ពិតមែន ចិត្តទាំង ១៧ ដួងនេះ គឺ

-ទ្វិបញ្ចវិញ្ញាណ ១០ ដួង -មនោធាតុ ៣ ដួង

-មនោវិញ្ញាណធាតុ ៣ ដួង -វិចិកិច្ឆាសហគតចិត្ត ១ ដួង ។

ព្រោះភាវៈនៃចិត្តទាំងនេះ ជាសភាពទុព្វល ទើបមិនបានក្នុងព្រះបាលីថា **"សណ្ឋិតិ អវដ្ឋិតិ** = ការឋិតនៅនៃចិត្ត ការតាំងនៅមាំនៃចិត្ត" ជាដើម ពាក្យដែលនៅសល់ទាំងអស់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងនិទ្ទេសនៃវិបាក-មនោធាតុ វៀរអំពីឋាននៃការកើតឡើង ព្រោះចិត្តនោះ (មនោធាតុដែលជាវិបាក) រមែងកើតឡើងក្នុងលំដាប់នៃបញ្ចវិញ្ញាណ, តែមនោធាតុដែលជាកិរិយាចិត្តនេះ រមែងកើតមុនគ្រប់ដួង ក្នុងបវត្តិកាល ត្រង់វិថិនៃបញ្ចទ្វារ ។

សេចក្តីនេះ តើយ៉ាងណា ? គឺថា ក្នុងចក្ខុទ្វារ កាលរូបារម្មណ៍ទាំងឡាយ ជាឥដ្ឋារម្មណ៍ ឥដ្ឋមជ្ឈត្តារម្មណ៍ អនិដ្ឋារម្មណ៍ និងអនិដ្ឋមជ្ឈត្តារម្មណ៍ អារម្មណ៍ណាមួយ មកប៉ះខ្ទប់បសាទមនោធាតុដែលជាកិរិយាចិត្ត ក៏ទទួលអារម្មណ៍នោះ ញុំាងភវង្គឱ្យឃ្លាតទៅហើយកើតឡើងប្រព្រឹត្តទៅមុន ដោយអំណាចនៃអាវជ្ជនៈ សូម្បីក្នុងសោតទ្វារជាដើម ក៏នំយនេះដែរ ៕

**ចប់មនោធាតុដែលជាកិរិយា**

# សម្តែងអំពីមនោវិញ្ញាណធាតុ ជាកិរិយាចិត្តសហគតៈដោយសោមនស្ស

ចិត្តនេះ ក្នុងព្រះបាលីថា **“មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ ។បេ។ សោមនស្សសហគតំ** = មនោវិញ្ញាណធាតុជាកិរិយា មិនមែនកុសល មិនមែនអកុសល និងមិនមែនកម្មវិបាកសហគតៈដោយវិបាកទេ” ដូច្នេះ ជាចិត្តចំពោះបុគ្គលមិនទូទៅដល់សត្វដទៃ ក្រៅអំពីព្រះខីណាស្រពប៉ុណ្ណោះ រមែងបានក្នុងទ្វារ ៦ ។

ពិតមែន **ក្នុងចក្ខុទ្វារ**ព្រះខីណាស្រពឃើញទីដែលសមគួរដល់ការធ្វើសេចក្តីព្យាយាម រមែងដល់សោមនស្សដោយចិត្តនេះ, **ក្នុងសោតទ្វារ** លោកដល់ទីដែលគួរដល់ការចែកភណ្ឌៈ កាលបើបុគ្គលអ្នកល្មោភធ្វើសំឡេងខ្លាំង ហើយកាន់យក លោកក៏ដល់សោមនស្សដោយចិត្តនេះថា “តណ្ហាជាហេតុឱ្យញាប់ញ័រ ឈ្មោះថាមានសភាពដូចនេះ យើងលះបានហើយ” , **ក្នុងឃានទ្វារ** កាលព្រះខីណាស្រពបូជាព្រះចេតិយ ដោយរបស់ក្រអូប ឬផ្កាឈើ ក៏សោមនស្សដោយចិត្តនេះ, **ក្នុងជិវ្ហាទ្វារ** ព្រះខីណាស្រពចែកបិណ្ឌបាត ដែលដល់ព្រមដោយរស ដែលបានមកឆាន់ក៏ដល់សោមនស្សដោយចិត្តនេះថា “សារាណីយធម៌ (ធម៌ដែលគួររឭក) យើង

បំពេញហើយហ្ន៎” ; **ក្នុងកាយទ្វារ** ព្រះខីណាស្រពបំពេញអភិសមាចារិកវត្ត ក៏ដល់សោមនស្ស ដោយចិត្តនេះថា “ក៏វត្តរបស់យើងពេញលេញហើយក្នុងកាយទ្វារ” , ព្រះខីណាស្រពរមែងបានក្នុងបញ្ចទ្វារយ៉ាងនេះមែនពិត ។

តែក្នុងមនោទ្វារ ចិត្តរបស់ព្រះខីណាស្រពរមែងកើតឡើង ព្រោះប្រារព្ធអតីតៈ និងអនាគត; ពិតមែន ព្រះតថាគតទ្រង់ធ្វើហើយក្នុងគ្រាដែលព្រះអង្គសោយព្រះជាតិជាជោតិបាល, ជាស្តេចមឃទេវរាជ និងជាកណ្ហតាបសជាដើម ទើបទ្រង់ធ្វើការញញឹមឱ្យប្រាកដ; ក៏ការរឭកនោះ ជាកិច្ច (មុខនាទី) របស់បុព្វេនិវាសញ្ញាណ និងសព្វញ្ញុតញ្ញាណ, ក៏ក្នុងវេលាទីបំផុតនៃការប្រព្រឹត្តទៅរបស់ញាណទាំងពីរនោះ ចិត្តដួងនេះ រមែងកើតសោមនស្ស ។ ក្នុងអនាគត ព្រះអង្គក៏បានទ្រង់ធ្វើការញញឹមឱ្យប្រាកដដូច្នេះថា “នឹងមានព្រះបច្ចេកពុទ្ធ មានសំឡេងដូចជាពិណ មានសំឡេងដូចស្គរ” ; ការរឭកនោះ ជាកិច្ចរបស់អនាគតំសញ្ញាណ និងសព្វញ្ញុតញ្ញាណ, ក្នុងវេលាទីបំផុត នៃការប្រព្រឹត្តទៅរបស់ញាណទាំងពីរពួកនោះ ចិត្តនេះ រមែងកើតសោមនស្ស ។

ក៏ក្នុងនិទ្ទេសវារៈនៃហសិតុប្បាទចិត្តនេះ ទ្រង់តាំងឯកគ្គតានៃចិត្តទុកដល់សមាធិពលៈ ព្រោះមានកម្លាំងជាងអហេតុកៈដែលនៅសល់, សូម្បីវីរិយៈ ក៏ទ្រង់តាំងទុកដល់វីរិយពលៈ; តែព្រោះក្នុងនិទ្ទេស មិនបានត្រាស់ទុកថា “សមាធិពលៈ

រមែងមាន, វិរិយពលៈរមែងមាន” ដូច្នេះទេ ឈ្មោះថា ពលៈ (គឺសតិពលៈ និង វិរិយពលៈ) ទាំងពីរនេះ ទើបមិនមានដោយអត្ថថា ជាកម្លាំង; ក៏ព្រោះចិត្តដួងនេះ មិនមែនកុសលចិត្ត មិនមែនអកុសលចិត្ត ព្រោះហេតុដូច្នេះ ទើបមិនត្រាស់តាំងទុកថា ជាពលៈទេ; និងព្រោះចិត្តដួងនេះ មិនមែនពលៈ ដោយនិប្បរិយាយ (ដោយត្រង់) ព្រោះហេតុដូច្នោះ សូម្បីក្នុងសង្គហវារៈ មិនបានត្រាស់ថា “ធម៌ទាំងពីរ (គឺសតិពលៈ និងវិរិយពលៈ) ជាពលៈ” ដូច្នេះទេ; ពាក្យដែលនៅសល់ទាំងអស់ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងនិទ្ទេសនៃអហេតុកមនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្សនោះឯង ៕

## សម្តែងអំពីមនោវិញ្ញាណធាតុ ជាកិរិយាចិត្ត សហគតៈដោយឧបេក្ខា

បទថា “**ឧបេក្ខាសហគតំ** (មនោវិញ្ញាណធាតុ) សហគតៈដោយឧបេក្ខា” អធិប្បាយថា ចិត្តដួងនេះ ទូទៅដល់សត្វអ្នកមានចិត្តគ្រប់ជំពូក ក្នុងភពទាំង ៣, ឈ្មោះថា រមែងមិនកើតឡើងដល់សត្វអ្នកមានចិត្តពួកខ្លះ មិនមានទេ; តែថា ការកើតក្នុងបញ្ចទ្វារ រមែងធ្វើវោដ្ឋព្វនកិច្ច, កើតក្នុងមនោទ្វារ រមែងធ្វើអាវជ្ជនកិច្ច;

សូម្បីអសាធារណញ្ញាណ (ញាណដែលមិនទូទៅដល់សត្វដទៃ) ៦ រមែងទទួលអារម្មណ៍ដែលកិច្ចនេះទទួលហើយដូចគ្នា។

ចិត្តនេះ ឈ្មោះថា **មហគ្គតៈ** (ដ៏វិធំ); ឈ្មោះថា វត្ថុដែលជាអារម្មណ៍របស់ចិត្តនេះ មិនបានមានទេ; កាលបើមានពាក្យសួរថា "ចិត្តដែលមិនមែនជាសព្វញ្ញុតញ្ញាណ តែឈ្មោះថា មានគតិដូចសព្វញ្ញុតញ្ញាណ ជាចិត្តដួងអ្វី ?" គប្បីឆ្លើយថា "ចិត្តដួងនេះ (មនោវិញ្ញាណធាតុ) ជាកិរិយាចិត្តសហគតៈដោយឧបេក្ខា"; ពាក្យដ៏សេស ក្នុងចិត្តនេះ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងចិត្តមុន (មនោ-វិញ្ញាណធាតុ ជាកិរិយាចិត្ត សហគតៈដោយសោមនស្ស) នោះឯង; ក៏ក្នុងហសនចិត្ត (មនោវិញ្ញាណធាតុជាកិរិយាចិត្ត សហគតៈដោយសោមនស្ស) នោះ ទ្រង់ចែកសង្ខារក្ខន្ធមានអង្គ ៩ ព្រោះមានបីតិ, តែក្នុងចិត្តដួងនេះ ទ្រង់ចែកសង្ខារក្ខន្ធ មានអង្គ ៨ ព្រោះមិនមានបីតិ ៕

## សម្តែងអំពីមហាកិរិយាចិត្ត ៨ ដួង

ឥឡូវនេះ មហាកិរិយាចិត្ត ៨ ដួងនោះ របស់កុសលពួកណា កិរិយាចិត្តទាំងនោះ កើតឡើងហើយ ព្រោះការកើតឡើងនៃព្រះខីណាស្រព, ព្រោះហេតុដូច្នោះ មហាកិរិយាចិត្តពួកនោះ គប្បីជ្រាបដោយន័យ តាមដែលពោលទុកក្នុងកុសលនិទ្ទេសនុ៎ះឯង ៕

## សម្តែងអំពីហសនចិត្ត ១៣ ដួង

បណ្ឌិតគប្បីញ៉ាំងហសនចិត្ត ឱ្យតាំងប្រជុំចុះក្នុងទីនេះ ។

***សួរថា*** ក៏ហសនចិត្តពួកនេះមានប៉ុន្មាន ?

ឆ្លើយថា មាន ១៣ ដួង ។

ពិតមែន បុថុជ្ជនរមែងសើចដោយចិត្ត ៨ ដួង គឺ

-កុសលចិត្តសហគតៈដោយសោមនស្ស ៤ ដួង

-អកុសលចិត្តសហគតៈដោយសោមនស្ស ៤ ដួង ។

ព្រះសេក្ខៈរមែងសើចដោយចិត្ត ៦ ដួង គឺ

-កុសលចិត្តដែលសហគតៈដោយសោមនស្ស ៤ ដួង

-អកុសលចិត្តដែលសហគតៈដោយសោមនស្ស មិនប្រកបដោយទិដ្ឋិ ២ ដួង

ព្រះខីណាស្រពរមែងសើចដោយចិត្ត ៥ ដួង គឺ

-សហិតុប្បាទចិត្ត សហគតៈដោយសោមនស្ស ១ ដួង

-មហាកិរិយាចិត្តដែលសហគតៈដោយសោមនស្ស ៤ ដួង ៕

## សម្តែងអំពីរូបាវចរកិរិយា និង អរូបាវចរកិរិយា

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃរូបាវចរកិរិយា និងអរូបាវចរកិរិយា ដូចតទៅ ៖

បទថា **“ទិដ្ឋធម្មសុខវិហារំ** = ជាទិដ្ឋធម្មសុខវិហារ” បានដល់ ល្មមនៅជាសុខក្នុងទិដ្ឋធម៌ គឺក្នុងអត្តភាពនេះប៉ុណ្ណោះ ។ ក្នុងសមាបត្តិទាំងនោះ សមាបត្តិដែលព្រះខីណាស្រពឱ្យកើតឡើងក្នុងវេលានៅជាបុថុជ្ជន ដរាបណាដែលព្រះខីណា-ស្រព នៅមិនទាន់ចូលសមាបត្តិនោះ ដរាបនោះ សមាបត្តិនោះ ក៏ជាកុសលនោះឯង; កាលលោកចូលសមាត្តិនោះហើយ សមាបត្តិនោះ ជាកិរិយា, តែសមាបត្តិដែលព្រះខីណាស្រពនោះ ឱ្យកើតឡើងក្នុងវេលាដែលនៅជាព្រះខីណាស្រព សមាបត្តិនោះ រមែងជាកិរិយាប៉ុណ្ណោះ ។ ពាក្យដ៏សេសទាំងអស់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងកុសលនិទ្ទេស ព្រោះដូចគ្នាជាមួយនឹងកុសលនុ៎ះឯង ។%

**ចប់កថាសម្តែងអំពីចិត្តុប្បាទកណ្ឌ ក្នុងអដ្ឋសាលិនី នៃធម្មសង្គហគាថា**

**តែបទអព្យាក្រឹត (រូប និងនិព្វាន) នៅមិនទាន់ចប់ទេ**

## ចប់អដ្ឋកថាចិត្តុប្បាទកណ្ឌ

# អដ្ឋកថារូបកណ្ឌ

## សម្តែងអំពីឯកកនិទ្ទេស

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់មានបំណងនឹងចែករូបកណ្ឌ (ប្រភេទនៃរូប) ទើបផ្តើមត្រាស់សម្តែងបាលីមានជាដើមថា **“កតមេ ធម្មា អព្យាកតា** = ធម៌ជាអព្យាក្រឹត តើដូចម្តេច?” ទៀត។

គប្បីជ្រាបវិនិច្ឆ័យពាក្យថា **អព្យាក្រឹត** ជាដើមនោះ ដូចតទៅ ៖

ព្រះបាលីក្នុងចិត្តុប្បាទកណ្ឌ ព្រះអង្គទ្រង់ចែកវិបាកាព្យាកតៈ (អព្យាកតៈ គឺវិបាកចិត្ត) និង **កិរិយាអព្យាកតៈ** (អព្យាកតៈ គឺកិរិយា) ទុកដោយសព្វគ្រប់ ក៏ពិតមែនហើយ, ប៉ុន្តែ មិនបានត្រាស់អព្យាកតៈ គឺរូប និង**អព្យាកតៈ គឺនិព្វានទេ**; កាលនឹងទ្រង់ប្រមូលអព្យាកតៈសូម្បីទាំង ៤ មកសម្តែង ដើម្បីត្រាស់អព្យាកតៈទាំងពីរ ដែលនៅសល់នោះ ទើបត្រាស់ថា **“កុសលាកុសលានំ ធម្មានំ វិបាកា** = វិបាកនៃកុសលធម៌ និងអកុសលធម៌ទាំងឡាយ” ។

បណ្តាបទទាំងនោះ បទថា **“កុសលាកុសលានំ”** បានដល់ កុសល និងអកុសលទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ព្រះអង្គទ្រង់កាន់យកបទ ទាំងពីរ គឺកុសលវិបាក និងអកុសលវិបាក សម្តែងអព្យាកតវិបាកចិត្តទុក ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ តែព្រោះអព្យាកតៈទាំងនោះ ជាកាមាវចរក៏មាន ជាធម៌យ៉ាងណានីមួយ បណ្តាធម៌ទាំងឡាយដែលជារូបាវចរក៏មាន, ព្រោះហេតុនោះ ទើបទ្រង់សម្តែងអព្យាកតៈ គឺវិបាកនោះឯង កាន់យកសេចក្តីប្លែកគ្នានៃភូមិ ដោយន័យមាន

ពាក្យថា **“កាមាវចរំ** = ជាកាមាវចរ” ជាដើម; ម្យ៉ាងទៀត ព្រោះអព្យាកតៈនោះ ជាវេទនាខន្ធក៏មាន ។ល។ ជាវិញ្ញាណក្ខន្ធក៏មាន, ព្រោះហេតុដូច្នោះ ទើបទ្រង់កាន់យកអព្យាកតៈនោះ សម្តែងដោយអំណាចនៃនាមក្ខន្ធ ៤ ដែលសម្បយុត្តគ្នា; គ្រាទ្រង់សម្តែងអព្យាកតៈ គឺវិបាកចិត្តយ៉ាងនេះ ដោយកាន់យកន័យទាំង ៣ គឺដោយអំណាចនៃ **កុសល និង អកុសល**, ដោយអំណាចនៃសេចក្តីផ្សេងគ្នានៃភូមិ និង ដោយអំណាចនៃខន្ធដែលសម្បយុត្តគ្នា កាលនឹងទ្រង់សម្តែងអព្យាកតៈ គឺកិរិយាចិត្តទៀត ទើបត្រាស់ពាក្យមានជាអាទិ៍ថា **“យេ ច ធម្មា កិរិយា** = ម្យ៉ាងទៀត ធម៌ពួកណាជាកិរិយា” ។

ក្នុងព្រះបាលីនោះ កិរិយាចិត្តនោះ បុគ្គលគប្បីពោលថា **“ជាកាមាវចរ, រូបាវចរ, អរូបាវចរ គឺវេទនាខន្ធ ។ល។ វិញ្ញាណក្ខន្ធ”**, ក៏ព្រះអង្គគ្រាទ្រង់សម្តែងន័យដែលបុគ្គលកាន់យកក្នុងគ្រាក្រោយនោះឯងហើយ ទើបទ្រង់លះចេញ ។

ឥឡូវនេះ កាលនឹងសម្តែងធម៌ដែលនៅមិនបានចែកទុក ទើបត្រាស់ថា **“សព្វញ្ច រូបំ អសង្ខតា ច ធាតុ** = រូបទាំងអស់ និងអសង្ខតធាតុ” ជាដើម ។

ក្នុងព្រះបាលីនោះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កាន់យកនូវរូប ២៥ កោដ្ឋាសៈនៃរូប ៩៦ ទុកដោយអស់ជើង (គ្មានសល់) ដោយបទថា **“សព្វញ្ច រូបំ”** ; ដោយបទថា **“អសង្ខតា ច ធាតុ”** នេះ ទ្រង់កាន់យកនិព្វានឡើងសម្តែងដោយសព្វគ្រប់ ។ បទថា **“អព្យាកតា ធម្មា** = ធម៌ជាអព្យាកតៈ”

ព្រះមានព្រះភាគទ្រង់លើកឡើងទុក ដោយពាក្យមានប្រមាណប៉ុណ្ណេះ ៕

## សម្តែងអំពីអព្យាកតៈ គឺ រូប

បណ្តាធម៌ជា**អព្យាកតៈ** នោះ ពាក្យថា ***រូបទាំងអស់តើដូចម្តេច ?*** នេះ ព្រះអង្គទ្រង់កាន់យកហើយ ព្រោះហេតុអ្វី ខាងក្រោយ ទើបត្រាស់អព្យាកតៈ គឺរូបទុកដោយសង្ខេប, ឥឡូវនេះ ទ្រង់នឹងចែករូបទាំងនោះ ដោយពិស្តារ ដោយអំណាចនៃរូបប្រភេទ ១ ប្រភេទ ២ ប្រភេទ ៣ ប្រភេទ ៤ ។ល ។ ប្រភេទ ១១ ទើបទ្រង់កាន់យករូបនេះ ។

សេចក្តីនោះ មានអធិប្បាយថា ៖

រូបណាដែលត្រាស់ទុកក្នុង ២ បទថា **"សព្វញ្ច រូបំ អសង្ខតា ច ធាតុ"** ដែលឈ្មោះថា រូបទាំងអស់ តើដូចម្តេច ?; ឥឡូវនេះ កាលនឹងសម្តែងរូបនោះ ទើបត្រាស់ពាក្យជាដើមថា **"ចត្តារោ ច មហាភូតា** = មហាភូតរូប ៤" ។

បណ្តាបទទាំងនោះ បទថា **"ចត្តារោ** = ៤" ជាពាក្យកំណត់ចំនួន, ដោយបទថា ៤ នោះ ទ្រង់បដិសេធការខ្វះ និងការលើសរបស់រូបទាំងនោះ; ចសព្ទ ជាសម្បិណ្ឌនត្ថៈ (ប្រើក្នុងអត្ថថាប្រមូលមក), ដោយចសព្ទនោះ ទើបប្រមូលមកនូវឧបាទាយរូប (រូបដែលអាស្រ័យ) ថា "មិនមែនតែមហាភូតរូប ៤ ប៉ុណ្ណោះទេ, សូម្បីរូបដទៃទៀត ក៏មានដែរ" ដូច្នេះ ៕

## សម្តែងអំពីមហាភូតរូប

ក្នុងពាក្យថា **មហាភូត** នេះ គប្បីជ្រាបថា សភាវៈដែលឈ្មោះថា មហាភូត ព្រោះហេតុទាំងឡាយ ដោយសេចក្តីប្រាកដថា **ជារបស់ធំ** ជាដើម; ព្រោះរូបទាំងនោះ ត្រាស់ថា “**មហាភូត**” ដោយហេតុទាំងនេះ គឺ ៖

**-មហន្តបាតុភាវតោ** ប្រាកដជារបស់ធំ ១

**-មហាភូតសាមញ្ញតោ** ដូចមហាភូតរូប គឺអ្នកលេងល្បិចកលជាដើម១

**-មហាបរិហារតោ** ព្រោះត្រូវបម្រុងរក្សាច្រើន ១

**-មហាវិការតោ** ព្រោះវិការៈ (ប្រែប្រួល) ច្រើន ១

**-មហន្តភូតត្តា** ព្រោះជារបស់ធំដែលមាន ១។

បណ្តាហេតុទាំងនោះ ខថា **មហាភូតរូបប្រាកដជារបស់ធំ** មានអធិប្បាយថា រូបទាំងនេះ ប្រាកដជារបស់ធំក្នុងអនុបាទិន្នកសន្តានខ្លះ [៤៩] ក្នុងឧបាទិន្នកសន្តានខ្លះ [៥០] ។ បណ្តាសន្តានទាំងពីរនោះ គប្បីជ្រាបក្នុងអនុបាទិន្នកសន្តាន ដោយភាវៈជារបស់ធំយ៉ាងនេះ ។

ពិតមែន ចក្រវាឡមួយមានបណ្តោយ និងទទឹង ១.២០៣.៤៥០ (មួយលាន

---

[៤៩] សំដៅដល់រូបដែលជាប់តណ្ហា ដែលមិនមានចិត្តគ្រប់គ្រង ។

[៥០] សំដៅដល់រូបដែលជាប់តណ្ហា ដែលមានចិត្តគ្រប់គ្រង ។

ពីរសែនបីពាន់បួនរយហាសិប) យោជន៍ * ព័ទ្ធដោយជុំវិញ តាមគាថាដែលលោកប្រព័ន្ធ (ចងក្រង) ទុកថា៖

"សព្វំ សតសហស្សានិ ឆត្តឹស បរិមណ្ឌលំ
ទសញ្ចេវ សហស្សានិ អឌ្ឍុឌ្ឍានិ សតានិ ច

ចក្រវាឡទាំងអស់មានសណ្ឋានមូលព័ទ្ធជុំវិញបាន ៣.៦១០.៣៥០. (បីលានប្រាំមួយសែនមួយម៉ឺនបីរយហាសិប) " យោជន៍ [៥១] ។

ក្នុងចក្រវាឡនោះ មានគាថាដូច្នេះថា៖

"ទុវេ សតសហស្សានិ ចត្តារិ នហុតានិ ច
ឯត្តកំ ពហលត្តេន សំខាតាយំ វសុន្ធរា

ផែនដីនេះ ព័ទ្ធដោយចំណែកក្រាស់មានប៉ុណ្ណោះ គឺ ២៤០.០០០ (ពីរសែនបួនម៉ឺន) យោជន៍" ។

ផែនដីនោះឯង មានទឹកទ្រ (ដូចគាថា)ដូច្នេះថា៖

"ចត្តារិ សតសហស្សានិ អដ្ឋេវ នហុតានិ ច
ឯត្តកំ ពហលត្តេន ជលំ វាតេ បតិដ្ឋិតំ

---

* យោជនានំ ទ្វាទសសតសហស្សានិ ចតុត្តឹស (ច. ម. តីណិ សហស្សានិ ចត្តារិ សតានិ) បញ្ញាសញ្ច យោជនានិ ។

[៥១] វិសុទ្ធិ. (ឆអនុស្សតិនិទ្ទេស) ។

ទឹកទ្រផែនដីកម្រាស់ដល់ ៤៨០.០០០ ( បួនសែន ប្រាំបីម៉ឺន)

យោជន៍ តាំងនៅលើខ្យល់ ។

សូម្បីទឹកនោះឯង ក៏មានខ្យល់ទ្រ ( ដូចគាថា) ដូច្នេះថា៖

**“នវ សតសហស្សានិ មាលុតោ នភមុគ្គតោ**

**សដ្ឋិញ្ចេវ សហស្សានិ ឯសា លោកស្ស សណ្ឋិតិ**

ខ្យល់ឡើងកាន់ផ្ទៃនភា ( ពពក) ដល់ ៩៦០.០០០ ( ប្រាំបួនសែន

ប្រាំមួយម៉ឺន) យោជន៍នោះ ជាការតាំងនៅរបស់លោកធាតុ” ។

ក៏កាលបើលោក មានការតាំងនៅយ៉ាងនេះ មានភ្នំខ្ពស់ឈ្មោះ **សិនេរុរាជ** ចាក់ជ្រៅចុះទៅក្នុងមហាសមុទ្រដល់ ៨៤.០០០ ( ប្រាំបីម៉ឺនបួនពាន់) យោជន៍ ខ្ពស់ឡើងអំពីមហាសមុទ្របាន ៨៤០.០០ យោជន៍ដែរ ។

មានភ្នំធំសុទ្ធតែសិលា ( ថ្ម) ៧ ព័ទ្ធជុំវិញខ្ពស់ដោយលំដាប់ដូចជា ភ្នំឈ្មោះ **យុគន្ធរ ឥសិន្ធរ ករវិក សុទស្សនៈ នេមិន្ធរ វិនតកៈ** និងភ្នំឈ្មោះ **អស្សកណ្ណ** សុទ្ធតែវិចិត្រដោយរតនៈផ្សេងៗ ដែលជាទិព្វ ចាក់ចុះទៅក្នុងមហាសមុទ្រ និងខ្ពស់ពីមហាសមុទ្រ ប្រមាណកន្លះៗ យោជន៍ ដូចដែលពោលទុកខាងលើ ខាងក្រោមព័ទ្ធដោយជុំវិញ ភ្នំខ្ពស់ឈ្មោះ **សិនេរុ** នោះ តាមលំដាប់ [៥២] ជាទីតាំងនៅរបស់មហារាជ

---

[៥២] យោជនាបានពន្យល់ថា **ឯតេ សត្ត បព្វតា បដិបាដិយាសមុគ្គតា សោបាណសទិសា ហុត្វា ឋិតា** = ភ្នំ ៧ ជួរនោះ ខ្ពស់ឡើងដោយលំដាប់ តាំងនៅដូចជាជណ្តើរ ។

ទាំងឡាយ និងជាទីនៅជាប្រចាំ របស់ពួកទេវតា និងពួកយក្ខ ។

នៅមានភ្នំឈ្មោះ **ហេមពាន្ត**[៥៣] កម្ពស់ ៥០០ (ប្រាំរយ) យោជន៍ បណ្ដោយ និងទទឹង ៣.០០០ (បីពាន់) យោជន៍ ស្រស់ស្អាតដោយកំពូល ៨៤.០០០ (ប្រាំបីម៉ឺនបួនពាន់) កំពូល ជម្ពូទ្វីបរុងរឿងហើយ ដោយអានុភាពនៃដើមជម្ពូ (ព្រីង) ណា, ដើមជម្ពូនោះ ព័ទ្ធជុំវិញ ប្រមាណ ១៥ យោជន៍ មានមែកបណ្ដោយ ៥០ យោជន៍ ជុំវិញទិស បែកចេញបានមួយរយយោជន៍ ខ្ពស់ឡើងមួយរយយោជន៍ដែរ ។

ម្យ៉ាងទៀត ប្រមាណនៃដើមជម្ពូនេះ យ៉ាងណា, **ដើមចិត្តបាដលី** (ជ្រនៀង...) របស់ពួកអសុរក្តី, **ដើមសិម្ពលី** (រកាស្រុក) របស់ពួកគ្រុឌក្តី, **ដើមកទម្ពៈ** (ក្ទម្ព) ក្នុងទ្វីបអមរគោយានក្តី, **ដើមកល្បព្រឹក្ស** ក្នុងទ្វីបឧត្តរកុរុក្តី, **ដើមសិរីសៈ** (ច្រេស) ក្នុងទ្វីបបុព្វវិទេហៈក្តី, **ដើមបារិច្ឆត្តកៈ** (រលួសផ្អុង) ក្នុងតាវត្តិង្សទាំងឡាយក្តី ក៏មានប្រមាណប៉ុណ្ណោះដែរ; ដោយហេតុនោះ ទើបព្រះបោរាណាចារ្យទាំងឡាយពោលថា ៖

**"ដើមបាដលី ១, ដើមសិម្ពលី ១, ដើមជម្ពូ ១, ដើមបារិច្ឆត្តកៈរបស់ពួកទេវតា ១, ដើមកទម្ពៈ ១, ដើមកប្បព្រឹក្ស ១ និងដើមសិរីសៈជាទី ៧" ។**

"ភ្នំចក្រវាឡចាក់ជ្រៅចុះទៅក្នុងមហាសមុទ្រ ៨២.០០០ (ប្រាំបីម៉ឺនពីរពាន់) យោជន៍ ខ្ពស់ផុតពីមហាសមុទ្រ ៨២.០០០ យោជន៍ដែរ បានជុំវិញលោកធាតុទាំងអស់

[៥៣] តាមន័យនេះ បញ្ជាក់ឱ្យឃើញថា ភ្នំសិនេរុផ្សេង ភ្នំហេមពាន្តផ្សេង គឺមិនដូចគ្នាទេ (អត្ថនោម័ត) ។

នេះ ឈ្មោះថា សន្តានរបស់រូបដែលមិនមានចិត្តគ្រប់គ្រង"។

សូម្បីសន្តានរបស់រូប ដែលមានចិត្តគ្រប់គ្រង (ឧបាទិន្នកសន្តាន) ក៏ប្រាកដជារបស់ធំនោះឯង ដោយអំណាចនៃសរីរៈ **មានត្រី អណ្តើក ទេព** និង **ទានព** (អសុរ) ជាដើម; សេចក្តីនេះ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ សត្វធំសូម្បីបណ្តោយទាំងរយយោជន៍ក៏មាន" [៥៤] ជាដើម ៕

## សម្តែងអំពីមហាភូត គឺអ្នកលេងកលល្បិចជាដើម

មានអធិប្បាយថា មហាភូតរូបពួកនេះ ប្រៀបដូចអ្នកលេងកលល្បិច រមែងធ្វើទឹកដែលមិនមែនកែវមណីទេ ឱ្យជាកែវមណី, រមែងសម្តែងដុំថ្ម ដែលមិនមែនមាសទេ ឱ្យជាដុំមាសបាន យ៉ាងណា, ម្យ៉ាងទៀត ខ្លួនឯង (មហាភូតរូប) មិនមែនយក្ស មិនមែនបក្សី (សត្វស្លាប) រមែងសម្តែងភាវៈជាយក្ខខ្លះ បក្សីខ្លះ យ៉ាងណា; សេចក្តីនេះ ក៏ដូច្នោះដែរ គឺខ្លួនឯង (មហាភូតរូប) មិនមែនពណ៌ខៀវ ក៏សម្តែងឧបាទាយរូប (រូបដែលអាស្រ័យ) ឱ្យជាពណ៌ខៀវ; ខ្លួនឯងមិនមែនជាពណ៌លឿង ក៏សម្តែងឧបាទាយរូបឱ្យជាពណ៌លឿង; មិនមែនជាពណ៌ក្រហម... មិនមែនជាពណ៌ស ក៏សម្តែងឧបាទាយរូប ឱ្យជាពណ៌សបាន ព្រោះហេតុដូច្នោះ រូបទាំងនោះ ទើបឈ្មោះថា

[៥៤] វិនយ. ១១ / ឧ. ឧ. / អំ. អដ្ឋក. ។

**មហាភូត** ព្រោះដូចជាមហាភូត គឺអ្នកលេងកលល្បិច ។

ម្យ៉ាងទៀត **មហាភូត** គឺយក្សប្រុសជាដើមរមែងចូលវត្ថុណា, ឬសត្វណា ដែលជាខាងក្នុង, ឬខាងក្រៅវត្ថុនោះ, ឬថារបស់សត្វនោះ ក៏រកវា (មហាភូតខ្លួនយក្សប្រុសជាដើមនោះ) មិនបាន និងមិនអែបអបវត្ថុនោះ ឬសត្វនោះក៏គ្មាន សេចក្ដីនេះយ៉ាងណា, មហាភូតរូបពួកនេះ ក៏យ៉ាងនោះដែរ នឹងស្វែងរកខាងក្នុង ឬខាងក្រៅរបស់គ្នានឹងគ្នា ក៏មិនបាន និងមិនមែនមហាភូតរូបពួកនេះ នឹងអាស្រ័យនូវគ្នានឹងគ្នាក៏មិនបានឡើយ ព្រោះហេតុដូច្នោះ រូបពួកនេះ ទើបឈ្មោះថា **មហាភូត** ព្រោះដូចជាមហាភូតមានយក្សប្រុសជាដើម ព្រោះភាពជាឋានដែលអ្នកណាៗ មិនគប្បីគិត ។

ម្យ៉ាងទៀត **មហាភូត** ពោលគឺនាងយក្ខិនីបិទបាំងនូវភាវៈនៃវាជាបិសាចគួរឱ្យខ្លាច ទើបបញ្ឆោតសត្វទាំងឡាយដោយពណ៌សម្រស់ រូបរាង និងការដើររាងសង្ហា ដែលគួរឱ្យពេញចិត្ត យ៉ាងណា, សូម្បីពួកមហាភូតនោះ ក៏យ៉ាងនោះដែរ បិទបាំងនូវលក្ខណៈនៃសភាវៈរបស់ខ្លួន ដែលផ្សេងដោយវត្ថុជារបស់រឹងជាដើមរបស់ខ្លួនទុកដោយពណ៌សម្បុរ ដែលគួរឱ្យសប្បាយ ដោយអាកប្បកិរិយានៃអវយវៈតូច ធំដែលគួរឱ្យរីករាយចិត្ត ដោយដើរវាសដៃជើង ម្រាមដៃ និងញាក់ចិញ្ចើម ដែលគួរឱ្យរីករាយចិត្ត ក្នុងរាងកាយរបស់បុរសស្ត្រីជាដើម ហើយបោកបញ្ឆោតមនុស្សល្ងង់ (ជនពាល) រមែងមិនឱ្យដើម្បីឃើញសភាវៈរបស់ខ្លួន, ព្រោះហេតុនោះ ទើបឈ្មោះថា **មហាភូត** ព្រោះវាដូចគ្នានឹងមហាភូត (មហាបិសាច) គឺនាងយក្ខិនី ព្រោះអត្ថថា

ធ្វើសេចក្ដីបោកបញ្ឆោត (**វញ្ចកដេន្ទី**) ដោយប្រការដូច្នេះ។

ពាក្យថា **ព្រោះត្រូវបម្រុងរក្សាច្រើន** គឺព្រោះត្រូវបរិហារដោយបច្ច័យជាច្រើន; ពិតមែន សភាវរូបទាំងនេះ ឈ្មោះថា **មហាភូត** ដោយអត្ថថា ត្រូវឱ្យប្រព្រឹត្តទៅដោយការស៊ី ការនៅ និងគ្រឿងស្លៀកដណ្ដប់ជាច្រើន ព្រោះត្រូវបង្អោនចូលទៅរាល់ៗ ថ្ងៃ; ម្យ៉ាងទៀត ដែលឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាវត្ថុបម្រុងរក្សាច្រើន ដូច្នេះក៏មាន ។

ពាក្យថា **ព្រោះវិការៈច្រើន** បានដល់ ព្រោះភូតទាំងឡាយប្រែប្រួលច្រើន; ពិតមែន រូបពួកនេះ ជារូបដែលមានចិត្តគ្រប់គ្រងក្ដី ជារូបដែលមិនមានចិត្តគ្រប់គ្រងក្ដី រមែងជារបស់ប្រែប្រួលច្រើន; បណ្ដារូបទាំងពីរនោះ រូបដែលមិនមានចិត្តគ្រប់គ្រង រមែងប្រាកដជាការប្រែប្រួលច្រើន ក្នុងពេលដែលកប្បវិនាស, ចំណែករូបដែលមានចិត្តគ្រប់គ្រង រមែងប្រាកដជាការប្រែប្រួលច្រើនក្នុងវេលាធាតុកម្រើក។

ពិតយ៉ាងនោះមែន តាមដែលលោកពោលថា៖

ក្នុងពេលណា លោកនឹងវិនាសដោយភ្លើងឆេះបំផ្លាញ ក្នុងពេលនោះ ភ្លើងរមែងឆេះឡើងតាំងអំពីផ្ទៃដី ទៅដល់ព្រហ្មលោក ។ ក្នុងពេលណា លោកនឹងវិនាសដោយទឹកកម្រើក[៥៥], ក្នុងពេលនោះ សែនកោដិចក្រវាឡ រមែងរលាយប្រព្រឹត្តទៅជាមួយគ្នានឹងទឹកដោះជូរ ។ ក្នុងពេលណា លោកនឹងវិនាសដោយខ្យល់កម្រើក, ក្នុង

---

[៥៥] ច្បាប់អង់គ្លេសថា ទឹកលិច (អ្នកពិនិត្យ)។

ពេលនោះ ខ្យល់រមែងញ៉ាំងសែនកោដិចក្រវាឡ ឱ្យខ្ចាត់ខ្ចាយប្រព្រឹត្តទៅជាមួយគ្នា។ កាយណាដែលត្រូវពស់ឈ្មោះ **កដ្ឋមុខ** (មាត់ឈើ) ចឹកហើយ រមែងរឹងយ៉ាងណា, កាយនោះ រមែងដូចជានៅក្នុងមាត់ពស់កដ្ឋមុខចឹកយក ព្រោះសភាពនៃ**បឋវីធាតុ** ខូចទៅ យ៉ាងនោះ; កាយណាដែលត្រូវពស់ឈ្មោះ **បូតិមុខ** (មាត់ស្អុយ) ចឹកហើយ រមែងស្អុយយ៉ាងណា, កាយនោះដូចនៅក្នុងមាត់ពស់ **បូតិមុខ** ចឹកយក ព្រោះអាបោ-ធាតុកម្រើកយ៉ាងនោះ; កាយណាដែលត្រូវពស់ឈ្មោះ **អគ្គិមុខ** (មាត់ភ្លើង) ចឹកយកហើយរមែងក្តៅ យ៉ាងណា, កាយនោះ ដូចជានៅក្នុងមាត់ពស់**អគ្គិមុខ** ចឹកយក ព្រោះសេចក្តីដែលតេជោធាតុ ខូចទៅយ៉ាងនោះ; កាយណា ដែលត្រូវពស់ឈ្មោះ **សត្ថមុខ** (មាត់សស្ត្រា) ចឹកយកហើយរមែងដាច់ដូចបន្ទះ យ៉ាងណា, កាយនោះ ដូចជានៅក្នុងមាត់ពស់សត្ថមុខចឹកយក ព្រោះសភាពនៃវាយោធាតុខូចទៅដូច្នោះ ។

រូបដែលឈ្មោះថា **មហាភូត** ព្រោះជាវិការៈ គឺប្រែប្រួលច្រើន ដោយប្រការដូច្នេះ។

ខថា **ព្រោះជារបស់ធំដែលមានពិត** ពិតមែន រូបពួកនោះ ឈ្មោះថា **ជារបស់ធំ** ព្រោះជារបស់ដែលផ្គាប់ផ្គុនដោយសេចក្តីព្យាយាមធំ និងដែលឈ្មោះថា **មានពិត** ព្រោះជារបស់ដែលមានពិតប្រាកដ ព្រោះហេតុនោះ រូបទើបឈ្មោះថា **មហាភូត** ព្រោះជារបស់ធំដែលមានពិត ។ មហាភូតរូប ជារូបធំ ដោយហេតុជារបស់ធំជាដើម មានប្រការដូច្នេះ ។

ពាក្យថា **“ចតុន្នំ ច មហាភូតានំ ឧបាទាយ រូបំ** = ក៏រូបដែលអាស្រ័យមហាភូតរូប ៤” នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ (ឱ្យប្រែថា អាស្រ័យនូវមហាភូតរូប ៤) អធិប្បាយថា រូបត្រូវពឹងពាក់អាស្រ័យ នឹងប្រព្រឹត្តទៅបាន មិនដាច់ពីមហាភូតរូបទាំង ៤ ឡើយ ។

បទថា **“ឥទំ វុច្ចតិ សព្វំ រូបំ** = នេះហៅថារូបទាំងអស់” សេចក្តីថា រូបនេះមានប្រភេទ ២៧ គឺមហាភូតរូប ៤ ឧបាទាយរូប ២៣ តាមដែលលើកយកមកសម្តែងដោយលំដាប់នៃបទនេះ ឈ្មោះថា រូបទាំងអស់ ៕

# អដ្ឋកថាមាតិការូបកណ្ឌ

## សម្តែងអំពីឯកមាតិកា

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់មានបំណងនឹងសម្តែងនូវរូបនោះ ដោយពិស្តារ កាលនឹងទ្រង់តាំងមាតិកាដោយការសង្គ្រោះរូប ១១ ប្រភេទ មានរូបប្រភេទមួយជាដើម ទើបត្រាស់ថា **“សព្វំ រូបំ ន ហេតុ** = រូបទាំងអស់មិនមែនជាហេតុ” ជាដើម ។

ក្នុងព្រះបាលីនោះ ក៏បទថា **សព្វំ រូបំ** នេះ បណ្ឌិតគប្បីប្រកបជាមួយបទទាំងពួងយ៉ាងនេះថា **“សព្វំ រូបំ ន ហេតុ, សព្វំ រូបំ អហេតុកំ** = រូបទាំង

អស់ មិនមែនហេតុ, រូបទាំងអស់មិនមានហេតុ [៥៦]" បទទាំងអស់ដែលទ្រង់តាំងទុក ៤៣ បទ មានពាក្យថា "**ន ហេតុ** = មិនមែនហេតុ" ជាដើម ទ្រង់លើកឡើងសម្តែងហើយ ។ បណ្តាបទទាំង ៤៣ នោះ បទ ៤០ ទ្រង់កាន់យកអំពីមាតិកាហើយតាំងទុកដោយលំដាប់, ៣ បទខាងចុង ជាបទក្រៅអំពីមាតិកា ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបព្រះបាលីក្នុងសង្គហៈ (ការសង្គ្រោះ) ទី ១ នេះសិនចុះ ។ ក្នុងសង្គហៈទី ២ ជាដើម ក៏មានសេចក្តីដូចគ្នាយ៉ាងនេះដែរ ៕

## សម្តែងអំពីការសង្គ្រោះរូបមាន ២ ប្រភេទ

បណ្តាសង្គហៈទាំងនេះ មានន័យដូចតទៅនេះ ៖

សង្គហៈទី ២ ជាមុនសិន រូបប្រភេទ ២ មាន ១០៤ ទុកៈ ; ក្នុងទុកៈ ១០៤ នោះ ទុកៈ ១៤ ខាងដើម មានជាអាទិ៍ថា "**អត្ថិ រូបំ ឧបាទា, អត្ថិ រូបំ នោ ឧបាទា** = រូបជាឧបាទាក៏មាន, រូបជាអនុបាទាក៏មាន" [៥៧] ឈ្មោះថា **បកិណ្ណកទុកៈ** ព្រោះមិនមានការសម្ព័ន្ធនូវគ្នានឹងគ្នា ។ ទុកៈតអំពីនោះ ២៥ ទុកៈ មានពាក្យជាដើមថា "**អត្ថិ រូបំ ចក្ខុសម្ផស្សស្ស វត្ថុ** = រូបជាទីអាស្រ័យរបស់ចក្ខុសម្ផស្សក៏មាន" ឈ្មោះថា វត្ថុទុកៈ ព្រោះការប្រព្រឹត្តទៅដោយអំណាចនៃការ

---

[៥៦] មិនមែនលោកសំដៅដល់ហេតុទាំង ៦ នោះទេ (ច្បាប់អង់គ្លេស) ។

[៥៧] អភិ. (ធម្មសង្គណី) ។

ពិចារណាវត្ថុ និងអវត្ថុ ។ តអំពីនោះ ទុកៈ ២៥ មានជាអាទិ៍ថា **“អត្ថិ រូបំ ចក្ខុសម្ផស្សស្ស អារម្មណំ** = រូបជាអារម្មណ៍របស់ចក្ខុសម្ផស្សក៏មាន” ឈ្មោះថា អារម្មណទុកៈ ព្រោះការប្រព្រឹត្តទៅដោយអំណាចនៃការពិចារណាដល់អារម្មណ៍ និង អនារម្មណ៍ ។ តអំពីនោះ ទុកៈ ១០ មានជាអាទិ៍ថា **“អត្ថិ រូបំ ចក្ខាយតនំ** = រូបជាចក្ខាយតនៈក៏មាន” ឈ្មោះថា **អាយតនទុកៈ** ព្រោះការប្រព្រឹត្តទៅដោយ អំណាចនៃការពិចារណា **អាយតនៈ និង អនាយតនៈ** ។ តអំពីនោះ ទុកៈ ១០ មានជាអាទិ៍ថា **“អត្ថិ រូបំ ចក្ខុធាតុ** = រូបជាចក្ខុធាតុក៏មាន” ឈ្មោះថា **ធាតុ-ទុកៈ** ព្រោះការប្រព្រឹត្តទៅដោយ អំណាចនៃការពិចារណា**ធាតុ និងអធាតុ** ។ តអំពីនោះ ទុកៈ ៨ មានពាក្យជាអាទិ៍ ថា **“អត្ថិ រូបំ ចក្ខុន្ទ្រិយំ** = រូបជាចក្ខុន្ទ្រិយ ក៏មាន” ឈ្មោះថា **ឥន្ទ្រិយទុកៈ** ព្រោះការប្រព្រឹត្តទៅដោយអំណាចនៃការពិចារណា នូវ **ឥន្ទ្រិយ និង អនិន្ទ្រិយ** ។ តអំពីនោះ ទុកៈ ១២ មានជាអាទិ៍ថា **“អត្ថិ រូបំ កាយវិញ្ញត្តិ** = រូបជាកាយវិញ្ញត្តិ ក៏មាន” ឈ្មោះថា **សុខុមរូបទុកៈ** ព្រោះការ ប្រព្រឹត្តទៅដោយអំណាចនៃការពិចារណា **សុខុមរូប និង អរូប** ។ នេះជាការ កំណត់ព្រះបាលីក្នុងទុតិយសង្គហៈ ៕

## សម្តែងអំពីតិករូប គឺ រូបមាន ៣ ប្រភេទ

ក្នុងសង្គហៈទី ៣ មានចំនួន ១០៣ តិកៈ; បណ្តាតិកៈទាំងនោះ តិកៈ ១៣

ដែលប្រកបដោយ**អជ្ឈត្តិកទុកៈ ១ ក្នុងបកិណ្ណកទុកៈ ១៤** តាមដែលពោលទុកក្នុងទុតិយសង្គហៈផង តិកៈ ១៣ ដែលតាំងទុកដោយន័យ មានជាអាទិ៍ថា **“យន្តំ រូបំ អជ្ឈត្តិកំ តំ ឧបាទា, យន្តំ រូបំ ពាហិរំ តំ អត្ថិ ឧបាទា, អត្ថិ នោ ឧបាទា** = រូបខាងក្នុងជាឧបាទា, រូបខាងក្រៅដែលជាឧបាទាក៏មាន, ដែលជាអនុ-បាទាក៏មាន” ឈ្មោះថា **បកិណ្ណកតិកៈ**; តអំពីនោះ ក៏ទ្រង់ប្រកបទុកៈនោះឯងជាមួយទុកៈដ៏ សេស ហើយទ្រង់តាំងតិកៈដ៏សេស ដោយន័យមានជាអាទិ៍ថា **“យន្តំ រូបំ ពាហិរំ តំ ចក្ខុសម្ផស្សស្ស ន វត្ថុ, យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ ចក្ខុសម្ផស្សស្ស វត្ថុ, អត្ថិ ចក្ខុសម្ផស្សស្ស ន វត្ថុ** = រូបខាងក្រៅមិនជាទីអាស្រ័យកើតរបស់ចក្ខុសម្ផស្សទេ, រូបខាងក្នុងជាទីអាស្រ័យកើតរបស់ចក្ខុសម្ផស្សក៏មាន, មិនជាទីអាស្រ័យកើតរបស់ចក្ខុសម្ផស្សក៏មាន”។ គប្បីជ្រាបឈ្មោះ និងការរាប់តិកៈពួកនោះ ដោយអំណាចនៃវត្ថុទុកៈជាដើមពួកនោះ៧ ឯង ។ នេះជាការកំណត់ព្រះបាលីក្នុងសង្គហៈទី ៣ ៕

## សម្តែងអំពីរូបមាន ៤ ប្រភេទជាដើម

ក្នុងសង្គហៈទី ៤ មាន ២២ ចតុក្កៈ; បណ្តាចតុក្កៈ ២២ ពួកនោះ ចតុក្កៈខាងចុងមិនបានទ្រង់កាន់យកមាតិកា តាមដែលពោលទុកក្នុងទុកៈនេះ យ៉ាងនេះថា **“រូបជាឧបាទាក៏មាន, រូបមិនជាឧបាទាក៏មាន”** ហើយទ្រង់តាំងទុកទេ, តែទ្រង់កាន់

យក ចតុក្កៈក្រៅនេះតាំងទុកយ៉ាងណា ? គឺទុកៈ ៣ ខាងដើម ក្នុងបកិណ្ណកៈទាំង-ឡាយ ដែលសង្គ្រោះរូប ២ យ៉ាងពួកណា, ក្នុងទុកៈ ៣ ពួកនោះ ទ្រង់កាន់យកមួយៗទុកៈ ប្រកបជាមួយទុកៈនីមួយៗ ៥ ទុកៈ ដោយន័យមានជាអាទិ៍ថា “**យន្តំ រូបំ ឧបាទា តំ អត្ថិ ឧបាទិន្នំ, អត្ថិ អនុបាទិន្នំ** = រូបជាឧបាទាដែលជាឧបាទិន្នកៈក៏មាន, ដែលជាអនុបាទិន្នកៈក៏មាន” ហើយទ្រង់តាំងទុកចតុក្កៈ ១៥ ខាងដើម ដែលមាន ៣ ទុកៈ ជាមូល ។

ឥឡូវនេះ គប្បីជ្រាបសនិទស្សនទុកៈទី ៤ នេះឯង, ព្រោះសនិទស្សនទុកៈនោះ មិនដល់ការប្រកបជាមួយទុកៈដទៃៗ ដោយន័យមានជាអាទិ៍ថា “រូបជាសនិទស្សនៈ = ឃើញបាន ប៉ះខ្ទប់បានក៏មាន, ប៉ះខ្ទប់មិនបានក៏មាន” ដូច្នេះ ឬជាមួយទុកៈខាងដើមដោយន័យថា “រូបជាឧបាទាក៏មាន, មិនមែនជាឧបាទាក៏មាន” ជាដើម ព្រោះមិនមានអត្ថ*, ព្រោះមិនមានលំដាប់ប្រព្រឹត្តទៅ និងព្រោះមិនមានសេចក្តីផ្សេងគ្នា; ពិតមែន រូបដែលឈ្មោះថា **សនិទស្សនៈ** (ឃើញបាន) **ប៉ះខ្ទប់មិនបាន** ឬថា **ជាអនុបាទារមែងមិនមាន** ព្រោះហេតុដូច្នោះ ទើបរូបនោះមិនដល់ការប្រកប ព្រោះមិនមាន (អត្ថ) ហេតុនៃការប្រកប; តែរូបដែលជាឧបាទិន្នកៈ និងអនុបាទិន្នកៈមាន, ព្រោះហេតុដូច្នោះ ទើបមិនដល់ការប្រកប ព្រោះមិនមានលំដាប់ប្រព្រឹត្តទៅផង; ព្រោះថា ទុកៈទាំងអស់ ព្រះអង្គទ្រង់ប្រកបជាមួយទុកៈក្រោយៗ ពួក

---

* ហេតុនៃការប្រកបទៅតាមលំដាប់ (យោជនា) ។

នោះ, នេះជាលំដាប់ដែលប្រព្រឹត្តទៅក្នុងអធិការនេះ; តែជាមួយបទដើមៗ មិនមានលំដាប់ប្រព្រឹត្តទៅដូច្នេះឡើយ; ប្រសិនបើមានអ្នកសួរថា កាលបើយ៉ាងនោះ មិនមានការប្រព្រឹត្តទៅតាមលំដាប់ ក៏មិនមែនជាហេតុសំខាន់, ព្រោះហេតុដូច្នោះ គួរប្រកបជាមួយបទដែលជាឧបាទិន្នកៈជាដើមឬ ? ។ ឆ្លើយថា នឹងប្រកបជាមួយរូបនេះមិនបាន ព្រោះមិនមានសេចក្ដីផ្សេងគ្នាជាមួយរូប ដែលជាបទឧបាទិន្នករូបជាដើម, ក្នុងអធិការនៃបទមានឧបាទិន្នៈជាដើម ប្រកបជាមួយបទ សនិទស្សនទុកៈនោះឯង កាលពោលថា **“រូបជាឧបាទិន្នកៈ ជាសនិទស្សនៈ**, ឬរូបដែលជាសនិទស្សនៈ ជាឧបាទិន្នកៈ” ដូច្នេះ សេចក្ដីផ្សេងគ្នាក៏មិនមាន ទើបមិនដល់ការប្រកបគ្នា ព្រោះមិនមានសេចក្ដីផ្សេងគ្នាដូច្នេះ ។ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់តាំងចតុក្កៈទុក ៦ ចតុក្កៈ ប្រកបមួយគ្រាៗ ២ ទុកៈ ដែលប្រកបដោយន័យមានជាអាទិ៍ថា **“យន្តំ រូបំ សប្បដិឃំ, តំ អត្ថិ ឥន្ទ្រិយំ អត្ថិ ន ឥន្ទ្រិយំ, យន្តំ រូបំ អប្បដិឃំ, តំ អត្ថិ ឥន្ទ្រិយំ, អត្ថិ ន ឥន្ទ្រិយំ** = រូបប៉ះខ្ទប់បាន (សប្បដិឃរូប) ដែលជាឥន្ទ្រិយក៏មាន, ដែលមិនមែនជាឥន្ទ្រិយក៏មាន, រូបដែលប៉ះ ខ្ទប់មិនបាន (គឺអប្បដិឃរូប) ដែលជាឥន្ទ្រិយក៏មាន, ដែលមិនជាឥន្ទ្រិយក៏មាន” ជាមួយ ៣ ទុកៈមានជាអាទិ៍ថា **“អត្ថិ រូបំ សប្បដិឃំ”**, ដទៃអំពីនោះ ព្រោះមិនកាន់យកទុកៈទី ៤ នោះ ។

ក៏ទុកៈទី ៤ នេះមិនមានការប្រកបយ៉ាងណា, សូម្បីទុកៈដើម ក៏មិនដល់

ការប្រកបជាមួយទុកៈទី ៤ នោះ យ៉ាងនោះដែរ ។ ព្រោះហេតុអ្វី? ព្រោះហេតុដែល **អនុបាទារូប** (រូបដែលមិនមានចិត្តគ្រប់គ្រង) ជា **អនិទស្សនរូប** (ឃើញមិនបាន) ដោយចំណែកមួយ ។ ពិតមែន ទុកៈខាងដើម កាលប្រកបជាមួយទុកៈទី ៤ យ៉ាងនេះថា "រូបនេះជាឧបាទា ជាសនិទស្សនៈក៏មាន, ជាអនិទស្សនៈក៏មាន" រមែងមិនដល់ការប្រកបបាន, ព្រោះហេតុដូច្នោះ ទើបត្រូវកន្លងទុកៈនោះទៅប្រកបជាមួយនឹងទុកៈទី ៥ ។ ទុកៈណាដល់ការប្រកបបាន, ប្រកបមិនបានជាមួយការប្រកបយ៉ាងនេះ គប្បីជ្រាបទុកៈនោះដូច្នេះ ។ នេះជាការកំណត់តាមព្រះបាលីក្នុងសង្គហៈទី ៤ ៕

## សម្តែងអំពីការសង្គ្រោះរូបមាន ៥ ប្រភេទ

ក៏ខាងមុខអំពីនេះ សង្គហៈ (ការសង្គ្រោះ) ៧ យ៉ាង មានការសង្គ្រោះរូប ៥ យ៉ាងជាដើម ជាការសង្គ្រោះលាយគ្នាមែនពិត ។ គប្បីជ្រាបការកំណត់ព្រះបាលីក្នុងមាតិកាសូម្បីទាំងអស់ ដោយប្រការដូច្នេះឯង ។

*ឧទ្ទេសនៃរូប ចប់*

**អដ្ឋសាលិនី អដ្ឋកថាព្រះអភិធម្មបិដក**

**ឈ្មោះធម្មសង្គណី បឋមភាគ ៣ ចប់**

**នៅមានបឋមភាគ ៤ ជាបន្តទៀត**

**បោះពុម្ពលើកទី ២**

រក្សាសិទ្ធិ (ហាមថតចម្លង)